# រីកចម្រើន ទាំងអស់គ្នា

# ផ្នែកខាងក្នុងនៃរបាយការណ៍





**អំពី ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក**

**១៨៦** អំពីធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក
**១៨៨** ព័ត៌មានទូទៅអំពីធនាគារ

**ផ្នែកសំខាន់ហិរញ្ញវត្ថុ**

**១៩២** សង្ខេបហិរញ្ញវត្ថុរយៈពេល ៥ឆ្នាំ ផ្នែកសំខាន់ហិរញ្ញវត្ថុ
**១៩៣** សង្ខេបហិរញ្ញវត្ថុរយៈពេល ៥ឆ្នាំ

**រចនាសម្ព័ន្ធគ្រប់គ្រង**

**១៩៦** រចនាសម្ព័ន្ធគ្រប់គ្រង

**១៩៨** របាយការណ៍ប្រធានក្រុមប្រឹក្សាភិបាល
**២០០** របាយការណ៍លោកអគ្គនាយក

**ក្រុមប្រឹក្សាភិបាល**

**២០៦** សមាសភាពក្រុមប្រឹក្សាភិបាល
**២១១** ប្រធានក្រុមប្រឹក្សាភិបាល

**ថ្នាក់ដឹកនាំជាន់ខ្ពស់**

**២១៤** សមាសភាពរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់
**២២១** គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

**២២២** របាយការណ៍ក្រុមប្រឹក្សាភិបាល
**២២៤** របាយការណ៍សវនករឯករាជ្យ
**២២៦** របាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងប្រចាំឆ្នាំ
**២៥០** ផ្នែកប្រតិបត្តិតាម

**របាយការណ៍ហិរញ្ញវត្ថុ**

**២៥៥** របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ២០២០




អំពី
ធនាគារ អ អេច ប៊ី
(ខេមបូឌា) ម.ក

# អំពីធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក



**ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក (ហៅកាត់ថា "ធនាគារ")** ត្រូវបានបង្កើតឡើងនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៨ និងបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ដោយមានវិញ្ញាបនបត្រចុះបញ្ជីលេខ ០០០០១៨១២ និងត្រូវបានធនាគារជាតិនៃ កម្ពុជា (ហៅកាត់ថា "ធនាគារកណ្តាល") ផ្តល់អាជ្ញាប័ណ្ណប្រកបអាជីវកម្មធនាគារនៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៨។

នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ធនាគារបានប្តូរនាមករណ៍របស់ខ្លួនទៅជា ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក។ ធនាគារគឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលត្រូវបានកាន់កាប់ទាំងស្រុងដោយធនាគារ RHB Bank Berhad ជាក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកម្រិត បានចុះបញ្ជីពាណិជ្ជកម្ម នៅប្រទេសម៉ាឡេស៊ី ហើយក្រុមហ៊ុនមេធំជាងគេគឺក្រុមហ៊ុន RHB Banking Group ដោយអនុលោមទៅតាមរចនាសម្ព័ន្ធសាជីវកម្មក្រុមហ៊ុនរួម ចូលជាធរមានចាប់ពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦។

ធនាគារ គឺជាធនាគារពាណិជ្ជ និងធ្វើប្រតិបត្តិការអាជីវកម្មក្រោមច្បាប់ស្តីពីសហគ្រាសពាណិជ្ជនៃកម្ពុជា និងក្រោមបទប្បញ្ញត្តិនៃធនាគារជាតិនៃកម្ពុជា។

ការិយាល័យចុះបញ្ជីរបស់ធនាគារមានទីតាំងបច្ចុប្បន្នស្ថិតនៅអគារ ជាន់ទី១ ជាន់ M ជាន់ទី២ និងជាន់ទី៩ ផ្លូវលេខ១១០កែងផ្លូវលេខ ៩៣ ភូមិ ៣ សង្កាត់ ស្រះចក ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ក្រុមប្រឹក្សាភិបាលបានអនុម័តឱ្យចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុ នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០។ ក្រុមប្រឹក្សាភិបាលមានសិទ្ធិកែប្រែ និងចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុនេះឡើងវិញ។






www.rhbgroup.com.kh

# ព័ត៌មានទូទៅអំពីធនាគារ



## វត្តមានប្រតិបត្តិការ និងការអនុវត្តន៍របស់យើង




**២៤៦**

ចំនួនបុគ្គលិក

**១៣**

សាខា/ការិយាល័យកណ្តាល

## ការិយាល័យកណ្តាល

ជាន់ទី២ & ជាន់ទី៩ អគារOHK
កែងផ្លូវ១១០ & ផ្លូវ៩៣ រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទលេខ ៖ (៨៥៥) ២៣ ៩៩២ ៨៣៣
ទូរសារលេខ ៖ (៨៥៥) ២៣ ៩៩១ ៨២២
វេបសាយ ៖ www.rhbgroup.com.kh
ហ្វេសប៊ុក ៖ facebook.com/RHBCambodia
Toll Free: ១៨០០-២០-៨១១៨

# បណ្តាញសាខាទូទាំងរាជធានី-ខេត្ត ក្រុង

## ទីស្នាក់ការកណ្តាល
**ចំនួនបុគ្គលិក ៖ ១៨ នាក់**

ទីតាំងជាន់ទី១ អគារ OHK កែងផ្លូវ១១០ & ផ្លូវ៩៣
រាជធានីភ្នំពេញ ប្រទេសកម្ពុជា។
ទូរស័ព្ទលេខ ៖ ( ៨៥៥ ) ២៣ ៩៩២ ៨៣៣
ទូរសារលេខ ៖ ( ៨៥៥ ) ២៣ ៩៩១ ៨២២

## សាខា ពេទ្យលោកសង្ឃ
**ចំនួនបុគ្គលិក ៖ ៩ នាក់**

ទីតាំងអគារលេខ១-៣ វិថី២៧១ រាជធានីភ្នំពេញ
ប្រទេសកម្ពុជា។
ទូរស័ព្ទលេខ ៖ ( ៨៥៥ ) ២៣ ៩៦៩ ៣៦៨
ទូរសារលេខ ៖ ( ៨៥៥ ) ២៣ ៩៦៩ ៣៧០

## សាខា ស៊ីធីម៉លអូឡាំពិក
**ចំនួនបុគ្គលិក ៖ ១៦ នាក់**

ទីតាំងឡូតិ៍លេខ អាប៊ីអឹស៊ីរ៉ូ ជាន់ផ្ទាល់ដីផ្សារស៊ីធីម៉ល
វិថីមុន្នីរ៉េត រាជធានីភ្នំពេញ ប្រទេសកម្ពុជា។
ទូរស័ព្ទលេខ ៖ ( ៨៥៥ ) ២៣ ៩៩៣ ៥៦៨
ទូរសារលេខ ៖ ( ៨៥៥ ) ២៣ ៩៩៣ ៥៦៥

## សាខា ទួលគោក
**ចំនួនបុគ្គលិក ៖ ៩ នាក់**

ទីតាំងអគារលេខ ១៨ស៊ី គីមអ៊ីលស៊ុង
( វិថី ២៨៩ ) រាជធានីភ្នំពេញ ប្រទេសកម្ពុជា។
ទូរស័ព្ទលេខ ៖ ( ៨៥៥ ) ២៣ ៩៨៩ ៦០០
ទូរសារលេខ ៖ ( ៨៥៥ ) ២៣ ៩៨៩ ៦០៦



**ភ្នំពេញ**

## សាខា ស្ទឹងមានជ័យ
**ចំនួនបុគ្គលិក ៖ ៩ នាក់**

ទីតាំងវិថីមុន្នីរ៉េត ( ផ្លូវ២១៧ ) កែងផ្លូវចាក់សំរាម
រាជធានីភ្នំពេញ ប្រទេសកម្ពុជា។
ទូរស័ព្ទលេខ ៖ ( ៨៥៥ ) ២៣ ៩៦៩ ២២៨
ទូរសារលេខ ៖ ( ៨៥៥ ) ២៣ ៩៦៩ ២៣១

## សាខា ម៉ៅសេទុង
**ចំនួនបុគ្គលិក ៖ ១០ នាក់**

ទីតាំងអគារលេខ ២៨១អា វិថី ម៉ៅសេទុង
រាជធានីភ្នំពេញ ប្រទេសកម្ពុជា។
ទូរស័ព្ទលេខ ៖ ( ៨៥៥ ) ២៣ ៩៨៩ ៨៨១
ទូរសារលេខ ៖ ( ៨៥៥ ) ២៣ ៩៨៩ ៨៨៥

## សាខា បឹងកេងកង
**ចំនួនបុគ្គលិក ៖ ៨ នាក់**

ទីតាំងអគារលេខ ១៦៧ មហាវិថីព្រះនរោត្តម
រាជធានីភ្នំពេញ ប្រទេសកម្ពុជា។
ទូរស័ព្ទលេខ ៖ ( ៨៥៥ ) ២៣ ៩៨៩ ១១៨
ទូរសារលេខ ៖ ( ៨៥៥ ) ២៣ ៩៨៩ ៧៨៨

## សាខា ក្បាលថ្នល់
**ចំនួនបុគ្គលិក ៖ ៩ នាក់**

ទីតាំងអគារលេខ ៥៣០អា-៥៣០ប៊ី មហាវិថីមុនីវង្ស
( កែងវិថី២៧១ ) រាជធានីភ្នំពេញ ប្រទេសកម្ពុជា។
ទូរស័ព្ទលេខ ៖ ( ៨៥៥ ) ២៣ ៩៩៣ ៥៩៨
ទូរសារលេខ ៖ ( ៨៥៥ ) ២៣ ៩៩៣ ៥៩៣



**សៀមរាប**

## សាខា សៀមរាប
**ចំនួនបុគ្គលិក ៖ ១២ នាក់**

ទីតាំងអគារលេខ ១២-១៤-១៦ ផ្លូវជាតិលេខ ៦
ខេត្តសៀមរាប ប្រទេសកម្ពុជា។
ទូរស័ព្ទលេខ ៖ ( ៨៥៥ ) ៦៣ ៩៦៩ ៨១១
ទូរសារលេខ ៖ ( ៨៥៥ ) ៦៣ ៩៦៩ ៨១៦



**ព្រះសីហនុ**

## សាខា ព្រះសីហនុ
**ចំនួនបុគ្គលិក ៖ ៩ នាក់**

ទីតាំងអគារលេខ ១២៩ ផ្លូវ ៧ មករា ខេត្តព្រះសីហនុ
ប្រទេសកម្ពុជា។
ទូរស័ព្ទលេខ ៖ ( ៨៥៥ ) ៣៤ ៩៣៤ ៨១១
ទូរសារលេខ ៖ ( ៨៥៥ ) ៣៤ ៩៣៤ ៨១៦



**បាត់ដំបង**

## សាខា បាត់ដំបង
**ចំនួនបុគ្គលិក ៖ ៩ នាក់**

ទីតាំងអគារលេខ ១-៣-៥-៧ វិថីលេខ ៣
ខេត្តបាត់ដំបង ប្រទេសកម្ពុជា។
ទូរស័ព្ទលេខ ៖ ( ៨៥៥ ) ៣៤ ៩៣៤ ៨១១
ទូរសារលេខ ៖ ( ៨៥៥ ) ៣៤ ៩៣៤ ៨១៦



**កំពង់ចាម**

## សាខា កំពង់ចាម
**ចំនួនបុគ្គលិក ៖ ៨ នាក់**

ទីតាំងអគារលេខ ៤១ ផ្លូវជាតិលេខ ៧
ខេត្តកំពង់ចាម ប្រទេសកម្ពុជា។
ទូរស័ព្ទលេខ ៖ ( ៨៥៥ ) ៤២ ៩៤២ ៨១១
ទូរសារលេខ ៖ ( ៨៥៥ ) ៤២ ៩៤២ ៨៩៩



# ផ្នែកសំខាន់ ហិរញ្ញវត្ថុ


11.60
0.00
14.40
0.00
0.00
0.00
Last
Chg
11.60
14.40
0.00
0.00
0.00

# សង្ខេបហិរញ្ញវត្ថុរយៈពេល ៥ឆ្នាំ ផ្នែកសំខាន់ហិរញ្ញវត្ថុ

២០២០ ២០១៩ ២០១៨ ២០១៧ ២០១៦ ២០១៥


















# សង្ខេបហិរញ្ញវត្ថុរយៈពេល ៥ឆ្នាំ

បណ្តាច់ឆ្នាំ កាលបរិច្ឆេទត្រឹមថ្ងៃទី៣១ ខែធ្នូ

| | ២០២០ | ២០១៩ | ២០១៨ | ២០១៧ | ២០១៦ |
|---|---|---|---|---|---|
| **លទ្ធផលប្រតិបត្តិការ (ប្រាក់ដុល្លា)** | | | | | |
| ប្រាក់ចំណេញមុនបង់ពន្ធ | ៣.៣ | ១៨.៩ | ១៣.៧ | ១០.៧ | ៨.៤ |
| ប្រាក់ចំណេញក្រោយបង់ពន្ធ | ២.៧ | ១៥.០ | ១០.៩ | ៨.៦ | ៦.៧ |
| **ទិន្នន័យតារាងតុល្យការ (ប្រាក់ដុល្លា)** | | | | | |
| ទ្រព្យសកម្មសរុប | ៩៥៤.៨ | ៩៤៣.៣ | ៧៥៩.៣ | ៧១២.៨ | ៦២២.៩ |
| ឥណទាន និងបុរេប្រទាន | ៥៦៤.៤ | ៥០៦.២ | ៤២៨.៦ | ៣៩៦.១ | ៣៤៧.៦ |
| ទ្រព្យអសកម្មសរុប | ៨២៤.៣ | ៨១៥.៦ | ៦៤៦.៦ | ៦១៥.០ | ៥៣៨.៤ |
| ប្រាក់បញ្ញើអតិថិជន | ៥៩៩.១ | ៦៣២.៨ | ៥៨៥.៦ | ៤៧៦.២ | ២៩៧.៣ |
| ប្រាក់បញ្ញើសរុប | ៧៦៩.៦ | ៧៧៦.២ | ៦៣៧.៥ | ៦០៦.៧ | ៥២៨.៦ |
| ដើមទុន | ៧៥.០ | ៧៥.០ | ៧៥.០ | ៧១.០ | ៦៧.០ |
| មូលនិធិម្ចាស់ក្រុមហ៊ុន | ១៣០.៤ | ១២៧.៧ | ១១២.៧ | ៩៧.៨ | ៨៤.៤ |
| **អនុបាត (ភាគរយ)** | | | | | |
| ឥណទានមិនដំណើរការធៀប នឹងឥណទាន និងបុរេប្រទាន | ៤.៤ | ៣.៩ | ៤.៩ | ៤.០ | ២.៥ |
| ការបង្វិលចំណូលលើទ្រព្យសកម្មសុទ្ធ | ០.៣ | ១.៨ | ១.៥ | ១.៣ | ១.១ |
| ការបង្វិលចំណូលលើមូលនិធិម្ចាស់ហ៊ុន | ២.១ | ១២.៥ | ១០.៤ | ៩.៤ | ៧.៩ |
| អនុបាតឥណទានធៀប នឹងប្រាក់អតិថិជន | ៩៤.២ | ៨០.០ | ៧៣.២ | ៨៣.២ | ១១៦.៩ |
| អនុបាត ឥណទាន/ប្រាក់បញ្ញើ | ៧៣.៣ | ៦៥.២ | ៦៧.២ | ៦៥.៣ | ៦៥.៧ |

# រចនាសម្ព័ន្ធ គ្រប់គ្រង





# រចនាសម្ព័ន្ធគ្រប់គ្រង

- គណៈកម្មាធិការគ្រប់គ្រងហានិភ័យ
- គណៈកម្មាធិការសវនកម្ម
  - គណៈកម្មាធិការសវនកម្មគ្រប់គ្រង
- គណៈកម្មាធិការលាភការ និងការតែងតាំង
- គណៈកម្មការអភិវឌ្ឍសេវាកម្ម និងផលិតផលថ្មី
- គណៈកម្មាធិការគ្រប់គ្រងហានិភ័យ
- គណៈកម្មការគ្រប់គ្រងទ្រព្យ និងបំណុល

**នាយកផ្នែកហិរញ្ញវត្ថុ រតនាគារ និងយុទ្ធសាស្ត្រ**

**នាយកផ្នែកប្រតិបត្តិតាម**
- អធិការកិច្ចនិយ័តកម្ម និងត្រួតពិនិត្យ
- ផ្នែកតាមដានការប្រឆាំង និងការសម្អាត់ប្រាក់

**នាយកផ្នែកគ្រប់គ្រងហានិភ័យ**
- ហានិភ័យឥណទាន
- ហានិភ័យប្រតិបត្តិការ
- ហានិភ័យព័តមានវិទ្យា
- ហានិភ័យការគ្រប់គ្រងទ្រព្យសកម្ម និងបំណុល

**នាយកផ្នែកសវនកម្មផ្ទៃក្នុង**
- សវនកម្មឥណទាន
- សវនកម្មសាខា
- សវនកម្មការិយាល័យកណ្តាល

**នាយកផ្នែកច្បាប់ និងលេខាធិការ**
- ច្បាប់
- លេខាធិការ

**នាយកផ្នែកព័តមានវិទ្យា**
- ផ្នែកកម្មវិធីព័តមានវិទ្យា
- ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា
- ផ្នែកសុវត្ថិភាពព័តមានវិទ្យា
- ផ្នែកស្ថាបត្យកម្មសហគ្រាសអភិបាលកិច្ច
- ផ្នែកគ្រប់គ្រងគំរោង

**ធនាគារឌីជីថល**
- ផ្នែកគ្រប់គ្រងកម្មវិធី
- ផ្នែកបច្ចេកវិទ្យា & វិស្វកម្ម Digital
- ផ្នែកការរចនាបទពិសោធន៍
- ផ្នែកការរចនាបទអាជីវកម្ម

**នាយកផ្នែកប្រតិបត្តិការ**
- ផ្នែកទ្រទ្រង់និងសេវាកម្មធនាគារ
- ផ្នែកគ្រប់គ្រងទ្រព្យសម្បត្តិ
- ផ្នែកពង្រឹងគុណភាពសេវាកម្មនិងបណ្តឹងរបស់អតិថិជន
- ផ្នែកទ្រទ្រង់ប្រតិបត្តិការ (Trade, Remittance, Fores,SWIT)
- ផ្នែកទ្រទ្រង់ប្រតិបត្តិកាត
- ផ្នែកទ្រទ្រង់ប្រតិបត្តិ eKYC

**នាយកផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាល**
- ផ្នែកគ្រប់គ្រងសមិទ្ធផល និងយុទ្ធិសាស្ត្រ
- ផ្នែកប្រតិបត្តិហិរញ្ញវត្ថុ
- ផ្នែកទូទាត់សេវាកម្ម


ក្រុមប្រឹក្សាភិបាល
គណៈកម្មាធិការគ្រប់គ្រង
ក្រុមប្រឹក្សាភិបាល គណៈកម្មាធិការឥណទាន
គណៈកម្មការ បច្ចេកទេសព័ត៌មានវិទ្យា
គណៈកម្មាធិការវិន័យ
ដំណើរការ ឬទ្រទ្រង់ឥណទាន
គណៈកម្មាធិការឥណទាន
នាយកសម្ព័ន្ធ សេវាកម្មធនាគារខ្នាតធំ
អគ្គនាយក
នាយក ផ្នែកគ្រប់គ្រង ហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រ
នាយកផ្នែកសេវាកម្មហិរញ្ញវត្ថុបុគ្គល
រតនាគារ និងគ្រប់គ្រង ទ្រព្យសកម្ម អកម្ម
នាយកផ្នែកវាយតម្លៃ និងត្រួតពិនិត្យឥណទាន
នាយកផ្នែក គ្រប់គ្រងឥណទាន
នាយកផ្នែក អាជីវកម្មធនគារ
នាយកផ្នែកធនធាន មនុស្ស និងបណ្តុះបណ្តាល
នាយកផ្នែកផ្សព្វផ្សាយ និងទំនាក់ទំនង
នាយកផ្នែកគ្រប់គ្រង និងអភិវឌ្ឍផលិផល
នាយកផ្នែកអាជីវកម្ម និងគ្រប់គ្រងសាខា
រតនាគារ និងគ្រប់គ្រង ទ្រព្យសកម្ម និងបំណុល
វាយតម្លៃឥណទាន
ត្រួតពិនិត្យឥណទាន ឡើងវិញ
រដ្ឋបាលឥណទាន
ការគ្រប់គ្រងឥណទាន និងស្តារបំណុល
អាជីវកម្មខ្នាតធំ
អាជីវកម្មខ្នាតមធ្យម
ជំនួយផ្នែកឥណទាន/ ប្រតិបត្តិផ្នែកឥណទាន
ផ្នែកជំនួញសេវាកម្មធនាគារ
ផ្នែកសំណង និង អត្ថប្រយោជន៍
បណ្តុះបណ្តាល និង គ្រប់គ្រងទេពកោសល្យ
ជំនួយការទីផ្សារ
ទំនាក់ទំនងទីផ្សារ
ផ្នែក និង សម្ព័ន្ធ យុទ្ធសាស្ត្រ
ប្រាក់បញ្ញើរ និងកាត
ឥណទាន លំនៅដ្ឋាន
ផ្នែកផ្តល់ព័តមាន និងទទួលអតិថិជន
ផ្នែកត្រួតពិនិត្យ សាខា
ផ្នែកបញ្ជូនការ លក់ចល័ត
ទីស្នាក់ការកណ្តាល
ស៊ីធីម៉លអូឡាំពិក
ស្ទឹងមានជ័យ
ក្បាលថ្នល់
ពេទ្យលោកសង្ឃ
បឹងកេងកង
ម៉ៅសេងទុង
ទួលគោក
សៀមរាប
កំពង់ចាម
ព្រះសីហនុ
បាត់ដំបង
ប្រព័ន្ធធនាគារ ហិរញ្ញវត្ថុ ឌីជីថលកម្ពុជា
ប្រព័ន្ធធនាគារ តាមអេឡិចត្រូនិច

# របាយការណ៍ប្រធានក្រុមប្រឹក្សាភិបាល



ឆ្នាំ ២០២០ ជាឆ្នាំដ៏អាក្រក់មួយដែលពិភពលោកទាំងមូលប្រយុទ្ធប្រឆាំងជំងឺកូវីដ ១៩។ ជំងឺនេះបានបង្កអស្ថិរភាពទូទាំងពិភពលោក ដែលមិនត្រឹមតែបង្អាក់ប្រតិបត្តិការអាជីវកម្មប៉ុណ្ណោះទេ ប៉ុន្តែរបរចិញ្ចឹមជីវិត និងសុខភាពរបស់សហគមន៍នៅជុំវិញពិភពលោកក៏រងអន្តរាយដោយសារជំងឺរាតត្បាតនេះផងដែរ។

មនុស្សជាច្រើនបានបាត់បង់បុគ្គលជាទីស្រឡាញ់។ មនុស្សនៅគ្រប់ទីកន្លែងត្រូវបានបង្ខំឱ្យរស់នៅតាមគន្លងថ្មី ដែលពោរពេញដោយការបិទខ្ទប់ និងការរឹតត្បិតការដើរហើរ។

ប្រទេសកម្ពុជាក៏រងផលប៉ះពាល់ដោយសារជំងឺនេះផងដែរ។ ជំងឺនេះបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើសេដ្ឋកិច្ចក្នុងតំបន់ ជាពិសេសវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ចរបស់កម្ពុជារងផលប៉ះពាល់ខ្លាំងជាងគេ។ ការស្រុតចុះនៃតម្រូវការសកលបានដាក់សម្ពាធយ៉ាងខ្លាំងលើសេដ្ឋកិច្ចនាំចេញរបស់កម្ពុជា ហើយបូករួមនឹងការថយចុះទំនុកចិត្តរបស់អ្នកប្រើប្រាស់ សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ ២០២០ មានអត្រាកំណើនអវិជ្ជមាន -៣.១% ដែលជាការស្រុតចុះខ្លាំងបំផុតក្នុងទំព័រប្រវត្តិសាស្ត្រថ្មីៗបំផុតរបស់កម្ពុជា។

សំណាងល្អដែលរាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តវិធានការដោះស្រាយប្រកបដោយប្រសិទ្ធភាព និងអាចគ្រប់គ្រងវិបត្តិនេះ និងបញ្ចៀសមិនឱ្យស្ថានភាពរីករាលដាលធំ។ ក្រៅពីនេះ ធនគារជាតិនៃកម្ពុជាបានប្រកាសពីវិធានការផ្សេងៗសម្រាប់ការសម្រួលកម្ចីសម្រាប់បុគ្គល និងអាជីវកម្ម ដើម្បីជួយទ្រទ្រង់សេដ្ឋកិច្ច។

## ការអនុវត្តការងាររបស់យើង

ទោះបីជាស្ថិតក្នុងបរិយាកាសដ៏លំបាក និងប្រឈមយ៉ាងណាក្តី ក៏ធនាគារ RHB នៅតែអាចទទួលបានប្រាក់ចំណេញ។ ធនាគារទទួលបានប្រាក់ចំណេញសុទ្ធ ៣ លានដុល្លារ ទោះជាកម្រិតនេះទាបជាងកម្រិតកាលពីឆ្នាំមុនក្តី។ ការថយចុះប្រាក់ចំណេញនេះបណ្តាលមកពីការផ្តល់ជូនកម្រិតខ្ពស់ដែលធនាគារត្រូវអនុវត្តដោយសារភាពមិនប្រាកដប្រជាផ្នែកសេដ្ឋកិច្ច។

## ការរួមសុខទុក្ខជាមួយសហគមន៍របស់យើង

ផ្អែកតាមការប្តេជ្ញាចិត្តរបស់យើងចំពោះអតិថិជន ក្នុងអំឡុងពេលដ៏លំបាកនេះ និងដើម្បីជួយសម្រាលបន្ទុកហិរញ្ញវត្ថុរបស់អតិថិជន ធនាគារ RHB បានផ្តល់ភាពបត់បែនក្នុងការទូទាត់សង តាមរយៈកម្មវិធីរៀបចំកម្ចីឡើងវិញដើម្បីជួយដល់ដៃគូរបស់យើងក្នុងគ្រាដ៏លំបាកនេះ។ គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ ករណីសរុបដែលត្រូវបានរៀបចំឡើងវិញគឺ ១៣% នៃអ្នកខ្ចីសរុប ស្មើនឹង ១៨៦ លានដុល្លារ ឬ ៣២% នៃកម្ចីដុលដែលមិនទាន់សងចំនួន ៥៨៣ លានដុល្លារ។ យើងជឿថា ទន្ទឹមនឹងភាពចាំបាច់ក្នុងការបង្កើតប្រាក់ចំណេញសម្រាប់ម្ចាស់ភាគហ៊ុនរបស់យើង យើងត្រូវធានាវឌ្ឍនភាពប្រកបដោយនិរន្តរភាពជាមួយអតិថិជនដ៏មានតម្លៃរបស់យើង។

អាទិភាពចម្បងរបស់យើងគឺការធានាការពារសុវត្ថិភាព និងសុខុមាលភាពអតិថិជន និងបុគ្គលិករបស់យើង។ ក្នុងន័យនេះ យើងបានធានាថា យើងអនុលោមតាមនីតិវិធីប្រតិបត្តិស្តង់ដារទាំងអស់ ដូចជា ការពិនិត្យសីតុណ្ហភាព ការផ្តល់បរិក្ខារការពារ និងជែលលាងសម្អាតដៃ ក៏ដូចជាការរក្សាគម្លាតសង្គម និងការចាក់វ៉ាក់សាំងបុគ្គលិករបស់យើង។ ចំណុចនេះបានរួមចំណែកជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការបញ្ឈប់ការឆ្លងរាលដាលជំងឺកូវីដ ១៩។

ខណៈដែលពិភពលោកកំពុងខិតខំប្រយុទ្ធប្រឆាំងជំងឺរាតត្បាតនេះ និងជួយដល់អាជីវកម្ម យើងតែងគិតគូរពីប្រជាជនដែលជួបការលំបាក។ ធនាគារបានធ្វើការជាមួយស្ថាប័នផ្សេងៗដូចជា កាកបាទក្រហមកម្ពុជា និងសមាគមធនាគារនៅកម្ពុជា ក្នុងការផ្តល់ជំនួយហិរញ្ញវត្ថុដល់ជនរងគ្រោះដោយទឹកជំនន់ និងគ្រួសារដែលរងផលប៉ះពាល់ដោយជំងឺកូវីដ-១៩។ ធនាគារក៏បានធ្វើការជាមួយអ្នករៀបចំពិធីក្នុងស្រុក ដើម្បីចូលរួមក្នុងការប្រារព្ធពិធីបុណ្យហារីយ៉ាយ៉ា ដល់គ្រួសារមូស្លីមក្រីក្រជួបការលំបាក នៅក្នុងខេត្តស្ទឹងត្រែង ដោយការបរិច្ចាគសាច់ប្រាក់ និងស្បៀងអាហារផ្សេងៗ។ លើសពីនេះទៀត ធនាគារបានគាំទ្រអង្គការ ស្មាយល៍ ខេមបូឌា ដែលបានផ្តល់ការវះកាត់ដោយឥតគិតថ្លៃដល់កុមារក្រីក្រ ដែលមានបញ្ហាឆែបមាត់ ឆែបក្រអូមមាត់ និងខូចទ្រង់ទ្រាយមុខពីកំណើត ដើម្បីជួយឱ្យកុមារទាំងនោះមានភាពប្រក្រតីឡើងវិញ។

## ការឆ្ពោះទៅមុខ

ក្រោមវឌ្ឍនភាពនៃការកិច្ចខិតខំប្រឹងប្រែងចាក់វ៉ាក់សាំងបង្ការ យើងជឿថា យើងបានឆ្លងផុតព្រឹត្តិការណ៍ដ៏អាក្រក់បំផុតនេះ។ ខណៈដែលសេដ្ឋកិច្ចពិភពលោកកំពុងងើបឡើងវិញ និងការវិលត្រឡប់មកវិញនូវគំនិតសុទិដ្ឋិនិយមរបស់វិនិយោគិន យើងសង្ឃឹមថា សេដ្ឋកិច្ចនឹងត្រូវបានស្តារឡើងវិញ ប៉ុន្តែយើងនៅតែមានភាពប្រុងប្រយ័ត្ន។ យើងរំពឹងថា កម្ពុជានឹងវិលត្រឡប់ទៅរកគន្លងកំណើនវិជ្ជមាននៅឆ្នាំ ២០២១។ ក្រៅពីការងើបឡើងវិញនៃតម្រូវការសកល ចំណាយ និងការវិនិយោគរបស់រដ្ឋាភិបាលលើគម្រោងហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានរំពឹងថានឹងរួមចំណែកដល់ការស្តារសេដ្ឋកិច្ចក្នុងស្រុក។ ការប្រើប្រាស់របស់វិស័យឯកជនត្រូវបានរំពឹងថានឹងមានភាពប្រសើរឡើង ទន្ទឹមនឹងភាពល្អប្រសើរនៃប្រាក់ចំណូលគ្រួសារ ដោយសារនិកម្មភាពថយចុះ។ នៅក្រៅប្រទេស យើងមើលឃើញការស្តារឡើងវិញនៃការនាំចេញទំនិញ ដូចជា កង់ សម្ភារៈអេឡិចត្រូនិក និងផលិតផលកសិកម្ម។ ការនាំចេញផលិតផលកាត់ដេរ ត្រូវបានរំពឹងថានឹងកើនឡើងនៅពីក្រោយការស្តារឡើងវិញជាសកល និងការកើនឡើងនៃតម្រូវការ។ តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាង កម្ពុជា-ចិន ដែលត្រូវបានចុះហត្ថលេខានាពេលថ្មីៗនេះ និងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនឹងក្លាយជាកត្តារួមចំណែកយ៉ាងសំខាន់ដែលជួយទ្រទ្រង់ការស្តារឡើងវិញក្នុងព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ ២០២១។ យោងតាមធនាគារពិភពលោក សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងងើបឡើងវិញនៅឆ្នាំ ២០២១ ដោយមានកំណើនជាង ៤%។

ក្រៅពីនេះ ការរស់នៅតាមបែបគន្លងថ្មីបានពន្លឿនការប្រើប្រាស់សេវាឌីជីថល ហើយធនាគារ RHB បានពង្រីកកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការធ្វើឌីជីថលភាវូបនីយកម្ម ដើម្បីផ្តល់ភាពងាយស្រួលកាន់តែខ្លាំងដល់អតិថិជនរបស់យើង។ ចំណុចនេះរួមមានការផ្លាស់ប្តូរវេទិកាតាមប្រព័ន្ធអ៊ីនធឺណិត និងសេវាធនាគារចល័តរបស់យើងដែលផ្តល់បទពិសោធន៍កាន់តែរលូន និងមានប្រសិទ្ធផលដល់អតិថិជនរបស់យើង។ គំនិតផ្តួចផ្តើមសំខាន់ៗ ២ សម្រាប់ឆ្នាំ ២០២១ រួមមាន RHB REFLEX និង RHB Cambodia Retail Banking។

## សេចក្តីថ្លែងអំណរគុណ

ខ្ញុំសូមឆ្លៀតឱកាសនេះថ្លែងអំណរគុណចំពោះធនាគារជាតិនៃកម្ពុជាដែលនៅតែផ្តល់ការគាំទ្រ និងការណែនាំ ជាពិសេសក្នុងអំឡុងវិបត្តិសុខភាពបច្ចុប្បន្ន និងសហគមន៍ជំនួញដែលបានសហការ និងជឿទុកចិត្តលើធនាគារ RHB ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ ជាចុងបញ្ចប់ ខ្ញុំសូមអរគុណយ៉ាងស្មោះស្ម័គ្រចំពោះចលកររបស់ធនាគារ RHB។ នោះគឺបុគ្គលិករបស់យើងដែលជួយឱ្យយើងអាចសម្រេចបានវឌ្ឍនភាពរហូតមកដល់សព្វថ្ងៃនេះ។

**“យើងរីកចម្រើនជាមួយគ្នា”**



**ឈិន យុង ខឹង**
ប្រធានក្រុមប្រឹក្សាភិបាល

# របាយការណ៍លោកអគ្គនាយក



**ប្រាក់ចំណេញសុទ្ធ**

**៩៥៥ លានដុល្លារ**

**១១៤%**
អនុបាត LCR

**១២.៨%**
កម្ចី

ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក សម្រេចបានវឌ្ឍនភាពដ៏ត្រចះត្រចង់ក្នុងការក្លាយខ្លួនទៅជាធនាគារឈានមុខគេមួយ ក្នុងចំណោមធនាគារឈានមុខគេទាំង១៥ នៅកម្ពុជា ដោយបានយកឈ្នះលើធនាគារជាង ៥០ នៅទូទាំងប្រទេសកម្ពុជា។

នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០២០ ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក បានផ្លាស់ទីតាំងទៅអគារសាជីវកម្មរបស់យើង និងបានប្តូរឈ្មោះពីធនាគារ ធនាគារ អ អេ ប៊ី ឥណ្ឌូឆៃណាទៅជាធនគារ អ អេច ប៊ី (ខេមបូឌា) ម.ក និងបានទទួលការអនុម័តពីធនាគារជាតិនៃកម្ពុជា (NBC) ដែលចូលជាធរមាននៅថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០២០។ សមិទ្ធផលនេះកើតចេញពីការគាំទ្រ និងទំនុកចិត្តពីសំណាក់ម្ចាស់ភាគហ៊ុនរបស់យើង។

## ការពិនិត្យឡើងវិញលើដំណើរការហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០២០

លទ្ធផលហិរញ្ញវត្ថុរបស់យើងនៅឆ្នាំ ២០២០ រងផលប៉ះពាល់ដោយសារជំងឺរាតត្បាតកូវីដ ១៩។ ការថយចុះនៃប្រាក់ចំណេញសុទ្ធមកត្រឹម ៣ លានដុល្លារនៅឆ្នាំ ២០២០ បណ្តាលមកពីការផ្តល់ជូនកម្រិតខ្ពស់ដែលធនាគារបានកំណត់ទុកដោយសារភាពមិនប្រាកដប្រជាផ្នែកសេដ្ឋកិច្ច នៅចំពោះមុខផលប៉ះពាល់នៃជំងឺកូវីដ ១៩។ ទ្រព្យសកម្មសរុប ត្រូវបានកើនឡើងដល់ ៩៥៥ លានដុល្លាពីឆ្នាំមុនដោយមានអនុបាតសោធនភាពរឹងមាំចំនួន ១៦.៩% និងអនុបាតវិសាលភាពសន្ទនីយភាពចំនួន ១១៤% ដែលលើសពីអត្រាកាតព្វកិច្ចចំនួន ១៥% សម្រាប់អនុបាតសោធនភាព និង ១០០% សម្រាប់អនុបាតវិសាលភាពសន្ទនីយភាព។ យើងក៏ដូចគ្នាដែរ បានកត់ត្រាកំណើនប្រាក់កម្ចី ១២,៨% ។ លេខទាំងនេះ គឺជាការបញ្ជាក់ពីការជឿទុកចិត្តដែលសហគមន៍បានដាក់ធនាគារនិងការប្តេជ្ញាចិត្តឥតលយប់ឈររបស់និយោជិកនៃធនាគារ។ អនុបាតចំណាយ-ប្រាក់ចំណូល កើនបន្តិចចំនួន ៣៧.៤% ដោយសារចំណាយដែលពាក់ព័ន្ធនឹងអគារសាជីវកម្មថ្មី និងការវិនិយោគលើសេវាធនាគារកម្រិត Premier (Premier Banking) មជ្ឈមណ្ឌលបម្រើសេវាអតិថិជនថ្មី និងការធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា។

## ធនធានមនុស្សរបស់យើង

ក្នុងនាមជាធនាគារឈានមុខគេមួយ ក្នុងចំណោមធនាគារធំៗទាំង ១៥ នៅកម្ពុជា និងជាគ្រឹះស្ថានមានកេរ្តិ៍ឈ្មោះល្អដែលស្រូបទាញនិយោជិត យើងបន្តពង្រឹងការអភិវឌ្ឍទេពកោសល្យ ទន្ទឹមនឹងការបង្កប់ការអនុវត្តនិរន្តរភាពក្នុងការគ្រប់គ្រងមូលធនមនុស្សរបស់យើង។ ដើម្បីធានាកំណើនអាជីវកម្មយូរអង្វែង យើងបានគ្រប់គ្រងកម្លាំងពលកម្មចម្រុះរបស់យើង ដោយផ្តោតអាទិភាពលើការគ្រប់គ្រងទេពកោសល្យ ការបណ្តុះបណ្តាល និងការអប់រំនិយោជិត សុខភាព និងសុវត្ថិភាពនិយោជិត ក៏ដូចជានានាភាព និងឱកាសស្មើភាព។

យើងមានគោលបំណងប្រែក្លាយទៅជាគ្រឹះស្ថានដ៏គួរឱ្យទាក់ទាញ ដែលផ្តល់កម្លាំងពលកម្មមានផលិតភាពខ្ពស់ និងចូលរួមយ៉ាងស្វាហាប់ ដែលផ្តល់សេវាល្អផ្តាច់គេដល់អតិថិជនរបស់យើង។ ក្រុមរបស់យើងគ្រប់គ្រងទេពកោសល្យនិយោជិត តាមរយៈការផ្តោតអាទិភាពលើការអភិវឌ្ឍ និងគ្រប់គ្រងទេពកោសល្យដែលជាធាតុផ្សំសំខាន់ៗនៃការរៀបចំផែនការបន្តវេន និងការកសាងបណ្តុញភាពជាអ្នកដឹកនាំ។ យើងមានគោលដៅកសាងកម្លាំងពលកម្មដែលមានលក្ខណៈចម្រុះ និងត្រៀមខ្លួនបានល្អនាពេលអនាគត ទន្ទឹមនឹងការផ្តោតលើការទាក់ទាញ ការរក្សាទុក និងការអភិវឌ្ឍនិយោជិតដែលមានទេពកោសល្យ។

## ជំងឺរាតត្បាតកូវីដ ១៩ និងបញ្ហាប្រឈម

ឆ្នាំ ២០២០ ជាឆ្នាំដែលពិភពលោករងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារជំងឺកូវីដ ១៩ និងនាំទៅរកការបង្អាក់សកម្មភាពអាជីវកម្ម និងធ្វើឱ្យមនុស្សជាច្រើនស្លាប់បាត់បង់ជីវិតនៅទូទាំងពិភពលោក ក៏ដូចជានៅប្រទេសកម្ពុជា។ ជំងឺកូវីដ ១៩ បានបំផ្លាញរបរចិញ្ចឹមជីវិតរបស់ប្រជាជនរាប់សិបលានដែលធ្វើឱ្យបណ្តាប្រទេសនានាប្រកាសពីការបិទខ្ទប់ ការរឹតត្បិតការធ្វើដំណើរ និងវិធានការចត្តាឡីស័កជាហេតុនាំទៅរកការបង្អាក់សកម្មភាពសេដ្ឋកិច្ច។ កម្ពុជាបានឆ្លើយតបទៅនឹងជំងឺរាតត្បាតនេះតាមរយៈការអនុវត្តវិធានការសារពើពន្ធ និងវិធានការរូបិយវត្ថុដែលមិនធ្លាប់មាន ដើម្បីជួយសម្រាលផលប៉ះពាល់នៃវិបត្តិនេះលើបុគ្គលទាំងឡាយ និងបានប្រកាសវិធានការផ្សេងៗដើម្បីទ្រទ្រង់សេដ្ឋកិច្ចនៅអំឡុងពេលនេះ។

ធនាគារជាតិនៃកម្ពុជាបានប្រកាសដាក់ចេញវិធានការជាច្រើនដើម្បីកាត់បន្ថយវិបត្តិហិរញ្ញវត្ថុ រួមទាំងការផ្អាកការសងបំណុលរហូតដល់ ៦ ខែ និងការអនុវត្តតែការបង់ការប្រាក់ប្រចាំខែ។ ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក បានចាត់វិធានការតាមរយៈការអនុញ្ញាតឱ្យផ្អាកការសងបំណុលសម្រាប់ ៩៦ គណនី ដែលអតិថិជនមិនបានសងបណ្តាក់ប្រចាំខែ និង ៨៣ គណនីផ្សេងទៀតដែលត្រូវបង់តែការប្រាក់ប្រចាំខែ។

ក្នុងអំឡុងពេលដ៏លំបាកនេះ បុគ្គលិករបស់ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក នៅតែមានភាពធន់ និងសមត្ថភាពបន្សាំទៅនឹងការប្រែប្រួលកាលៈទេសៈ ហើយធនាគារនៅតែបន្តគាំទ្រដល់បុគ្គលិកដែលបំពេញការងារបានល្អ ដូចជា បុគ្គលិកធ្វើការនៅផ្ទះដែលមានប្រសិទ្ធផល និងការបំពាក់បំប៉នបុគ្គលិកឱ្យត្រៀមខ្លួនសម្រាប់អនាគត និងការទាញប្រយោជន៍ពីឱកាសនេះដើម្បីពង្រឹងរបៀបវារៈឌីជីថលភាវូបនីយកម្មរបស់ធនាគារ ដើម្បីផ្តល់សេវាកាន់តែប្រសើរដល់អតិថិជនរបស់យើង។

## ដំណើរការនៃសេវាធនាគារតាមប្រព័ន្ធអេឡិចត្រូនិក (E-BANKING)

ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក បានវិនិយោគយ៉ាងច្រើនលើសេវាធនាគារឌីជីថល ដើម្បីគាំទ្រដល់អតិថិជនរបស់យើងឆ្ពោះទៅរកសេវាធនាគារឌីជីថល។ នៅឆ្នាំ ២០២០ ជំងឺរាតត្បាតកូវីដ ១៩ បានបង្កើនអ្នកប្រើប្រាស់សេវានេះចំនួន ២៩%។ ជំងឺកូវីដ ១៩ បានផ្លាស់ប្តូររបៀបដែលអតិថិជនរបស់យើងធ្វើប្រតិបត្តិការជាមួយធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក ហើយយើងបានមើលឃើញការផ្លាស់ប្តូរផ្នែកប្រជាសាស្ត្រ ជាពិសេសការកើនឡើងនៃការប្រើប្រាស់ប្រចាំថ្ងៃចំនួន ៤៨% ដោយអតិថិជន E-banking នៅឆ្នាំ ២០២០។ ក្រៅពីនេះ អតិថិជនរបស់យើងបានអនុវត្តមធ្យោបាយទូទាត់បែបថ្មី ហើយទំហំនៃការទូទាត់តាមប្រព័ន្ធឌីជីថលកើនចំនួន ៣៨% នៅឆ្នាំ ២០២០។

## សេវាធនាគារកម្រិត PREMIER

ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក បានអនុវត្តហេដ្ឋារចនាសម្ព័ន្ធសេវាធនាគារកម្រិត Premier ដំបូងគេសម្រាប់អតិថិជនដ៏មានតម្លៃរបស់យើងនៅខែ វិច្ឆិកា ឆ្នាំ ២០២០និងជាធនាគារដំបូងគេនៅកម្ពុជាដែលផ្តល់ប្រអប់ប្រាក់បញ្ញើសុវត្ថិភាពដល់អតិថិជនរបស់យើង។ ប្រធានគ្រប់គ្រងផ្នែកទំនាក់ទំនងរបស់យើងនៅចាំផ្តល់ដំណោះស្រាយលើការគ្រប់គ្រងទ្រព្យសម្បត្តិ ដើម្បីប៉ាន់ស្មាន និងយល់ពីតម្រូវការអតិថិជន និងជួយសម្រេចគោលដៅទ្រព្យសម្បត្តិរយៈពេលខ្លី និងរយៈពេលវែងរបស់អតិថិជន។

នៅធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក យើងផ្តល់ហេដ្ឋារចនាសម្ព័ន្ធសេវាធនាគារកម្រិត Premier ដល់អតិថិជនដែលមានសមតុល្យអប្បបរមាចាប់ពី ៥០,០០០ ដុល្លារឡើងទៅ។ បុព្វសិទ្ធិមួយចំនួននៃសេវាធនាគារកម្រិត Premier នេះមានការផ្តល់ជូនកាន់តែច្រើន ដោយកំណត់ទំហំទឹកប្រាក់ដែលអាចដកតាមម៉ាស៊ីន ATM បានរហូតដល់ ៥,០០០ ដុល្លារក្នុងមួយថ្ងៃ និងការមិនគិតកម្រៃសេវាសម្រាប់ Inward Telegraphic។

កម្មវិធីផ្តល់ជូនពិសេសៗ នឹងត្រូវប្រារព្ធធ្វើឡើងជាប្រចាំ ដើម្បីបង្កើននូវគុណតម្លៃរបស់យើងចំពោះអតិថិជនធនាគារ Premier ដែលមានស្រាប់ ក៏ដូចជាការកសាងនូវសមិទ្ធិផលល្អៗរបស់យើងនៅក្នុងផ្នែកផងដែរនេះ។

## វប្បធម៌អនុលោមភាព និងការគ្រប់គ្រងហានិភ័យ

ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក ផ្តោតអាទិភាពលើវប្បធម៌អនុលោមភាព និងការគ្រប់គ្រងហានិភ័យនៅកម្ពុជា។ ធនាគារធានាថា រាល់លក្ខខណ្ឌតម្រូវត្រូវបានបំពេញ ហើយគោលនយោបាយ និងដំណើរការផ្ទៃក្នុងត្រូវបានអនុលោមតាមគ្រប់ពេលវេលា។ មុខងារអនុលោមភាព និងហានិភ័យដែលជាខ្សែបន្ទាត់ការពារទីពីរ កំណត់ពីព្រំដែនកំណត់ វិធាន និងកម្រិត ដែលជាមូលដ្ឋានសម្រាប់ការអនុវត្តសកម្មភាពជួរមុខ ស៊ីសង្វាក់គ្នានឹងកម្រិតហានិភ័យរបស់ធនាគារ និងពិនិត្យតាមដានការអនុវត្តការងារធៀបនឹងដែនកំណត់ និងកម្រិតទាំងនេះជារៀងរាល់ខែ។ ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក នឹងបន្តអនុវត្តយ៉ាងតឹងរ៉ឹង និងអនុលោមតាមការវិវត្ត និងការផ្លាស់ប្តូរចុងក្រោយ ដែលជាលក្ខខណ្ឌតម្រូវក្នុងបទប្បញ្ញត្តិ និងគោលនយោបាយ ដែលកំណត់ដោយនិយ័តករ ដើម្បីធានាថា ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក នឹងរីកចម្រើនប្រកបដោយភាពទទួលខុសត្រូវ។

## ដំណើរឆ្ពោះទៅមុខ

ផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើបុគ្គល និងអាជីវកម្ម នៅតែមានទំហំធំគួរឱ្យកត់សម្គាល់នៅឡើយ ហើយវិធានការផ្សេងៗនឹងត្រូវបន្តអនុវត្តដោយធនាគារ ដើម្បីកាត់បន្ថយភាពតានតឹងផ្នែកហិរញ្ញវត្ថុ និងផ្តល់ការគាំទ្រដល់អតិថិជនរបស់យើង ដែលរងផលប៉ះពាល់ដោយជំងឺរាតត្បាតនេះ។ ទោះជាយ៉ាងណាក៏ដោយ យើងត្រូវការពេលវេលា មុនពេលយើងអាចមើលឃើញសកម្មភាពសេដ្ឋកិច្ចដំណើរការជាធម្មតាឡើងវិញ។

វិស័យធនាគារនឹងនៅតែរឹងមាំដដែរដោយគ្មានការសង្ស័យ និងបន្សាំខ្លួន ពុះពារនឹងកត្តាប្រឈមផ្សេងៗក្នុងបរិយាកាសដែលមិនធ្លាប់មានពីមុនមកនេះ។ រដ្ឋាភិបាលមានទំនុកចិត្ត និងបានព្យាករណ៍ថា សេដ្ឋកិច្ចកម្ពុជានឹងកើនចំនួន ៤% នៅឆ្នាំ ២០២១ ដែលនាំមុខដោយការងើបឡើងនៃវិស័យឧស្សាហកម្មផលិត និងទ្រទ្រង់ដោយគ្រឿងជំរុញសារពើពន្ធជាបន្តបន្ទាប់ពីសំណាក់រដ្ឋាភិបាល។

ធនាគារនឹងបើកដំណើរការគេហទំព័រអក្ខរកម្មហិរញ្ញវត្ថុនៅឆ្នាំ ២០២១ ជាការគាំទ្រដល់របៀបវារៈរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការបង្កើនអក្ខរកម្ម និងបរិយាប័ន្នហិរញ្ញវត្ថុក្នុងចំណោមសាធារណជនទូទៅ។ គេហទំព័រអក្ខរកម្មហិរញ្ញវត្ថុនេះនឹងមានអត្ថបទសរសេរ និងឯកសារណែនាំ ជុំវិញប្រធានបទហិរញ្ញវត្ថុ វីដេអូអប់រំអំពីមូលដ្ឋានគ្រឹះនៃហិរញ្ញវត្ថុ និងយោបល់គន្លឹះអំពីរបៀបគ្រប់គ្រង និងបង្កើនទ្រព្យសម្បត្តិ ក្នុងដំណើរហិរញ្ញវត្ថុរបស់មនុស្សម្នាក់ៗ។

ធនាគារនឹងបន្តវិនិយោគលើទម្រង់ឌីជីថល ដើម្បីបំពេញតម្រូវការថ្មីៗរបស់អតិថិជន និងផ្តល់នូវសេវាដែលមានភាពរីករាយ ក៏ដូចជាដើម្បីរក្សាកំណើនទ្រព្យសកម្មអោយបានខ្ពស់ នៅក្នុងអាជីវកម្មរបស់ធនាគារ។ វិន័យផ្នែកឥណទាននឹងជាបុព្វសិទ្ធិ នៅក្នុងកម្លាំងជម្រុញរបស់យើង ដើម្បីសម្រេចបានកំណើនប្រកបដោយចីរភាព សូម្បីតែក្នុងខណៈដែលយើងកំពុងតម្រង់ផ្លូវប្រតិបត្តិការក្នុងកាលៈទេសៈដ៏លំបាក។

ធនាគារនឹងបន្តផ្តល់ការងារ និងរក្សាបុគ្គលិកដែលល្អបំផុតឱ្យនៅបម្រើការងារ និងវិនិយោគលើការបណ្តុះបណ្តាល និងអភិវឌ្ឍអ្នកមានទេពកោសល្យសម្រាប់អាជីពដែលមានលទ្ធផលល្អនៅក្នុងធនាគារ។

ជាចុងក្រោយ ក្នុងនាមធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រឥតប្រែប្រួល ដល់អតិថិជនដ៏មានតម្លៃ ដៃគូ និងបុគ្គលិកដែលមានការលះបង់គ្រប់រូប។ យើងខ្ញុំសូមកោតសរសើរអស់ពីដួងចិត្តចំពោះធនាគារជាតិនៃកម្ពុជា ដែលបានផ្តល់ការគាំទ្រជាទៀងទាត់ និងដំបូន្មានដល់ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក។

**"យើងរីកចម្រើនជាមួយគ្នា"**



**វង្ស គី ប៉**
អគ្គនាយក





# ក្រុមប្រឹក្សាភិបាល



# សមាសភាពក្រុមប្រឹក្សាភិបាល



**លោក ឈិន យូង ខឹង**
ប្រធានក្រុមប្រឹក្សាភិបាល, អភិបាលឯករាជ្យ មិនប្រតិបត្តិ
ជនជាតិម៉ាឡេស៊ី

លោក ឈិន យូង ខឹង ("លោក ឈិន") ត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាលឯករាជ្យ មិនប្រតិបត្តិ នៃធនាគារ អ អេច ប៊ី ( ខេមបូឌា ) ម.ក (RHBBCP) នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ ។

លោក ឈិន ក៏មានតួនាទីជាប្រធានគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងតណទានកម្រិតក្រុមប្រឹក្សាភិបាល និងជាសមាជិកគណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការលាភការ និងជ្រើសតាំង។

លោក ឈិន ត្រូវបានតែងតាំងជាសមាជិកឯករាជ្យនៃក្រុមប្រឹក្សាភិបាល នៃធនាគារ RHB Investment Bank នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០១៦។ បន្ទាប់មក នៅថ្ងៃទី៣០ខែកញ្ញា ឆ្នាំ២០១៦ លោកត្រូវបានតែងតាំងជា អភិបាលឯករាជ្យមិនប្រតិបត្តិជាន់ខ្ពស់នៃក្រុមប្រឹក្សាភិបាល។ លោកក៏មានតួនាទីជាប្រធានគណៈកម្មាធិការហានិភ័យកម្រិតក្រុមប្រឹក្សាភិបាលរបស់ធនាគារ RHB Investment Bank ផងដែរ។

លោក ឈិន មានបរិញ្ញាបត្រ( កិត្តិយស ) ផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ចពីសាកលវិទ្យាល័យលីតស៍ (University of Leeds) និងជាសមាជិកនៃវិទ្យាស្ថានគណនេយ្យករជំនាញនៅប្រទេសអង់គ្លេស និងវេលស៍។ លោកក៏ជាសមាជិកនៃវិទ្យាស្ថានគណនេយ្យករជំនាញសាធារណៈ និងវិទ្យាស្ថានគណនេយ្យករប្រទេសម៉ាឡេស៊ីផងដែរ។ លោក ឈិន បានចូលនិវត្តន៍ពីការងារជាដៃគូរបស់ក្រុមហ៊ុន KPMG ដែលជាក្រុមហ៊ុនមួយ ក្នុងចំណោមក្រុមហ៊ុនគណនេយ្យនាំមុខគេជាច្រើន នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ក្រោយពីលោកបានបម្រើការងារនៅក្នុងក្រុមហ៊ុននេះ អស់រយៈពេលជាង៣៤ ឆ្នាំ នៅចក្រភពអង់គ្លេស ប្រទេសវៀតណាម និងប្រទេសម៉ាឡេស៊ី។ លោក ឈិន មានបទពិសោធន៍យ៉ាងទូលំទូលាយក្នុងវិស័យធុរកិច្ច ដូចជាផ្នែកយុទ្ធសាស្ត្រ ផ្នែកធនធានមនុស្ស ផ្នែកការអភិវឌ្ឍប្រសិទ្ធភាពការងារសម្រាប់វិស័យសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធ ទីផ្សារអតិថិជន និងឧស្សាហកម្ម និងឧស្សាហកម្មសេវាហិរញ្ញវត្ថុ។ ពេញអាជីពការងារដ៏យូរអង្វែងរបស់លោកជាមួយក្រុមហ៊ុន KPMG លោក ឈិន មានបទពិសោធន៍ផ្នែកមុខងារសវនកម្ម មុនពេលទទួលបានជំនាញផ្នែកពន្ធដារអស់រយៈពេល១៤ ឆ្នាំ។ លោក ឈិន ធ្លាប់ទទួលខុសត្រូវលើការបង្កើតការអនុវត្តរបស់ក្រុមហ៊ុន KPMG នៅប្រទេសវៀតណាម និងក្រោយមកបានបំពេញតួនាទីជាប្រធានផ្នែកអនុវត្តការប្រឹក្សាយោបល់របស់ក្រុមហ៊ុន KPMG អស់រយៈពេល៧ ឆ្នាំ។

លោក ឈិន ធ្លាប់កាន់តំណែងជាប្រធាន/សមាជិកក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនផ្សេងៗជាច្រើន រួមមាន ក្រុមហ៊ុនអរអេចប៊ីគ្រប់គ្រងទ្រព្យសកម្ម (RHB Asset Management Sdn Bhd) ក្រុមហ៊ុនអរអេចប៊ីគ្រប់គ្រងទ្រព្យសកម្មឥស្លាមអន្តរជាតិ (RHB Islamic International Asset Management Berhad ) ក្រុមហ៊ុនមូលប័ត្រ អរអេចប៊ី ( ប្រទេសថៃ ) សាធារណៈចំកាត់ (RHB Securities (Thailand) Public Company Limited ) ក្រុមហ៊ុនមូលប័ត្រ អរអេចប៊ីវៀតណាម សាធារណៈចំកាត់ (RHB Securities Vietnam Company Limited) ធនាគារអរអេចប៊ីឡាវចំកាត់ (RHB Bank Lao Sole Co., Ltd) ក្រុមហ៊ុន អ អេច ប៊ី ស៊ីឃ្យូរីធី ( ខេមបូឌា ) ) ម.ក (RHB Securities (Cambodia) Plc.) និងក្រុមហ៊ុន Ayer Holdings Berhad ជាក្រុមហ៊ុនដែលមានសន្លឹកហ៊ុនលក់ទិញនៅផ្សារហ៊ុនកូឡាឡាំពួរ (Kuala Lumpur Stock Exchange)។



## លោក អាឌិស្សាឌិគីន អាលី

អភិបាលមិនឯករាជ្យ មិនប្រតិបត្តិ និងជាតំណាងភាគទុនិកជនជាតិម៉ាឡេស៊ី

លោក អាឌិស្សាឌិគីន អាលី (“លោក អាឌិស្សាឌិគីន”) ត្រូវបានតែងតាំងជាអភិបាលមិនឯករាជ្យ មិនប្រតិបត្តិនៃធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក (RHBBCP) នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៩។

លោក អាឌិស្សាឌិគីន ត្រូវបានតែងតាំងជានាយកគ្រប់គ្រង/នាយកប្រតិបត្តិ (“MD/CEO”) នៃធនាគារ RHB Islamic Bank នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០១៦។ លោក អាឌិស្សាឌិគីន ទទួលខុសត្រូវលើការដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍសេវាធនាគារ Islamic Banking និង Shariah Business នៅក្នុង RHB Banking Group។

លោក អាឌិស្សាឌិគីន មានបទពិសោធន៍ជាង២០ឆ្នាំ ក្នុងឧស្សាហកម្មសេវាហិរញ្ញវត្ថុ ដោយបានកាន់តំណែងជាន់ខ្ពស់នៅក្នុងធនាគារ RHB Islamic Bank និងធនាគារ AlKhair International Islamic Bank Berhad ។ មុនពេលចូលបម្រើការនៅធនាគារ អ អេច ប៊ី គាត់បានកាន់តំណែងជានាយកគ្រប់គ្រង និងប្រធានផ្នែកប្រតិបត្តិការ នៅធនាគារ Export-Import Bank Malaysia Berhad ។

គាត់មានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រង និងធុរកិច្ច (ហិរញ្ញវត្ថុ) ពីសាកលវិទ្យាល័យម៉ាឡេស៊ី និងបរិញ្ញាបត្រធុរកិច្ច (ធនាគារ និងហិរញ្ញវត្ថុ) ពីសាកលវិទ្យាល័យម៉ូណាស៍នៃប្រទេសអូស្ត្រាលី។ បន្ថែមពីនេះ គាត់ក៏មានគុណវុឌ្ឍិផ្សេងទៀតដូចជាសញ្ញាបត្រឌីប្លូមផ្នែកវិភាគការវិនិយោគ ពីសាកលវិទ្យាល័យ Teknologi MARA-“UiTM” នៃប្រទេសម៉ាឡេស៊ី និងកម្មវិធីគ្រប់គ្រងកម្រិតខ្ពស់ (“AMP”) ពីសាលាធុរកិច្ចហារវើត នៅទីក្រុងបូស្តុននៃសហរដ្ឋអាមេរិក។ គាត់ក៏ជាធនាគារិកជំនាញនៃវិទ្យាស្ថានធនាគារិកជំនាញនៅអាស៊ី (“AICB”) ធនាគារិកជំនាញនៃវិទ្យាស្ថានធនាគារិកជំនាញនៃចក្រភពអង់គ្លេស និងជាអ្នកប្រកបវិជ្ជាជីវៈជំនាញផ្នែកហិរញ្ញវត្ថុឥស្លាម នៃវិទ្យាស្ថាន Islamic Finance Professionals នៅប្រទេសម៉ាឡេស៊ី។

លោក អាឌិស្សាឌិគីន ក៏ធ្លាប់កាន់តំណែងជានាយកប្រតិបត្តិនៃធនាគារ អ អេច ប៊ី ប្រចាំប្រទេសឡាវ (RHB Bank Lao Sole Co., Ltd) និងក្រុមហ៊ុន អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា) ម.ក (RHB Securities (Cambodia) Plc.) ផងដែរ។ លោក អាឌិស្សាឌិគីន ជាសមាជិកខាងក្រៅ នៅក្នុងក្រុមប្រឹក្សាទីប្រឹក្សាឧស្សាហកម្មធនាគារ មហាវិទ្យាល័យធុរកិច្ច និងគណនេយ្យ នៃសាកលវិទ្យាល័យម៉ាឡេស៊ី ក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុឥស្លាម (“IBFIM”) នៃប្រទេសម៉ាឡេស៊ី និងជាប្រធាន និងសមាជិកក្រុមប្រឹក្សានៃសមាគមគ្រឹះស្ថានធនាគារឥស្លាម នៃប្រទេសម៉ាឡេស៊ី (“AIBIM”)។

# សមាសភាពក្រុមប្រឹក្សាភិបាល (ត)



**លោក ស៊ីថ អាហ៍ម៉ាត ទូហ្វីក អាល់បារ៍**
**អភិបាលមិនឯករាជ្យ មិនប្រតិបត្តិ**
**ជនជាតិម៉ាឡេស៊ី**

លោក ស៊ីថ អាហ៍ម៉ាត ទូហ្វីក អាល់បារ៍ ("លោក ស៊ីថ") ត្រូវបានតែងតាំងជាអភិបាលមិនឯករាជ្យ មិនប្រតិបត្តិ នៃធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក (RHBBCP) នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១។

លោក ស៊ីថ មានតួនាទីជាសមាជិកនៃគណៈកម្មាធិការសវនកម្ម គណៈកម្មាធិការលាភការ និងជ្រើសតាំង គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងគណៈកម្មាធិការឥណទានកម្រិតក្រុមប្រឹក្សាភិបាល។

លោកត្រូវបានតែងតាំងជាប្រធាន Group International Business នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២១។ ក្នុងតួនាទីថ្មីនេះ ទំនួលខុសត្រូវជាចម្បងរបស់លោក ស៊ីថ គឺត្រួតពិនិត្យលើការរីកចម្រើន និងការអនុវត្តការងាររបស់ Group International Business ដែលគ្របដណ្តប់លើការគ្រប់គ្រងពាណិជ្ជកម្ម សេវាធនាគារវិនិយោគ និង ទ្រព្យសកម្ម ដោយធ្វើឱ្យមានកិច្ចសហការរវាងមុខងារ និងធនធាន នៅទូទាំងគ្រុប និងក្នុងបណ្តាប្រទេសដែល RHB Group មានវត្តមាន។ លោកស៊ីថ ក៏នឹងត្រួតពិនិត្យលើអាជីវកម្មប្រមូលមកវិញនូវប្រាក់កម្ចីមិនមែនលក់រាយផងដែរ ដោយផ្តោតលើការពង្រឹងកិច្ចប្រឹងប្រែងក្នុងការប្រមូលមកវិញ។

មុនពេលតែងតាំងឱ្យកាន់តំណែងនេះ លោកមានតំណែងជាប្រធានផ្នែកហិរញ្ញវត្ថុរបស់គ្រុប ចាប់តាំងពីថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៦។

លោក ស៊ីថ មានបទពិសោធជាង ២០ឆ្នាំ លើជំនាញជគណនេយ្យករ និងជាអ្នកប្រកបវិជ្ជាជីវៈហិរញ្ញវត្ថុ ជាមួយមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ក្នុងវិស័យប្រេង និងឧស្ម័ន ទូរគមនាគមន៍ចល័ត និងហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាការអភិវឌ្ឍអចលនទ្រព្យ និងសំណង់។ លោកបានចាប់ផ្តើមអាជីពក្នុងវិស័យហិរញ្ញវត្ថុជាមួយក្រុមហ៊ុន Shell ហើយបានធ្វើការនៅការិយាល័យផ្សេងៗរបស់ក្រុមហ៊ុន Shell នៅប្រទេសម៉ាឡេស៊ី អូស្រ្តាលី និងហូឡង់។ មុនពេលចូលបម្រើការងារជាមួយ RHB Group លោកគឺជាប្រធានផ្នែកហិរញ្ញវត្ថុនៃក្រុមហ៊ុន UEM Group Berhad និងជាប្រធានផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Smart Axiata (កម្ពុជា)។

លោក ស៊ីថ ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ច និងបរិញ្ញាបត្រផ្នែកគណនេយ្យ ពីសាកលវិទ្យាល័យអ៊ីស្លាមអន្តរជាតិម៉ាឡេស៊ី។ លោក ស៊ីថ គឺជាសមាជិកនៃវិទ្យាស្ថានគណនេយ្យករជំនាញផ្នែកគ្រប់គ្រង (CIMA) និងជាសមាជិកនៃវិទ្យាស្ថានគណនេយ្យករម៉ាឡេស៊ី (MIA)។

លោក ស៊ីថ ធ្លាប់កាន់តំណែងជាប្រធានក្រុមហ៊ុន RHB (Philippines), ក្រុមហ៊ុន RHB Kawal Sdn Bhd, ក្រុមហ៊ុន RHB Trustees Berhad, ក្រុមហ៊ុន Malaysian Trustees Berhad, ក្រុមហ៊ុន RHB Investment Ltd និងក្រុមហ៊ុន Banfora Pte Ltd។



## លោកស្រី ម៉ៅ សំរុទ្ធារី

**អភិបាលឯករាជ្យ មិនប្រតិបត្តិ**

**ជនជាតិខ្មែរ**

លោកស្រី ម៉ៅ សំរុទ្ធារី (“លោកស្រី សំរុទ្ធារី”) ត្រូវបានតែងតាំងជាអភិបាលឯករាជ្យ មិនប្រតិបត្តិ នៃធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក (RHBBCP) នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៩។

លោកស្រី សំរុទ្ធារី ក៏ជាប្រធានគណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការលាភការ និងជ្រើសតាំង ហើយក៏ជាសមាជិកនៃគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងគណៈកម្មាធិការឥណទានកម្រិតក្រុមប្រឹក្សាភិបាលផងដែរ។

លោកស្រី សំរុទ្ធារី គឺជាដៃគូស្ថាបនិក និងជានាយិកាគ្រប់គ្រងនៃក្រុមហ៊ុន អេចអឹមអិល (HML)។ លោកស្រីមានជំនាញផ្នែកធនាគារ ប្រតិបត្តិការពាណិជ្ជកម្ម ប្រតិបត្តិការដីធ្លី ការងារ/កម្មភាព ទូរគមនាគមន៍ សណ្ឋាគារ និងរមណីយដ្ឋាន សម្រុះសម្រួល បណ្តឹងវិវាទ និងមានបណ្តាញការងារល្អជាមួយគ្រប់វិស័យដែលពាក់ព័ន្ធ រួមទាំងមន្ត្រីរដ្ឋាភិបាលផង។ ដោយមានបទពិសោធន៍ជាង២០ឆ្នាំ រួមជាមួយសញ្ញាបត្របណ្ឌិតផ្នែកវិទ្យាសាស្ត្រ នយោបាយ និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិសាស្ត្រ លោកស្រីត្រូវបានគេទទួលស្គាល់ជាមេធាវីដែលល្បីឈ្មោះនៅកម្ពុជា ដែលប្រកបព្រមដោយចំណេះដឹង និងបទពិសោធន៍ដ៏ប្រសើរថ្លៃថ្លា ក្នុងការដោះស្រាយបញ្ហាសម្រាប់កូនក្តីប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្នុងនាមជាមេធាវីក្រុមហ៊ុន និងបណ្តឹងវិវាទ លោកស្រី សំរុទ្ធារី បានធ្វើជាតំណាងកូនក្តីក្នុងសំណុំរឿងដែលស្មុគស្មាញរាប់រយករណី ទាំងសម្រាប់ស្ថាប័នឯកជន និងសាធារណៈ។ លោកស្រី បានតំណាងឱ្យធនាគារផ្សេងៗ ប្រកបដោយជោគជ័យក្នុងការប្រមូលបានវិញនូវប្រាក់កម្ចីជាប្រាក់ដុល្លារយ៉ាងច្រើន ហើយត្រូវបានតែងតាំងជាមេធាវីជាន់ខ្ពស់របស់ធនាគារពាណិជ្ជផ្សេងៗ។ លើសពីនេះទៀត លោកស្រីបានតំណាងឱ្យក្រុមហ៊ុនសេវាកម្សាន្តធំជាងគេនៅកម្ពុជាសម្រាប់ការដាក់សំណើលក់ដំបូងជាសាធារណៈ (IPO) ដែលមានតម្លៃ ៣៦៩ លានដុល្លារអាមេរិក សម្រាប់ការចុះបញ្ជីរបស់ខ្លួននៅផ្សារភាគហ៊ុនហុងកុង ហើយបានក្លាយជាក្រុមហ៊ុនកម្ពុជាដំបូង ដែលបានចេញសញ្ញាប័ណ្ណនៅក្រៅប្រទេស ដោយបានបង្កើនប្រាក់ចំនួន ៣០០លានដុល្លារអាមេរិក។

លោកស្រី សំរុទ្ធារី ក៏ជាសមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារ RHB Bank Lao Sole Co., Ltd និងក្រុមហ៊ុន អ អេច ប៊ី ស៊ីឃ្យួរីធី (ខេមបូឌា) ម.ក (RHB Securities (Cambodia) Plc) ផងដែរ។

# សមាសភាពក្រុមប្រឹក្សាភិបាល (ត)



**លោក វង្ស គី ប៉**
**អគ្គនាយក/អភិបាលឯករាជ្យ ប្រតិបត្តិ**
**ជនជាតិម៉ាឡេស៊ី**

លោក វង្ស គី ប៉ ត្រូវបានតែងតាំងជានាយកប្រតិបត្តិ ចាប់ពីថ្ងៃទី១ ខែកញ្ញាឆ្នាំ ២០២០និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារអរអេចប៊ី (ខេមបូឌា) ម.ក នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០។

លោកមានបទពិសោធន៍យ៉ាងទូលំទូលាយ ដោយបានបំពេញតួនាទីជាអ្នកដឹកនាំក្នុងវិស័យធនាគារអស់រយៈជាង ៣៨ ឆ្នាំមកហើយ។ លោកបានកាន់តួនាទីជាអ្នកគ្រប់គ្រងជាន់ខ្ពស់ ក្នុងការដឹកនាំកំណើនក្នុងធនាគារអាជីវកម្ម និងធនាគារលក់រាយ និងអតិថិជន នៅក្នុងគ្រឹះស្ថានហិរញ្ញវត្ថុដែលល្បីឈ្មោះនានា នៅក្នុងប្រទេសម៉ាឡេស៊ី។

បទពិសោធន៍ការងាររបស់លោក មានវិសាលភាពយ៉ាងទូលំទូលាយក្នុងវិស័យធនាគារនៅតាមសាខា ការិយាល័យកណ្តាល និងថ្នាក់តំបន់ គ្របដណ្តប់លើធនាគារសាជីវកម្ម ពាណិជ្ជកម្មនិងអតិថិជន ហិរញ្ញវត្ថុពាណិជ្ជកម្ម ការអភិវឌ្ឍផលិតផលការគ្រប់គ្រងឥណទាន ការលក់ និងទីផ្សារ ក៏ដូចជាការអភិវឌ្ឍន៍អាជីវកម្មថ្នាក់តំបន់។

មុនពេលការតែងតាំង លោក វង្ស ត្រូវបានបញ្ជូនទៅបម្រើការជាប្រធានស្តីទីនៃធនាគារអរអេចប៊ីប្រចាំប្រទេសថៃ នៅក្នុងខែតុលា ឆ្នាំ២០១៤ មុនពេលលោកត្រូវបានតែងតាំងជានាយកប្រតិបត្តិ ចាប់ពីខែឧសភា ឆ្នាំ២០១៥ ដល់ខែសីហា ឆ្នាំ២០២០។ លោកធ្លាប់ជាអនុប្រធានប្រចាំប្រទេសនៃធនាគារអរអេចប៊ី (ខេមបូឌា) ភីអិលស៊ី ចាប់ពីខែមករា ឆ្នាំ២០១៣ រហូតដល់ពេលលោកត្រូវទៅកាន់តំណែងជាប្រធានស្តីទីនៃធនាគារអរអេចប៊ី នៅប្រទេសថៃ នៅខែតុលា ឆ្នាំ២០១៤។

លោកជាសមាជិកនៃគណៈកម្មាធិការសំខាន់ៗ ដូចជា គណៈកម្មាធិការគ្រប់គ្រង គណៈកម្មាធិការទ្រព្យសកម្ម និងបំណុល គណៈកម្មាធិការសវនកម្មគ្រប់គ្រង និង គណៈកម្មាធិការផ្តល់កម្ចីឥណទាន។ លោកបានបញ្ចប់អនុបណ្ឌិតផ្នែករដ្ឋបាលពាណិជ្ជកម្មពីប្រទេសកាណាដា និងជាម្ចាស់ពានរង្វាន់ប្រធានក្រុមប្រឹក្សាភិបាលដោយបានបញ្ចប់ summa cum laude។ លោកក៏បានចូលរួមកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំជាន់ខ្ពស់របស់ INSEAD ក្នុងឆ្នាំ២០១៤ ផងដែរ។

លោក វង្ស ក៏ជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ អ អេច ប៊ី ស៊ីយូរីធី (ខេមបូឌា) ម.ក ផងដែរ។

# ប្រធានក្រុមប្រឹក្សាភិបាល

## ប្រធានក្រុមប្រឹក្សាភិបាល

**លោក ឈិន យួង ខឹង**
ប្រធានគណៈកម្មាធិការគ្រប់គ្រង

**លោក ទួន ស៊ីថ អាហ៍ម៉ាត ទូហ្វីក អាល់បារ៍**
សមាជិកគណៈកម្មាធិការ

**លោក អាឌិស្សាឌិគីន អាលី**
សមាជិកគណៈកម្មាធិការ

**លោកស្រី ម៉ៅ សំវុទ្ធារី**
សមាជិកគណៈកម្មាធិការ

**លោក វង្ស គី ប៉**
សមាជិកគណៈកម្មាធិការ

## គណៈកម្មាធិការគ្រប់គ្រង

### គណៈកម្មាធិការសវនកម្ម

**លោកស្រី ម៉ៅ សំវុទ្ធារី**
ប្រធានគណៈកម្មាធិការគ្រប់គ្រង

**លោក ឈិន យួង ខឹង**
សមាជិកគណៈកម្មាធិការ

**លោក ទួន ស៊ីថ អាហ៍ម៉ាត ទូហ្វីក អាល់បារ៍**
សមាជិកគណៈកម្មាធិការ

### គណៈកម្មាធិការលាភការ និងការតែងតាំង

**លោកស្រី ម៉ៅ សំវុទ្ធារី**
ប្រធានគណៈកម្មាធិការគ្រប់គ្រង

**លោក ឈិន យួង ខឹង**
សមាជិកគណៈកម្មាធិការ

**លោក ទួន ស៊ីថ អាហ៍ម៉ាត ទូហ្វីក អាល់បារ៍**
សមាជិកគណៈកម្មាធិការ

### គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

**លោក ឈិន យួង ខឹង**
ប្រធានគណៈកម្មាធិការគ្រប់គ្រង

**លោក ទួន ស៊ីថ អាហ៍ម៉ាត ទូហ្វីក អាល់បារ៍**
សមាជិកគណៈកម្មាធិការ

**លោកស្រី ម៉ៅ សំវុទ្ធារី**
សមាជិកគណៈកម្មាធិការ

### គណៈកម្មាធិការឥណទាន

**លោក ឈិន យួង ខឹង**
ប្រធានគណៈកម្មាធិការគ្រប់គ្រង

**លោក ទួន ស៊ីថ អាហ៍ម៉ាត ទូហ្វីក អាល់បារ៍**
សមាជិកគណៈកម្មាធិការ

**លោកស្រី ម៉ៅ សំវុទ្ធារី**
សមាជិកគណៈកម្មាធិការ

# ថ្នាក់ដឹកនាំជាន់ខ្ពស់





# សមាសភាពរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់



## លោក វង្ស គី ប៉

**នាយកប្រចាំប្រទេស/នាយកប្រតិបត្តិ**

លោក វង្ស គី ប៉ ត្រូវបានតែងតាំងជានាយកប្រតិបត្តិ (CEO) នៃធនាគារ អ អេច ប៊ី (ខេមបូឌា) ភីអិលស៊ី ជាផ្លូវការចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០។ លោក គី ផូ មានបទពិសោធការងារជាច្រើនជាង៣៤ឆ្នាំ នៅក្នុងឧស្សាហកម្មធនាគារ ដោយលោកបានកាន់មុខតំណែងជាថ្នាក់គ្រប់គ្រង និងដឹកនាំជាន់ខ្ពស់ រួមមានតំណែងជាប្រធានសេវាធនាគារធុរៈកិច្ច និងជាប្រធានសេវាធនាគារកិច្ចផ្នែកលក់រាយនិងអតិថិជន នៅក្នុងស្ថាប័នហិរញ្ញវត្ថុដែលល្បីៗ ដែលមានការទទួលស្គាល់នៅក្នុងប្រទេសម៉ាឡេស៊ី។

បទពិសោធន៍ការងារដ៏ច្រើនរបស់លោកនៅក្នុងវិស័យធនាគារ រួមមានសេវាធនាគារធុរៈកិច្ច និងអតិថិជន ហិរញ្ញវត្ថុពាណិជ្ជកម្ម ការគ្រប់គ្រងសាខា ការអភិវឌ្ឍន៍ផលិតផល ការគ្រប់គ្រងឥណទាន ការលក់ និងទីផ្សារ ក៏ដូចជាការគ្រប់គ្រងអាជីវកម្មក្នុងតំបន់។

មុនពេលទទួលបានការតែងតាំងនេះ លោក គី ផូ ត្រូវបានចាត់តាំងទៅបម្រើការជាប្រធានស្តីទី នៃធនាគារ RHB Bank នៅប្រទេសថៃ នៅក្នុង ខែតុលា ឆ្នាំ២០១៤ មុនពេលលោកត្រូវបានតែងតាំងជានាយកប្រតិបត្តិចាប់ពីខែឧសភា ឆ្នាំ២០១៥ ដល់ខែសីហា ឆ្នាំ២០២០។ លោក គឺជាអនុប្រធានប្រចាំប្រទេសសម្រាប់ធនាគារ អ អេច ប៊ី (កម្ពុជា) ភីអិលស៊ី ចាប់ពីខែមករា ឆ្នាំ២០១៣ រហូតដល់ពេលដែលលោកត្រូវបានចាត់តាំងទៅបម្រើការនៅធនាគារ RHB នៅប្រទេសថៃក្នុងខែតុលា ឆ្នាំ២០១៤។

លោកជាសមាជិកនៃគណៈកម្មាធិការសំខាន់ៗ ដូចជា គណៈកម្មាធិការគ្រប់គ្រង គណៈកម្មាធិការទ្រព្យសកម្ម និងបំណុល គណៈកម្មាធិការសវនកម្មគ្រប់គ្រង និង គណៈកម្មាធិការផ្តល់កម្ចីឥណទាន។ លោកបានបញ្ចប់អនុបណ្ឌិតផ្នែករដ្ឋបាលពាណិជ្ជកម្មពីប្រទេសកាណាដា និងជាម្ចាស់ពានរង្វាន់ប្រធានក្រុមប្រឹក្សាភិបាល ដោយបានបញ្ចប់ summa cum laude។ លោកក៏បានចូលរួមកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំជាន់ខ្ពស់របស់ INSEAD ក្នុងឆ្នាំ២០១៤ ផងដែរ។

ក្នុងនាមជានាយកគ្រប់គ្រងប្រចាំប្រទេស លោក វង្ស ក៏ជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ អ អេច ប៊ី ស៊ីយ្យូរីធី (ខេមបូឌា) ម.ក ផងដែរ។



## លោក ឡឹង មូន ហ្វី
ប្រធានសេវាធនាគារផ្នែកលក់រាយ



## លោក យ៉ុង ជីងសាន
ប្រធានផ្នែកគ្រប់គ្រងឥណទាន

លោក ឡឹង មូន ហ្វី ត្រូវបានតែងតាំងជាប្រធានសេវាធនាគារផ្នែកលក់រាយ នៅធនាគារ អ អេច ប៊ី (កម្ពុជា) ភីអិលស៊ី (RHBBCP ឬ ធនាគារ) ក្នុងឆ្នាំ២០២០។ គាត់បានចូលរួមជាមួយ RHB GROUP តាំងពីខែតុលា ឆ្នាំ២០២០។ គាត់មានបទពិសោធន៍ច្រើនជាង ១៨ ឆ្នាំក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ជាមួយធនាគារបរទេស និងធនាគារក្នុងស្រុកឈានមុខគេ នៅប្រទេសម៉ាឡេស៊ី។

គាត់មានបទពិសោធន៍ជាច្រើនលើផ្នែកយុទ្ធសាស្ត្រលក់រាយ ការគ្រប់គ្រងផ្នែកការគ្រប់គ្រងផលិតផល ការគ្រប់គ្រងការលក់ និងការគ្រប់គ្រងបណ្តាញ (បណ្តាញធនាគារឌីជីថល និងបណ្តាញចែកចាយការលក់តាមសាខា) ។

លោកបានបញ្ចប់ការសិក្សាពីវិទ្យាស្ថាន Chartered Institute of Marketing (CIM) ពីចក្រភពអង់គ្លេសក្នុងឆ្នាំ២០០២ ។ លោកក៏ជា Chartered Marketer នៃវិទ្យាស្ថាន CIM មួយរូបផងដែរ ហើយលោកបានចូលរួមក្នុងកម្មវិធិអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំជាន់ខ្ពស់របស់ INSEAD នៅក្នុងឆ្នាំ២០១៨។

លោក យ៉ុង បានបម្រើការនៅក្នុងធនាគារ អ អេច ប៊ី (ខេមបូឌា)ភីអិលស៊ី ចាប់តាំងខែវិច្ឆិកា ឆ្នាំ២០១០ហើយបច្ចុប្បន្ននេះ លោកមានមុខតំណែងជាប្រធានផ្នែកគ្រប់គ្រងឥណទាន។

លោកមានបទពិសោធសរុប ៣៤ ឆ្នាំ ក្នុងវិស័យធនាគារ និងវិស័យហិរញ្ញវត្ថុ ដោយអនុវត្តជាក់ស្តែងយ៉ាងទូលំទូលាយនៅក្នុងផ្នែកគ្រប់គ្រងឥណទាន។ ចំណេះដឹងក្នុងស្រុករបស់លោក យ៉ុង ដែលបានធ្វើការជាង ១១ ឆ្នាំ នៅប្រទេសកម្ពុជា ផ្តល់ទំនុកចិត្តបន្ថែម លើសមត្ថភាពរបស់លោក ក្នុងការបន្ថែមតម្លៃលើតួនាទីដែលបានអនុវត្ត។

លោកក៏មានបទពិសោធ និងជំនាញយ៉ាងទូលំទូលាយ ក្នុងការរៀបចំផែនការ និងយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងឥណទានរបស់ធនាគារ អអេចប៊ី (ខេមបូឌា) ម.ក ដោយធានាថា អភិបាលកិច្ច និងការអនុលោម នៃដំណើរការ SLA ត្រូវបានប្រកាន់ខ្ជាប់គ្រប់ពេលវេលា។

ចំណុចដែលលេចធ្លោមួយនៅក្នុងអាជីពធនាគាររបស់លោក គឺការចូលរួមក្នុងការងារត្រួតពិនិត្យសវនកម្មមូលនិធិរូបិយវត្ថុអន្តរជាតិ នៅប្រទេសកម្ពុជា ក្នុងឆ្នាំ២០១០។ លោកបានចូលរួមកម្មវិធីភាពជាអ្នកដឹកនាំជាន់ខ្ពស់ INSEAD នៅប្រទេសម៉ាឡេស៊ី និងទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងធុរកិច្ច។

# សមាសភាពរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ (ត)



**លោក ខារីន យាប យូ ហុង**
ប្រធានផ្នែកហិរញ្ញវត្ថុ រតនាគារ និងយុទ្ធសាស្ត្រ



**លោក លឹម ឈិន វ៉ាន**
ប្រធានផ្នែកបច្ចេកវិទ្យា

លោកខារីន ត្រូវបានតែងតាំងជាប្រធានហិរញ្ញវត្ថុ រតនាគារ និងយុទ្ធសាស្ត្រ នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២០។ លោក ខរីន ដឹកនាំមុខងារហិរញ្ញវត្ថុផ្សេងៗនៅក្នុងធនាគារ រួមមានការរៀបចំថវិកា ការរាយការណ៍ ការគ្រប់គ្រងមូលធន និងតារាងតុល្យការ ពន្ធដារ និងលទ្ធកម្ម។ ខារីន មានបទពិសោធន៍ចម្រុះជាង ២០ឆ្នាំលើផ្នែកប្រឹក្សាយោបល់ផ្នែកគណនេយ្យ និងការគ្រប់គ្រងសាជីវកម្ម ដែលរួមមានសេវានៅក្នុងក្រុមធនាគារកិច្ចក្រៅប្រទេស និងក្រុមហ៊ុនប្រឹក្សាយោបល់អន្តរជាតិ។

មុនពេលចូលរួមជាមួយធនាគារ អ អេច ប៊ី ( កម្ពុជា ) ភីអិលស៊ី លោកគឺជាប្រធានផ្នែកផែនការ និងវិភាគអាជីវកម្ម,សេវាធនាគារលក់រាយរបស់គ្រុប និងជាប្រធានស្តីទីសម្រាប់ផ្នែកយុទ្ធសាស្ត្រអតិថិជន, សេវាធនាគារលក់រាយរបស់គ្រុប។

លោកបានចូលបម្រើការងារនៅ RHB GROUP បន្ទាប់ពីធនាគារ OCBC នៅប្រទេសម៉ាឡេស៊ី ដែលនៅទីនោះលោកបានបម្រើការងារក្នុងតួនាទីជាច្រើន រួមមានប្រធានផ្នែកហិរញ្ញវត្ថុធនាគារលក់រាយ និងជាប្រធានផ្នែកហិរញ្ញវត្ថុនៃក្រុមហ៊ុន e⍰ Power Sdn Bhd ដែលជាបុត្រសម្ព័ន្ធរបស់ OCBC Group។ លោកបានចាប់ផ្តើមអាជីពការងារជាមួយErnst & Young នៅចក្រភពអង់គ្លេស។

លោក ខារីន បានបញ្ចប់ការសិក្សាដោយទទួលបានសញ្ញាប័ត្រកិត្តិយសថ្នាក់ទី១ ផ្នែកសេដ្ឋកិច្ចពីសាកលវិទ្យាល័យ Manchester នៃចក្រភពអង់គ្លេស។ គាត់ជាសមាជិកនៃវិទ្យាស្ថានគណនេយ្យករជំនាញ នៅប្រទេសអង់គ្លេស និងវែល ( ICAEW ) ។

លោក លឹម ឈិន វ៉ាន បច្ចុប្បន្នមានតួនាទីជាប្រធានផ្នែកបច្ចេកវិទ្យានៃធនាគារ អ អេច ប៊ី ( ខេមបូឌា ) ភីអិលស៊ី។

មុនពេលចូលរួមជាមួយធនាគារ អ អេច ប៊ី ( ខេមបូឌា ) ភីអិលស៊ី លោក ឈិនវ៉ាន បានបម្រើការងារជា ប្រធានផ្នែកបច្ចេកវិទ្យា នៅធនាគារវឌ្ឍនៈ និងធនាគារកាណាឌីយ៉ា ដែលជាធនាគារក្នុងស្រុកកាន់កាប់ដោយជនជាតិខ្មែរ។ លោកបានចាប់ផ្តើមអាជីពការងារក្នុងវិស័យធនាគារនៅឆ្នាំ២០០០ដែលលោកបានដឹកនាំជំនាញធនាគារអេឡិចត្រូនិក មួយក្រុមក្នុងការបើកដំណើរការធនាគារអ៊ីនធើណិតសាជីវកម្មដំបូងបង្អស់នៅប្រទេសម៉ាឡេស៊ី។

លោក ឈិនវ៉ាន តែងតែជម្រុញក្រុមការងាររបស់លោក ឱ្យធ្វើការលើបញ្ហាសំខាន់ៗជាច្រើនក្នុងផ្នែកធនាគារឌីជីថល ដើម្បីបង្កើន “ការគិតឱ្យបានទូលំទូលាយ” ដើម្បីជួយក្រុមរបស់លោកអោយបង្កើតនូវទស្សនវិស័យ យុទ្ធសាស្ត្រ ផលិតផល និងសេវាថ្មីៗ។

លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ពីសាកលវិទ្យាល័យខេមប៊ែល (Campbell University) និងបានធ្វើជាវាគ្មិននៅក្នុងសន្និសីទស្តីពីកិច្ចការធនាគារនៅក្នុងតំបន់។



## លោក សុខ ឡេង
ប្រធានផ្នែកកិច្ចការធនាគារអាជីវកម្ម



## លោក មហាម៉ាត់ រ៉ស់យ៉េត ប៊ីន អាប់ រ៉ាហ៍ម៉ាន់
ប្រធានផ្នែកបច្ចេកវិទ្យា

លោក សុខ ឡេងបានចូលរួមបម្រើការងារនៅធនាគារ អ អេច ប៊ី ក្នុងតំណែងជាប្រធានកិច្ចការធនាគារអាជីវកម្ម ចាប់តាំងពីខែកញ្ញា ឆ្នាំ២០១៨។ គាត់ទទួលខុសត្រូវក្នុងការរៀបចំ និងអនុវត្តការអភិវឌ្ឍអាជីវកម្ម យុទ្ធសាស្ត្រទីផ្សារ និងផែនការសកម្មភាព ដើម្បីឆ្លើយតបទៅនឹងគោលដៅ គោលបំណង និងគោលនយោបាយប្រតិបត្តិការអាជីវកម្មរបស់ធនាគារ។

មុនពេលចូលរួមជាមួយធនាគារ អ អេច ប៊ី លោកមានបទពិសោធន៍ក្នុងផ្នែកលក់ជួរមុខ ប្រធានផ្នែកទំនាក់ទំនង និងប្រធានផ្នែកអាជីវកម្មជាមួយធនាគារបរទេសចំនួនពីរ នៅក្នុងប្រទេសកម្ពុជា អស់រយៈពេលជាង ១៣ ឆ្នាំ។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែករដ្ឋបាលអាជីវកម្មនៅឆ្នាំ២០០៥ ក្នុងជំនាញគ្រប់គ្រងអាជីវកម្ម និងទទួលបានអនុបណ្ឌិតផ្នែកគ្រប់គ្រងធុរកិច្ច (MBA) លើជំនាញហិរញ្ញវត្ថុ និងធនាគារនៅសាកលវិទ្យាល័យបៀលប្រាយ ក្នុងឆ្នាំ២០១០។ លោកបានបញ្ចប់វគ្គវាយតម្លៃជំនាញឥណទាន (CSA) - Certified OMEGA ពី Global លើការអនុវត្តឥណទាន និងកម្ចីដែលល្អបំផុត ក្នុងឆ្នាំ២០១៤។

បច្ចុប្បន្ននេះ លោក រ៉ស់យ៉េត ប៊ីន អាប់ រ៉ាហ៍ម៉ាន់ បម្រើការជាប្រធានផ្នែកគ្រប់គ្រងហានិភ័យ នៅក្នុងធនាគារ អ អេច ប៊ី (ខេមបូឌា) ភីអិលស៊ីនិងក្រុមហ៊ុន អ អេ ប៊ី (ស៊ីយូរីធី) ភីអិលស៊ី។

លោក ធ្លាប់បម្រើការជាសមាជិកក្រុមប្រតិបត្តិការផ្នែកហានិភ័យ នៅធនាគារ RHB Bank Berhad (ការិយាល័យកណ្តាល) នៅទីក្រុងកូឡាឡាំពួ ប្រទេសម៉ាឡេស៊ី និងមានបទពិសោធផ្នែកធនាគារ ទាំងនៅធនាគារក្នុងស្រុក និងធនាគារបរទេស។

លោក ត្រូវបានទទួលស្គាល់ជាអ្នកជំនាញវិជ្ជាជីវៈផ្នែកធនាគារ វិទ្យាស្ថាន Chartered Banker អាស៊ី, ជាអ្នកជំនាញផ្នែក ACCA ព្រមទាំងបានបញ្ចប់បរិញ្ញាបត្រផ្នែកគណនេយ្យ នៅសាកលវិទ្យាល័យ Oxford Brookes ។

ចក្ខុវិស័យរបស់លោក លើការគ្រប់គ្រងហានិភ័យ គឺបង្កើនកម្រិត វប្បធម៌ហានិភ័យ និងការយល់ដឹង នៅក្នុងស្ថាប័ន ដោយធានាថា យើងរួមគ្នាបង្កើននូវវឌ្ឍនភាព ប្រកបដោយការទទួលខុសត្រូវ។

# សមាសភាពរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ (ត)



**លោក ឈឹម សារ៉េត**
ប្រធានផ្នែកប្រតិបត្តិការ



**លោក តាំង សៀវហ៊ុន**
ប្រធានផ្នែកវាយតម្លៃ និងពិនិត្យមើលឥណទាន

លោក សារ៉េត បានបម្រើការ នៅក្នុងធនាគារ អ អេច ប៊ី (ខេមបូឌា) ភីអិលស៊ី នៅខែកក្កដា ឆ្នាំ២០០៩ ជាប្រធានផ្នែកសវនកម្មផ្ទៃក្នុង។ បច្ចុប្បន្ននេះ លោក មានតួនាទីជាប្រធានផ្នែកប្រតិបត្តិការ ចាប់តាំងពីខែកក្កដា ឆ្នាំ២០១៩។ លោក មានបទពិសោធការងារក្នុងវិស័យធនាគារអស់រយៈពេលជាង១២ឆ្នាំ និង មានបទពិសោធជាសវនករឯករាជ្យ រយៈពេល៤ឆ្នាំ ជាមួយក្រុមហ៊ុន KPMG កម្ពុជា។

ជាក់ស្តែង លោកមានបទពិសោធ ជាច្រើន នៅក្នុងផ្នែកអនុវត្តតាម, សវនកម្ម, និងប្រតិបត្តិការ។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ និងគណនេយ្យ នៅវិទ្យាស្ថានជាតិគ្រប់គ្រង ក្នុងឆ្នាំ២០០៣ និងបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែក ពាណិជ្ជកម្មខាងហិរញ្ញវត្ថុ នៅវិទ្យាស្ថានអន្តរជាតិកម្ពុជា ក្នុងឆ្នាំ២០០៦។

លោកទទួលបាននូវសញ្ញាបត្រកម្រិតមូលដ្ឋានគ្រឹះនៃACCA ក្នុងឆ្នាំ២០០៩។ បច្ចុប្បន្ននេះ លោកកំពុងបន្តសិក្សាផ្នែកជំនាញសវនករផ្ទៃក្នុង (CIA) និងជា សមាជិកនៃវិទ្យាស្ថានសវនករផ្ទៃក្នុងកម្ពុជាផងដែរ។

លោក តាំង បានបម្រើការ នៅក្នុងធនាគារ អ អេច ប៊ី (ខេមបូឌា) ចាប់តាំង ពីខែមករា ឆ្នាំ២០១៤ និងបច្ចុប្បន្ននេះ លោក ជាប្រធានផ្នែកវាយតម្លៃ និង ពិនិត្យមើលឥណទាន។ លោកមានបទពិសោធក្នុងវិស័យធនាគាររយៈពេល ១៣ឆ្នាំ ជាពិសេសនៅក្នុងផ្នែកធនាគារពាណិជ្ជកម្ម និងផ្នែកលក់រាយ ដោយបាន បម្រើការ ទាំងនៅសាខា ទាំងនៅការិយាល័យកណ្តាល នៅក្នុងផ្នែកប្រតិបត្តិការ ឥណទានសាខា និងគ្រប់គ្រងឥណទាន។

លោក បានបញ្ចប់បរិញ្ញាបត្រផ្នែកវិទ្យាសាស្រ្ត នៅសាកលវិទ្យាល័យបច្ចេកវិទ្យា ម៉ាឡេស៊ី ក្នុងឆ្នាំ២០០៨។ លើសពីនេះទៀត លោកក៏បានទទួលសញ្ញាបត្រ វិជ្ជាជីវៈឥណទាន ពីវិទ្យាស្ថាន Chartered Bankers អាស៊ី (AICB) នៅ ក្នុងឆ្នាំ២០១២។



**លោកស្រី ណ័រហ្សារីណា ប៊ីនទី អាហ៍ម៉ាត់**
ប្រធានផ្នែកធនធានមនុស្ស និងការបណ្តុះបណ្តាល



**កញ្ញា អាន ម៉ារី**
ប្រធានផ្នែកច្បាប់ និងលេខាធិការ

បច្ចុប្បន្ននេះ លោកស្រី ហ្សាហ្សា បានបម្រើការជាប្រធានផ្នែកធនធានមនុស្ស នៃធនាគារ អ អេច ប៊ី ( ខេមបូឌា ) ភីអិលស៊ី។

លោកស្រី ធ្លាប់បម្រើការជាមន្ត្រីផ្នែកក្រុមធនធានមនុស្ស នៅក្នុងធនាគារ RHB Bank Berhad ( ការិយាល័យកណ្តាល ) នៅទីក្រុងកូឡាឡាំពួ ប្រទេសម៉ាឡេស៊ី ដោយមានតួនាទីមួយចំនួនដូចជា ផ្នែក Attract & Join, ផ្នែកដៃគូអាជីវកម្ម ផ្នែកធនធានមនុស្ស និងផ្នែកប្រធានបណ្តុះបណ្តាល Squad Lead, ផ្នែក Employee Experience & ផ្នែក Chapter Lead និងការប្រាស្រ័យទាក់ទង។ មុនពេលឈានជើងចូលប្រឡូកនៅក្នុងវិស័យធនាគារ លោកស្រី ជាវិស្វករជាន់ខ្ពស់ នៅក្នុងក្រុមហ៊ុន TOYOTA នៅម៉ាឡេស៊ី និងជាអ្នកប្រឹក្សាយោបល់ផ្នែកវិស្វកម្ម។ លោកស្រី ហ្សាហ្សា តែងប្រឈមនឹងប្រតិបត្តិ និងបទដ្ឋានធនធានមនុស្ស ដោយណែនាំបង្ហាញអំពីគំនិតផ្តួចផ្តើមច្នៃប្រឌិត “ការគិតឱ្យបានទូលំទូលាយ” ដើម្បីបង្កើនបទពិសោធផ្នែកនិយោជិត ដែលគ្របដណ្តប់លើការធ្វើដំណើររបស់និយោជិតដល់ចុងបញ្ចប់ ព្រមទាំងផលិតភាព។ លើសពីនេះទៀត លោកស្រី ក៏ជាអ្នកគាំទ្រ “ចំណុចកែលំអ (Kaizen)” ( ការលើកកម្ពស់បន្ត )។ លោកស្រី មានបរិញ្ញាបត្រផ្នែកវិស្វកម្មគ្រឿងយន្ត ពីសាកលវិទ្យាល័យឥស្លាមអន្តរជាតិ នៅម៉ាឡេស៊ី។

កញ្ញា ម៉ារី ត្រូវបានតែងតាំងជាប្រធានផ្នែកច្បាប់ និងលេខាធិការ ក្នុងឆ្នាំ២០១៨។ ទំហំការងាររបស់កញ្ញា គឺការផ្តល់ជូនយោបល់ផ្នែកច្បាប់និងដំណោះស្រាយ ដោយដើរតួនាទីជាលេខាធិការរបស់ក្រុមហ៊ុន លើការសម្របសម្រួលកិច្ចការសាជីវកម្មរបស់ធនាគារ។ កញ្ញា ត្រូវជានាលើការអនុលោមតាមរបស់ធនាគារ ទៅនឹងច្បាប់និងបទបញ្ញត្តិក្នុងស្រុក និងអភិបាលកិច្ចសាជីវកម្ម, គោលនយោបាយ, និងលក្ខខណ្ឌតម្រូវ ត្រូវបានអនុវត្តឲ្យបានសមស្រប។ មុនពេលចូលបម្រើការ ធនាគារ អ អេច ប៊ី ( ខេមបូឌា ) ភីអិលស៊ី, កញ្ញា ម៉ារី មានបទពិសោធន៍រយៈពេល ៦ឆ្នាំ នៅក្នុងគ្រឹះស្ថានហិរញ្ញវត្ថុនានា។ ជាក់ស្តែង កញ្ញាបានទទួលការអប់រំ និងបទពិសោធផ្នែកច្បាប់ជាច្រើន។ កញ្ញាជាប្រធានអនុវត្តផ្នែកច្បាប់ និងលេខាធិការសាជីវកម្ម ជាមួយវិស័យឯកជន និងជាជំនួយការផ្នែកច្បាប់ សហដើមបណ្តឹងរដ្ឋប្បវេណី នៅអង្គជំនុំជម្រះវិសាមញ្ញ នៅក្នុងតុលាការកម្ពុជា (ECCC)។

កញ្ញា ម៉ារី បានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកច្បាប់ជាកម្មវិធីជាភាសាអង់គ្លេស នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និង បានទទួលនូវកម្មវិធីកម្មសិក្សារដូវក្តៅ នៅសាកលវិទ្យាល័យសាកា នៅជប៉ុន ក្នុងឆ្នាំ២០១៦។ បច្ចុប្បន្ននេះ កញ្ញាកំពុងបន្តសិក្សាថ្នាក់អនុបណ្ឌិតផ្នែកច្បាប់អាជីវកម្មផ្ទៃក្នុងពី សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅកម្ពុជា។

# សមាសភាពរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ (ត)



**លោក តាំង លីឌី**
ប្រធានផ្នែកប្រតិបត្តិតាម



**លោក ម៉ែន ណារិទ្ធ**
ប្រធានសវនកម្មផ្ទៃក្នុង

លោក តាំង លីឌី បានចូលរួមជាមួយធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក ក្នុងខែមករា ឆ្នាំ២០១៩ ជាប្រធានផ្នែកប្រតិបត្តិតាម។ លោកមានបទពិសោធន៍ជាង ១៧ ឆ្នាំ ទាក់ទងនឹងវិស័យធនាគារ រួមមានប្រតិបត្តិការឥណទាន សវនកម្មផ្ទៃក្នុង ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាមនៅក្នុងធនាគារក្នុងស្រុក និងធនាគារបរទេស។ លោកមានបទពិសោធខាងធនាគារយ៉ាងទូលំទូលាយក្នុងវិស័យធនាគារ ជាពិសេសផ្នែកឧក្រិដ្ឋកម្មហិរញ្ញវត្ថុ និងការអនុលោមតាមនិយតកម្មហិរញ្ញវត្ថុ។

លោកទទួលបានបរិញ្ញាបត្រផ្នែកគណនេយ្យ ពីវិទ្យាស្ថានជាតិគ្រប់គ្រង ក្នុងឆ្នាំ២០០៣។ លោកបានបន្តការសិក្សានៅមជ្ឈមណ្ឌលបណ្តុះបណ្តាលការអនុលោមតាមអន្តរជាតិ (ICT) ក្នុងឆ្នាំ២០១៣ និងទទួលបានវិញ្ញាបនប័ត្រជាន់ខ្ពស់កម្រិតអន្តរជាតិ(ICA)ផ្នែក AML ហើយក្រោយមក បានបញ្ចប់ការសិក្សា និងទទួលបានសញ្ញាបត្រប្រតិបត្តិតាមនិយតកម្ម ពីវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ ក្នុងឆ្នាំ២០១៩។

លោក ណារិទ្ធ បានចូលបម្រើការងារជាមួយធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក នៅខែសីហា ឆ្នាំ២០១៩ ដែលមានតួនាទីជាប្រធានសវនកម្មផ្ទៃក្នុង។ លោកមានបទពិសោធន៍ការងារជាង១៥ឆ្នាំ ក្នុងវិស័យសវនកម្មជាមួយនិងធនាគារដែលឈានមុខគេមួយនៅក្នុងប្រទេសកម្ពុជា និងជាមួយក្រុមហ៊ុន KPMG Cambodia ដែលជាក្រុមហ៊ុនគណនេយ្យអន្តរជាតិធំមួយក្នុងចំណោមក្រុមហ៊ុនធំៗទាំងបួន។ លោកមានបទពិសោធន៍ជាច្រើន នៅក្នុងវិស័យសវនកម្មសម្រាប់ឧស្សាហកម្មផ្សេងៗ ជាពិសេសសម្រាប់គ្រឹះស្ថាន ធនាគារនិងហិរញ្ញវត្ថុ។

លោកបានបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយទទួលបានបរិញ្ញាបត្រវិទ្យាសាស្ត្រផ្នែកគណិតវិទ្យា នៅឆ្នាំ១៩៩៩ បន្ទាប់មកលោកបានបញ្ចប់ការសិក្សាជាមួយ ACCA កម្រិតមូលដ្ឋាន ក្នុងឆ្នាំ២០០៩។ លោកត្រូវបានទទួលស្គាល់នូវជំនាញឥណទានជាផ្លូវការ (Credit Skill Accreditation) ពី Omega Performance Corporation ក្នុងឆ្នាំ២០១៤។ លោកក៏ទទួលបានវិញ្ញាបនបត្រគណនេយ្យករផ្នែកគ្រប់គ្រង (Certified Management Accountants) ពី Institute of Certified Management Accountants ប្រទេសអូស្ត្រាលី និងវិញ្ញាបនបត្រផ្នែកវិជ្ជាជីវៈធនាគារ (Professional Banker) ពី Asian Institute of Chartered Bankers ក្នុងឆ្នាំ២០១៨។

# គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

## គណៈកម្មការគ្រប់គ្រង

លោក វង្ស គី ប៉ី
ប្រធាន

លោក ឡឹង មូន ហ្វី
សមាជិក

លោក យ៉ុង ជីងសាន
សមាជិក

លោក ខារីន យាប យូ ហុង
សមាជិក

លោក សុខ ឡេង
សមាជិក

លោក ឈឹម សារ៉េត
សមាជិក

លោក តាំង សៀវហ៊ុន
សមាជិក

លោកស្រី ណ័រហ្សារីណា ប៊ីនទី អាហ៍ម៉ាត់
សមាជិក

លោក លឹម ឈិន វ៉ាន
សមាជិក

## គណៈកម្មការទ្រព្យ និងបំណុល

លោក វង្ស គី ប៉ី
ប្រធាន

លោក ខារីន យាប យូ ហុង
សមាជិក

លោក ឡឹង មូន ហ្វី
សមាជិក

លោក សុខ ឡេង
សមាជិក

លោក មហាម៉ាត់ រ៉ស់យ៉េត
ប៊ីន អាប់ រ៉ាហ៍ម៉ាន់
សមាជិក

## គណៈកម្មការគ្រប់គ្រងសវនកម្ម

លោក វង្ស គី ប៉ី
ប្រធាន

លោក ឈឹម សារ៉េត
សមាជិក

លោក ម៉ែន ណារិទ្ធិ
សមាជិក

លោក តាំង លីឌី
សមាជិក

លោក មហាម៉ាត់ រ៉ស់យ៉េត
ប៊ីន អាប់ រ៉ាហ៍ម៉ាន់
សមាជិក

## គណៈកម្មការឥណទាន

លោក វង្ស គី ប៉ី
ប្រធាន

លោក យ៉ុង ជីងសាន
សមាជិក

លោក តាំង សៀវហ៊ុន
សមាជិក

លោក សុខ ឡេង
សមាជិក

លោក ខារីន យាប យូ ហុង
សមាជិក

## គណៈគ្រប់គ្រងជាន់ខ្ពស់នៃធានាគារ អ អេច ប៊ី

លោក វង្ស គី ប៉ី
នាយកប្រចាំប្រទេស/នាយកប្រតិបត្តិ

លោក ឡឹង មូន ហ្វី
ប្រធានសេវាធនាគារផ្នែកលក់រាយ

លោក យ៉ុង ជីងសាន
ប្រធានផ្នែកគ្រប់គ្រងឥណទាន

លោក ខារីន យាប យូ ហុង
ប្រធានផ្នែកហិរញ្ញវត្ថុ រតនាគារ និងយុទ្ធសាស្ត្រ

លោក លឹម ឈិន វ៉ាន
ប្រធានផ្នែកបច្ចេកវិទ្យា

លោក សុខ ឡេង
ប្រធានផ្នែកកិច្ចការធនាគារអាជីវកម្ម

លោក មហាម៉ាត់ រ៉ស់យ៉េត
ប៊ីន អាប់ រ៉ាហ៍ម៉ាន់
ប្រធានផ្នែកបច្ចេកវិទ្យា

លោក ឈឹម សារ៉េត
ប្រធានផ្នែកប្រតិបត្តិការ

លោក តាំង សៀវហ៊ុន
ប្រធានផ្នែកវាយតម្លៃ និងពិនិត្យមើលឥណទាន

លោកស្រី ណ័រហ្សារីណា ប៊ីនទី អាហ៍ម៉ាត់
ប្រធានផ្នែកធនធានមនុស្ស
និងការបណ្តុះបណ្តាល

កញ្ញា អាន ម៉ារី
ប្រធានផ្នែកច្បាប់ និងលេខាធិការ

លោក តាំង លីឌី
ប្រធានផ្នែកប្រតិបត្តិតាម

លោក ម៉ែន ណារិទ្ធ
ប្រធានសវនកម្មផ្ទៃក្នុង

# របាយការណ៍ក្រុមប្រឹក្សាភិបាល

**ក្រុមប្រឹក្សាភិបាលរបស់ ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក (ហៅកាត់ថា "ធនាគារ") សូមដាក់ជូនរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ធនាគារ សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។**

## អំពីធនាគារ

ធនាគារ អ អេច ប៊ី ( ខេមបូឌា ) ម.ក ( ហៅកាត់ថា "ធនាគារ" ) ត្រូវបានបង្កើតឡើងនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៨ និងបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ដោយមានវិញ្ញាបនបត្រចុះបញ្ជីលេខ ០០០០១៨១២ និងត្រូវបានធនាគារជាតិនៃកម្ពុជា ( ហៅកាត់ថា "ធនាគារកណ្តាល" ផ្តល់អាជ្ញាប័ណ្ណប្រកបអាជីវកម្មធនាគារ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៨។ នៅថ្ងៃទី៣១ ខែមករាឆ្នាំ២០២០ធនាគារបានប្តូរនាមករណ៍របស់ខ្លួនទៅជា ធនាគារ អ អេច ប៊ី ( ខេមបូឌា ) ម.ក។ ធនាគារគឺជាបុត្រសម្ព័ន្ធ ដែលត្រូវបានកាន់កាប់ទាំងស្រុងដោយធនាគារ RHB Bank Berhad ជាក្រុមហ៊ុន សាធារណៈទទួលខុសត្រូវមានកម្រិត បានចុះបញ្ជីពាណិជ្ជកម្មនៅប្រទេសម៉ាឡេស៊ី ហើយក្រុមហ៊ុនមេធំជាងគេគឺក្រុមហ៊ុន RHB Banking Group ដោយអនុលោមទៅតាមរចនាសម្ព័ន្ធសាជីវកម្មក្រុមហ៊ុនរួម ចូលជាធរមានចាប់ពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦។

ធនាគារ គឺជាធនាគារពាណិជ្ជ និងធ្វើប្រតិបត្តិការអាជីវកម្មក្រោមច្បាប់ស្តីពីសហគ្រាសពាណិជ្ជនៃកម្ពុជា និងក្រោមបទប្បញ្ញត្តិរបស់ធនាគារកណ្តាល។

## សកម្មភាពចម្បង

ធនាគារធ្វើសកម្មភាពចម្បងក្នុងការផ្តល់សេវាធនាគារពាណិជ្ជជាច្រើនប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលប្រតិបត្តិការ និងភាគលាភ

លទ្ធផលហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ត្រូវបានបង្ហាញក្នុងរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ នៅលើទំព័រទី ២៥៧។

ក្នុងអំឡុងឆ្នាំ មិនមានការប្រកាស ឬការបង់ភាគលាភទេ។

## ដើមទុន

ក្នុងអំឡុងឆ្នាំ ដើមទុនរបស់ធនាគារមិនមានការប្រែប្រួលទេ។

## ឥណទាន និងបុរេប្រទានអាក្រក់ និងឥណទានសង្ស័យ

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យពាក់ព័ន្ធទៅនឹងការជម្រះឥណទាន និងបុរេប្រទានអាក្រក់ចេញពីបញ្ជី និងការធ្វើសំវិធានធនសម្រាប់ការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃ ហើយបានយល់ស្របថារាល់ឥណទាន និងបុរេប្រទានអាក្រក់ទាំងអស់ដែលបានដឹង ត្រូវបានជម្រះចេញពីបញ្ជី និងបានកត់ត្រាសំវិធានធនសម្រាប់ការខាតបង់ឥណទាន និងបុរេប្រទានអាក្រក់ និងសង្ស័យ ពេញលេញ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកលើកម្រិតនៃការយល់ដឹង ក្រុមប្រឹក្សាភិបាលមិនដឹងពីកាលៈទេសៈណាមួយ ដែលនាំឱ្យចំនួនឥណទាន និងបុរេប្រទានអាក្រក់ដែលបានជម្រះចេញពីបញ្ជី ឬចំនួនសំវិធានធនសម្រាប់ការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមានតម្លៃមិនគ្រប់គ្រាន់ជាសារវន្តនោះទេ។

## ទ្រព្យសកម្ម

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋាន សមរម្យដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មទាំងឡាយ ដែលមិនទំនងជាមិនអាចបង្វិលមកវិញនៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា តាមតម្លៃក្នុងបញ្ជីគណនេយ្យរបស់ធនាគារ ត្រូវបានកត់ត្រាបន្ថយឱ្យស្មើនឹងតម្លៃដែលរំពឹងថានឹងអាចលក់បាននៅលើទីផ្សារជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកលើកម្រិតនៃការយល់ដឹង ក្រុមប្រឹក្សាភិបាលមិនបានដឹងពីកាលៈទេសៈណាមួយ ដែលបណ្តាលអោយតម្លៃនៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មិនត្រឹមត្រូវជាសារវន្តនោះទេ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមាន ៖

ក. បន្ទុកណាមួយលើទ្រព្យសកម្មរបស់ធនាគារ ដែលបានកើតឡើងដោយសារការដាក់បញ្ចាំសម្រាប់ការធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីដំណាច់ឆ្នាំហិរញ្ញវត្ថុមក ឬ

ខ. បំណុលយថាហេតុណាមួយរបស់ធនាគារ ដែលបានកើតឡើងចាប់តាំងពីដំណាច់ឆ្នាំហិរញ្ញវត្ថុមក ក្រៅពីបំណុលផ្សេងៗនៅក្នុងដំណើរការអាជីវកម្មធនាគារធម្មតានោះទេ។

ក្រៅពីអ្វីដែលបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ៣២ ( ឃ ) តាមយោបល់របស់ក្រុមប្រឹក្សាភិបាល មិនមានបំណុលយថាហេតុ ឬបំណុលផ្សេងៗរបស់ធនាគារដែលត្រូវបានទាមទារឱ្យសង ឬអាចនឹងត្រូវបានទាមទារឱ្យសង ក្នុងរយៈពេល១២ខែបន្ទាប់ពីដំណាច់ឆ្នាំហិរញ្ញវត្ថុ ដែលនឹង ឬអាចនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ធនាគារក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃដល់ពេលកំណត់សងនោះទេ។

## ការប្រែប្រួលកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងពីកាលៈទេសៈណាមួយដែលមិនបាន រែកញែកនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលអាចបណ្តាលឱ្យចំនួនទឹកប្រាក់ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានភាពមិនត្រឹមត្រូវនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារសម្រាប់ដំណាច់ឆ្នាំហិរញ្ញវត្ថុនេះ មិនមានរងនូវផលប៉ះពាល់ជាសារវន្តពីគណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។ តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះពេលរវាងដំណាច់ឆ្នាំហិរញ្ញវត្ថុ មកទល់នឹងកាលបរិច្ឆេទនៃ របាយការណ៍នេះ មិនមានគណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតី ដែលទំនងជាមានផលប៉ះពាល់ជាសារវន្តដល់លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ សម្រាប់ឆ្នាំ ហិរញ្ញវត្ថុដែលរបាយការណ៍នេះត្រូវបានធ្វើឡើងនោះទេ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារដែលនៅបម្រើការក្នុងអំឡុងឆ្នាំ រហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះមានរាយនាមដូចខាងក្រោម៖

**លោក Chin Yoong Kheong**
ប្រធានក្រុមប្រឹក្សាភិបាល (អភិបាលឯករាជ និងមិនប្រតិបត្តិ)

**En Abdul Aziz Peru Mohamed**
អភិបាល (អភិបាលឯករាជ និងមិនប្រតិបត្តិ)

**អ្នកស្រី ម៉ៅ សំវុទ្ធារី**
អភិបាល (អភិបាលឯករាជ និងមិនប្រតិបត្តិ)

**លោក Wong Kee Poh**
អភិបាល (អភិបាលមិនឯករាជ និងមិនប្រតិបត្តិ)
បានតែងតាំងនៅថ្ងៃ ទី២៨ ខែតុលា ឆ្នាំ២០២០

**Dato' Adissadikin bin Ali**
អភិបាល (អភិបាលមិនឯករាជ និងមិនប្រតិបត្តិ និងជាអ្នក តំណាងរបស់ភាគទុនិក)

**លោក Chulapong Yukate**
អភិបាល (អភិបាលឯករាជ និងមិនប្រតិបត្តិ) -
បានលាឈប់នៅថ្ងៃ ទី៣១ ខែមករា ឆ្នាំ២០២០

**លោក Thoo Kim Seng**
អភិបាល (អភិបាលឯករាជ និងមិនប្រតិបត្តិ) -
បានលាឈប់នៅថ្ងៃ ទី២៩ ខែមិថុនា ឆ្នាំ២០២០

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុ បង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និង លំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CIFRS")។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ តម្រូវឱ្យក្រុមប្រឹក្សាភិបាល៖

១. អនុវត្តគោលការណ៍គណនេយ្យសមស្រប ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនេះជាប្រចាំ។

២. អនុវត្តតាមតម្រូវការក្នុងការលាតត្រដាងព័ត៌មានរបស់ CIFRS ហើយប្រសិនបើមានការប្រាសចាកណាមួយក្នុងការបង្ហាញឱ្យមានភាពត្រឹមត្រូវ ការប្រាសចាកទាំងនោះត្រូវបានបង្ហាញ ពន្យល់ និងកំណត់ចំនួនទឹកប្រាក់ឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

៣. រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព។

៤. រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែមានករណីសន្មតសមរម្យថាធនាគារនឹងមិនអាចបន្តកិច្ចប្រតិបត្តិការអាជីវកម្មនៅពេលអនាគតដ៏ខ្លី និង

៥. គ្រប់គ្រងនិងដឹកនាំធនាគារឱ្យមានប្រសិទ្ធភាព តាមរយៈការសម្រេចចិត្តជាសារវន្តទាំងអស់ដែលជះឥទ្ធិពលដល់ប្រតិបត្តិការ និងលទ្ធផលរបស់ធនាគារ ហើយត្រូវធានាថាផលប៉ះពាល់ទាំងនោះត្រូវបានឆ្លុះបញ្ចាំងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ធនាគារបានអនុវត្តតាមតម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ ព្រមទាំងកំណត់សម្គាល់ទាំងឡាយបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់របស់ធនាគារសម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាម CIFRS ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

**ចុះហត្ថលេខាដោយយោងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។**




**លោក Chin Yoong Kheong**
**ប្រធានក្រុមប្រឹក្សាភិបាល**

*រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា*
*ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១*

# របាយការណ៍សវនកររងករាជ្យ



## ជូនភាគទុនិកធនាគារ អ អេច ប៊ី ( ខេមបូឌា ) ម.ក

### មតិយោបល់របស់យើងខ្ញុំ

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ អ អេច ប៊ី ( ខេមបូឌា ) ម.ក ( ហៅកាត់ថា “ធនាគារ” ) គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ( ហៅកាត់ថា “CIFRS” )។

### របាយការណ៍ដែលយើងខ្ញុំបានធ្វើសវនកម្ម

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ រួមមាន៖

- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០
- របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ សម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍បម្រែបម្រួលមូលធន សម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍លំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ និង
- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ រួមទាំងគោលការណ៍គណនេយ្យសំខាន់ៗ និងព័ត៌មានពន្យល់ផ្សេងៗទៀត។

### មូលដ្ឋាននៃមតិយោបល់របស់យើងខ្ញុំ

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាម ស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា ( ហៅកាត់ថា “ស្តង់ដារ សវនកម្ម” )។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលអនុលោមទៅតាមស្តង់ដារទាំងនោះ ត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌការទទួលខុសត្រូវរបស់សវនករក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងរបាយការណ៍សវនកររបស់យើងខ្ញុំ។

យើងខ្ញុំជឿជាក់ថាភ័ស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួល មានភាពគ្រប់គ្រាន់ និងសមហេតុផល ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

### ឯករាជ្យ

យើងខ្ញុំមានឯករាជ្យពីធនាគារ ដែលអនុលោមទៅតាមក្រមសីលធម៌អន្តរជាតិសម្រាប់គណនេយ្យករវិជ្ជាជីវៈ (រួមទាំងស្តង់ដារឯករាជ្យអន្តរជាតិ ) ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារក្រមសីលធម៌អន្តរជាតិ សម្រាប់គណនេយ្យករ ( ហៅកាត់ថា “ក្រមសីលធម៌អន្តរជាតិ” ) និងអនុលោមទៅតាមក្រមសីលធម៌របស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា ( ហៅកាត់ថា “ក្រមសីលធម៌ វគសក” ) ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ ចំពោះរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងប្រទេសកម្ពុជា។ យើងខ្ញុំបានបំពេញកាតព្វកិច្ចក្នុងការទទួលខុសត្រូវផ្នែកក្រមសីលធម៌ ផ្សេងៗទៀតដែលកំណត់ដោយក្រមសីលធម៌អន្តរជាតិ និងក្រមសីលធម៌ វគសក។

### ព័ត៌មានផ្សេងៗ

គណៈគ្រប់គ្រងទទួលខុសត្រូវចំពោះព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗដែលយើងខ្ញុំបានទទួលនាកាលបរិច្ឆេទនៃរបាយការណ៍សវនករនេះ រួមមាន របាយការណ៍ក្រុមប្រឹក្សាភិបាល និងព័ត៌មានហិរញ្ញវត្ថុបន្ថែម និងការលាតត្រដាងព័ត៌មានផ្សេងៗទៅតាមតម្រូវការរបស់ធនាគារជាតិនៃកម្ពុជា ប៉ុន្តែមិនរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងខ្ញុំទេ។

មតិយោបល់របស់យើងខ្ញុំចំពោះរបាយការណ៍ហិរញ្ញវត្ថុ ពុំបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗនោះទេ ហើយយើងខ្ញុំមិនធ្វើការធានាអះអាងចំពោះព័ត៌មានទាំងនោះទេ។

ទាក់ទងនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ យើងខ្ញុំទទួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗដែលបានរៀបរាប់ខាងលើ ដើម្បីពិចារណាថាតើព័ត៌មានផ្សេងៗទាំងនោះមានភាពផ្ទុយគ្នាជាសារវន្តពីរបាយការណ៍ហិរញ្ញវត្ថុ ឬផ្ទុយពីការយល់ដឹងរបស់យើងខ្ញុំផ្អែកលើលទ្ធផលនៃការធ្វើសវនកម្ម ឬមានការរាយការណ៍ពីកំហុសឆ្គងជាសារវន្តដែលបានកើតឡើងឬទេ។

ផ្អែកទៅលើការងារដែលយើងខ្ញុំបានបំពេញទៅលើព័ត៌មានផ្សេងៗ ដែលយើងខ្ញុំបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនករនេះ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តដែលកើតចេញពីព័ត៌មានផ្សេងៗទាំងនេះ យើងខ្ញុំត្រូវរាយការណ៍ពីអង្គហេតុនៃកំហុសឆ្គងទាំងនោះ។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍ចំពោះបញ្ហានេះទេ។

### ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកដែលទទួលបន្ទុកលើអភិបាលកិច្ចចំពោះរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងបង្ហាញរបាយការណ៍ទាំងនោះឱ្យបានត្រឹមត្រូវ ដោយអនុលោមទៅតាម CIFRS និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យចៀសផុតពីការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការវាយតម្លៃអំពីលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម ការលាតត្រដាងព៌ត័មានដែលពាក់ព័ន្ធ ក៏ដូចជាបញ្ហាផ្សេងៗដែលទាក់ទិនទៅនឹងនិរន្តរភាពអាជីវកម្មដោយប្រើមូលដ្ឋានគណនេយ្យសម្រាប់និរន្តរភាពអាជីវកម្ម លើកលែងតែគណៈគ្រប់គ្រងមានគម្រោងបិទអាជីវកម្មរបស់ធនាគារ ឬបញ្ឈប់ ប្រតិបត្តិការ ឬដោយមិនមានជម្រើសណាផ្សេងប្រកបដោយភាពប្រាកដប្រជាណាមួយ។

អ្នកដែលទទួលបន្ទុកលើអភិបាលកិច្ច ទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

## ការទទួលខុសត្រូវរបស់សវនករ ក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺស្វែងរកអំណះអំណាងដែលសមហេតុផល ថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលពុំមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ និងចេញរបាយការណ៍សវនករដែលមានមតិយោបល់របស់យើងខ្ញុំ។ អំណះអំណាងដែលសមហេតុផលគឺជាការអះអាងក្នុងកម្រិតខ្ពស់ ប៉ុន្តែវាមិនមែនជាការធានាថាសវនកម្មដែលបានធ្វើឡើង ដោយអនុលោមទៅតាមស្តង់ដារសវនកម្ម តែងតែរកឃើញជានិច្ចនូវការរាយការណ៍ខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការរាយការណ៍ខុសអាចកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គង ហើយវាត្រូវបានចាត់ទុកថាមានលក្ខណ:ជាសារវន្ត ប្រសិនបើការរាយការណ៍ខុសនីមួយៗ ឬការរាយការណ៍ខុសសរុប អាចត្រូវបានរំពឹងថាវាជះឥទ្ធិពលលើមូលដ្ឋាននៃការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់ អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ផ្នែកមួយនៃការធ្វើសវនកម្មដែលអនុលោមទៅតាមស្តង់ដារសវនកម្មតម្រូវឱ្យយើងខ្ញុំប្រើប្រាស់ការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈ និងរក្សាការសង្ស័យស្របតាមវិជ្ជាជីវៈ ក្នុងពេលបំពេញការងារសវនកម្មរបស់យើងខ្ញុំ។ យើងខ្ញុំ៖

- កំណត់ និងវាយតម្លៃហានិភ័យនៃភាពខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលអាចបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ ដោយតាក់តែងនីតិវិធីសវនកម្ម និងធ្វើសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងស្វែងរកភ័ស្តុតាងសវនកម្មគ្រប់គ្រាន់និងសមស្រប ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលបណ្តាលមកពីការរកមិនឃើញកំហុសឆ្គងជាសារវន្តពីការក្លែងបន្លំ វាមានទំហំធំជាងហានិភ័យដែលបណ្តាលមកពីកំហុសឆ្គងអចេតនា ដោយសារការក្លែងបន្លំរួមមាន ការសមគំនិត ការក្លែងបន្លំឯកសារ ការលុបបំបាត់ដោយចេតនា ការបង្ហាញខុស ឬការរំលងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងសវនកម្ម ដើម្បីតាក់តែងនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនបញ្ចេញមតិយោបល់របស់យើងខ្ញុំ ទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារទេ។

- វាយតម្លៃអំពីភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ ភាពសមហេតុផលនៃការប៉ាន់ស្មាន គណនេយ្យ និងការលាតត្រដាងពាក់ព័ន្ធដែលគណៈគ្រប់គ្រងបានធ្វើឡើង។

- សន្និដ្ឋានលើភាពសមស្រប នៃការប្រើប្រាស់មូលដ្ឋានគណនេយ្យនិរន្តរភាពអាជីវកម្មរបស់គណៈគ្រប់គ្រងអាស្រ័យទៅលើភ័ស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន ថាតើវាមានភាពមិនច្បាស់លាស់ជាសារវន្តដែលបានកើតឡើងកម្រិតណា ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានា ដែលអាចបណ្តាលឱ្យមានការសង្ស័យជាដុំកំភួនទៅលើលទ្ធភាពរបស់ធនាគារ ក្នុងការបន្តនិរន្តរភាពអាជីវកម្មរបស់ខ្លួនដែរឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាវាមានភាពមិនច្បាស់លាស់ជាសារវន្តបានកើតឡើង នោះយើងខ្ញុំត្រូវធ្វើការបង្ហាញនៅក្នុងរបាយការណ៍សវនករ ដើម្បីទាញចំណាប់អារម្មណ៍អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ចំពោះការលាតត្រដាងព័ត៌មាន នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងនោះនៅមិនទាន់គ្រប់គ្រាន់ទៀត យើងខ្ញុំត្រូវធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ សេចក្តីសន្និដ្ឋានសរុបរបស់យើងខ្ញុំ អាស្រ័យទៅលើភ័ស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបានរហូតដល់ថ្ងៃចុះហត្ថលេខាលើរបាយការណ៍សវនករនេះ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានាក្នុងពេលអនាគតអាចបណ្តាលឱ្យធនាគារឈប់បន្តនិរន្តរភាពអាជីវកម្ម។

- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងខ្លឹមសារក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមទាំងការលាតត្រដាងព័ត៌មានផ្សេងៗ និងកំណត់ថារបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ជាក់ស្តែង ដែលអាចធ្វើឱ្យមានការបង្ហាញត្រឹមត្រូវ។

យើងខ្ញុំបានរាយការណ៍ជូនអ្នកដែលទទួលបន្ទុកអភិបាលកិច្ចនូវបញ្ហាផ្សេងៗដូចជា ទំហំការងារតាមផែនការ និងពេលវេលាសវនកម្ម ព្រមទាំងបញ្ហាសវនកម្មសំខាន់ៗ រួមទាំងរាយការណ៍ពីភាពខ្វះខាតជាសារវន្តក្នុងការគ្រប់គ្រងផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ។

**ជ. ក្រុមហ៊ុន ប្រាយវ៉តធ័រហោវខូភើស៍ (ខេមបូឌា)**

**គុយ លីម**
Partner

*រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា*
*ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១*

# របាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងប្រចាំឆ្នាំ

## សេចក្តីផ្តើម

អនុលោមទៅតាមប្រការ២៥ នៃប្រកាស ធ-៧-០១០-១៧២ ប្រ.ក ស្តីពីការត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០និងលិខិតលេខ ធ-៧-០១៥-១៦១សជណ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ តម្រូវឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅប្រទេសកម្ពុជាធ្វើការរៀបចំនូវរបាយការណ៍ប្រចាំឆ្នាំស្តីពីរចនាសម្ព័ន្ធ និងប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

របាយការណ៍ខាងក្រោមត្រូវបានរៀបចំឡើងទៅតាមសេចក្តីណែនាំ ដែលបានចែងក្នុងប្រកាសស្តីពី ការត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ៖ សេចក្តីណែនាំសម្រាប់ការរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីរចនាសម្ព័ន្ធ និងប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

### ទំនួលខុសត្រូវរបស់គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលប្តេជ្ញាទទួលខុសត្រូវជារួមទៅលើការបង្កើតប្រព័ន្ធគ្រប់គ្រងហានិភ័យ និងត្រួតពិនិត្យផ្ទៃក្នុងដ៏ប្រសើរមួយនៅក្នុងធនាគារ។ ទំនួលខុសត្រូវរបស់គណៈកម្មាធិការក្រុមប្រឹក្សាភិបាលរួមមានការពិនិត្យឡើងវិញនូវភាពសមស្រប និងប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ក្នុងការការពារផលប្រយោជន៍របស់ម្ចាស់ភាគហ៊ុន និងទ្រព្យសកម្មរបស់ធនាគារ។ ខណៈពេលដែលការលុបបំបាត់ហានិភ័យទាំងស្រុងមិនអាចធ្វើទៅរួច ប្រព័ន្ធនេះត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងរីសអាប់ភែថាយ (Risk Appetite) របស់ធនាគារក្នុងកម្រិតអនុគ្រោះនៃហានិភ័យ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងដើម្បីគាំទ្រដល់ការសម្រេចគោលដៅអាជីវកម្មរបស់ធនាគារ។ ដូច្នេះប្រព័ន្ធនេះអាចត្រឹមតែផ្តល់អំណះអំណាងសមហេតុផលតែប៉ុណ្ណោះ ប៉ុន្តែពុំអាចធានាបានទាំងស្រុងចំពោះកំហុសឆ្គងជាសារវន្ត ការបាត់បង់ ឬការក្លែងបន្លំឡើយ។

នៅក្នុងការទទួលស្គាល់ថាមានការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដ៏ប្រសើរមួយមានភាពចាំបាច់ ក្រុមប្រឹក្សាភិបាលបានបង្កើតរចនាសម្ព័ន្ធអភិបាលកិច្ចដែលធានានូវការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពនៃហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង នៅគ្រប់កម្រិតក្នុងធនាគារ។ ដើម្បីសំរេចបាននូវគោលបំណងនេះ ក្រុមប្រឹក្សាភិបាលមានការជួយជ្រុមជ្រែងពីគណៈកម្មាធិកាគ្រប់គ្រងហានិភ័យ និងគណៈកម្មាធិការសវនកម្ម ដែលត្រូវបានផ្ទេរភារកិច្ចទទួលខុសត្រូវលើការត្រួតពិនិត្យបឋមលើប្រព័ន្ធគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ។ ក្រុមប្រឹក្សាភិបាលនៅតែទទួលខុសត្រូវចំពោះអភិបាលកិច្ចហានិភ័យ និងរាល់សកម្មភាពរបស់គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ទាក់ទងនឹងការអនុវត្តន៍ទំនួលខុសត្រូវលើការត្រួតពិនិត្យដែលបានធ្វើប្រតិភូកម្ម។ ក្រុមប្រឹក្សាភិបាលបានទទួលការធានាអះអាងពីនាយកប្រតិបត្តិ និងនាយកនាយកដ្ឋានហិរញ្ញវត្ថុ រតនាគារ និងយុទ្ធសាស្រ្តថា ប្រព័ន្ធគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុងមានដំណើរការគ្រប់គ្រាន់និងមានប្រសិទ្ធភាព។

### ទំនួលខុសត្រូវរបស់គណៈគ្រប់គ្រង

គណៈគ្រប់គ្រងមានទំនួលខុសត្រូវក្នុងការអនុវត្តជារួមនូវគោលនយោបាយ និងដំណើរការរបស់ធនាគារ ក្នុងការកំណត់វាយតម្លៃ វាស់វែង ត្រួតពិនិត្យ និងរាយការណ៍អំពីហានិភ័យព្រមទាំងប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង តាមរយៈចំណាត់វិធានការកែតម្រូវឲ្យបានសមស្រប និងទាន់ពេលវេលា។ មុខងាររបស់គណៈគ្រប់គ្រងរួមមាន៖

- កំណត់និងវាយតម្លៃលើហានិភ័យដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់ជានាគារ និងសមិទ្ធិផលនៃគោលដៅ និងយុទ្ធសាស្រ្តអាជីវកម្ម
- បង្កើតគោលនយោបាយ និងនីតិវិធីដែលពាក់ព័ន្ធ ដើម្បីគ្រប់គ្រងហានិភ័យ និងក្រមសីលធម៌របស់អាជីវកម្ម
- រចនា និងអនុវត្តក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងជាមួយនឹងការត្រួតពិនិត្យប្រសិទ្ធភាពរបស់វា
- អនុវត្តគោលនយោបាយដែលអនុម័តដោយក្រុមប្រឹក្សាភិបាល
- អនុវត្តចំណាត់វិធានការ ដើម្បីដោះស្រាយកង្វះខាតនៃការប្រតិបត្តិតាម ដូចដែលបានណែនាំដោយក្រុមប្រឹក្សាភិបាល
- រាយការណ៍ឲ្យបានទាន់ពេលវេលាទៅកាន់ក្រុមប្រឹក្សាភិបាល អំពីការផ្លាស់ប្តូរណាមួយនៃ ហានិភ័យ និងចំណាត់វិធានការកែតម្រូវដែលបានអនុវត្ត។

ដូច្នោះហើយគណៈគ្រប់គ្រងបានផ្តល់ការធានាដល់ក្រុមប្រឹក្សាភិបាលថា ប្រព័ន្ធគ្រប់គ្រងហានិភ័យ និងត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារកំពុងដំណើរយ៉ាងពេញលេញ និងមានប្រសិទ្ធិភាព ជាមួយនឹង ដំណើរការចាំបាច់ដែលត្រូវបានអនុវត្ត។

## រចនាសម្ព័ន្ធនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

### ◆ ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ

ធនាគារបានបង្កើតក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលសម្រាប់ កំណត់អត្តសញ្ញាណ វាស់វែង ត្រួតពិនិត្យ និងរាយការណ៍អំពីហានិភ័យសំខាន់ៗ ដែលប្រឈមដោយធនាគារ ក្នុងការសំរេចគោលដៅអាជីវកម្ម និងយុទ្ធសាស្ត្រ។ ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យរបស់ធនាគារ គឺដើម្បីជានាឲ្យមាននូវដំណើរការដ៏មានប្រសិទ្ធភាព និងស្ថិរភាព ក្នុងការកំណត់អត្តសញ្ញាណ វាយតម្លៃ និងគ្រប់គ្រងហានិភ័យរបស់ធនាគារទាំងមូល ដូចដែលបានបង្ហាញនៅក្នុងតារាងខាងក្រោមនេះ៖




#### អភិបាលកិច្ច និងការត្រួតពិនិត្យហានិភ័យ

ក្រុមប្រឹក្សាភិបាល តាមរយៈគណៈកម្មាធិការក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការគ្រប់គ្រងជាន់ខ្ពស់ដែលពាក់ព័ន្ធ ក៏ដូចជាមុខងារគ្រប់គ្រងហានិភ័យ បានបង្កើតនូវរីសអាប់ភែថាយ និងគោលការណ៍ហានិភ័យសម្រាប់ធនាគារ។ គណៈកម្មាធិការគ្រប់គ្រងហានិភ័យគឺជាគណៈកម្មាធិការក្រុមប្រឹក្សាភិបាលចំបង ដែលផ្តល់ការត្រួតពិនិត្យលើរាល់សកម្មភាពគ្រប់គ្រងហានិភ័យរបស់ធនាគារ ដើម្បីធានាថាដំណើរការគ្រប់គ្រងហានិភ័យរបស់ធនាគារ បានបង្កើតឡើងឲ្យប្រើប្រាស់ និងមានដំណើរការ។ គណៈកម្មាធិការគ្រប់គ្រងហានិភ័យជួយដល់ក្រុមប្រឹក្សាភិបាលក្នុងការពិនិត្យឡើងវិញនូវទស្សនៈវិស័យក្នុងការគ្រប់គ្រងហានិភ័យ ក្របខ័ណ្ឌ គោលនយោបាយ និងម៉ូដែលនានា ជារួមរបស់ធនាគារ។

#### រីសអាប់ភែថាយ

រីសអាប់ភែថាយ សម្រាប់ធនាគារត្រូវបានកំណត់ជាចំនួន និងប្រភេទនៃហានិភ័យដែលធនាគារមានឆន្ទៈក្នុងការទទួលយក ដោយស្របតាមគោលដៅយុទ្ធសាស្ត្រ និងអាជីវកម្មរបស់ខ្លួន។ ម្យ៉ាងវិញទៀត កម្រិតអនុគ្រោះនៃហានិភ័យ គឺជាកម្រិតដែលធនាគារអាចទទួលយកបាននៅពេលមានបំរែបំរួល ដែលទាក់ទងទៅនឹងការសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រ និងអាជីវកម្មរបស់ធនាគារ ហើយវាត្រូវបានវាស់ជាឯកតាដូចគ្នាទៅនឹងគោលដៅដែលជាប់ទាក់ទង។ រីសអាប់ភែថាយបានប្រែទៅជារង្វាស់ប្រតិបត្តិការ ហើយវាអាចត្រូវបានកំណត់នៅកម្រិតណាមួយនៃធនាគារ។

# របាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងប្រចាំឆ្នាំ (ត)

## រចនាសម្ព័ន្ធនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង (ត)

វិសអាប់តែថាយ និងកម្រិតអនុគ្រោះនៃហានិភ័យដែលបានបង្កើតឡើង ហើយធ្វើការពិនិត្យឡើងវិញជាទៀងទាត់ ដោយគណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាល ដើម្បីឲ្យស្របតាមយុទ្ធសាស្ត្រ និងបរិយាកាសប្រតិបត្តិការរបស់ធនាគារ។ ការពិនិត្យឡើងវិញនេះរួមមានការកំណត់អត្តសញ្ញាណ និងកំណត់រង្វាស់វិសអាប់តែថាយថ្មីសម្រាប់ធនាគារ ឬការដកចេញនូវរង្វាស់វិសអាប់តែថាយ ដែលលែងមានសុពលភាព ក៏ដូចជាការធ្វើបច្ចុប្បន្នភាពលើកម្រិតកំណត់វិសអាប់តែថាយឲ្យស្របទៅនឹងយុទ្ធសាស្ត្រអាជីវកម្ម និងឥរិយាបថហានិភ័យរបស់ធនាគារ។

ហានិភ័យអាជីវកម្ម និងប្រតិបត្តិការសំខាន់ៗដែលត្រូវយកមកពិចារណា នៅពេលធ្វើការពិនិត្យឡើងវិញនូវវិសអាប់តែថាយ រួមមានហានិភ័យអនុលោមតាមបទប្បញ្ញត្តិ ហានិភ័យឥណទាន ហានិភ័យទីផ្សារនិងសន្ទនីយភាព ហានិភ័យប្រតិបត្តិការ និងហានិភ័យបច្ចេកវិទ្យា និងអ៊ីនធឺណិត។

### ដំណើរការគ្រប់គ្រងហានិភ័យ

ដំណើរការគ្រប់គ្រងហានិភ័យនៅក្នុងធនាគារ ដើម្បីកំណត់អត្តសញ្ញាណ វាយតម្លៃ វាស់ស្ទង់ តាមដាន និងគ្រប់គ្រងហានិភ័យ ដូច្នេះទំហំហានិភ័យត្រូវតែគ្រប់គ្រងឲ្យគ្រប់ជ្រុងជ្រោយ ហើយប្រាក់ចំណេញរំពឹងទុកអាចទូទាត់បានជៀបនឹងហានិភ័យ។

- ការកំណត់អត្តសញ្ញាណ៖ ការកំណត់អត្តសញ្ញាណ និងការវិភាគហានិភ័យដែលមានស្រាប់ និងហានិភ័យសក្តានុពល គឺជាដំណើរដែលកំពុងបន្ត ដើម្បីជួយសម្រួល និងធានាថាហានិភ័យអាចគ្រប់គ្រងបានស្របតាមវិសអាប់តែថាយរបស់ធនាគារ។
- ការវាស់ស្ទង់៖ ហានិភ័យត្រូវបានវាស់វែង វាយតម្លៃ និងរួមបញ្ចូលគ្នា ដោយប្រើប្រាស់វិធីសាស្ត្រយ៉ាងល្អិតល្អន់ដើម្បីវាស់វែងហានិភ័យតាមបែបគុណភាព និងបរិមាណ ហើយដំណើរការនេះក៏ដើរតួជាឧបករណ៍សំខាន់មួយផងដែរ ព្រោះវាផ្តល់នូវការវាយតម្លៃពីភាពគ្រប់គ្រាន់នៃដើមទុន និងសាធនភាព។
- ការគ្រប់គ្រង និងតាមដាន៖ ការគ្រប់គ្រង ការដាស់តឿន និងការកម្រិតត្រូវបានប្រើប្រាស់ដើម្បីគ្រប់គ្រងផលប៉ះពាល់នៃហានិភ័យ និងដើម្បីជួយសម្រួលដល់ការកំណត់អត្តសញ្ញាណ បញ្ហាដែលមានសក្តានុពលឱ្យបានទាន់ពេលវេលា។
- ការវិភាគ និងរាយការណ៍៖ ការវិភាគ និងរបាយការណ៍ ដែលបានរៀបចំនៅកម្រិតអង្គភាព ក៏ដូចជាកម្រិតអាជីវកម្ម ត្រូវបានរាយការណ៍ជាប្រចាំទៅដល់គណៈគ្រប់គ្រង គណៈកម្មាធិការ និងក្រុមប្រឹក្សាភិបាលដែលពាក់ព័ន្ធ ដើម្បីធានាថាហានិភ័យដែលបានកំណត់រួច នៅតែស្ថិតក្នុងអាប់តែថាយដែលបានបង្កើតឡើង និងដើម្បីជួយគាំទ្រដល់ដំណើរការក្នុងការសម្រេចចិត្តប្រកបដោយព័ត៌មានគ្រប់គ្រាន់។

### ឯកសារ និងហេដ្ឋារចនាសម្ព័ន្ធហានិភ័យ

ធនាគារទទួលស្គាល់ថា ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃប្រព័ន្ធ និងដំណើរការគ្រប់គ្រងហានិភ័យ ត្រូវតែមានការគាំទ្រដោយឯកសារ និងហេដ្ឋារចនាសម្ព័ន្ធហានិភ័យដ៏រឹងមាំមួយ។ ដើម្បីឆ្លើយតបទៅនឹងចំនុចទាំងនេះ ធនាគារបានបង្កើតក្របខ័ណ្ឌ គោលនយោបាយ និងឯកសារការត្រួតពិនិត្យដែលពាក់ព័ន្ធដទៃទៀត ដើម្បីធានាឲ្យបានថាការអនុវត្ត និងដំណើរការដែលបាន កំណត់ច្បាស់លាស់ត្រូវបានយកមកប្រើប្រាស់យ៉ាងជាប់លាប់នៅក្នុងធនាគារទាំងមូល។

ទាក់ទងទៅនឹងហេដ្ឋារចនាសម្ព័ន្ធហានិភ័យ ធនាគារបានរៀបចំ ធនធាន និងបុគ្គលិកដែលមានទេពកោសល្យរបស់ខ្លួន ទៅដល់មុខងារគ្រប់គ្រងហានិភ័យ ហើយបានវិនិយោគលើបច្ចេកវិទ្យា រួមមានទាំងការគ្រប់គ្រងទិន្នន័យ ដើម្បីគាំទ្រដល់សកម្មភាពគ្រប់គ្រងហានិភ័យរបស់ធនាគារ។

### វប្បធម៌ហានិភ័យ

ការគ្រប់គ្រងហានិភ័យគឺមានសារៈសំខាន់ចំពោះគ្រប់ផ្នែកទាំងអស់នៃអាជីវកម្ម និងប្រតិបត្តិការរបស់ធនាគារ ហើយវាជាទំនួលខុសត្រូវរបស់និយោជិកទាំងអស់របស់ធនាគារទាំងមូល។ ស្របតាមតម្រូវការបទប្បញ្ញត្តិ និងការអនុវត្តដែលល្អបំផុតក្នុងវិស័យធនាគារ ធនាគារបានអនុវត្តគោលការណ៍ដែលថា “ហានិភ័យ និងការប្រតិបត្តិតាម គឺជាទំនួលខុសត្រូវរបស់បុគ្គលិកគ្រប់រូប” ហេតុដូច្នេះការគ្រប់គ្រងហានិភ័យគឺជាទំនួលខុសត្រូវស្នូលមួយរបស់ផ្នែកអាជីវកម្ម និងផ្នែកប្រតិបត្តិការរៀងៗខ្លួន។ វាត្រូវបានបញ្ជាក់ និងកត់ត្រានៅក្នុងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យរបស់ធនាគារ។

ធនាគារបានអនុវត្តកម្មវិធីមន្ត្រីហានិភ័យអាជីវកម្មនិងប្រតិបត្តិតាម ដែលមានគោលបំណង ដើម្បីបណ្តុះនូវការគ្រប់គ្រងហានិភ័យនិងការប្រតិបត្តិតាមជាមុន និងដើម្បីបង្កើតវប្បធម៌ហានិភ័យដ៏រឹងមាំមួយ។

### ការវាយតម្លៃហានិភ័យ

ធនាគារមានដំណើរការមួយដែលបានបង្កើតឡើង និងមានភាពល្អិតល្អន់ សម្រាប់ធ្វើការកំណត់អត្តសញ្ញាណហានិភ័យ នៅគ្រប់ដំណាក់កាលនៃសកម្មភាពដែលអាចបណ្តាលឱ្យមានហានិភ័យ ដូចជាលើប្រតិបត្តិការ ផលិតផល និងនៅលើកម្រិតអង្គភាពផងដែរ។ ហានិភ័យនានាក៏ត្រូវបានកំណត់តាមរយៈរបាយការណ៍ព្រឹត្តិការណ៍ការបាត់បង់នៃហានិភ័យប្រតិបត្តិការ និងការវិភាគតាមសំពាធហានិភ័យ។ ផ្នែកមួយនៃការវាយតម្លៃហានិភ័យជាសារវន្តទៅតាមកាលកំណត់ ធនាគារត្រូវពិនិត្យឡើងវិញអំពីប្រភេទ និងជាតុផ្សំនៃហានិភ័យជាសារវន្តទាំងនោះ ហើយកំណត់បរិមាណ នៃសារៈសំខាន់ ហើយធ្វើការកែលម្អដំណើរការរបស់ខ្លួន ដោយយកមតិដែលទទួលបាន រួមទាំងការពិនិត្យដោយឯករាជ្យមកពិចារណា។

## រចនាសម្ព័ន្ធនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង (ត)

ការវាយតម្លៃហានិភ័យជាសារវន្ត ត្រូវវាស់ពីទំហំនៃប្រូបាប៊ីលីតេនៃការកើតឡើង និងភាពធ្ងន់ធ្ងរនៃផលប៉ះពាល់។ លើសពីនេះទៀតការវាយតម្លៃហានិភ័យក៏ត្រូវពិចារណា កត្តាដទៃទៀតដូចជាប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងផលប៉ះពាល់ចំពោះសូចនាករហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុឧទាហរណ៍ដូចជាហានិភ័យកេរ្តិ៍ឈ្មោះ។ ទាំងអស់នេះត្រូវបានបកប្រែទៅក្នុងម៉ាទ្រីសផែនទីកំដៅ (heat map matrix) ដើម្បីដាក់បញ្ចូលភាពជាសារវន្តនៃហានិភ័យដូចដែលបានបង្ហាញក្នុងតារាងខាងក្រោម៖




ការប្រើប្រាស់ម៉ាទ្រីសខាងលើ គឺជាយន្តការសាមញ្ញមួយដើម្បីបង្កើននូវការមើលឃើញនូវហានិភ័យ និងជួយក្នុងការសម្រេចចិត្ត។ ធនាគារចាត់ទុកថាហានិភ័យក្នុងតំបន់ក្រហមគឺជា "ហានិភ័យជាសារវន្ត" ដែលអាចមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ហិរញ្ញវត្ថុ និងឬមិនមែនហិរញ្ញវត្ថុរបស់ធនាគារ។ កិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងត្រូវបានអនុវត្ត ដើម្បីគ្រប់គ្រងនិងកាត់បន្ថយព្រឹត្តិការណ៍ហានិភ័យទាំងនេះ។

### ការវាយតម្លៃខ្លួនឯងលើហានិភ័យ និងការត្រួតពិនិត្យ

ដើម្បីគាំទ្រ និងលើកកម្ពស់គណនេយ្យភាព និងភាពជាម្ចាស់នៃការគ្រប់គ្រងហានិភ័យ គោលការណ៍ណែនាំនៃការវាយតម្លៃខ្លួនឯងលើហានិភ័យ និងការត្រួតពិនិត្យមួយ ត្រូវបានយកមកអនុវត្តនៅក្នុងផ្នែកអាជីវកម្ម និងផ្នែកប្រតិបត្តិការផ្សេងៗនៅក្នុងធនាគារ ហើយវាជាផ្នែកមួយនៃដំណើរការគ្រប់គ្រងហានិភ័យ។ ផ្នែកអាជីវកម្ម និងផ្នែកប្រតិបត្តិការទាំងនេះ តម្រូវឲ្យកំណត់និងចងក្រងឯកសារវិធានការត្រួតពិនិត្យ និងដំណើរការ សម្រាប់ការគ្រប់គ្រងហានិភ័យដែលកើតមានឡើងពីសកម្មភាព និងប្រតិបត្តិការអាជីវកម្មរបស់ពួកគេ ក៏ដូចជាវាយតម្លៃពីប្រសិទ្ធភាពរបស់វាដើម្បីធានាថាហានិភ័យដែលបានកំណត់នោះ ត្រូវបានគ្រប់គ្រងបានល្អប្រសើរ និងកាត់បន្ថយផងដែរ។ នៅពេលបញ្ចប់ការវាយតម្លៃលើហានិភ័យ និងការត្រួតពិនិត្យ គ្រប់ផ្នែកអាជីវកម្មនិងផ្នែកប្រតិបត្តិការ នៅក្នុងធនាគារតម្រូវឲ្យបញ្ជូនលទ្ធផលរៀងៗខ្លួនទៅនាយកដ្ឋានគ្រប់គ្រងហានិភ័យ ដើម្បីពិនិត្យឡើងវិញ ។

## ◆ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រង និងកាត់បន្ថយហានិភ័យដែលរារាំងធនាគារក្នុងការសម្រេចបាននូវគោលដៅ និងគោលបំណងរបស់ខ្លួន។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគាររួមមាន គោលនយោបាយ នីតិវិធី ដំណើរការ រចនាសម្ព័ន្ធគ្រប់គ្រង និងផ្នែកត្រួតពិនិត្យផ្សេងៗទៀតដែលត្រូវបានអនុវត្ត ដើម្បីធានាឲ្យបាននូវការសម្រេចគោលបំណងរបស់ធនាគារប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលប្រតិបត្តិការ រួមទាំងរបាយការណ៍ហិរញ្ញវត្ថុដែលអាចជឿទុកចិត្តបាន និងអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយផ្ទៃក្នុងផ្សេងៗទៀត។

ដំណើរការសំខាន់ៗដែលបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាល ដើម្បីផ្តល់នូវប្រសិទ្ធភាពនៃការត្រួតពិនិត្យ និងអភិបាលកិច្ចប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរួមមាន៖

### *បរិស្ថានត្រួតពិនិត្យ និងសកម្មភាពត្រួតពិនិត្យ*

#### រចនាសម្ព័ន្ធគ្រប់គ្រង

ធនាគារមានរចនាសម្ព័ន្ធគ្រប់គ្រងជាផ្លូវការ ប្រកបដោយគណនេយ្យភាព និងទំនួលខុសត្រូវយ៉ាងជាក់លាក់នូវកម្រិតសិទ្ធិអំណាច និងបណ្តាញនៃការរាយការណ៍។ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ធនាគារផ្តល់នូវក្របខ័ណ្ឌជាមូលដ្ឋានក្នុងការធានាថាអាជីវកម្ម និងប្រតិបត្តិការ ដំណើរការបានរលូន ក៏ដូចជាចង្អុលបង្ហាញពីវិសាលភាពនៃការត្រួតពិនិត្យ ដើម្បីធានាឲ្យបាននូវការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពលើប្រតិបត្តិការ និងគណនេយ្យភាពអាជីវកម្មប្រចាំថ្ងៃ។

#### គោលនយោបាយ និងនីតិវិធី

គោលនយោបាយ នីតិវិធី និងដំណើរការ គ្រប់គ្រងលើអាជីវកម្ម និងប្រតិបត្តិការរបស់ធនាគារ ត្រូវបានចងក្រងទុកជាឯកសារ និងផ្សព្វផ្សាយក្នុងធនាគារទាំងមូល ហើយរាល់បុគ្គលិកទាំងអស់ក៏អាចរកមើលបានតាមរយៈឯកសារដែលបានរក្សាទុកនៅក្នុងប្រព័ន្ធកុំព្យូទ័ររបស់ធនាគារ ដែលមានភាពងាយស្រួលក្នុងការយោង និងអនុលោមតាម។ គោលនយោបាយ នីតិវិធី និងដំណើរការទាំងនេះត្រូវបានពិនិត្យ និងធ្វើបច្ចុប្បន្នភាពឡើងវិញដោយផ្នែកអាជីវកម្ម និងប្រតិបត្តិការ តាមរយៈដំណើរការពិនិត្យឡើងវិញ និងអនុម័តជាប្រព័ន្ធ ដើម្បីបត់បែនទៅតាមការផ្លាស់ប្តូរនៃច្បាប់ និងបទប្បញ្ញត្តិនានា ក៏ដូចជាការផ្លាស់ប្តូរនៃបរិបទអាជីវកម្ម និងប្រតិបត្តិការ។

#### ដែនកំណត់សិទ្ធិអំណាច

ក្រុមប្រឹក្សាភិបាលបានអនុម័តលើម៉ាទ្រីសសិទ្ធិអំណាចអនុម័តក្នុងធនាគារ ដែលកំណត់សិទ្ធិអំណាចអនុម័តជាមួយនឹងដែនកំណត់សិទ្ធិអំណាច ទៅតាមលំដាប់ជាន់ថ្នាក់នៃគណៈគ្រប់គ្រងនៅក្នុងធនាគារ។ ដូច្នោះហើយគណៈគ្រប់គ្រងត្រូវបានផ្តល់សិទ្ធិអំណាចឲ្យអនុវត្តទំនួលខុសត្រូវរបស់ខ្លួន និងទទួលខុសត្រូវចំពោះការសម្រេចចិត្ត និងសកម្មភាពរបស់ពួកគេ។ ម៉ាទ្រីសសិទ្ធិអំណាចអនុម័តក្នុងធនាគារត្រូវបានពិនិត្យឡើងវិញជាប្រចាំ និងធ្វើបច្ចុប្បន្នភាពឲ្យស្របទៅតាមការផ្លាស់ប្តូរនៃរចនាសម្ព័ន្ធអង្គភាព បរិយាកាសអាជីវកម្ម ឬតម្រូវការប្រតិបត្តិការ។

# របាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងប្រចាំឆ្នាំ (ត)

## រចនាសម្ព័ន្ធនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង (ត)

### សន្តិសុខព័ត៌មានវិទ្យា

ធនាគារចាត់ទុកសន្តិសុខព័ត៌មានវិទ្យាជាអាទិភាពខ្ពស់មួយដើម្បីជានាការសម្ងាត់ សុចរិតភាព និង ភាពអាចរកបាននៃទ្រព្យសកម្មព័ត៌មាន និងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យារបស់ធនាគារ។

សន្តិសុខព័ត៌មានវិទ្យានៅក្នុងធនាគារ សម្រេចបានតាមរយៈការអនុវត្តនូវវិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យដែលគ្របដណ្តប់លើមនុស្ស ដំណើរការ និង បច្ចេកវិទ្យា។ គោលនយោបាយ គោលការណ៍ណែនាំនិងនីតិវិធីសន្តិសុខព័ត៌មានវិទ្យា ត្រូវបានបង្កើតឡើង និងគាំទ្រដោយរចនាសម្ព័ន្ធចាត់ចែងយ៉ាងត្រឹមត្រូវ ជាមួយនឹងធនធានដែលមានសមត្ថភាព។ ការការពារតាមយុទ្ធសាស្ត្រស៊ីជម្រៅត្រូវបានប្រើប្រាស់នៅពេលដែលប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាជាច្រើនស្រទាប់ ត្រូវបានអនុវត្តនៅក្នុងហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធព័ត៌មានវិទ្យាទាំងមូល។ ប៉ុន្តែអ្វីដែលមានសារៈសំខាន់ដូចគ្នាទៅនឹងការត្រួតពិនិត្យលើដំណើរការ និង បច្ចេកវិទ្យា គឺជាកម្មវិធីជាបន្តបន្ទាប់ដើម្បីបង្កើនកម្រិតនៃការយល់ដឹងអំពីសុវត្ថិភាពរបស់បុគ្គលិកគ្រប់ជាន់ថ្នាក់។

### ដំណើរការរៀបចំគម្រោងថវិកា

ដំណើរការរៀបចំគម្រោងថវិកាដ៏រឹងមាំមួយត្រូវបានធ្វើឡើង ដោយតម្រូវឲ្យផ្នែកប្រតិបត្តិការសំខាន់ៗនៅក្នុងធនាគារធ្វើការរៀបចំគម្រោងថវិកា និងផែនការអាជីវកម្មប្រចាំឆ្នាំដើម្បីស្នើសុំការអនុម័តពីក្រុមប្រឹក្សាភិបាល។ គម្រោងថវិកា និងផែនការអាជីវកម្មរបស់ធនាគាររួមទាំងគំនិតផ្តួចផ្តើមជាយុទ្ធសាស្ត្រដែលផ្អែកទៅតាមវិសអាប់តែថាយដែលបានបង្កើតឡើង ត្រូវឆ្លងកាត់កិច្ចប្រជុំរែកញែកជាមួយគណៈគ្រប់គ្រង មុននឹងដាក់ចូលទៅពិភាក្សានៅក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាល ដែលជាពេលដែលគម្រោងថវិការបស់ធនាគារត្រូវបានបង្ហាញ។

### ការគ្រប់គ្រងធនធានមនុស្ស

ធនាគារបានទទួលស្គាល់ថាធម្មនុញ្ញមួយនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងគឺធនធានមនុស្ស ហើយប្រព័ន្ធគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង គឺពឹងផ្អែកលើការទទួលខុសត្រូវ សុចរិតភាព និងការវិនិច្ឆ័យត្រឹមត្រូវរបស់បុគ្គលិកក្នុងការអនុវត្តការងារ។ ដូច្នេះហើយធនាគារមានគោនយោបាយនិងនីតិវិធីសម្រាប់គ្រប់គ្រងលើការជ្រើសរើស ការតែងតាំង ការគ្រប់គ្រងលទ្ធផលការងារ និងការផ្តល់រង្វាន់ ក៏ដូចជាគោលនយោបាយ និងនីតិវិធីសម្រាប់គ្រប់គ្រងវិន័យ ការបញ្ឈប់ការងារ និងការបណ្តេញចេញ។

ដើម្បីឲ្យមានការលូតលាស់ប្រកបដោយនិរន្តរភាព ធនាគារសង្កត់ធ្ងន់ទៅលើការអភិវឌ្ឍន៍ធនធានមនុស្ស ការគ្រប់គ្រងទេពកោសល្យ និងការរៀបចំផែនការបន្តវេន។ ដើម្បីបង្កើនសមត្ថភាពបុគ្គលិកការបង្ហាត់បង្រៀនលើផ្នែកបច្ចេកទេសជាលក្ខណៈប្រព័ន្ធ ព្រមទាំងសិក្ខាសាលាស្តីពីភាពជាអ្នកដឹកនាំនិងគ្រប់គ្រង ត្រូវបានផ្តល់ទៅឲ្យពួកគេទៅតាមសេចក្តីត្រូវការរបស់ពួកគេដែលបានកំណត់រួចនៅអំឡុងពេលវាយតម្លៃលទ្ធផលការងារប្រចាំឆ្នាំ។ ចំពោះការគ្រប់គ្រងអ្នកមានទេព្យកោសល្យ គំនិតផ្តួចផ្តើមដូចជាកម្មវិធីអភិវឌ្ឍភាពជាអ្នកដឹកនាំ ផែនការសម្រាប់អភិវឌ្ឍន៍ខ្លួន និងការណែនាំក៏ត្រូវបានអនុត្តន៍ផងដែរ ដើម្បីធ្វើឲ្យអ្នកមានទេព្យកោសល្យទាំងនោះមានការលូតលាស់នៅក្នុងធនាគារ ដើម្បីជួយជំរុញឲ្យមានអ្នកបន្តវេណដែលសក្តិសម និងមានសក្តានុពលខ្ពស់សម្រាប់កាន់តំណែងដឹកនាំផ្សេងៗទៅថ្ងៃអនាគត។

### ក្រមសីលធម៌

ក្រមសីលធម៌របស់ធនាគារកំណត់នូវលក្ខណៈស្តង់ដារលើការអនុវត្តដែលមានភាពល្អប្រសើរ និងប្រកបដោយក្រមសីលធម៌ ក៏ដូចជាគោលបំណងដើម្បីរក្សាទំនុកចិត្តលើសន្តិសុខ និងសុចរិតភាពនៃការអនុវត្តន៍អាជីវកម្មរបស់ធនាគារ។ គ្រប់បុគ្គលិកទាំងអស់របស់ធនាគារតម្រូវឲ្យមានការយល់ដឹងនិងប្រតិបត្តិតាមក្រមសីលធម៌។ បុគ្គលិកដែលចូលថ្មីត្រូវបានទទួលការណែនាំ អំពីក្រមសីលធម៌ និងតម្រូវឲ្យចុះហត្ថលេខាលើកិច្ចសន្យាការងារនៅពេលចូលធ្វើការនៅក្នុងធនាគារ។

### គោលនយោបាយប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

គោលនយោបាយប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់ធនាគារត្រូវបានបង្កើតឡើងស្របតាមច្បាប់ប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនៃព្រះរាជាណាចក្រកម្ពុជា។ គោលនយោបាយនេះកំណត់នូវលក្ខណៈស្តង់ដាកម្រិតខ្ពស់ ទៅលើការបង្កើតរបបប្រតិបត្តិតាមដែលខ្លាំង និងរឹងមាំមួយនៅក្នុងធនាគារក្នុងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ហើយជួយសម្រួលនូវភាពជាប់លាប់ក្នុងការគ្រប់គ្រងហានិភ័យនៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនៅក្នុងធនាគារទាំងមូល និងកំណត់គោលនយោបាយធនាគារ ដោយយោងទៅតាមគោលការណ៍ទូទៅ និងវិធានការណ៍សំខាន់ៗដែលធនាគារបានប្រកាន់ខ្ជាប់។

អនុលោមតាមគោលនយោបាយប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់ធនាគារអង្គភាព និងនិយោជិកទាំងអស់នៅក្នុងធនាគារ ត្រូវប្រើវិធីសាស្ត្រផ្អែកលើហានិភ័យក្នុងការទទួលយកអតិថិជន និងអនុវត្តតាមក្របខ័ណ្ឌកម្មវិធីប្រតិបត្តិតាមប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ ទាំងនេះរួមមានតម្រូវការយកចិត្តទុកដាក់ស្គាល់អតិថិជន ការតាមដានសកម្មភាព ឬប្រតិបត្តិការរបស់អតិថិជន ការរាយការណ៍ទៅលើប្រតិបត្តិការដែលគួរឲ្យសង្ស័យ ការរក្សាទុកឯកសារកត់ត្រា ការបណ្តុះបណ្តាលប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ការការពារព័ត៌មានអតិថិជន និងការពិន័យលើករណីមិនប្រតិបត្តិតាមតម្រូវការ។

គោលនយោបាយប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់ធនាគារក៏មានចែងផងដែរអំពីតួនាទីនិងទំនួលខុសត្រូវ ក៏ដូចជាបង្កើតគណនេយ្យភាពយ៉ាងច្បាស់លាស់របស់ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងជាន់ខ្ពស់ និងបុគ្គលិកទាំងអស់នៅក្នុងធនាគារ។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវត្រួតពិនិត្យ លើការបង្កើតគោលនយោបាយ នីតិវិធី និងបទដ្ឋានអប្បបរិមាប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ចំណែកគណៈគ្រប់គ្រងជាន់ខ្ពស់មានទំនួលខុសត្រូវក្នុងការអនុវត្ត និងគ្រប់គ្រងកម្មវិធីប្រតិបត្តិតាមប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដោយអនុលោមតាមគោលនយោបាយ និងនីតិវិធីដែលអនុម័តដោយក្រុមប្រឹក្សាភិបាល។

## រចនាសម្ព័ន្ធនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង (ត)

### *ព័ត៌មាន និងទំនាក់ទំនង*

#### ការពិនិត្យឡើងវិញលើលទ្ធផលការងារ

ព័ត៌មានយ៉ាងទៀងទាត់ និងលម្អិតត្រូវបានផ្តល់ឲ្យដោយគណៈគ្រប់គ្រង ក្នុងការតាមដានលើលទ្ធផលការងារជាក់ស្តែង ដោយធៀបនឹងផែនការយុទ្ធសាស្រ្តអាជីវកម្ម និងគម្រោងថវិការប្រចាំឆ្នាំដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។ ព័ត៌មានទាំងនេះរួមមានសូចនាករហិរញ្ញវត្ថុ និងប្រតិបត្តិការសំខាន់ៗទាំងឡាយ ព្រមទាំងការផ្តួចផ្តើមយុទ្ធសាស្រ្តសំខាន់ៗ ដែលធនាគារបានអនុវត្តនៅក្នុងការិយបរិច្ឆេទ។

គណៈកម្មាធិការក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការគ្រប់គ្រង ទទួលនិងពិនិត្យឡើងវិញនូវរបាយការណ៍ហិរញ្ញវត្ថុជាប្រចាំខែ និងប្រចាំត្រីមាស ធៀបសមិទ្ធផលនឹងគោលដៅដែលបានអនុម័តរួច និងមូលហេតុនៃគម្លាតគ្នាឆ្ងាយណាមួយ ក៏ដូចជាវិធានការណ៍ផ្សេងៗទៀតដែលកំពុងអនុវត្តដើម្បីសម្រេចបាននូវគោលដៅ។

នាយកផ្នែកអាជីវកម្ម និងប្រតិបត្តិការសំខាន់ៗនៅក្នុងធនាគារធ្វើបទបង្ហាញអំពីរបាយកាណ៏ថ្នាក់គ្រប់គ្រងរៀងៗខ្លួនក្នុងអង្គប្រជុំគណៈកម្មាធិការគ្រប់គ្រងប្រចាំខែដែលផ្តោតទៅលើសមិទ្ធផល ហិរញ្ញវត្ថុ លទ្ធផលសកម្មភាពសំខាន់ៗ និងសំណើរឬដំណើរការអាជីវកម្មថ្មីៗ ដើម្បីឲ្យគណៈកម្មាធិការគ្រប់គ្រងជ្រាបជាព័ត៌មាន និងធ្វើកិច្ចពិភាក្សា។

#### គោលនយោបាយវិស្សលប៉្លូវីង (whistleblowing)

គោលនយោបាយវិស្សលប៉្លូវីងត្រូវបានបង្កើតឡើងដោយធនាគារ ហើយបានធ្វើបច្ចុប្បន្នភាពក្នុងខែតុលា ឆ្នាំ២០១៩។ គោលនយោបាយនេះផ្តល់នូវយន្តការត្រឹមត្រូវ និងកំណត់បទដ្ឋានអប្បបរិមាដែលត្រូវប្រកាន់ខ្ជាប់ដោយធនាគារ ក្នុងការដោះស្រាយលើការលាតត្រដាង ពីសកម្មភាពគួរឲ្យសង្ស័យ ឬការប្រព្រឹត្តខុសរបស់បុគ្គលិកនៅក្នុងធនាគារ។

#### ការរាយការណ៍ពីការគ្រប់គ្រងឧប្បត្តិហេតុ

ដើម្បីបំពេញបន្ថែមលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ ប្រព័ន្ធរាយការណ៍ការគ្រប់គ្រងឧប្បត្តិហេតុដែលលម្អិតមួយត្រូវបានអនុវត្ត ដើម្បីធានាឲ្យបានថាមានការរាយការណ៍ និងគ្រប់គ្រងឧប្បត្តិហេតុបានត្រឹមត្រូវ ដោយយោងទៅតាមកម្រិតនៃភាពធ្ងន់ធ្ងរ។ ប្រព័ន្ធរាយការណ៍ការគ្រប់គ្រងឧប្បត្តិហេតុ ក៏ធានាឲ្យបានថាគ្រប់ឧប្បត្តិហេតុណាដែលមានហានិភ័យ និងការខាតបង់ជាសារវន្ត ត្រូវបានរាយការណ៍ទាន់ពេលវេលាទៅកាន់គណៈគ្រប់គ្រងជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាល ជាមួយនឹងវិធានការណ៍ចាំបាច់ ដើម្បីកាត់បន្ថយហានិភ័យដែលមានសក្តានុពល។ ទាំងនេះអាចឲ្យអ្នកសម្រេចចិត្ត ធ្វើការសម្រេចចិត្តប្រកបដោយព័ត៌មានគ្រប់គ្រាន់ និងយល់ដឹងពីស្ថានភាពទាន់ហេតុការណ៍ ព្រមទាំងគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព។

### *ការតាមដាន*

#### គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានគណៈកម្មាធិការក្រុមប្រឹក្សាភិបាលដែលបានបង្កើតឡើងដើម្បីគាំទ្រក្រុមប្រឹក្សាភិបាលក្នុងការត្រួតពិនិត្យរបស់ខ្លួន។ គណៈកម្មាធិការក្រុមប្រឹក្សាភិបាលរួមមាន គណៈកម្មាធិការគ្រប់គ្រងហានិភ័យ គណៈកម្មាធិការសវនកម្ម គណៈកម្មាធិការជ្រើសតាំងនិងសំណង និងគណៈកម្មាធិការក្រុមប្រឹក្សាភិបាលឥណទាន។ គណៈកម្មាធិការក្រុមប្រឹក្សាភិបាលទាំងនេះ ត្រូវបានប្រគល់ភារកិច្ចជាក់លាក់ក្នុងការពិនិត្យមើលឡើងវិញ និងពិចារណាទៅលើគ្រប់បញ្ហាទាំងអស់នៅក្នុងវិសាលភាពនៃទំនួលខុសត្រូវដែលមានចែងក្នុងក្រមប្រតិបត្តិរៀងៗខ្លួន។

#### គណៈកម្មាធិការគ្រប់គ្រង

គណៈកម្មាធិការគ្រប់គ្រងមានសមាសភាពពីបុគ្គលិកគ្រប់គ្រងសំខាន់ៗរបស់ធនាគារ ហើយមាននាយកប្រតិបត្តិ ឬអភិបាលប្រតិបត្តិជាប្រធាន។ គណៈកម្មាធិការគ្រប់គ្រងផ្តល់នូវការដឹកនាំ និងទិសដៅក្នុងការអនុវត្តយុទ្ធសាស្រ្តនិងគោលនយោបាយដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលនិងជួបប្រជុំប្រចាំខែដើម្បីពិភាក្សា និងវែកញែកលើបញ្ហាយុទ្ធសាស្រ្តដែលប៉ះពាល់ដល់ប្រតិបត្តិការរបស់ធនាគារ។

#### គណៈកម្មាធិការសវនកម្មថ្នាក់គ្រប់គ្រង

គណៈកម្មាធិការសវនកម្មថ្នាក់គ្រប់គ្រងត្រូវបានបង្កើតឡើង ដើម្បីធានាឲ្យបាននូវការកែតម្រូវយ៉ាងទាន់ពេលវេលា លើគំហើញសវនកម្ម និងបុព្វហេតុមូលដ្ឋានដែលបានលើកឡើងដោយសវនករផ្ទៃក្នុង សវនករឯករាជ្យ និងនិយ័តករ។ ស្ថានភាពនៃការកែតម្រូវរាល់គំហើញសវនកម្ម និងវិធានការណ៍ដែលបានធ្វើឡើងដោយគណៈគ្រប់គ្រងដើម្បីដោះស្រាយលើបុព្វហេតុមូលដ្ឋាន ត្រូវបានតាមដានយ៉ាងដិតដល់ក្នុងរាល់អង្គប្រជុំគណៈកម្មាធិការសវនកម្មថ្នាក់គ្រប់គ្រង។

គណៈកម្មាធិការសវនកម្មថ្នាក់គ្រប់គ្រងមានសមាសភាពអ្នកតំណាងជាន់ខ្ពស់ពីផ្នែកផ្សេងៗ ហើយមាននាយកប្រតិបត្តិ ឬអភិបាលប្រតិបត្តិនៃធនាគារជាប្រធាន។ គណៈកម្មាធិការសវនកម្មថ្នាក់គ្រប់គ្រងជួបប្រជុំជារៀងរាល់ខែ ឬតាមការកំណត់របស់ប្រធាន ហើយកំណត់ត្រានៃកិច្ចប្រជុំព្រមទាំងរបាយការណ៍សវនកម្មដែលពាក់ព័ន្ធ ត្រូវបានដាក់បញ្ចូលជាបន្តបន្ទាប់ក្នុងអង្គប្រជុំគណៈកម្មាធិការសវនកម្មសម្រាប់ជាព័ត៌មាន ពិភាក្សាវែកញែក និងផ្តល់ទិសដៅសំរាប់ធ្វើសកម្មភាពបន្តទៀតប្រសិនបើចាំបាច់។

#### ការប្រតិបត្តិតាម

ការប្រតិបត្តិតាម គឺជាទំនួលខុសត្រូវរួមរបស់ក្រុមប្រឹក្សាភិបាលគណៈគ្រប់គ្រងជាន់ខ្ពស់ និងបុគ្គលិកគ្រប់រូបរបស់ធនាគារ។ មុខងារប្រតិបត្តិតាមជាផ្នែកដ៏សំខាន់មួយនៃក្របខ័ណ្ឌការគ្រប់គ្រង ហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង។ ក្នុងទស្សនៈមួយដែលថាវប្បធម៌ប្រតិបត្តិតាមដ៏រឹងមាំមួយនឹងឆ្លុះបញ្ចាំងអំពីវប្បធម៌ជារួមនៃសុច្ចរិតភាព និងក្រមសីលធម៌ខ្ពស់ ហើយរំពឹងថាបុគ្គលិកគ្រប់រូបនឹងជំរុញការគោរពបទប្បញ្ញត្តិដោយខ្លួនឯង និងមានទំនួលខុសត្រូវលើរាល់សកម្មភាពរបស់ខ្លួនហើយប្រកាន់ខ្ជាប់នូវគោលការណ៍ និងអាកប្បកិរិយាប្រកបដោយសីលធម៌។

# របាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងប្រចាំឆ្នាំ (ត)



## រចនាសម្ព័ន្ធនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង (ត)

បន្ថែមលើការតាមដានប្រចាំថ្ងៃ ការប្តេជ្ញារបស់ធនាគារលើការដាក់បញ្ចូលវប្បធម៌ប្រតិបត្តិតាមដ៏រឹងមាំមួយ ត្រូវបានបង្ហាញតាមរយៈការបង្កើតក្របខ័ណ្ឌតាមដានការប្រតិបត្តិតាម ដែលរួមមានការអនុវត្តគោលនយោបាយប្រតិបត្តិតាមយ៉ាងទូលំទូលាយ ការពិនិត្យឡើងវិញ ឬការវាយតម្លៃហានិភ័យលើការប្រតិបត្តិតាមប្រចាំគ្រា ជំនួបប្រជុំជាប្រចាំរវាងផ្នែកអាជីវកម្មនិងផ្នែកប្រតិបត្តិការនានា និងការរៀបចំកម្មវិធីបណ្តុះបណ្តាលនិងយល់ដឹងជាបន្តបន្ទាប់ ដើម្បីធានាឲ្យបានថាបុគ្គលិកទាំងអស់នៅក្នុងធនាគារ បានយល់ដឹងយ៉ាងច្បាស់លាស់អំពីតម្រូវការនៃបទប្បញ្ញត្តិថ្មីៗ។ លើសពីនេះក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់បានជ្រាបជាព័ត៌មាននូវស្ថានភាពប្រតិបត្តិតាមរបស់ធនាគារ តាមរយៈការប្រគល់ជូនរបាយការណ៍ប្រតិបត្តិតាមរបស់ធនាគារប្រចាំគ្រា។

### ◆ គណៈកម្មាធិការសវនកម្ម

គណៈកម្មាធិការសវនកម្មទទួលខុសត្រូវដោយផ្ទាល់ទៅកាន់ក្រុមប្រឹក្សាភិបាល ហើយក្រុមប្រឹក្សាភិបាលនឹងបន្តទទួលខុសត្រូវលើរាល់បញ្ហាពាក់ព័ន្ធផ្សេងៗនៅក្នុងធនាគារ។

#### ក្រមប្រតិបត្តិរបស់គណៈកម្មាធិការសវនកម្ម

**គោលបំណង**

១) ផ្តល់ការត្រួតពិនិត្យដោយឯករាជ្យទៅលើរបាយការណ៍ហិរញ្ញវត្ថុ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ហើយធានាលើការត្រួតពិនិត្យ និងតុល្យភាពសម្រាប់អង្គភាពនៅក្នុងធនាគារ។

២) ពិនិត្យឡើងវិញនូវគុណភាពនៃការធ្វើសវនកម្មដោយសវនករផ្ទៃក្នុង និងឯករាជ្យ។

៣) ផ្តល់បណ្តាញទំនាក់ទំនងរវាង ក្រុមប្រឹក្សាភិបាល និងសវនករឯករាជ្យ។

៤) ជួយក្នុងការផ្តល់ឲ្យមានឯករាជ្យភាពនៃសវនករឯករាជ្យ និងធានាថាមិនមានការរាំងស្ទះក្នុងដំណើរការសវនកម្ម។

៥) ផ្តល់ចំណាប់អារម្មណ៍បន្ថែមទៅលើមុខងារសវនកម្មផ្ទៃក្នុង ដោយបង្កើននូវភាពមិនលម្អៀងនិងឯករាជ្យភាពសម្រាប់សវនករផ្ទៃក្នុង និងផ្តល់វេទិការសម្រាប់ការពិភាក្សា ដែលក្នុងនោះមានឯករាជ្យភាពពីគណៈគ្រប់គ្រង។

៦) លើកកម្ពស់ការយល់ឃើញដល់ភាគីពាក់ព័ន្ធ (រួមបញ្ចូលទាំង ម្ចាស់ភាគហ៊ុន និយ័តករ ម្ចាស់បំណុល និងនិយោជិក) លើភាពជឿជាក់ និងភាពមិនលម្អៀងនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយធានាឲ្យបានថាព័ត៌មានផ្តល់ជូនទៅសាធារណៈ គឺច្បាស់លាស់ ត្រឹមត្រូវ និងជឿទុកចិត្តបាន។

៧) គណៈកម្មាធិការត្រូវបានជួយជ្រុមជ្រែងដោយគណៈគ្រប់គ្រង ដែលជាអ្នកទទួលខុសត្រូវសម្រាប់ការបង្កើតនិងថែរក្សាលើការត្រួតពិនិត្យ និតិវិធី សេចក្តីណែនាំលើដំណើរការ និង អនុសាសន៍។

**សិទ្ធិអំណាច**

គណៈកម្មាធិការសវនកម្ម មានសិទ្ធិអំណាចតាមក្រមប្រតិបត្តិរបស់ខ្លួនក្នុងការៈ

១) ទទួលបាននូវធនធានដែលខ្លួនត្រូវការ ក្នុងការស៊ើបអង្កេតរាល់បញ្ហាទៅតាមក្រមប្រតិបត្តិរបស់ខ្លួន និងមានសិទ្ធិពេញលេញ ដោយមិនមានការហាមប្រាមលើការទាញយកព័ត៌មានដែលពាក់ព័ន្ធ។ គណៈកម្មាធិការត្រូវបានអនុញ្ញាតផងដែរក្នុងការស្វែងរកព័ត៌មានផ្សេងៗដែលខ្លួនត្រូវការ ពីបុគ្គលិកណាមួយរបស់ធនាគារ ហើយបុគ្គលិកទាំងអស់ត្រូវតែសហការជាមួយនឹងសំណើរផ្សេងៗ ដែលបានលើកឡើងដោយគណៈកម្មាធិការសវនកម្ម។

២) ចុះហត្ថលេខាទៅលើរបាយការណ៍ផ្ទៃក្នុងប្រចាំឆ្នាំ និងឬរបាយការណ៍ផ្សេងៗទៀតដែលស្នើដោយនិយ័តករ និងទៅតាមច្បាប់ដែលពាក់ព័ន្ធ។

៣) មានបណ្តាញទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងសវនករឯករាជ្យ និងសវនករផ្ទៃក្នុង។

៤) មានធនធានគ្រប់គ្រាន់ រួមបញ្ចូលទាំងការទទួលបានព័ត៌មានពេញលេញ និងគ្មានការរឹតត្បិត ដែលចាំបាច់ដើម្បីបំពេញភារកិច្ចរបស់ខ្លួន។

៥) បង្កើតគណៈគ្រប់គ្រង ឬអនុគណៈកម្មាធិការក្នុងករណីដែលចាំបាច់ និងសមស្រប។

៦) ទទួលអនុសាសន៍ឯករាជ្យប្រកបដោយវិជ្ជាជីវៈ ឬអនុសាសន៍ផ្សេងៗទៀត និងអញ្ជើញអ្នកដែលមានបទពិសោធន៍ និងជំនាញពាក់ព័ន្ធដើម្បីចូលរួមអង្គប្រជុំ ប្រសិនបើចាំបាច់។

៧) អញ្ជើញសវនករផ្ទៃក្នុង ឬឯករាជ្យ នាយកគ្រប់គ្រង ឬនាយកគ្រប់គ្រងសម្ព័ន្ធ អភិបាល ឬសមាជិកនៃគណៈគ្រប់គ្រងដទៃទៀត និងបុគ្គលិកក្នុងសម្ព័ន្ធឲ្យចូលរួមប្រជុំដើម្បីជួយក្នុងការពិភាក្សាវែកញែកប្រសិនបើចាំបាច់។

៨) ចែករំលែកការទទួលខុសត្រូវផ្សេងៗទៅកាន់បុគ្គល ឬគណៈកម្មាធិការណាមួយប្រសិនបើគិតថាសមស្រប (ឧទាហរណ៍ ចែករំលែកតួនាទីស៊ើបអង្កេតទៅឲ្យក្រុមហ៊ុនឯករាជ្យដើម្បីរក្សាឯករាជ្យភាពក្នុងការស៊ើបអង្កេត ដែលពាក់ព័ន្ធទៅនឹងសមាជិកក្រុមប្រឹក្សាភិបាល)។

៩) អនុម័តផែនការសវនកម្ម និងគម្រោងថវិការ (ការបណ្តុះបណ្តាល និងបេសកកម្ម) សម្រាប់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

១០) មានសិទ្ធិកោះប្រជុំជាមួយសវនករឯករាជ្យ សវនករផ្ទៃក្នុង ឬទាំងពីរ ដោយគ្មានវត្តមានរបស់អភិបាល និងបុគ្គលិកធនាគារដទៃទៀត និងជាមួយនឹងភាគីខាងក្រៅផ្សេងទៀតក្នុងករណីដែលចាំបាច់។

១១) ស៊ើបអង្កេតសកម្មភាពផ្សេងៗដែលមានចែងនៅក្នុងក្រមប្រតិបត្តិ។

## រចនាសម្ព័ន្ធនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង (ត)

### តួនាទី និងទំនួលខុសត្រូវ

គណៈកម្មាធិការសវនកម្មទទួលខុសត្រូវដោយផ្ទាល់ ទៅកាន់ក្រុមប្រឹក្សាភិបាល ហើយក្រុមប្រឹក្សាភិបាលនឹងបន្តទំនួលខុសត្រូវសម្រាប់បញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងធនាគារ។

ខាងក្រោមនេះគឺជាតួនាទី និងទំនួលខុសត្រូវរបស់គណៈកម្មាធិការសវនកម្ម៖

**១) មុខងារសវនកម្មផ្ទៃក្នុង**

ក) ត្រួតពិនិត្យទៅលើមុខងាររបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងជានាឲ្យបានលើការគោរពតាមច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ រួមបញ្ចូលទាំងការរាយការណ៍ប្រកបដោយភាពត្រឹមត្រូវ មានតម្លាភាព និងទាន់ពេលវេលានៃរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

ខ) ធានាថានាយកដ្ឋានសវនកម្មផ្ទៃក្នុងមានភាពខុសប្លែក និងមានឋានៈមួយសមស្របនៅក្នុងរចនាសម្ព័ន្ធអង្គភាពទាំងមូល ដើម្បីឲ្យសវនករផ្ទៃក្នុងអាចបំពេញគោលដៅសវនកម្មផ្ទៃក្នុងរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

គ) ពិនិត្យឡើងវិញលើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុង និងដំណើរការគ្រប់គ្រងហានិភ័យរួមបញ្ចូលទាំងវិសាលភាពនៃកម្មវិធីសវនកម្មផ្ទៃក្នុង និងភាពសមស្របនៃវិធីសាស្ត្រវាយតម្លៃហានិភ័យ ដើម្បីកំណត់ភាពញឹកញាប់ និងវិសាលភាពនៃសវនកម្ម។

ឃ) ពិនិត្យឡើងវិញលើភាពគ្រប់គ្រាន់នៃវិសាលភាព មុខងារ សមត្ថភាព និងធនធានរបស់សវនកម្មផ្ទៃក្នុង ថាតើមុខងារនេះមានសិទ្ធិអំណាចដែលចាំបាច់សម្រាប់បំពេញការងាររបស់ខ្លួន ឬទេ។

ង) ពិនិត្យឡើងវិញ និងអនុម័តផែនការសវនកម្មផ្ទៃក្នុង និងពិនិត្យលើលទ្ធផលនៃកម្មវិធីសវនកម្មផ្ទៃក្នុង ឬការស៊ើបអង្កេតដែលបានធ្វើឡើង ថាតើសកម្មភាពសមស្របត្រូវបានអនុវត្តដោយអ្នកគ្រប់គ្រងទៅតាមអនុសាសន៍របស់សវនករផ្ទៃក្នុងដែរ ឬទេ។

ច) ពិនិត្យឡើងវិញលើភាពគ្រប់គ្រាន់នៃវិសាលភាព មុខងារ សមត្ថភាព និងធនធាននៃមុខងារសវនកម្មផ្ទៃក្នុង លក្ខន្តិកៈសវនកម្ម ថាតើមុខងារនេះមានសិទ្ធិអំណាចដែលចាំបាច់សម្រាប់បំពេញការងាររបស់ខ្លួនដែរ ឬទេ។

ឆ) ធានាថាទំនាក់ទំនងលើការរាយការណ៍របស់បុគ្គលិកសវនកម្មផ្ទៃក្នុង មិនប៉ះពាល់ដល់ឯករាជ្យភាព ក្នុងការវិនិច្ឆ័យរបស់សវនករផ្ទៃក្នុង។ ជាពិសេសរបាយការណ៍សវនករផ្ទៃក្នុងមិនត្រូវដាក់ទៅជម្រះដោយនាយកប្រតិបត្តិ ឬអភិបាលប្រតិបត្តិណាមួយឡើយ។

ជ) ធានាថារាល់គំហើញ និងអនុសាសន៍ដែលលើកឡើង ត្រូវបានពិនិត្យឡើងវិញ និងដោះស្រាយប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។

ឈ) អនុវត្តការត្រួតពិនិត្យតាមកាលកំណត់ ដែលឯករាជ្យពីការត្រួតពិនិត្យជាអចិន្ត្រៃយ៍ ហើយរាយការណ៍ពីគំហើញទៅកាន់ប្រធានគណៈកម្មាធិការសវនកម្ម។

ញ) ធានាថានាយកដ្ឋានសវនកម្មមានបុគ្គលិកគ្រប់គ្រាន់ និងទទួលបានការបណ្ដុះបណ្ដាលដែលចាំបាច់ដើម្បីអនុវត្តការងារសវនកម្ម។ គួរតែមានកម្មវិធីអប់រំ និងបណ្ដុះបណ្ដាលជាបន្តបន្ទាប់ដើម្បីឲ្យសវនករផ្ទៃក្នុងតាមឲ្យទាន់នូវទំនោរអាជីវកម្ម និងការអភិវឌ្ឍន៍ថ្មីៗ ទាំងក្នុងកម្រិតវិទ្យាស្ថាន និងឧស្សាហកម្ម ក៏ដូចជាលើកកម្ពស់ជំនាញបច្ចេកទេសដែលត្រូវការដើម្បីគាំទ្រមុខងារសវនកម្មផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព។

ដ) វាយតម្លៃលទ្ធផលបំពេញការងាររបស់នាយកផ្នែកសវនកម្មផ្ទៃក្នុង និងពិនិត្យលើការវាយតម្លៃរបស់បុគ្គលិកជាន់ខ្ពស់នៃសវនកម្មផ្ទៃក្នុង។ នាយកផ្នែកសវនកម្មផ្ទៃក្នុង ត្រូវរាយការណ៍ដោយផ្ទាល់ទៅកាន់ប្រធានគណៈកម្មាធិការសវនកម្ម។

ឋ) អនុម័តរាល់ការតែងតាំង កំណត់ការលើកទឹកចិត្ត វាយតម្លៃលទ្ធផលបំពេញការងារ ការផ្ទេរ ឬបញ្ឈប់នាយកផ្នែកសវនកម្មផ្ទៃក្នុង និងសមាជិកជាន់ខ្ពស់នៃសវនកម្មផ្ទៃក្នុង និងពិនិត្យឡើងវិញរាល់ការលាឈប់របស់នាយកផ្នែកសវនកម្មផ្ទៃក្នុង និងបុគ្គលិកសវនកម្មផ្ទៃក្នុងហើយផ្ដល់ឱកាសឲ្យបុគ្គលិកលាឈប់បានផ្ដល់ហេតុផលនៃការលាឈប់ ប្រសិនបើចាំបាច់។

ឌ) ធានាថារាល់ការផ្លាស់ប្ដូរពាក់ព័ន្ធនឹងមុខតំណែងនៃនាយកផ្នែកសវនកម្មផ្ទៃក្នុង ត្រូវបានជូនដំណឹងទៅកាន់ធនាគារជាតិនៃកម្ពុជា។

**២) មុខងារសវនកម្មឯករាជ្យ**

ក) ពិនិត្យឡើងវិញទៅលើសេវាកម្មមិនមែនជាសេវាកម្មសវនកម្ម ដែលបានផ្ដល់ដោយសវនករឯករាជ្យ ព្រមទាំងថ្លៃឈ្នួលសេវាកម្ម ក្នុងការផ្ដល់អនុសាសន៍ទៅកាន់ក្រុមប្រឹក្សាភិបាលដើម្បីធ្វើការអនុម័ត។

ខ) ផ្ដល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលលើការតែងតាំង និងការតែងតាំងសារឡើងវិញប្រចាំឆ្នាំនៃសវនករឯករាជ្យ និងវាយតម្លៃលើថ្លៃឈ្នួលសវនកម្ម ដោយពិចារណាអំពីឯករាជ្យភាព និងភាពមិនលម្អៀងនៃសវនករឯករាជ្យ ព្រមទាំងប្រសិទ្ធភាពចំណាយលើ សវនកម្ម ក៏ដូចជាការផ្លាស់ប្ដូរសវនករ។

គ) វាយតម្លៃលើភាពមិនលម្អៀង លទ្ធផលការងារ និងឯករាជ្យភាពរបស់សវនករឯករាជ្យ ( ឧទាហរណ៍ តាមរយៈការពិនិត្យឡើងវិញ និងវាយតម្លៃលើទំនាក់ទំនងនានារវាងសវនករឯករាជ្យជាមួយធនាគារ ឬអង្គភាពណាផ្សេងទៀត )។

ឃ) ពិនិត្យឡើងវិញជាមួយនឹងសវនករឯករាជ្យ ថាតើបុគ្គលិករបស់ធនាគារបានផ្ដល់នូវជំនួយសមស្របក្នុងការបំពេញភារកិច្ចរបស់ពួកគេ។

ង) ពិនិត្យឡើងវិញជាមួយសវនករឯករាជ្យនូវមូលដ្ឋាន និងវិសាលភាពនៃផែនការសវនកម្មរបស់ពួកគេ (រួមបញ្ចូលទាំងការផ្លាស់ប្ដូរផ្សេងៗទៅលើវិសាលភាពនៃផែនការសវនកម្ម) ការវាយតម្លៃទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងលិខិតផ្ដល់អនុសាសន៍របស់ពួកគេ និងពិភាក្សាពីបញ្ហាផ្សេងៗ ដែលសវនកម្មឯករាជ្យចង់លើកឡើងដោយគ្មានវត្តមានគណៈគ្រប់គ្រង ប្រសិនបើចាំបាច់។

## រចនាសម្ព័ន្ធនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង (ត)

ច) ពិនិត្យឡើងវិញយ៉ាងទៀងទាត់ទៅលើគំហើញសវនកម្ម និងធានាឲ្យបានថារាល់គំហើញត្រូវបានគ្រប់គ្រង និងកែតម្រូវឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។

ឆ) ពិភាក្សា និងពិនិត្យឡើងវិញជាមួយនឹងសវនករឯករាជ្យរាល់ការស្នើសុំពីការលាឈប់របស់ពួកគេជាសវនករ។

ជ) ពិនិត្យឡើងវិញទៅលើសេវាកម្មមិនមែនជាសេវាកម្មសវនកម្ម ដែលផ្តល់ដោយសវនករឯករាជ្យ និងថ្លៃឈ្នួលសេវាកម្ម សម្រាប់ការផ្តល់អនុសាសន៍ ទៅកាន់ក្រុមប្រឹក្សាភិបាលដើម្បីធ្វើការអនុម័តឲ្យសមស្របទៅនឹងគោលនយោបាយ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជា លើថ្លៃឈ្នួលមិនមែនសវនកម្មដែលត្រូវបង់ទៅឲ្យសវនករឯករាជ្យ ដើម្បីធានាឲ្យប្រាកដថា ការផ្គត់ផ្គង់សេវាកម្មមិនមែនជាសេវាកម្មសវនកម្ម មិនប៉ះពាល់ដល់ការវិនិច្ឆ័យដោយឯករាជ្យរបស់សវនករ។

ឈ) ពិនិត្យឡើងវិញលើការសម្របសម្រួលនៃនីតិវិធីសវនកម្ម នៅពេលដែលមានក្រុមហ៊ុនសវនករឯករាជ្យលើសពីមួយ។

ញ) ជួបជាមួយនឹងសវនករឯករាជ្យដោយមិនមានវត្តមានគណៈគ្រប់គ្រង ឬសមាជិកក្រុមប្រឹក្សាភិបាលប្រតិបត្តិដ៏ទៃទៀត តាមការស្នើសុំរបស់សវនករឯករាជ្យ ប្រធានក្រុមប្រឹក្សាភិបាលសវនកម្ម គួរតែកោះប្រជុំដើម្បីពិចារណាលើបញ្ហាដែលសវនករឯករាជ្យគិតថាគួរតែបានយកចិត្តទុកដាក់ ដោយក្រុមប្រឹក្សាភិបាល ឬម្ចាស់ភាគហ៊ុន។

### ៣) របាយការណ៍ហិរញ្ញវត្ថុ

ពិនិត្យឡើងវិញនូវលទ្ធផលពាក់កណ្តាលឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុសារពើពន្ធរបស់ធនាគារសម្រាប់ការផ្តល់អនុសាសន៍ទៅកាន់ក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តដោយផ្តោតជាចំបងទៅលើ៖

ក) ការផ្លាស់ប្តូរ ឬការអនុវត្តនៃការផ្លាស់ប្តូរចំបងៗនៃគោលនយោបាយគណនេយ្យ។

ខ) បញ្ហាសំខាន់ៗដែលបានលើកឡើង រួមបញ្ចូលទាំងបញ្ហាលើរបាយការណ៍ហិរញ្ញវត្ថុ ការវិនិច្ឆ័យសំខាន់ៗដោយគណៈគ្រប់គ្រង ព្រឹត្តិការណ៍ឬប្រតិបត្តិការដែលមិនប្រក្រតី ហើយមានលក្ខណៈជាសារវន្ត និងរបៀបដែលបញ្ហាទាំងនេះត្រូវបានដោះស្រាយ។

គ) វិធីសាស្ត្រគណនេយ្យនានាដែលបានប្រើប្រាស់ ក្នុងការរៀបចំគណនីជាបុគ្គល និងរួមបញ្ចូលគ្នា (ប្រសិនបើមាន)។

ឃ) អនុលោមតាមស្តង់ដារគណនេយ្យ និងបទប្បញ្ញត្តិផ្សេងៗ។

### ៤) ការត្រួតពិនិត្យផ្ទៃក្នុង

ក) ពិនិត្យឡើងវិញលើប្រសិទ្ធភាពនៃដំណើរការ គោលនយោបាយនៃការត្រួតពិនិត្យផ្ទៃក្នុងនិងការគ្រប់គ្រងហានិភ័យ រួមបញ្ចូលទាំងវិសាលភាពនៃកម្មវិធីសវនកម្មផ្ទៃក្នុង និងនីតិវិធីវាយតម្លៃហានិភ័យសមស្របដើម្បីកំណត់ភាពញឹកញាប់ និងវិសាលភាពនៃសវនកម្ម។

ខ) ពិនិត្យឡើងវិញជាប្រចាំ និងលើកឡើងនូវបញ្ហាប្រឈមនានាទៅកាន់គណៈគ្រប់គ្រង លើភាពជឿជាក់ និងភាពរឹងមាំនៃគោលនយោបាយគ្រប់គ្រងហានិភ័យ ក្របខ័ណ្ឌ និងការរាយការណ៍ព័ត៌មានហានិភ័យដើម្បីធានាថា វាគ្មានគំលាត ឬភាពទន់ខ្សោយជាសារវន្តឡើយ។

### ៥) ប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ

ពិនិត្យឡើងវិញនូវប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ និងស្ថានភាពទំនាស់ផលប្រយោជន៍ ដែលអាចកើតឡើងនៅក្នុងធនាគារ និងសម្ព័ន្ធធនាគារ អ អេច ប៊ី រួមបញ្ចូលទាំងប្រតិបត្តិការ នីតិវិធី ឬក្រុមសីលធម៌ណាដែលចោទជាសំនួរ ទាក់ទងនឹងភាពស្មោះត្រង់របស់គណៈគ្រប់គ្រង។ សមាជិកទាំងនោះត្រូវបានរំពឹងថានឹងជៀសវាងរាល់ស្ថានភាពទាំងឡាយណាដែលអាចប៉ះពាល់ដល់ទំនាស់ផលប្រយោជន៍របស់ធនាគារ។

### ៦) បញ្ហាផ្សេងៗ

ក) អនុវត្តមុខងារផ្សេងទៀតដូចបានផ្តល់សិទ្ធិដោយក្រុមប្រឹក្សាភិបាល។

ខ) ធានាលើការពិនិត្យដោយឯករាជ្យនៃការគ្រប់គ្រងហានិភ័យ និងដំណើរការគ្រប់គ្រងមូលធន ដែលពាក់ព័ន្ធនឹងដំណើរការវាយតម្លៃភាពគ្រប់គ្រាន់នៃមូលធន ដោយសុចរិតភាព មិនលម្អៀង និងការអនុវត្តយ៉ាងជាប់លាប់របស់ពួកគេ។

គ) ពិនិត្យឡើងវិញនូវរបាយការណ៍ត្រួតពិនិត្យ និងអធិការកិច្ចចេញដោយនិយ័តករ និងធានាថា វិធានការសមស្រប និងទាន់ពេលវេលាត្រូវបានអនុវត្តលើរាល់គំហើញណាមួយ។

ឃ) ពិនិត្យឡើងវិញនូវកំណត់ត្រាអង្គប្រជុំ ថាតើដំណោះស្រាយរបស់គណៈគ្រប់គ្រងចំពោះបញ្ហាដែលកើតមានឡើងមានភាពសមស្រប គួរឲ្យពេញចិត្តដែរ ឬទេ។

### របាយការណ៍

ក្នុងខណៈពេលដែលគណៈកម្មាធិការសវនកម្មរាយការណ៍ជូនក្រុមប្រឹក្សាភិបាលរបាយការណ៍សវនកម្ម ក៏ត្រូវបានលើកឡើងនៅក្នុងអង្គប្រជុំគណៈកម្មាធិការក្រុមប្រឹក្សាភិបាលសវនកម្មសម្ព័ន្ធផងដែរ ដែលជាផ្នែកមួយនៃការត្រួតពិនិត្យ បើសិនជាចាំបាច់។

## រចនាសម្ព័ន្ធនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង (ត)

សមាសភាពនៃគណៈកម្មាធិការសវនកម្ម

### ១) សមាជិក

ក) សមាជិករបស់គណៈកម្មាធិការសវនកម្ម នឹងត្រូវតែងតាំងឡើងដោយក្រុមប្រឹក្សាភិបាល ក្នុងចំណោមអភិបាលនានារបស់ធនាគារ។

ខ) សមាជិករបស់គណៈកម្មាធិការសវនកម្ម ត្រូវមានសមាជិកយ៉ាងតិចបំផុតបី (៣) នាក់ និងយ៉ាងហោចណាស់ពីរ (២) នាក់ (រួមបញ្ចូលទាំងប្រធានគណៈកម្មាធិការ) គួរតែជាអភិបាលឯករាជ្យដែលមានបទពិសោធន៍ផ្នែកហិរញ្ញវត្ថុ និងគណនេយ្យ និងអភិបាលឯករាជ្យម្នាក់ទៀតមានសាវតាផ្នែកច្បាប់ និងធនាគារ។

គ) ប្រសិនបើសមាជិកម្នាក់ចូលនិវត្ត ឬលាលែងពីសមាជិកគណៈកម្មាធិការដែលហេតុផលនេះធ្វើឲ្យចំនួនសមាជិកកាត់បន្ថយមកក្រោមបី (៣) នាក់ ក្រុមប្រឹក្សាភិបាលត្រូវតែងតាំងសមាជិកថ្មីម្នាក់នៃគណៈកម្មាធិការឲ្យបានឆាប់ តាមដែលអាចរកបានធ្វើជាអ្នកបន្តដំណែងប្រកបដោយលក្ខណៈសម្បត្តិគ្រប់គ្រាន់។

ឃ) មិនមានសមាជិកគណៈកម្មាធិការសវនកម្មណា ត្រូវបានតែងតាំងនូវមុខងារប្រតិបត្តិនៅក្នុងធនាគារឡើយ បើមិនដូច្នេះទេវាធ្វើឲ្យមានទំនាក់ទំនងដែលក្រុមប្រឹក្សាភិបាលយល់ថានឹងប៉ះពាល់ដល់ឯករាជ្យភាពនៃការវិនិច្ឆ័យ ក្នុងការអនុវត្តមុខងារជាគណៈកម្មាធិការសវនកម្ម។ លើសពីនេះទៅទៀត សមាជិកនៃគណៈកម្មាធិការសវនកម្ម មិនគួរទទួលខុសត្រូវដោយផ្ទាល់ ឬជាផ្នែកនៃគណៈកម្មាធិការដែលបានពាក់ព័ន្ធណាមួយសម្រាប់មុខងារគណៈគ្រប់គ្រងនៅក្នុងធនាគារ។

ង) សរុបមកគណៈកម្មាធិការសវនកម្មគួរមានជំនាញយ៉ាងទូលំទូលាយដែលចំបាច់ ដើម្បីអនុវត្តកាតព្វកិច្ច និងទំនួលខុសត្រូវរបស់ខ្លួន ហើយត្រូវបានរំពឹងទុកថាមានជំនាញលើផ្នែកនានា ដូចមាននៅក្នុងវិសាលភាពនៃសវនកម្មផ្ទៃក្នុង និងជំនាញក្នុងការគ្រប់គ្រងហានិភ័យ។

### ២) ប្រធានគណៈកម្មាធិការ

ក) ប្រធានគណៈកម្មាធិការសវនកម្ម ត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល ក្នុងចំណោមសមាជិកគណៈកម្មាធិការដែលជាអភិបាលឯករាជ្យមិនប្រតិបត្តិ។

ខ) អង្គប្រជុំគណៈកម្មាធិការត្រូវដឹកនាំដោយប្រធានគណៈកម្មាធិការ។

គ) ក្នុងករណីអវត្តមានប្រធានគណៈកម្មាធិការ ប្រធានស្តីទីគួរត្រូវបានតែងតាំងឡើងដោយសមាជិកដែលមានវត្តមាន។ ក្នុងករណីចំនួននៃការបោះឆ្នោតស្មើគ្នា ប្រធានគណៈកម្មាធិការ ឬប្រធានស្តីទីគណៈកម្មាធិការ (ក្នុងករណីប្រធានគណៈកម្មាធិការអវត្តមាន) ត្រូវធ្វើការសម្រេចចិត្តក្នុងការរាប់សម្លេងឆ្នោត ក្នុងអំឡុងពេលពិភាក្សាវែកញែក។

### ៣) រយៈពេលសមាជិកភាពនៃគណៈកម្មាធិការសវនកម្ម

អភិបាលដែលត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការសវនកម្មត្រូវរក្សាមុខងាររហូតដល់ពីរ (២) ឆ្នាំ និងអាចបន្តរយៈពេលបន្ថែមតាមការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាលអាចតែងតាំង ឬតែងតាំងសមាជិកគណៈកម្មាធិការឡើងវិញ ពីគ្រាមួយទៅគ្រាមួយ ប្រសិនបើសមស្រប។

អង្គប្រជុំ កំណត់ត្រា និង លេខាធិការ

ក) គណៈកម្មាធិការនឹងត្រូវប្រជុំប្រចាំត្រីមាស ឬពេលណាដែលចាំបាច់ ប៉ុន្តែនៅក្នុងហេតុការណ៍ណាក៏ដោយ អង្គប្រជុំមិនត្រូវតិចជាងបួន (៤) ដង ក្នុង១ឆ្នាំ ។

ខ) កូរ៉ុមនៃអង្គប្រជុំត្រូវមានយ៉ាងហោចណាស់ ៥០% នៃចំនួនសមាជិកទាំងអស់ (រាប់បញ្ចូលទាំង ប្រធានគណៈកម្មាធិការ) ឬមួយណាដែលច្រើនជាង។

គ) ការជូនដំណឹងនៃអង្គប្រជុំន ត្រូវរៀបចំមុនពេលប្រជុំ។ ការជូនដំណឹងត្រូវមានលម្អិតពីទីតាំង ថ្ងៃ និងពេលវេលានៃអង្គប្រជុំ។ របៀបវារៈនិងឯកសារសម្រាប់អង្គប្រជុំគួរត្រូវបានផ្ញើរ ដោយពេញលេញទៅកាន់សមាជិកនៃគណៈកម្មាធិការទាំងអស់ ឲ្យបានទាន់ពេលវេលា មុនថ្ងៃប្រជុំនៃគណៈកម្មាធិការ។

ឃ) គណៈកម្មាធិការក៏ត្រូវបានអនុញ្ញាតឲ្យអនុវត្តសេចក្តីសម្រេច ដោយប្រើប្រាស់សារាចរណ៍ផងដែរ។

ង) សេចក្តីសម្រេចអាចធ្វើឡើងដោយមតិភាគច្រើន (៥០% បូក ១) នៃសមាជិកទាំងអស់ដែលអាចធ្វើដោយផ្ទាល់មាត់ និងមិនផ្ទាល់មាត់។ សេចក្តីសម្រេចពិសេសអាចធ្វើឡើងតាមរយៈសារអេឡិចត្រូនិច ឬក្នុងអង្គប្រជុំ។

ច) នាយកផ្នែកនីមួយៗ និងបុគ្គលិកថ្នាក់គ្រប់គ្រងដែលពាក់ព័ន្ធ (ឬផ្នែកផ្សេងទៀត ក្នុងករណីចាំបាច់) អាចត្រូវបានអញ្ជើញឲ្យចូលរួមក្នុងអង្គប្រជុំជាមួយគណៈកម្មាធិការ។

ឆ) គណៈកម្មាធិការអាចធ្វើឡើងនៅទីកន្លែងណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ឬប្រទេសណាមួយផ្សេងទៀត។ គណៈកម្មាធិការអាចចាត់ចែងអង្គប្រជុំរបស់ខ្លួនតាមវិធីផ្សេងៗ ដែលខ្លួនយល់ថាសមស្រប អាចតាមរយៈបច្ចេកវិទ្យាទំនាក់ទំនងណាមួយ ដែលអ្នកចូលរួមក្នុងអង្គប្រជុំទាំងអស់អាចស្តាប់គ្នាលឺ ដោយមិនចាំបាច់ឲ្យសមាជិកមានវត្តមានជារាងកាយនៅក្នុងអង្គប្រជុំនោះឡើយ។ សមាជិកចូលរួមក្នុងអង្គប្រជុំនឹងត្រូវរាប់ជាកូរ៉ុមសម្រាប់កិច្ចប្រជុំ។ រាល់សេចក្តីសម្រេចដែលយល់ព្រមដោយសមាជិកនៅក្នុងអង្គប្រជុំប្រភេទនេះ នឹងមានសុពលភាពដូចគ្នានឹងសេចក្តីសម្រេចក្នុងអង្គប្រជុំធម្មតាដែរ។

ជ) សេចក្តីសម្រេច សំណើរ និងបញ្ហាផ្សេងៗ ដែលបានដាក់ជូនសម្រាប់ការអនុម័តនៅអង្គប្រជុំណាមួយរបស់គណៈកម្មាធិការ គួរត្រូវបានសម្រេចចិត្តដោយយោងតាមមតិភាគច្រើននៃសមាជិកទាំងអស់ដែលមានវត្តមាន។

## រចនាសម្ព័ន្ធនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង (ត)

ឈ) ប្រធានគណៈកម្មាធិការ នឹងត្រូវតែងតាំងនរណាម្នាក់ជាលេខាធិការ និងកត់ត្រានៃអង្គប្រជុំ។

ញ) កំណត់ត្រាអង្គប្រជុំ ត្រូវកត់ត្រា ដកស្រង់ និងសរសេរជាលាយលាក់អក្សរដោយលេខាធិការ និងលើកឡើងក្នុងរបៀបវារៈនៃអង្គប្រជុំបន្ទាប់សម្រាប់ការអនុម័ត និងចុះហត្ថលេខា។ កំណត់ត្រាអង្គប្រជុំ ត្រូវចុះហត្ថលេខាដោយប្រធាន ឬប្រធានស្តីទី (ប្រសិនបើប្រធានអវត្តមាន)។ កំណត់ត្រានៃអង្គប្រជុំគួរកត់ត្រាពីដំណើរការទាំងមូលនៃអង្គប្រជុំ រួមបញ្ចូលទាំងព័ត៌មាននៃការសំណូមពរ ការផ្តល់អនុសាសន៍ និងការព្រួយបារម្ភណាមួយរបស់សមាជិក និងឬអ្នកដែលបានអញ្ជើញចូលរួមក្នុងអំឡុងពេលពិភាក្សា និងជជែកវែកញែក។

ដ) កំណត់ត្រានៃអង្គប្រជុំគណៈកម្មាធិការសវនកម្មនីមួយៗ ត្រូវរក្សាទុក និងចែកជូនដល់សមាជិក ទាំងអស់របស់គណៈកម្មាធិការសវនកម្ម។ កំណត់ត្រានៃអង្គប្រជុំគណៈកម្មាធិការសវនកម្ម ត្រូវបានបង្ហាញនៅក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាល ហើយប្រធាន ឬប្រធានស្តីទី (ប្រសិនបើប្រធានអវត្តមាន) នៃគណៈកម្មាធិការសវនកម្ម គួររាយការណ៍លើបញ្ហាសំខាន់ៗដែលបានពិភាក្សានៅក្នុងអង្គប្រជុំគណៈកម្មាធិការទៅកាន់ក្រុមប្រឹក្សាភិបាល។

### ភាពសម្ងាត់នៃព័ត៌មាន

សមាជិកទាំងអស់នៃគណៈកម្មាធិការសវនកម្ម និងអ្នកដែលបានអញ្ជើញឲ្យចូលរួម ត្រូវចាត់ទុកព័ត៌មានដែលបានបង្ហាញនៅក្នុងនិងក្រៅអង្គប្រជុំគណៈកម្មាធិការ ជាឯកសារឯកជន និងសម្ងាត់។ ឯកសារប្រជុំត្រូវផ្តល់ឲ្យអ្នកចូលរួមអង្គប្រជុំគណៈកម្មាធិការ ជាច្បាប់បោះពុម្ព ឬសូហ្វកូពីឲ្យបានមុនពេលប្រជុំ។

### សមាសភាពនៃគណៈកម្មាធិការសវនកម្ម និងវត្តមានក្នុងការចូលរួមប្រជុំ

ក្នុងអំឡុងការិយបរិច្ឆេទនេះ ការជួបប្រជុំគណៈកម្មាធិការសវនកម្ម ត្រូវបានរៀបចំឡើងចំនួនបួន(៤) ដង។ សមាជិករបស់គណៈកម្មាធិការសវកម្មមានសមាសភាពដូចខាងក្រោម ហើយព័ត៌មានលម្អិតអំពីវត្តមានរបស់សមាជិកនីមួយៗ ក្នុងការចូលរួមអង្គប្រជុំក្នុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| សមាសភាពនៃគណៈកម្មាធិការសវនកម្ម | ចំនួននៃអង្គប្រជុំដែលបានចូលរួម |
|---|---|
| **លោកស្រី ម៉ៅ សំវុទ្ធារី**<br>*ប្រធានគណៈកម្មាធិការ ឬអភិបាលឯករាជ្យមិនប្រតិបត្តិ*<br>*តែងតាំងឡើងវិញជាប្រធានគណៈកម្មាធិការនៅថ្ងៃទី៣០ខែមករា ឆ្នាំ២០២០* | ៤/៤ |
| **Abdul Aziz Peru Mohamed**<br>*សមាជិក ឬអភិបាលឯករាជ្យមិនប្រតិបត្តិ*<br>*តែងតាំងជាសមាជិកគណៈកម្មាធិការនៅថ្ងៃទី២០ខែធ្នូ ឆ្នាំ២០១៦* | ៤/៤ |
| **Chin Yoong Kheong**<br>*សមាជិក ឬអភិបាលឯករាជ្យមិនប្រតិបត្តិ*<br>*តែងតាំងជាសមាជិកគណៈកម្មាធិការនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩* | ៤/៤ |
| **Chulapong Yukate**<br>*ប្រធានគណៈកម្មាធិការ ឬអភិបាលឯករាជ្យមិនប្រតិបត្តិ*<br>*បានលាឈប់ពីគណៈកម្មាធិការនៅថ្ងៃទី៣០ខែមករា ឆ្នាំ២០២០* | - |

អង្គប្រជុំគណៈកម្មាធិការសវនកម្ម បានចូលរួមដោយពីនាយកប្រតិបត្តិ ឬអភិបាលប្រតិបត្តិដែលដើរតួជាប្រធានគណៈកម្មាធិការសវនកម្មថ្នាក់គ្រប់គ្រង និងនាយកផ្នែកសវនកម្មផ្ទៃក្នុង។ ចំណែកឯការចូលរួមពីគណៈគ្រប់គ្រងជាន់ខ្ពស់ផ្សេងៗទៀត គឺធ្វើទៅតាមការអញ្ជើញដោយអាស្រ័យលើបញ្ហាដែលលើកយកមកពិភាក្សាដោយគណៈកម្មាធិការសវនកម្ម។

បញ្ហាសំខាន់ៗដែលបានពិភាក្សាក្នុងអង្គប្រជុំគណៈកម្មាធិការសវនកម្ម ជាមួយនឹងអនុសាសន៍ និងការសម្រេចចិត្តរបស់គណៈកម្មាធិការ ត្រូវបានសង្ខេបនិងធ្វើបទបង្ហាញជូនទៅក្រុមប្រឹក្សាភិបាលដោយប្រធានគណៈកម្មាធិការ ឬអ្នកតំណាងនៃគណៈកម្មាធិការសវនកម្ម។ ការធ្វើបែបនេះនឹងអាចជួយឲ្យក្រុមប្រឹក្សាភិបាលបានជ្រួតជ្រាបអំពីបញ្ហាសំខាន់ៗ ដែលបានពិភាក្សាក្នុងគណៈកម្មាធិការសវនកម្មបានទាន់ពេលវេលា និងសម្រាប់ឲ្យក្រុមប្រឹក្សាភិបាលធ្វើការតម្រង់ទិស ប្រសិនបើចាំបាច់។ សម្រង់សេចក្តីចេញពីកំណត់ត្រានៃអង្គប្រជុំគណៈកម្មាធិការសវនកម្មត្រូវបានផ្តល់ជូនក្រុមប្រឹក្សាភិបាលទុកជាព័ត៌មាន។

# រចនាសម្ព័ន្ធនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង (ត)

## សេចក្តីសង្ខេបពីសកម្មភាពរបស់គណៈកម្មាធិការសវនកម្មនៅឆ្នាំ ២០២០

កិច្ចការងារដែលបានអនុវត្តដោយគណៈកម្មាធិការសវនកម្ម ក្នុងការបំពេញកាតព្វកិច្ច និងការទទួល ខុសត្រូវរបស់ខ្លួន ក្នុងការិយបរិច្ឆេទត្រូវបានសង្ខេបដូចខាងក្រោម៖

### របាយការណ៍ហិរញ្ញវត្ថុ

ក) ពិនិត្យឡើងវិញលើរបាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្មប្រចាំឆ្នាំរបស់ធនាគារ ដើម្បីធានាថា របាយការណ៍ហិរញ្ញវត្ថុ និងកំណត់បង្ហាញផ្សេងៗ បានអនុលោមទៅតាមស្តង់ដារគណនេយ្យ។ ដំណើរការនៃពិនិត្យឡើងវិញមានដូចខាងក្រោម៖

- ពិនិត្យឡើងវិញលើការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ និងការដាក់ឲ្យប្រើប្រាស់នៃស្តង់ដារគណនេយ្យថ្មី ឬស្តង់ដារដែលបានធ្វើបច្ចុប្បន្នភាព និងផលប៉ះពាល់របស់វាចំពោះរបាយការណ៍ហិរញ្ញវត្ថុ។
- ពិនិត្យឡើងវិញលើរបាយការណ៍ហិរញ្ញវត្ថុ និងសុំការពន្យល់ពីគណៈគ្រប់គ្រងជាន់ខ្ពស់ក៏ដូចជាពីនាយកហិរញ្ញវត្ថុ រតនាគារ និងយុទ្ធសាស្ត្រ លើការផ្លាស់ប្តូរសំខាន់ៗរវាងអំឡុងពេលបច្ចុប្បន្ន និងអំឡុងពេលផ្ទួង ដើម្បីវាយតម្លៃភាពសមហេតុផលរបស់វា។

ខ) ពិភាក្សាជាមួយសវនករឯករាជ្យលើបញ្ហាខាងក្រោមដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្មតាមច្បាប់សម្រាប់ការិយបរិច្ឆេទនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩៖

- បញ្ហាសវនកម្ម និងគណនេយ្យសំខាន់ៗរួមបញ្ចូលទាំងឥណទាន និងការវាយតម្លៃខិនភាព។
- បញ្ហាដែលចាំបាច់ផ្សេងៗទៀត និងសេចក្តីសង្ខេបនៃការកែតម្រូវសវនកម្ម។

### សវនកម្មផ្ទៃក្នុង

ក) ពិនិត្យឡើងវិញ និងអនុម័តលើផែនការប្រចាំឆ្នាំរបស់សវនកម្មផ្ទៃក្នុងសម្រាប់ការិយបរិច្ឆេទឆ្នាំ២០២១ នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ ដើម្បីធានាលើភាពគ្រប់គ្រាន់នៃវិសាលភាព ដែនកំណត់ និងធនធានក្នុងការធ្វើសវនកម្មទៅលើផ្នែកនានាដូចដែលបានកំណត់រួច។

ខ) ពិនិត្យឡើងវិញទៅលើតម្រូវការបុគ្គលិកសវនកម្មផ្ទៃក្នុង ក្នុងនោះរួមមានជំនាញ និងសមត្ថភាពស្នូលរបស់សវនករផ្ទៃក្នុង ដើម្បីធានាឲ្យបាននូវប្រសិទ្ធភាពក្នុងការបំពេញកាតព្វកិច្ច និងទំនួលខុសត្រូវរបស់សវនកម្មផ្ទៃក្នុង។

គ) ធ្វើការវាយតម្លៃទៅលើការបំពេញការងាររបស់នាយកផ្នែកសវនកម្មផ្ទៃក្នុង និងធ្វើការអនុម័តលើការផ្តល់រង្វាន់លើកទឹកចិត្តដល់នាយកផ្នែកសវនកម្មផ្ទៃក្នុង សម្រាប់ការិយបរិច្ឆេទ២០១៩ ដោយយោងទៅតាមម៉ាទ្រីសដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

ឃ) ពិភាក្សា និងអនុម័តទៅលើសូចនាករលទ្ធផលការងារសំខាន់ៗ របស់នាយកផ្នែកសវនកម្មផ្ទៃក្នុងសម្រាប់ការិយបរិច្ឆេទ២០២០ដោយបានពិចារណាទៅលើភាពពាក់ព័ន្ធ និងភាពចាំបាច់នៃសូចនាករលទ្ធផលការងារសំខាន់ៗ ដែលបានកំណត់។

ង) ពិនិត្យឡើងវិញ និងពិភាក្សាលើកំណត់ត្រាអង្គប្រជុំគណៈកម្មាធិការសវនកម្មថ្នាក់គ្រប់គ្រង របាយការណ៍សវនកម្មផ្ទៃក្នុង អនុសាសន៍របស់សវនករផ្ទៃក្នុង និងការឆ្លើយតបរបស់គណៈគ្រប់គ្រង ក៏ដូចជាសកម្មភាពនានាដែលបានអនុវត្តដោយគណៈគ្រប់គ្រង ដើម្បីធ្វើការកែលំអប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងដំណើរការរបស់ខ្លួន លើផ្នែកដែលបានលើកឡើង។

ច) ពិនិត្យឡើងវិញលើរបាយការណ៍ត្រួតពិនិត្យដែលចេញដោយអាជ្ញាធរបទប្បញ្ញត្តិ និងការឆ្លើយតបរបស់គណៈគ្រប់គ្រង ក៏ដូចជាសកម្មភាពកែតម្រូវដែលបានអនុវត្តដោយគណៈគ្រប់គ្រងពាក់ព័ន្ធនឹងគំហើញដែលបានរាយការណ៍ ដើម្បីធានាឲ្យបានថារាល់បញ្ហាទាំងអស់ដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ ត្រូវបានដោះស្រាយដោយគណៈគ្រប់គ្រងយ៉ាងគ្រប់គ្រាន់ និងទាន់ពេលវេលា។

ឆ) ពិនិត្យឡើងវិញ និងធ្វើការកត់សម្គាល់លើការតាមដានចំពោះការកែតម្រូវនៃគំហើញសវនកម្មផ្ទៃក្នុង ដើម្បីធានាថារាល់គំហើញទាំងអស់ត្រូវបានដោះស្រាយដោយមានប្រសិទ្ធភាព និងទាន់ពេលវេលា។

### សវនកម្មឯករាជ្យ

ក) ពិនិត្យឡើងវិញលើផែនការសវនកម្មឆ្នាំ២០២០របស់សវនករឯករាជ្យនៅក្នុងអង្គប្រជុំគណៈកម្មាធិការសវនកម្មដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០គ្របដណ្តប់លើយុទ្ធសាស្ត្រនៃការធ្វើសវនកម្ម ការវាយតម្លៃលើហានិភ័យ និងផ្នែកដែលសវនកម្មនឹងសង្កត់ធ្ងន់នៅក្នុងឆ្នាំ។

ខ) ពិនិត្យឡើងវិញជាមួយសវនករឯករាជ្យ លើលទ្ធផលនៃសវនកម្ម រួមជាមួយនឹងការផ្តល់ អនុសាសន៍ និងការឆ្លើយតបរបស់គណៈគ្រប់គ្រងទៅនឹងគំហើញ ក៏ដូចជាលើការផ្តល់នូវទស្សនៈ វិស័យ និងទិសដៅចំពោះផ្នែកដែលមានការព្រួយបារម្ភ ប្រសិនបើចាំបាច់។

គ) បានជួបពិភាក្សាជាមួយសវនករឯករាជ្យនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ដោយមិនមានវត្តមានគណៈគ្រប់គ្រង ឬអភិបាលប្រតិបត្តិ ដើម្បីអាចឲ្យសវនករឯករាជ្យធ្វើការពិភាក្សាទៅលើបញ្ហាមួយចំនួនជាមួយគណៈកម្មាធិការសវនកម្មជាឯកជន។

ឃ) ពិនិត្យឡើងវិញលើការបំពេញការងារ និងឯករាជ្យភាពរបស់សវនករឯករាជ្យ មុនពេលណែនាំពួកគេជូនទៅក្រុមប្រឹក្សាភិបាល ធ្វើការតែងតាំងឡើងវិញជាសវនករឯករាជ្យសម្រាប់ធនាគារ។

## រចនាសម្ព័ន្ធនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង (ត)

### ប្រតិបត្តិការសម្ព័ន្ធញាតិ

ក ) ពិនិត្យលើប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងភាពសមស្របនៃនិតិវិធីរបស់ធនាគារនៅក្នុងការកំណត់ តាមដាន រាយការណ៍ និងពិនិត្យឡើងវិញលើប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ។

## ការត្រួតពិនិត្យអចិន្ត្រៃយ៍

នាយកដ្ឋានដែលប្រឈមនឹងហានិភ័យ ត្រូវទទួលខុសត្រូវលើការគ្រប់គ្រងហានិភ័យដែលអាចបណ្តាលមកពីសកម្មភាពអាជីវកម្មរបស់ខ្លួនជាប្រចាំ។ ផ្នែកគ្រប់គ្រងហានិភ័យមានតួនាទីត្រួតពិនិត្យលើហានិភ័យសំខាន់ៗ ដើម្បីធ្វើអោយប្រាកដថាគោលនយោបាយហានិភ័យស្នូលត្រូវបានអនុវត្តបានត្រឹមត្រូវ និងត្រួតពិនិត្យលើការអនុវត្តគោលនយោបាយហានិភ័យផ្សេងៗ ព្រមទាំងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

មុខងារប្រតិបត្តិតាម ត្រូវទទួលខុសត្រូវលើការវាយតម្លៃ និងពិនិត្យឡើងវិញនូវហានិភ័យប្រតិបត្តិតាម បង្កើតនិងពិនិត្យឡើងវិញនូវគោលនយោបាយ គោលការណ៍ណែនាំ វិធីសាស្រ្ត មធ្យោបាយ និងទម្រង់ហានិភ័យប្រតិបត្តិតាមទៅតាមច្បាប់និងបទប្បញ្ញត្តិ ដើម្បីបញ្ជាក់ថាគោលនយោបាយ គោលការណ៍ណែនាំ វិធីសាស្រ្ត មធ្យោបាយ និងទម្រង់ទាំងនេះនៅតែត្រឹមត្រូវ និងមានបច្ចុប្បន្នភាពតាមដានការប្រតិបត្តិតាមរបស់ធនាគារ ហើយរាយការណ៍រាល់គំហើញទៅកាន់ថ្នាក់គ្រប់គ្រង ឬក្រុមប្រឹក្សាភិបាល និងរក្សានូវការត្រួតពិនិត្យ និងការរាយការណ៍ទៅលើការអនុលោមតាមច្បាប់ ក្បួនច្បាប់ គោលនយោបាយ និងស្តង់ដារផ្សេងៗដោយឯករាជ្យភាព។

មុខងារត្រួតពិនិត្យអចិន្ត្រៃយ៍ត្រូវរាយការណ៍ដោយផ្ទាល់ទៅកាន់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ដែលគណៈកម្មាធិការនេះមានតួនាទី និងទំនួលខុសត្រូវក្នុងការត្រួតពិនិត្យ ដើម្បីធានាថាសកម្មភាពអាជីវកម្មនិងប្រតិបត្តិការណ៍របស់ធនាគារដោយរួមបញ្ចូលទាំងសកម្មភាព និងផលិតផលថ្មីៗ ស្របតាមរីសអាប់ភែថាយ (Risk Appetite) គោលដៅយុទ្ធសាស្រ្តសម្រាប់រយៈពេលខ្លី និងរយៈពេលវែងដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល។

សម្រាប់ដំណើរការនិងការពង្រីកអាជីវកម្មរបស់ខ្លួន ធនាគារប្តេជ្ញាលើកស្ទួយ និងអនុវត្តតាមគោលការណ៍អភិបាលកិច្ចល្អ តម្រូវការបទប្បញ្ញត្តិ និងការអនុវត្តអន្តរជាតិល្អបំផុត។ ជាមគ្គុទ្ទេសដ៏សំខាន់សម្រាប់ធនាគារ ដើម្បីបំពេញតាមតម្រូវការដែលកាន់តែច្រើនឡើងៗ ក្នុងការអនុវត្តការប្រតិបត្តិតាមដែលល្អបំផុតនៅក្នុងប្រតិបត្តិការអាជីវកម្មរបស់ធនាគារ។ ក្របខ័ណ្ឌ គោលនយោបាយ នីតិវិធី និងសេចក្តីណែនាំប្រតិបត្តិការរបស់ធនាគារទាក់ទងនឹងមុខងារគ្រប់គ្រងអចិន្ត្រៃយ៍ត្រូវបានបង្កើត និងធ្វើការពិនិត្យឡើងវិញជាទៀងទាត់ដោយធនាគារ។

### ការត្រួតពិនិត្យប្រចាំគ្រា (សវនកម្មផ្ទៃក្នុង)

ធនាគារមាននាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ខ្លួន គោរពតាមលក្ខន្តិកៈសវនកម្មផ្ទៃក្នុង ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងក្របខ័ណ្ឌការអនុវត្តវិជ្ជាជីវៈអន្តរជាតិចុងក្រោយនៃវិទ្យាស្ថានសវនករផ្ទៃក្នុង។ តួនាទីចំបងរបស់សវនកម្មផ្ទៃក្នុងគឺ ផ្តល់ការវាយតម្លៃដោយឯករាជ្យទៅលើភាពគ្រប់គ្រាន់និងប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យរបស់ធនាគារ ដំណើរការនៃការត្រួតពិនិត្យ ផ្ទៃក្នុង និងអភិបាលកិច្ចដែលបានអនុវត្តដោយគណៈគ្រប់គ្រង។ នាយកផ្នែកសវនកម្មផ្ទៃក្នុងរាយការណ៍ដោយផ្ទាល់ទៅកាន់គណៈកម្មាធិការសវនកម្ម និងរាយការណ៍តាមបែបបទរដ្ឋបាលជូនទៅនាយកប្រតិបត្តិ ឬអភិបាលប្រតិបត្តិ។ ដើម្បីការពារបន្ថែមលើឯករាជ្យភាពរបស់សវនកម្មផ្ទៃក្នុង ការតែងតាំង និងការវាយតម្លៃលើលទ្ធផលការងាររបស់នាយកផ្នែកសវនកម្មផ្ទៃក្នុង ក៏ដូចជាវិសាលភាពការងារ និងធនធានរបស់សវនកម្មផ្ទៃក្នុង ត្រូវបានអនុម័តដោយគណៈកម្មាធិការសវនកម្ម។

ចក្រវាឡសវនកម្មផ្ទៃក្នុង (internal audit universe) គ្របដណ្តប់លើសកម្មភាពគន្លិះសំខាន់ៗរបស់ធនាគាររួមមាន សាខា នាយកដ្ឋាន ព្រមទាំងមុខងារទាំងអស់ដែលមាននៅក្នុងធនាគារ។ សវនកម្មផ្ទៃក្នុងប្រើប្រាស់វិធីសាស្រ្តផ្អែកលើហានិភ័យក្នុងការកំណត់នូវផ្នែកដែលត្រូវធ្វើសវនកម្ម និងភាពញឹកញយនៃសវនកម្មឲ្យស្របទៅតាមហានិភ័យសំខាន់ៗ យុទ្ធសាស្រ្ត និងផ្នែកនៃការផ្តោតអារម្មណ៍របស់ធនាគារ ដែលបានកំណត់ដោយផ្អែកតាមវីធីសាស្រ្តវាយតម្លៃហានិភ័យរបស់សវនកម្មផ្ទៃក្នុង។

ផ្នែកដែលនឹងត្រូវធ្វើសវនកម្មត្រូវបានកត់ត្រានៅក្នុងផែនការសវនកម្ម ដែលបានធ្វើឡើងតាមវិធីសាស្រ្តផ្អែកលើហានិភ័យ ហើយត្រូវបានអនុម័តជារៀងរាល់ឆ្នាំដោយគណៈកម្មាធិការសវនកម្ម។ របាយការណ៍សវនកម្មដែលរួមមាន គំហើញសវនកម្មលម្អិត អនុសាសន៍ និងការណែនាំរបស់សវនកម្មផ្ទៃក្នុង និងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង ត្រូវបានដាក់ជូនទៅគណៈកម្មាធិការសវនកម្មថ្នាក់គ្រប់គ្រងជាប្រចាំ និងគណៈកម្មាធិការសវនកម្មតាមត្រីមាស។

គណៈកម្មាធិការសវនកម្មថ្នាក់គ្រប់គ្រងដែលបានបង្កើតឡើង ត្រូវបានប្រគល់ភារកិច្ចដើម្បីធានាថារាល់បញ្ហាដែលបានលើកឡើងដោយសវនករផ្ទៃក្នុង សវនករឯករាជ្យ និងនិយ័តករ ត្រូវបានឆ្លើយតបយ៉ាងសមស្រប តាមពេលវេលាដែលបានព្រមព្រៀង។ ការបញ្ជាក់លើប្រសិទ្ធភាពនេះត្រូវតែផ្តល់ដោយគណៈគ្រប់គ្រងទៅកាន់សវនកម្មផ្ទៃក្នុង សម្រាប់ធ្វើការផ្ទៀងផ្ទាត់មុនពេលដែលបញ្ហាទាំងនោះ អាចត្រូវបានបិទបញ្ចប់នៅក្នុងអង្គប្រជុំគណៈកម្មាធិការសវនកម្មថ្នាក់គ្រប់គ្រង។

### លក្ខន្តិកៈសវនកម្មផ្ទៃក្នុង

លក្ខន្តិកៈសវនកម្មផ្ទៃក្នុង កំណត់នូវគោលបំណង សិទ្ធិអំណាច និងទំនួលខុសត្រូវនៃមុខងារសវនកម្មផ្ទៃក្នុង ហើយត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល។ លក្ខន្តិកៈសវនកម្មដែលបានអនុម័តរួច ត្រូវបានផ្សព្វផ្សាយក្នុងប្រព័ន្ធកុំព្យូទ័រផ្ទៃក្នុងរបស់ធនាគារ ដែលបុគ្គលិកទាំងអស់នៅក្នុងធនាគារអាចចូលមើលបាន។

លក្ខន្តិកៈសវនកម្មត្រូវបានពិនិត្យឡើងវិញដោយនាយកផ្នែកសវនកម្មផ្ទៃក្នុងរៀងរាល់២ឆ្នាំម្តង ឬនៅពេលណាដែលចាំបាច់ ដើម្បីវាយតម្លៃថាតើគោលបំណងសិទ្ធិអំណាច និងទំនួលខុសត្រូវរបស់សវនកម្មផ្ទៃក្នុងដែលបានកំណត់ក្នុងលក្ខន្តិកៈនៅតែគ្រប់គ្រាន់និងពាក់ព័ន្ធ ដើម្បីធ្វើឲ្យមុខងារសវនកម្មសម្រេចបាននូវគោលបំណងរបស់ខ្លួន។

## ការត្រួតពិនិត្យអចិន្ត្រៃយ៍ (ត)

### ធនធានសវនកម្មផ្ទៃក្នុង

នាយកផ្នែកសវនកម្មផ្ទៃក្នុង ធ្វើការពិភាក្សាជាមួយគណៈកម្មាធិការសវនកម្ម និងនាយកប្រតិបត្តិ ឬអភិបាលប្រតិបត្តិ ក្នុងការសម្រេចចិត្តលើធនធានដែលខ្លួនត្រូវការឲ្យបានសមស្របសម្រាប់សវនកម្មផ្ទៃក្នុង ដោយពិចារណាទៅលើទំហំ និងភាពស្មុគស្មាញនៃប្រតិបត្តិការរបស់ធនាគារ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ សវនកម្មផ្ទៃក្នុងមានសវនករប្រាំពីរ (៧) នាក់ ដែលមានគុណវុឌ្ឍិការសិក្សា ឬវិជ្ជាជីវៈ និងបទពិសោធន៍ពាក់ព័ន្ធដើម្បីអនុវត្តមុខងារសវនកម្មផ្ទៃក្នុង។ ការចំណាយដែលបានកើតឡើងសម្រាប់រក្សាឲ្យមានមុខងារសវនកម្មផ្ទៃក្នុង ក្នុងការិយបរិច្ឆេទឆ្នាំ២០២០ មានចំនួន ១៦៨.១៦២ ដុល្លារអាមេរិក។

### ជំនាញវិជ្ជាជីវៈ

នាយកផ្នែកសវនកម្មផ្ទៃក្នុង ធានាថាសវនករផ្ទៃក្នុងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងបានផ្តល់នូវការបណ្តុះបណ្តាលដែលចាំបាច់ និងធ្វើការអភិវឌ្ឍន៍វិជ្ជាជីវៈជាបន្តបន្ទាប់ ក្នុងគោលបំណងបង្កើនជំនាញ និងបច្ចេកទេសសវនកម្មដើម្បីបំពេញភារកិច្ច និងទំនួលខុសត្រូវរបស់ពួកគេ។

ផ្អែកលើផែនការអភិវឌ្ឍន៍របស់បុគ្គលិកម្នាក់ៗសម្រាប់ឆ្នាំ២០២០សវនករផ្ទៃក្នុងបានចូលរួមកម្មវិធីបច្ចេកទេសដែលពាក់ព័ន្ធ ក៏ដូចជាកម្មវិធីភាពជាអ្នកដឹកនាំ និងគ្រប់គ្រង ដែលផ្តល់ដោយ អ អេច ប៊ី អាខាដេមី (RHB Academy) ដែលជាមជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍របស់សម្ព័ន្ធ និងកម្មវិធីសិក្សាពីខាងក្រៅផ្សេងៗទៀតដែលបានផ្តល់ដោយវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ។

### ការពិនិត្យលើការធានាគុណភាពសវនកម្មផ្ទៃក្នុង

ដើម្បីធានាបាននូវប្រសិទ្ធភាពនៃមុខងារសវនកម្មផ្ទៃក្នុង សវនកម្មផ្ទៃក្នុងសម្ព័ន្ធបានបង្កើត និងរក្សាកម្មវិធីធានានិងកែលម្អគុណភាព ដែលគ្របដណ្តប់លើគ្រប់ទិដ្ឋភាពនៃសកម្មភាពសវនកម្មផ្ទៃក្នុងនៅក្នុងសម្ព័ន្ធ។ កម្មវិធីធានាគុណភាពវាយតម្លៃប្រសិទ្ធភាពនៃដំណើរការនៅក្នុងមុខងារសវនកម្មផ្ទៃក្នុង និងកំណត់ឱកាសសំរាប់កែលម្អតាមរយៈការវាយតម្លៃពីខាងក្នុងនិងខាងក្រៅ។

ការវាយតម្លៃផ្ទៃក្នុង ត្រូវធ្វើឡើងដោយក្រុមពិនិត្យលើការធានាគុណភាពនៅក្នុងសវនកម្មផ្ទៃក្នុងសម្ព័ន្ធ ដោយយោងទៅតាមផែនការពិនិត្យលើការធានាគុណភាពប្រចាំឆ្នាំដែលបានអនុម័តរួច។ នាយករបស់មុខងារពិនិត្យលើការធានាគុណភាពរាយការណ៍ដោយផ្ទាល់ទៅនាយកសវនកម្មផ្ទៃក្នុងសម្ព័ន្ធ ដើម្បីរក្សាឯករាជ្យភាពនៃសកម្មភាពសវនកម្មផ្ទៃក្នុងនៅក្នុងសវនកម្មផ្ទៃក្នុងសម្ព័ន្ធ។

បន្ថែមលើការវាយតម្លៃផ្ទៃក្នុង ការវាយតម្លៃគុណភាពឯករាជ្យត្រូវបានធ្វើឡើងរៀងរាល់បីឆ្នាំម្តងដោយអ្នកជំនាញដែលមានសមត្ថភាព។ ការតែងតាំងអ្នកត្រួតពិនិត្យឯករាជ្យគឺស្ថិតនៅក្រោមដំណើរការលទ្ធកម្មដែលបានបង្កើតឡើងដោយសម្ព័ន្ធ ហើយបានអនុម័តដោយគណៈកម្មាធិការសវនកម្មសម្ព័ន្ធ។ ការវាយតម្លៃគុណភាពឯករាជ្យគ្របដណ្តប់លើវិសាលភាពទូលំទូលាយដែលរួមមានការអនុលោមតាមនិយមន័យនៃសវនកម្មផ្ទៃក្នុង បទដ្ឋាននិងក្រមសីលធម៌ និងលក្ខន្តិកៈសវនកម្មផ្ទៃក្នុង ផែនការសវនកម្ម គោលនយោបាយនិងនីតិវិធីស្របតាមតម្រូវការនៃស្តង់ដារអន្តរជាតិសម្រាប់វិជ្ជាជីវៈនៃសវនកម្មផ្ទៃក្នុង សេចក្តីណែនាំបទប្បញ្ញត្តិ និងការអនុវត្តក្នុងឧស្សាហកម្មដែលល្អបំផុត។ លទ្ធផលនៃការពិនិត្យឡើងវិញដោយអ្នកត្រួតពិនិត្យឯករាជ្យត្រូវបានចងក្រងជាឯកសារនៅក្នុងរបាយការណ៍ដែលបានដាក់ជូនទៅគណៈកម្មាធិការសវនកម្ម។

### សេចក្តីសង្ខេបនៃសកម្មភាពសវនកម្មផ្ទៃក្នុង

ខាងក្រោមនេះជាសេចក្តីសង្ខេបនៃសកម្មភាពសំខាន់ៗ ដែលបានអនុវត្តដោយសវនករផ្ទៃក្នុងនៅក្នុងការិយបរិច្ឆេទ៖

ក) រៀបចំផែនការសវនកម្មដែលផ្អែកលើហានិភ័យប្រចាំឆ្នាំ សម្រាប់ធនាគារ ដែលរួមបញ្ចូលទាំង គោលបំណងនិងវិសាលភាពសវនកម្ម និងតម្រូវការកម្លាំងពលកម្ម សម្រាប់ផែនការសវនកម្មនីមួយៗដែលបានគ្រោងទុក។

ខ) អនុវត្តភារកិច្ចសវនកម្មទៅតាមផែនការសវនកម្មដែលបានអនុម័ត និងបានផ្តល់នូវការវាយតម្លៃ និងការធានាលើភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ចរបស់អង្គភាពដែលបានធ្វើសវនកម្ម។

គ) ធ្វើសវនកម្មលើផ្នែកសំខាន់ៗនៅក្នុងការិយបរិច្ឆេទរួមមាន សាខា នាយកដ្ឋានទីផ្សារនិងទំនាក់ទំនង នាយកដ្ឋានហិរញ្ញវត្ថុ រតនាគារនិងយុទ្ធសាស្ត្រ នាយកដ្ឋានផ្នែកច្បាប់និងលេខាធិការ នាយកដ្ឋានអភិវឌ្ឍន៍និងគ្រប់គ្រងផលិតផល នាយកដ្ឋានប្រតិបត្តិការ រួមទាំងប្រតិបត្តិការនិងការគ្រប់គ្រងព័ត៌មានវិទ្យា។

ឃ) ធ្វើការតាមដាននិងក្រើនរំលឹក តាមរយៈអង្គប្រជុំគណៈកម្មាធិការសវនកម្មផ្ទៃក្នុងថ្នាក់គ្រប់គ្រង ទៅលើការកែតម្រូវឲ្យបានទាន់ពេលវេលាចំពោះគំហើញសវនកម្ម ដែលបានរាយការណ៍ណាមួយ និងបុព្វហេតុមូលដ្ឋានមួយចំនួនដែលបានលើកឡើងដោយសវនករផ្ទៃក្នុង។ ស្ថានភាពនៃគំហើញដែលមិនទាន់ដោះស្រាយរួច ត្រូវបានសង្ខេប និងរាយការណ៍ទៅកាន់គណៈកម្មាធិការសវនកម្មរៀងរាល់ត្រីមាស។

ង) ពិនិត្យលើគោលនយោបាយ នីតិវិធី និងដំណើរការថ្មីៗ ឬដែលបានធ្វើបច្ចុប្បន្នភាពរួច ទៅតាមសំណើររបស់គណៈគ្រប់គ្រង ក្នុងការផ្តល់ជាមតិយោបល់ទៅលើភាពគ្រប់គ្រាន់នៃការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីកាត់បន្ថយហានិភ័យដែលពាក់ព័ន្ធ។

ច) បានចូលរួមសកម្មភាពផ្សេងៗក្នុងការអភិវឌ្ឍន៍ប្រព័ន្ធនិងផលិតផលដើម្បីផ្តល់អនុសាសន៍ជាមុន លើទិដ្ឋភាពនៃការត្រួតពិនិត្យដែលពាក់ព័ន្ធទៅថ្នាក់គ្រប់គ្រងដើម្បីធ្វើការពិចារណា។

ឆ) ចូលរួមអង្គប្រជុំថ្នាក់គ្រប់គ្រង ក្នុងនាមជាអ្នកអញ្ជើញឲ្យចូលរួមអចិន្ត្រៃយ៍ក្នុងមុខងារពិគ្រោះនិងប្រឹក្សា ដើម្បីផ្តល់មតិយោបល់ឯករាជ្យពាក់ព័ន្ធលើការត្រួតពិនិត្យផ្ទៃក្នុងបើចាំបាច់។

ជ) រៀបចំអង្គប្រជុំគណៈកម្មាធិការសវនកម្មថ្នាក់គ្រប់គ្រង រៀបចំឯកសារសម្រាប់អង្គប្រជុំ ក៏ដូចជាកំណត់ត្រានៃអង្គប្រជុំ សម្រាប់ដាក់ជូនគណៈកម្មាធិការសវនកម្ម។

## ការត្រួតពិនិត្យអចិន្ត្រៃយ៍ (ត)

ឈ) ធ្វើការរៀបចំរបាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំ សម្រាប់ដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំ និងផ្ញើជូនធនាគារជាតិនៃកម្ពុជាសម្រាប់ឆ្នាំ ២០១៩។

## សកម្មភាព និងសេវាកម្មផ្តល់ដោយតតិយភាគី

គោលនយោបាយតតិយភាគីនេះ ដាក់ចេញនូវវិធីសាស្ត្រជាប់លាប់មួយសម្រាប់គ្រប់គ្រង និងកាត់បន្ថយហានិភ័យដែលកើតចេញពីសកម្មភាពផ្តល់សេវាកម្មដោយតតិយភាគីនៅក្នុងធនាគារទាំងមូល ស្របទៅតាមស្តង់ដារបញ្ញត្តិដែលពាក់ព័ន្ធផ្សេងៗ។ សកម្មភាពរបស់តតិយភាគីត្រូវបានកំណត់ដូចខាងក្រោម៖

- ការរៀបចំតតិយភាគីត្រូវបានកំណត់ថា ជាការរៀបចំដែលអ្នកផ្តល់សេវាកម្មធ្វើសកម្មភាពជំនួសឲ្យធនាគារ (ដូចជា ប្រតិបត្តិការរបស់ធនាគារ ដំណើរការ និងមុខងារ -ល-) ជាបន្តបន្ទាប់តាមថ្លៃឈ្នួលដែលបានកំណត់មុន ដែលសកម្មភាពទាំងនោះត្រូវបានធ្វើឡើងជាធម្មតា ឬអាចធ្វើឡើងបានដោយធនាគារ។
- សកម្មភាពដែលធ្វើឡើងដោយអ្នកផ្តល់សេវាកម្ម អាចពាក់ព័ន្ធទៅនឹងការផ្ទេរកម្មសិទ្ធិឬព័ត៌មាន អតិថិជនរបស់ធនាគារ ដំណើរការ និងឬដំណើរការផ្ទៃក្នុងរបស់ធនាគារ នីតិវិធី ឬបច្ចេកវិទ្យាដែលត្រូវបានទំនាក់ទំនងទៅអ្នកផ្តល់សេវាកម្ម។

យោងតាមគោលនយោបាយតតិយភាគី គោលការណ៍អភិបាលកិច្ចសម្រាប់តតិយភាគីមានដូចតទៅ៖

**គោលការណ៍ទី១៖** ធនាគារត្រូវតែរក្សាទំនួលខុសត្រូវខ្ពស់បំផុតចំពោះសកម្មភាពរបស់តតិយភាគី។

ក) ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់ជាអ្នកទទួលខុសត្រូវទៅលើការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ចំពោះហានិភ័យដែលកើតឡើងពីសកម្មភាពរបស់តតិយភាគី។

ខ) ម្ចាស់សេវាកម្មរៀងៗខ្លួននៅក្នុងធនាគារជាអ្នកទទួលខុសត្រូវខ្ពស់បំផុតសម្រាប់សកម្មភាពរបស់តតិយភាគី និងលទ្ធកម្មនៃការប្រាស្រ័យទាក់ទងសេវាកម្ម។ ការទទួលខុសត្រូវនេះរួមបញ្ចូលនូវការធានាឲ្យបាននូវការប្រតិបត្តិតាមបទប្បញ្ញត្តិ និងតម្រូវការផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការផ្តល់សេវាកម្មដោយតតិយភាគី។

គ) ម្ចាស់សេវាកម្មត្រូវបង្ហាញនូវករណីអាជីវកម្ម ឬយុត្តិកម្ម ដើម្បីគាំទ្រឲ្យបានពេញលេញនូវតម្រូវការក្នុងការស្នើសុំការរៀបចំសេវាកម្មផ្តល់ដោយតតិយភាគី។

ឃ) ការប្រគល់ទំនួលខុសត្រូវឲ្យបានសមស្របនៅក្នុងធនាគារ គួរតែបង្កើតឡើងដើម្បីគ្រប់គ្រង ការផ្តល់សេវាកម្មដោយតតិយភាគី រួមបញ្ចូលការអភិវឌ្ឍន៍គោលនយោបាយដើម្បីគ្រប់គ្រងសកម្មភាពរបស់តតិយភាគី។

**គោលការណ៍ទី២៖** សកម្មភាពរបស់តតិយភាគីត្រូវទទួលបានការវាយតម្លៃឲ្យបានគ្រប់គ្រាន់។

ក) ម្ចាស់សេវាកម្មត្រូវធ្វើការវាយតម្លៃឲ្យបានគ្រប់គ្រាន់ ទៅលើសកម្មភាពផ្តល់ដោយតតិយភាគី រួមមានលទ្ធភាព ឬអត្ថប្រយោជន៍ ភាពងាយរងគ្រោះដែលមានសក្តានុពល ការវាយតម្លៃ ហានិភ័យ ការវាយតម្លៃទៅលើសារវន្តភាព ការប្រតិបត្តិតាមការណែនាំ ឬគោលនយោបាយផ្ទៃក្នុងពាក់ព័ន្ធផ្សេងៗ (ដូចជា គោលនយោបាយសន្តិសុខព័ត៌មានវិទ្យារបស់ធនាគារ) និងការយកចិត្តទុកដាក់ស្គាល់អ្នកផ្តល់សេវាកម្ម។

ខ) ការយកចិត្តទុកដាក់ស្គាល់អ្នកផ្តល់សេវាកម្ម សម្រាប់ដំណើរការជ្រើសរើសត្រូវតែស្ថិតក្រោមទម្រង់ប្រកបដោយនីតិវិធី តម្លាភាព និងភាពយុត្តិធម៌ រួមបញ្ចូលការពិចារណាទៅលើកិច្ចសន្យាបន្តណាមួយរបស់អ្នកផ្តល់សេវាកម្ម។

គ) វិសាលភាព និងភាពស៊ីជម្រៅនៃការវាយតម្លៃអាចខុសគ្នាទៅតាមលក្ខណៈនៃការរៀបចំ សេវាកម្មដោយតតិយភាគី (ឧទាហរណ៍ដូចជាសារៈសំខាន់ និងភាពស្មុគស្មាញរបស់វា) និងបទប្បញ្ញត្តិផ្សេងៗ។

ឃ) ការវាយតម្លៃចាំបាច់ត្រូវធ្វើឡើងឲ្យទាន់ពេលវេលា ដូចជាមុនពេលណាត់ជួបដែលជាផ្នែកមួយនៃដំណើរការជ្រើសរើស និងមុនពេលបន្តសារជាថ្មីសម្រាប់អ្នកផ្តល់សេវាកម្មដែលមានស្រាប់ ដែលជាផ្នែកមួយនៃដំណើរការនៃការពិចារណា ហើយព័ត៌មានសម្រាប់ធ្វើការវាយតម្លៃត្រូវបានដាក់បញ្ចូលក្នុងលិខិតស្នើសុំ។

**គោលការណ៍ទី៣៖** ការរៀបចំសេវាកម្មផ្តល់ដោយតតិយភាគីជាមួយអ្នកផ្តល់សេវាកម្មត្រូវតែធ្វើឡើងដោយកិច្ចសន្យា។

ក) ធនាគារត្រូវមានកិច្ចសន្យាចងក្រងស្របច្បាប់ និងមានកំណត់ថេរវេលា ជាមួយអ្នកផ្តល់ សេវាកម្ម ដូចជាកិច្ចព្រមព្រៀងកម្រិតសេវាកម្ម កិច្ចសន្យាសេវាកម្ម លិខិតនៃការផ្តល់កិច្ចសន្យា -ល-។

ខ) កិច្ចសន្យាត្រូវទទួលបានការពិគ្រោះផ្នែកច្បាប់ និងត្រួតពិនិត្យដោយភាគីពាក់ព័ន្ធឲ្យបានគ្រប់គ្រាន់ ដើម្បីឲ្យប្រាកដថាកិច្ចសន្យាមានភាពល្អិតល្អន់ ប្រតិបត្តិតាមគោលការណ៍ណែនាំផ្ទៃក្នុងដែលពាក់ព័ន្ធ ការពារនូវផលប្រយោជន៍របស់ធនាគារ និងបត់បែនទៅតាមការផ្លាស់ប្តូរ។ កិច្ចសន្យាត្រូវចងក្រងឲ្យច្បាស់លាស់នូវបញ្ហាដែលពាក់ព័ន្ធ (អាចខុសគ្នារវាងការផ្តល់សេវាកម្មដោយតតិយភាគី និងលទ្ធកម្មនៃសេវាកម្ម) រួមមានកម្រិតនៃសេវាកម្ម សិទ្ធិ ការទទួលខុសត្រូវ ការរក្សាព័ត៌មានដោយសម្ងាត់ ថ្លៃឈ្នួល ការរៀបចំប្រតិបត្តិការ និរន្តរភាពអាជីវកម្ម ការបញ្ចប់កិច្ចសន្យា សិទ្ធិក្នុងការធ្វើសវនកម្ម កិច្ចសន្យាបន្ត ការរាយការណ៍ពីបញ្ហា និងដំណោះស្រាយ។

គ) ម្ចាស់សេវាកម្មត្រូវធានាថា កិច្ចសន្យាត្រូវបានធ្វើឡើងមុនពេលចាប់ផ្តើមនៃសេវាកម្ម បន្ទាប់ពីទទួលបាននូវការអនុម័តផ្សេងៗ។

## សកម្មភាព និងសេវាកម្មផ្តល់ដោយតតិយភាគី (ត)

**គោលការណ៍ទី៤៖** ការរៀបចំយថាភាពត្រូវតែបង្កើតឡើង ដើម្បីធានានូវនិរន្តរភាពអាជីវកម្ម។

ក ) ការរៀបចំយថាភាពត្រូវបង្កើតឡើង ដើម្បីគ្រប់គ្រងការរំខានដែលកើតមកពីការបរាជ័យដែលអាចកើតមានឡើងរបស់អ្នកផ្តល់សេវាកម្ម ក្នុងការផ្តល់សេវាកម្មសម្រាប់ធនាគារដែលត្រូវបញ្ចូលក្នុងសំណើរសម្រាប់ការអនុម័ត។

ខ ) ម្ចាស់សេវាកម្មត្រូវពិនិត្យឡើងវិញ និងធានាថាកាតព្វកិច្ចរបស់អ្នកផ្តល់សេវាកម្មត្រូវបានដាក់ចេញនូវវិធានការចាំបាច់ ដើម្បីធានានូវការបន្តនៃការផ្តល់សេវាកម្មរបស់ពួកគេក្នុងអំឡុងពេលមានការរំខាន រួមបញ្ចូលទាំងការធ្វើតេស្តទៅលើផែនការនិរន្តរភាពអាជីវកម្ម។

គ ) ផែនការយថាភាព រួមបញ្ចូលទាំងការធានាថា ផែនការចាំបាច់ដែលត្រូវបានអភិវឌ្ឍដើម្បីគ្រប់គ្រងការបញ្ឈប់អ្នកផ្តល់សេវាកម្មភ្លាមៗ និងឬការគ្រប់គ្រងទៅលើការបញ្ចប់សេវាកម្ម។

ឃ ) ម្ចាស់សេវាកម្មត្រូវធានាផងដែរថា ផែនការនិរន្តរភាពអាជីវកម្មរបស់ខ្លួនត្រូវបានដាក់បញ្ចូលក្នុងដំណើរការពាក់ព័ន្ធនឹងសកម្មភាពរបស់តតិយភាគី។

**គោលការណ៍ទី៥៖** ការតាមដាន និងគ្រប់គ្រងជាបន្តបន្ទាប់ទៅលើអ្នកផ្តល់សេវាកម្មត្រូវតែមានជាចាំបាច់។

ក ) ម្ចាស់សេវាកម្មត្រូវតែជាអ្នកតាមដាន និងគ្រប់គ្រងជួរទី១ លើអ្នកផ្តល់សេវាកម្ម ក្រោមការមើលខុសត្រូវរបស់ពួកគេ ដើម្បីធានានូវការអនុវត្តទៅតាមកម្រិតសេវាកម្មដែលព្រមព្រៀងរួច ( ឧទាហរណ៍៖ ការតាមដានលើការបំពេញការងារ ) ដែលរួមបញ្ចូលសកម្មភាពចាំបាច់សម្រាប់ដំណោះស្រាយវិវាទ និងការគ្រប់គ្រងឧប្បត្តិហេតុ ឬបញ្ហា។

ខ ) ការពិនិត្យឡើងវិញបន្ទាប់ពីបានអនុវត្តន៍ ត្រូវតែធ្វើឡើងដើម្បីវាយតម្លៃការអនុវត្តន៍ក្នុងខណៈពេលដែលការយកចិត្តទុកដាក់ស្គាល់អ្នកផ្តល់សេវាកម្មតាមកាលកំណត់ ត្រូវបានធ្វើឡើង ដើម្បីវាយតម្លៃអ្នកផ្តល់សេវាកម្មទៅលើភាពសក្តិសមជាបន្តបន្ទាប់ សម្រាប់ការបន្តកិច្ចសន្យា ឬក្នុងគោលបំណងផ្សេងៗទៀត។

គ ) ដំណើរការរាយការណ៍ ត្រូវតែមានជាចាំបាច់ ទៅលើបញ្ហាដែលកើតមានឡើងពីការតាមដាន ការបំពេញការងារ ជម្លោះ ឧប្បត្តិហេតុ និងឬបញ្ហា។

**គោលការណ៍ទី៦៖** វិធានការគ្រប់គ្រាន់ត្រូវតែបង្កើតឡើង ដើម្បីថែរក្សាភាពសម្ងាត់នៃព័ត៌មាន របស់ធនាគារ។

ក ) ម្ចាស់សេវាកម្មត្រូវប្រាកដថាការបង្ហាញព័ត៌មាន ( ព័ត៌មានដែលជាកម្មសិទ្ធិរបស់ធនាគារ និងព័ត៌មានអតិថិជន ) ទៅកាន់អ្នកផ្តល់សេវាកម្ម គឺសម្រាប់តែក្នុងការប្រើប្រាស់ដើម្បីធ្វើសកម្មភាពផ្តល់ដោយតតិយភាគី និងស្ថិតក្នុងកម្រិតដែលចាំបាច់ត្រូវដឹងតែប៉ុណ្ណោះ។

ខ ) ម្ចាស់សេវាកម្មត្រូវធានាថា អ្នកផ្តល់សេវាកម្មបានពិចារណាគ្រប់គ្រាន់នូវបច្ចេកទេស បុគ្គលិក និងវិធានការសមស្របសម្រាប់គ្រឹះស្ថាន ដើម្បីការពារការសម្ងាត់នៃព័ត៌មាន (ទោះបីបន្ទាប់ពីការរៀបចំសេវាកម្មផ្តល់ដោយតតិយភាគីត្រូវបានបញ្ចប់ក៏ដោយ ) និងប្រតិបត្តិតាមតម្រូវការនៃបទប្បញ្ញត្តិ។

គ ) វិធានការចាំបាច់សម្រាប់ត្រួតពិនិត្យ តាមដាន និងឬពិនិត្យអ្នកផ្តល់សេវាកម្មឡើងវិញ ត្រូវតែបង្កើតឡើងដោយម្ចាស់សេវាកម្ម ឧទាហរណ៍ ដូចជាការចុះពិនិត្យនៅទីកន្លែងផ្ទាល់តាមកាលកំណត់ ដំណើរការនៃការបំផ្លាញកំណត់ត្រាដោយអ្នកផ្តល់សេវាកម្ម ការបែងចែកព័ត៌មានដោយភាគីផ្សេងៗ ដែលគ្រប់គ្រងដោយអ្នកផ្តល់សេវាកម្ម និងការផ្ញើព័ត៌មានត្រលប់មកវិញជាដើម-ល-។

## ផ្នែកប្រតិបត្តិតាម

### មុខងារ និងរចនាសម្ព័ន្ធប្រតិបត្តិតាម

នាយកដ្ឋានប្រតិបត្តិតាម ទទួលខុសត្រូវត្រួតពិនិត្យ លើមុខងារប្រតិបត្តិតាមរបស់ធនាគារ។ នាយកដ្ឋានប្រតិបត្តិតាម គ្រប់គ្រងដោយប្រធានផ្នែកប្រតិបត្តិតាមដែលត្រូវតែមានការទទួល ស្គាល់ពីធនាគារជាតិនៃកម្ពុជា ជាមន្ត្រីប្រតិបត្តិតាមរបស់ធនាគារ ហើយគាត់ត្រូវរាយការណ៍ដោយផ្ទាល់ទៅកាន់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ឬក្រុមប្រឹក្សាភិបាល និងរាយការណ៍ជាលក្ខណៈរដ្ឋបាលទៅកាន់មុខងារប្រតិបត្តិតាមប្រចាំតំបន់របស់សម្ព័ន្ធ និងនាយកប្រតិបត្តិ ទៅលើបញ្ហាដែលទាក់ទងនឹងការប្រតិបត្តិតាម ដោយមិនត្រូវមានការពាក់ព័ន្ធនឹងការសម្រេចចិត្តរបស់អាជីវកម្មឡើយ។

មន្ត្រីប្រតិបត្តិតាមត្រូវរាយការណ៍ជូនគណៈគ្រប់គ្រង គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ឬក្រុមប្រឹក្សាភិបាល នូវរបាយការណ៍ការប្រតិបត្តិតាមប្រចាំខែ និងស្ថានភាពនៃបញ្ហាដែលលើកឡើងហើយមិនទាន់បានបញ្ចប់របស់និយ័តករ ឬសវករឯករាជ្យ ជារៀងរាល់ខែនិងជារៀងរាល់ត្រីមាស។ ចំណែកឯរបាយការណ៍ស្តីពីស្ថានភាពការប្រតិបត្តិតាម ត្រូវបានផ្ញើជូនមន្ត្រីប្រតិបត្តិតាមរបស់ សម្ព័ន្ធ និងនាយកប្រតិបត្តិជាប្រចាំខែ។

ទំនួលខុសត្រូវសំខាន់ៗរបស់មន្ត្រីប្រតិបត្តិតាមរួមមាន៖

- បង្កើត ពិនិត្យឡើងវិញ និងអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីគ្រប់គ្រងជារួមលើគោលនយោបាយ នីតិវិធី សេចក្តីណែនាំ គោលការណ៍ណែនាំ និងសកម្មភាពប្រតិបត្តិការរបស់ធនាគារ ព្រមទាំងជំរុញទៅលើការរីកចម្រើនរបស់អាជីវកម្ម។
- ពិនិត្យឡើងវិញរាល់ គោលនយោបាយ សេចក្តីណែនាំ នីតិវិធី និងដំណើរការ។ រាយការណ៍ទៅគណៈគ្រប់គ្រង ហើយលើកឡើងនូវការកែលម្អ ដែលចាំបាច់ដើម្បីធានាអោយបាននូវការប្រតិបត្តិតាម។
- ធានាថាធនាគារអនុលោមតាមច្បាប់ បទប្បញ្ញត្តិ ការណែនាំ និងគោលការណ៍ណែនាំដែលពាក់ព័ន្ធ ដែលបានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច រួមទាំងគោលការណ៍ និងនីតិវិធីផ្ទៃក្នុងរបស់ធនាគារ។

# របាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងប្រចាំឆ្នាំ (ត)

## ផ្នែកប្រតិបត្តិតាម (ត)

- ធ្វើការទំនាក់ទំនងជាមួយនិយ័តករ (ដូចជាធនាគារជាតិនៃកម្ពុជា អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា) ដើម្បីធានាអោយបាននូវទំនាក់ទំនងល្អ និងរៀបចំរបាយការណ៍ជូននិយ័តករតាមការចាំបាច់។
- ដើរតួជាអ្នកទំនាក់ទំនងពាក់ព័ន្ធនឹងការវាស់វែងការប្រឆាំងការសម្អាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្មដែលធនាគារបានបង្កើតឡើង ដោយរួមមានការបណ្តុះបណ្តាល បុគ្គលិក និងការរាយការណ៍ពីប្រតិបត្តិការដែលគួរឲ្យសង្ស័យ។
- ធ្វើការវាយតម្លៃ ទៅលើហានិភ័យការប្រតិបត្តិតាម និងការប្រឆាំងការសម្អាតប្រាក់ជាប្រចាំ ដើម្បីវាយតម្លៃពីស្ថានភាពបច្ចុប្បន្ន និងកំណត់ពីកត្តាដែលតម្រូវអោយមានការកែលម្អអោយប្រសើរឡើង ដើម្បីអោយការអនុវត្តការគ្រប់គ្រងការប្រតិបត្តិតាម ក៏ដូចជាការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មស្របទៅតាមគោលការណ៍ណែនាំរបស់និយ័តករ និងការអនុវត្តដ៏ល្អផ្សេងៗនៅក្នុងវិស័យធនាគារ។
- កំណត់ពីហានិភ័យការប្រតិបត្តិតាម និងការប្រឆាំងការសម្អាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្មទៅលើផលិតផលនិងសេវាកម្មថ្មីៗ ក៏ដូចជាការប្រែប្រួលទៅលើផលិតផលនិងសេវាកម្មដែលមានស្រាប់។
- ធ្វើការពិនិត្យដល់កន្លែងទៅលើការប្រតិបត្តិតាម បង្កើតកម្មវិធីតាមដាន និងធានាថានីតិវិធីរបស់ធនាគារត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួន។
- កំណត់ពីហេតុការណ៍នៃការមិនអនុលោមតាម ឬបញ្ហារំលោភបំពានផ្សេងៗ ហើយផ្តល់នូវអនុសាសន៍សម្រាប់សកម្មភាពដែលត្រូវធ្វើឡើង ដើម្បីកែលម្អនូវបញ្ហាទាំងនោះអោយបានប្រសើរឡើងប្រកបដោយប្រសិទ្ធភាព និងអាចយកទៅអនុវត្តបានជាក់ស្តែង។
- រាយការណ៍ជូនគណៈកម្មាធិការនៅពេលដែលហេតុការណ៍នៃការមិនអនុលោមតាម ឬ បញ្ហារំលោភបំពានណាមួយត្រូវបានរកឃើញ។
- ប្រមូលរៀបចំឯកសារ និងព័ត៌មានដែលចាំបាច់សម្រាប់ធ្វើការឆ្លើយតបទៅនឹងសំណួររបស់និយ័តករ។
- ធ្វើការណែនាំ និងបណ្តុះបណ្តាលដល់បុគ្គលិកថ្មីលើការប្រតិបត្តិតាម តម្រូវការបទប្បញ្ញត្តិ និងគោលនយោបាយ និងនីតិវិធីផ្ទៃក្នុងរបស់ធនាគារ ហើយធានាថាពួកគាត់អនុវត្តបានខ្ជាប់ខ្ជួន។
- តាមដានលើគំហើញសវនកម្ម និងធ្វើការស៊ើបអង្កេតនៅពេលចាំបាច់។
- ផ្តល់របាយការណ៍ប្រចាំខែជូនក្រុមគណៈគ្រប់គ្រង គណៈកម្មាធិការ និងក្រុមប្រឹក្សាភិបាលពីបទប្បញ្ញត្តិផ្សេងៗ។

នៅក្នុងឆ្នាំ ២០២០រចនាសម្ព័ន្ធរបស់នាយកដ្ឋានប្រតិបត្តិតាមត្រូវបានកែសម្រួលឡើងវិញ និងទទួលបានការអនុម័តពីក្រុមប្រឹក្សាភិបាល។ រចនាសម្ព័ន្ធរបស់នាយកដ្ឋានប្រតិបត្តិតាមមានដូចតទៅ៖



## ផ្នែកប្រតិបត្តិតាម (ត)

### ធនធានមនុស្សដែលបានផ្តល់ជូន

មានបុគ្គលិកបួន (៤) នាក់ កំពុងបំរើការនៅក្នុងមុខងារប្រតិបត្តិតាម។ អាស្រ័យដោយមានការកើនឡើងនៃប្រតិបត្តិការ ក៏ដូចជាតម្រូវការក្នុងការគាំទ្រដល់អង្គភាពអាជីវកម្ម ក្រុមប្រឹក្សាភិបាលបាន អនុម័តយល់ព្រមអោយនាយកដ្ឋានប្រតិបត្តិតាមបង្កើនចំនួនបុគ្គលិក ក៏ប៉ុន្តែធនាគារបានជួបផលលំបាកមួយចំនួន ក្នុងការស្វែងរកធនធានដែលល្អៗ ដោយសារតែចំនួនបុគ្គលដែលមានបទពិសោធន៍នៅក្នុងមុខងារនៃវិស័យនេះនៅមានកម្រិតនៅឡើយ។ ការបង្ហាត់បង្រៀន និងការបណ្តុះបណ្តាលក្នុងពេលការងារត្រូវបានប្រើប្រាស់ជាមធ្យោបាយមួយ ក្នុងការបង្កើននូវចំណេះដឹងដល់បុគ្គលិកផ្នែកប្រតិបត្តិតាម។ បន្ថែមពីនេះបុគ្គលិកផ្នែកប្រតិបត្តិតាមក៏បានទទួលការបណ្តុះបណ្តាលផ្សេងៗខាងក្នុង និងក្រៅស្ថាប័នទៅតាមតម្រូវការរបស់ពួកគេ។

នាយកសាខា ត្រូវបានចាត់តាំងជាមន្ត្រីប្រតិបត្តិតាមប្រចាំសាខា ដោយទទួលខុសត្រូវលើកិច្ចការប្រតិបត្តិតាមនៅតាមសាខារបស់គេរៀងៗខ្លួន ដែលកិច្ចការទាំងនោះរួមមាន ការយកចិត្តទុកដាក់ស្គាល់អតិថិជន និងរាយការណ៍ប្រតិបត្តិការសង្ស័យ ទៅកាន់មន្ត្រីប្រតិបត្តិតាមរបស់ធនាគារ។ មន្ត្រីប្រតិបត្តិតាមរបស់ធនាគារត្រូវធ្វើការសិក្សា និងវាយតម្លៃជាបន្ទាន់ថាតើការសង្ស័យនោះមានមូលហេតុគ្រប់គ្រាន់ហើយឬនៅ ហើយត្រូវបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យទៅកាន់អង្គភាពស៊ើបការហិរញ្ញវត្ថុកម្ពុជាក្នុងកំឡុងពេល២៤ម៉ោង។ មន្ត្រីប្រតិបត្តិតាមរបស់ធនាគារត្រូវធ្វើការពិនិត្យឡើងវិញដោយឯករាជ្យ និងធានាថាព័ត៌មានត្រូវបានរក្សាការសម្ងាត់។

ជាការសម្របសម្រួលដល់សកម្មភាពប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងដើម្បីបង្កើនការចូលរួមសហការពីអតិថិជនរបស់យើង ក្នុងឆ្នាំនេះ នាយកដ្ឋានប្រតិបត្តិតាមបានផ្តល់នូវការបណ្តុះបណ្តាល និងការបណ្តុះបណ្តាលឡើងវិញ ទៅលើការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងវិស្សលប្ប៉ីវីងទៅកាន់បុគ្គលិកទាំងអស់ ដើម្បីធានាអោយបានថាបុគ្គលិកទាំងអស់មានចំណេះដឹងគ្រាប់គ្រាន់ក្នុងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ហើយអាចធ្វើការទំនាក់ទំនងជាមួយអតិថិជនបានកាន់តែប្រសើរឡើង។ បុគ្គលិកថ្មីៗទាំងអស់ត្រូវឆ្លងកាត់ការបណ្តុះបណ្តាលទៅលើការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មតាមប្រព័ន្ធអេឡិចត្រូនិច ហើយត្រូវតែប្រឡងអោយជាប់ក្នុងរយៈពេលមួយខែបន្ទាប់ពីពួកគាត់ចាប់ផ្តើមចូលបម្រើការងារអោយធនាគារ។

### សកម្មភាពនៃមុខងារប្រតិបត្តិតាម

នាយកដ្ឋានប្រតិបត្តិតាម មានទំនួលខុសត្រូវចម្បងក្នុងការធានាអោយបាននូវការប្រតិបត្តិតាមបទប្បញ្ញត្តិ និងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មដូចតទៅ៖

### ១) ការប្រតិបត្តិតាមការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

ប្រព័ន្ធតាមដាន និងរាយការណ៍ការគ្រប់គ្រងការប្រតិបត្តិតាម រួមមានការត្រួតពិនិត្យ ការប្រតិបត្តិ ប្រសិទ្ធភាពនិងការយល់ដឹង ត្រូវបានបង្កើតឡើង និងអនុវត្តនៅក្នុងធនាគារ ដើម្បីបញ្ជាក់ពីជំហររបស់ធនាគារទៅនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ បញ្ជីផ្ទៀងផ្ទាត់ត្រូវបានប្រើជាសមាសភាគសំខាន់ក្នុងការពិនិត្យឡើងវិញ ហើយនេះបង្កើតបានជាវិធីសាស្ត្រស្តង់ដាររួមសម្រាប់ការអនុវត្ត។ ការត្រួតពិនិត្យគ្របដណ្តប់លើ៖

- ការតាមដានទៅលើបុគ្គលដែលមានមូលនិធិផ្ទាល់សុទ្ធខ្ពស់
- ហានិភ័យទៅតាមប្រភេទអតិថិជន
- ការពិនិត្យទៅលើឈ្មោះ

ការវាយតម្លៃការយកចិត្តទុកដាក់ស្គាល់អតិថិជន និងការពិនិត្យឡើងវិញប្រចាំឆ្នាំទៅលើទំនាក់ទំនងធនាគារជាមួយធនាគារទំនាក់ទំនង និងធនាគារផ្សេងទៀតត្រូវបានធ្វើឡើងដើម្បីធានា អោយបានថាធនាគារនឹងមិនមានការប្រឈមទៅនឹង ការគម្រាមកំហែងពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មតាមរយៈគណនីទំនាក់ទំនង។

ដើម្បីពង្រឹង និងជម្រុញការតាមដានទៅលើការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មអោយកាន់តែមានភាពប្រសើរឡើង ធនាគារបានអនុវត្តប្រព័ន្ធការប្រឆាំងការសម្អាតប្រាក់ដែលបានបង្កើតឡើងដោយក្រុមសម្ព័ន្ធធនាគារ អ អេច ប៊ី ហើយប្រព័ន្ធនេះត្រូវបានដាក់ឲ្យដំណើរការនៅថ្ងៃទី២០ខែកញ្ញា ឆ្នាំ២០២០។

### ២) ការប្រតិបត្តិតាមច្បាប់ និងបទប្បញ្ញត្តិ

វិសាលភាពនៃមុខងារប្រតិបត្តិតាម គឺជាផ្នែកមួយនៃស្តង់ដារ និងតម្រូវការប្រតិបត្តិតាមទូទៅដែលគ្រប់គ្រងលើការងារទាំងមូលរបស់ធនាគារ។ ច្បាប់ បទប្បញ្ញត្តិ គោលការណ៍ និងនីតិវិធីផ្ទៃក្នុងទាំងអស់ដែលមានជាធរមានដែលកំពុងគ្របដណ្តប់ទៅលើប្រតិបត្តិការរបស់ធនាគារ ត្រូវតែកត់ត្រាទុកដើម្បីធានាឲ្យបាននូវការយល់ដឹងច្បាស់លាស់ទៅលើច្បាប់ បទប្បញ្ញត្តិ គោលការណ៍ណែនាំ និងគោលនយោបាយទាំងនោះ។

នាយកដ្ឋានប្រតិបត្តិតាមធ្វើការត្រួតពិនិត្យ និងតាមដានជាប្រចាំទៅលើបទប្បញ្ញត្តិរបស់ធនាគារ ជាតិនៃកម្ពុជា ដោយបង្កើតនូវបញ្ជីកត់ត្រារាល់បទប្បញ្ញត្តិដែលត្រូវបានដាក់អោយអនុវត្ត ដើម្បីធានាថាធនាគារប្រតិបត្តិអាជីវកម្មរបស់ខ្លួន ដោយអនុលោមតាមតម្រូវការនៃបទប្បញ្ញត្តិផ្សេងៗបានយ៉ាងខ្ជាប់ខ្ជួន។

### សកម្មភាព និងផលិតផលថ្មីៗ

ការកំណត់ពីហានិភ័យការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលពាក់ព័ន្ធនឹងសកម្មភាព ផលិតផល និងសេវាកម្មថ្មីៗ ដោយរួមបញ្ចូលទាំងការដាក់ឲ្យប្រើប្រាស់បច្ចេកវិទ្យានិងដំណើរការថ្មីៗត្រូវបានធ្វើឡើងដើម្បីធានាថាហានិភ័យត្រូវបានទប់ស្កាត់និងអាចគ្រប់គ្រងបាន។ នាយកដ្ឋានប្រតិបត្តិតាម គឺជាផ្នែកមួយនៃមុខងារពិនិត្យឡើងវិញក្នុងការផ្តល់នូវយោបល់និងអនុសាសន៍ទៅលើសកម្មភាព ផលិតផល និងសេវាកម្មថ្មីៗ។

នីតិវិធីពាក់ព័ន្ធនឹងសកម្មភាព ផលិតផល និងសេវាកម្មថ្មីៗ ត្រូវបានគ្រប់គ្រងដោយក្រុមប្រតិបត្តិរបស់ខ្លួន ដោយឡែកការអនុវត្តសកម្មភាព ផលិតផល និងសេវាកម្ម ត្រូវបានគ្រប់គ្រងដោយ ក្រុមសីលធម៌និងវិន័យ គោលនយោបាយប្រតិបត្តិតាម និងគោលនយោបាយប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

## ផ្នែកប្រតិបត្តិតាម (ត)

មុនពេលនឹងដាក់អោយអនុវត្តនូវសកម្មភាព ផលិតផល និងសេវាកម្មថ្មីៗ ការអនុម័តត្រូវតែទទួលបានពីក្រុមប្រឹក្សាភិបាល និងធនាគារជាតិនៃកម្ពុជា។

### ទំនាស់ផលប្រយោជន៏

ដោយធនាគារយកចិត្តទុកដាក់ក្នុងការរក្សាអោយបាននូវ ស្តង់ដារដ៏ប្រសើរបំផុតទៅសីលធម៌ និងវិជ្ជាជីវៈ ក្រុមសីលធម៌និងវិន័យត្រូវបានបង្កើតឡើង ដើម្បីផ្តល់អោយបុគ្គលិកនូវគោលនយោបាយ និងសេចក្តីណែនាំ ដែលអាចជួយអោយពួកគាត់ស្វែងយល់កាន់តែច្បាស់ពី ការអនុវត្តអាជីវកម្ម សីលធម៌វិជ្ជាជីវៈ និងសីលធម៌ផ្ទាល់ខ្លួននៅក្នុងសកម្មភាពប្រចាំថ្ងៃរបស់ពួកគាត់។

ដើម្បីអោយប្រាកដថា បុគ្គលិកទាំងអស់មានចំណេះដឹងគ្រប់គ្រាន់ទាក់ទងនឹងទំនាស់ផលប្រយោជន៍ការបណ្តុះបណ្តាលជាច្រើនត្រូវបានផ្តល់អោយបុគ្គលិកទាំងអស់រួមទាំងបុគ្គលិកថ្មីនិងបុគ្គលិកដែលមានស្រាប់។ ការផ្តល់ព័ត៌មានសារាចរ និងការជូនដំណឹងតាមរយៈអ៊ីម៉ែល ត្រូវបានផ្ញើអោយបុគ្គលិកទាំងអស់។ បន្ថែមពីនេះ ធនាគារក៏បានបង្កើតនូវគោលនយោបាយវិស្សលប៉្លូវីង និងគោលនយោបាយប្រឆាំងការសូកប៉ាន់ និងអំពើពុករលួយដែលអនុញ្ញាតឲ្យបុគ្គលិកទាំងអស់អាចធ្វើការទំនាក់ទំនងផ្ទាល់ទៅកាន់គណៈគ្រប់គ្រង នៅពេលដែលពួកគាត់សង្កេតឃើញថាមានភាពមិនប្រក្រតីផ្សេងៗបានកើតឡើង។

### ហានិភ័យកេរ្តិ៍ឈ្មោះ

ហានិភ័យកេរ្តិ៍ឈ្មោះ ត្រូវបានកំណត់ថាជាហានិភ័យដែលមានការផ្សព្វផ្សាយជាសាធារណៈ អំពីភាពអវិជ្ជមានទាក់ទងនឹងការប្រព្រឹត្តរបស់ធនាគារ និងការអនុវត្តអាជីវកម្មរបស់ធនាគារ ឬអ្នកពាក់ព័ន្ធផ្សេងៗ មិនថាពិតឬមិនពិត ដែលនឹងជះឥទ្ធិពលអវិជ្ជមានដល់ប្រាក់ចំណូល ប្រតិបត្តិការ ឬអតិថិជន ឬតម្រូវឲ្យមានការប្តឹងប្តល់ដែលនាំឲ្យខាតបង់ ឬវិធានការការពារផ្សេងៗទៀត។

ហានិភ័យកេរ្តិ៍ឈ្មោះនៅក្នុងធនាគារ ត្រូវបានគ្រប់គ្រងតាមរយៈក្រមសីលធម៌ ការអនុវត្តអភិបាលកិច្ច និងការអនុវត្តការគ្រប់គ្រងហានិភ័យ គោលនយោបាយ នីតិវិធី និងការបណ្តុះបណ្តាល។ ធនាគារបានបង្កើតនិងអនុវត្តគោលនយោបាយគ្រប់គ្រងហានិភ័យកេរ្តិ៍ឈ្មោះមួយ។ ធាតុសំខាន់ៗសម្រាប់ការគ្រប់គ្រងហានិភ័យកេរ្តិ៍ឈ្មោះរួមមាន៖

- អនុវត្តអភិបាលកិច្ចសាជីវកម្មល្អ និងវប្បធម៌សុចរិតភាពដើម្បីលើកកម្ពស់ការអនុវត្ត និងសមិទ្ធិផលនៃយុទ្ធសាស្ត្រសាជីវកម្ម និងគោលដៅអាជីវកម្ម។
- គ្រប់គ្រងហានិភ័យកេរ្តិ៍ឈ្មោះអោយស្ថិតក្នុង កម្រិតហានិភ័យទទួលយកបានទាបខ្លាំងមួយ ដោយមិនលើកលែងចំពោះឧប្បត្តិហេតុដែលប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ធនាគារ។
- ទទួលយកការអនុវត្តការគ្រប់គ្រងហានិភ័យដែលល្អ ដោយរួមបញ្ចូលការអនុវត្តនៃការកសាង “ដើមទុនកេរ្តិ៍ឈ្មោះ” និងទំនុកចិត្តពីភាគីពាក់ព័ន្ធសំខាន់ៗ។
- រក្សាបាននូវយន្តការសមស្របក្នុងការតាមដាន និងផ្តល់ព័ត៌មានពីចន្លោះប្រហោង ឬការរំលោភបំពានជាសរវន្ត ក្នុងការអនុលោមតាមគោលនយោបាយ គោលការណ៍ណែនាំផ្ទៃក្នុង និងបទប្បញ្ញត្តិដែលអាចធ្វើអោយកេរ្តិ៍ឈ្មោះរបស់ធនាគារស្ថិតក្នុងហានិភ័យ។
- ថែរក្សាបណ្តាញទំនាក់ទំនងសមស្រប ក្នុងការដោះស្រាយជាមួយនឹងភាគីពាក់ព័ន្ធទាំងខាងក្នុង និងខាងក្រៅ។

វាគឺជាការទំនួលខុសត្រូវរបស់នាយកប្រតិបត្តិ ឬអភិបាលប្រតិបត្តិរបស់ធនាគារក្នុងការលើកកម្ពស់ការយល់ដឹង និងការអនុវត្តគោលនយោបាយនិងនីតិវិធីរបស់ធនាគារទាក់ទងនឹងហានិភ័យកេរ្តិ៍ឈ្មោះនៅក្នុងរាល់ការទាក់ទងជាមួយអតិថិជនវិនិយោគិនសក្តានុពល និងនិយ័តករ។

## ប្រព័ន្ធគណនេយ្យ និងព័ត៌មាន

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង ដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៅកម្ពុជា (CIFRS) លើការរៀបចំ និងបង្ហាញអំពីរបាយការណ៍ហិរញ្ញវត្ថុ។ របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងផ្អែកលើមូលដ្ឋាននិរន្តរភាព និងផ្តល់ទស្សនៈពិតនិងត្រឹមត្រូវលើស្ថានភាពអាជីវកម្មរបស់ធនាគារនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

គោលនយោបាយគណនេយ្យដ៏សមស្របត្រូវបានយកមកអនុវត្តដោយជាប់លាប់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលមានការគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណប្រកបដោយភាពប្រុងប្រយ័ត្ន និងសមហេតុផល។ អភិបាលទាំងអស់មានទំនួលខុសត្រូវជារួមចំពោះការចាត់វិធានការណ៍ ដើម្បីការពារនូវទ្រព្យសកម្មរបស់ធនាគារ និងធានាថារបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារបង្ហាញអំពីការវាយតម្លៃប្រកបដោយសមតុល្យភាព និងភាពល្អិនល្អន់អំពីស្ថានភាព និងទិដ្ឋភាពហិរញ្ញវត្ថុរបស់ធនាគារ។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានធ្វើសវនកម្មជារៀងរាល់ឆ្នាំ ដោយក្រុមហ៊ុនអន្តរជាតិជំនាញផ្នែកគណនេយ្យមួយ ដែលត្រូវបានយល់ព្រមដោយគណៈកម្មាធិការសវនកម្ម និងបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

សម្រាប់ការត្រួតពិនិត្យដែលសមរម្យនិងត្រឹមត្រូវ សេចក្តីណែនាំពីហិរញ្ញវត្ថុ និងគណនេយ្យ ត្រូវបានបង្កើតឡើង និងធ្វើបច្ចុប្បន្នភាពប្រសិនបើចាំបាច់។ សេចក្តីណែនាំក៏បានពន្យល់យ៉ាងច្បាស់លាស់អំពីនីតិវិធីសំខាន់ៗ ឧទាហរណ៍ ដូចជាដំណើរគណនេយ្យនិងការហិរញ្ញវត្ថុ និងទិដ្ឋភាពទូទៅនៃសៀវភៅគណនេយ្យដើម្បីអនុលោមទៅតាមតារាងគណនីរបស់ធនាគារជាតិ។

នីតិវិធីគណនេយ្យនិងហិរញ្ញវត្ថុ រួមមានការកត់ត្រា ការផ្ទៀងផ្ទាត់នៃគណនីសំខាន់ៗ គណនី បណ្តោះអាសន្ន ការត្រួតពិនិត្យលើអចលនទ្រព្យ និងការផ្តល់សិទ្ធិលើការទូទាត់។ តួនាទីនិងទំនួលខុសត្រូវរបស់បុគ្គលិកគណនេយ្យក៏ត្រូវបានដាក់បញ្ចូល។ បន្ថែមលើនេះទៀត កម្រិតនៃការផ្តល់សិទ្ធិលើការចំណាយគ្រប់ប្រភេទ ដូចជាចំណាយមូលធន ចំណាយដែលកើតឡើងដដែលៗ និងចំណាយដែលកើតឡើងមិនដដែលៗ គឺស្ថិតក្រោមតារាងសិទ្ធិអំណាចក្នុងការអនុម័តរបស់នាយកដ្ឋានយុទ្ធសាស្ត្រ និងហិរញ្ញវត្ថុ។

## គោលនយោបាយ នីតិវិធី និងដំណើរការគ្រប់គ្រងហានិភ័យ

ការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព គឺជាមូលដ្ឋានគ្រឹះក្នុងការជំរុញការលូតលាស់ប្រកបដោយចីរភាព និងតម្លៃភាគហ៊ុន ខណៈពេលដែលរក្សាបាននូវអត្ថប្រយោជន៍ប្រកួតប្រជែង។ ដូច្នេះវាគឺជាផ្នែកសំខាន់មួយ ក្នុងការគ្រប់គ្រងហានិភ័យយ៉ាងសកម្មនៃបរិបទប្រតិបត្តិការរបស់ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក។

# គោលនយោបាយ នីតិវិធី និងដំណើរការគ្រប់គ្រងហានិភ័យ (ត)

## ◆ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

ក្នុងការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ការប្រជុំរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យត្រូវបានធ្វើឡើងសរុបចំនួនបួន (៤) ដង។

គណៈកម្មាធិការគ្រប់គ្រងហានិភ័យមានសមាជិកដូចខាងក្រោម ហើយព័ត៌មានលំអិតនៃការចូលរួមកិច្ចប្រជុំរបស់សមាជិកនីមួយៗ នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រងហានិភ័យដែលបានធ្វើឡើងក្នុងឆ្នាំមានដូចតទៅ៖

| សមាសភាពនៃគណៈកម្មាធិការគ្រប់គ្រងហានិភ័យ | ចំនួននៃអង្គប្រជុំដែលបានចូលរួម |
| --- | --- |
| **Abdul Aziz Peru Mohamed**<br>*ប្រធានគណៈកម្មាធិការ ឬអភិបាលឯករាជ្យមិនប្រតិបត្តិ*<br>*តែងតាំងជាប្រធានគណៈកម្មាធិការនៅថ្ងៃទី២០ខែធ្នូ ឆ្នាំ២០១៦* | ៤/៤ |
| **លោកស្រី ម៉ៅ សំវុទ្ធារី**<br>*សមាជិក ឬអភិបាលឯករាជ្យមិនប្រតិបត្តិ*<br>*តែងតាំងជាសមាជិកគណៈកម្មាធិការនៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៩* | ៤/៤ |
| **Chin Yoong Kheong**<br>*សមាជិក ឬអភិបាលឯករាជ្យមិនប្រតិបត្តិ*<br>*តែងតាំងជាសមាជិកគណៈកម្មាធិការនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩* | ៤/៤ |

## បន្ទាត់រាយការណ៍របស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ



# របាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងប្រចាំឆ្នាំ (ត)

## គោលនយោបាយ នីតិវិធី និងដំណើរការគ្រប់គ្រងហានិភ័យ (ត)

- គណៈកម្មាធិការគ្រប់គ្រងហានិភ័យរាយការណ៍ជូនក្រុមប្រឹក្សាភិបាល និងទទួលខុសត្រូវចម្បង ចំពោះការគ្រប់គ្រង និងការត្រួតពិនិត្យសកម្មភាពគ្រប់គ្រងហានិភ័យរបស់ធនាគារ ឲ្យស្របតាមគោលនយោបាយហានិភ័យ និងរីសអាប់តែថាយ របស់ធនាគារ។ នាយកដ្ឋានគ្រប់គ្រងហានិភ័យរាយការណ៍ទៅគណៈកម្មាធិការគ្រប់គ្រងហានិភ័យ៖ បន្ទាត់រាយការណ៍គឺពីនាយកដ្ឋានគ្រប់គ្រងហានិភ័យដោយផ្ទាល់ទៅគណៈកម្មាធិការគ្រប់គ្រងហានិភ័យរបស់ធនាគារ។
- នាយកដ្ឋានគ្រប់គ្រងហានិភ័យរាយការណ៍ទៅ នាយកដ្ឋានគ្រប់គ្រងហានិភ័យប្រចាំតំបន់ (នាយកដ្ឋានគ្រប់គ្រងហានិភ័យសម្ព័ន្ធ)៖ ម៉ាទ្រីសបន្ទាត់រាយការណ៍ទៅនាយកដ្ឋានគ្រប់គ្រងហានិភ័យប្រចាំតំបន់ គឺដើម្បីទទួលបានការផ្តល់ប្រឹក្សានិងពិគ្រោះយោបល់ ដើម្បីធានាថាសកម្មភាពគ្រប់គ្រងហានិភ័យរបស់ធនាគារ បានសមស្របទៅតាមក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសម្ព័ន្ធ និងយុទ្ធសាស្ត្រហានិភ័យនិងអាប់តែថាយរបស់សម្ព័ន្ធ។
- នាយកដ្ឋានគ្រប់គ្រងហានិភ័យរាយការណ៍ទៅនាយកប្រតិបត្តិចំពោះបញ្ហារដ្ឋបាលតែប៉ុណ្ណោះ។
- នាយកដ្ឋានគ្រប់គ្រងហានិភ័យផ្តល់ការគាំទ្រ និងដំបូន្មានដល់ប្រធាននាយកដ្ឋាន ឬអ្នកគ្រប់គ្រង ទាក់ទងទៅនឹងហានិភ័យ និងដំណើរការ នីតិវិធី និងគោលនយោបាយនៃការត្រួតពិនិត្យផ្ទៃក្នុង។

### តួនាទីរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

- រាយការណ៍ទៅក្រុមប្រឹក្សាភិបាល និងមានទទួលខុសត្រូវចម្បងចំពោះការគ្រប់គ្រងនិងការត្រួតពិនិត្យសកម្មភាពគ្រប់គ្រងហានិភ័យរបស់ធនាគារឲ្យស្របតាមគោលនយោបាយហានិភ័យ និងរីសអាប់តែថាយរបស់ធនាគារ។
- ធ្វើការពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍ចំពោះយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ ក្របខ័ណ្ឌគោលនយោបាយថ្មី ឬការផ្លាស់ប្តូរគោលនយោបាយ និងរីសអាប់តែថាយ ឬកម្រិតអនុគ្រោះហានិភ័យរបស់ធនាគារដើម្បីឲ្យក្រុមប្រឹក្សាភិបាលអនុម័ត។
- ធ្វើការពិនិត្យឡើងវិញ និងវាយតម្លៃអំពីភាពគ្រប់គ្រាន់នៃគោលនយោបាយ និងក្របខ័ណ្ឌនៃការគ្រប់គ្រងហានិភ័យក្នុងការកំណត់ វាស់វែង តាមដាន និងគ្រប់គ្រងហានិភ័យដែលនាំឲ្យប្រតិបត្តិការទាំងនេះមានប្រសិទ្ធភាព។
- ធ្វើការត្រួតពិនិត្យ និងអភិបាលកិច្ចដើម្បីធានាឲ្យបាននូវក្របខ័ណ្ឌ ហេដ្ឋារចនាសម្ព័ន្ធ ធនធាន និងប្រព័ន្ធគ្រប់គ្រងហានិភ័យបានបង្កើតឡើង និងដំណើរការបានសមស្របទៅនឹងលក្ខណៈ វិសាលភាព ភាពស្មុគស្មាញអាជីវកម្ម និងរីសអាប់តែថាយ របស់ធនាគារ។
- ធ្វើការពិនិត្យឡើងវិញនូវរបាយការណ៍តាមកាលកំណត់ ពីនាយកដ្ឋានគ្រប់គ្រងហានិភ័យស្តីពីទំហំហានិភ័យ សមាសភាពរបស់សម្ពាធហានិភ័យ និងសកម្មភាពគ្រប់គ្រងហានិភ័យ។
- ធ្វើការត្រួតពិនិត្យ និងធានានូវសកម្មភាពអាជីវកម្ម និងប្រតិបត្តិការរបស់ធនាគារ រួមទាំងសកម្មភាពនិងផលិតផលថ្មីៗ ដែលបានបង្កើតឡើង ស្របតាមរីសអាប់តែថាយ និងគោលដៅយុទ្ធសាស្ត្ររយៈពេលខ្លីនិងវែង។
- ធ្វើការពិនិត្យរាល់សកម្មភាពរបស់គណៈគ្រប់គ្រងជាន់ខ្ពស់ ក្នុងការគ្រប់គ្រងហានិភ័យឥណទាន ហានិភ័យទីផ្សារ ហានិភ័យសន្ទនីយភាព ហានិភ័យប្រតិបត្តិការ ហានិភ័យផ្នែកច្បាប់ និងហានិភ័យផ្សេងៗទៀត និងដើម្បីធានាថាដំណើរការគ្រប់គ្រងហានិភ័យរបស់ធនាគារ បានបង្កើតឡើង និងមានដំណើរការ។
- ធ្វើការលើកកម្ពស់ការគ្រប់គ្រងហានិភ័យរបស់ធនាគារ ឲ្យស្របតាមក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសហគ្រាស។
- ធ្វើការពិភាក្សា និងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលទាក់ទងនឹងបញ្ហាគ្រប់គ្រងហានិភ័យ។

### វិធានសម្រាប់បង្ហាញពីកំណត់ហេតុប្រជុំគណៈកម្មាធិការគ្រប់គ្រងហានិភ័យ

កំណត់ហេតុប្រជុំនីមួយៗរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ត្រូវរក្សាទុក និងចែកចាយដល់សមាជិកទាំងអស់នៃគណៈកម្មាធិការគ្រប់គ្រងហានិភ័យ។ កំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រងហានិភ័យនេះ នឹងត្រូវបង្ហាញនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ហើយប្រធាន ឬប្រធានស្តីទី (ក្នុងករណីអវត្តមាននៃប្រធាន) នៃគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ត្រូវរាយការណ៍អំពីបញ្ហាសំខាន់ៗដែលបានពិភាក្សាទៅក្រុមប្រឹក្សាភិបាល ។

## គោលនយោបាយ នីតិវិធី និងដំណើរការគ្រប់គ្រងហានិភ័យ (ត)

### ◆ គោលនយោបាយ និងនីតិវិធីគ្រប់គ្រងហានិភ័យ

| ល.រ | បញ្ជីគោលនយោបាយ និងនីតិវិធីគ្រប់គ្រងហានិភ័យ | កាលបរិច្ឆេទការអនុម័ត | អនុម័តដោយ |
|---|---|---|---|
| ១ | គោលនយោបាយឥណទាន | ២៩ មករា ២០១៩ | ក្រុមប្រឹក្សាភិបាល |
| ២ | គោលការណ៍ណែនាំឥណទាន | ២៩ មករា ២០១៩ | ក្រុមប្រឹក្សាភិបាល |
| ៣ | គោលនយោបាយប្រាក់កម្ចីអន់ថយ | ២៩ មករា ២០១៩ | ក្រុមប្រឹក្សាភិបាល |
| ៤ | គោលការណ៍ណែនាំស្តីពីប្រាក់កម្ចីអន់ថយ | ២៩ មករា ២០១៩ | ក្រុមប្រឹក្សាភិបាល |
| ៥ | គោលការណ៍ណែនាំស្តីពីការលើកកម្ពស់ការគ្រប់គ្រងគណនី | ១៩ មិថុនា ២០១៩ | ក្រុមប្រឹក្សាភិបាល |
| ៦ | គោលការណ៍ណែនាំស្តីពីហានិភ័យឥណទានប្រមូលផ្តុំ | ១៩ មិថុនា ២០១៩ | ក្រុមប្រឹក្សាភិបាល |
| ៧ | គោលការណ៍ណែនាំវិធីសាស្រ្តហានិភ័យសន្ទនីយភាព | ១៣ ឧសភា ២០២០ | ក្រុមប្រឹក្សាភិបាល |
| ៨ | គោលការណ៍ណែនាំអំពីការគ្រប់គ្រងឧប្បត្តិហេតុ និងការប្រមូលទិន្នន័យបាត់បង់ | ១៩ មិថុនា ២០១៩ | ក្រុមប្រឹក្សាភិបាល |
| ៩ | គោលការណ៍ណែនាំស្តីពីអាយុកាលផលិតផល និងសេវាកម្មថ្មី | ១៩ មិថុនា ២០១៩ | ក្រុមប្រឹក្សាភិបាល |
| ១០ | ក្របខណ្ឌ និងគោលនយោបាយគ្រប់គ្រងហានិភ័យសហគ្រាស | ១៩ មិថុនា ២០១៩ | ក្រុមប្រឹក្សាភិបាល |
| ១១ | គោលនយោបាយស្តីពីប្រតិបត្តិការរបស់សម្ព័ន្ធញាតិ | ១៩ មិថុនា ២០១៩ | ក្រុមប្រឹក្សាភិបាល |
| ១២ | ផែនការគ្រប់គ្រងឧប្បត្តិហេតុសន្ទនីយភាព | ១៩ មិថុនា ២០១៩ | ក្រុមប្រឹក្សាភិបាល |
| ១៣ | ក្រមសីលធម៌ និងអាកប្បកិរិយាសម្រាប់និយោជិក | ១៩ មិថុនា ២០១៩ | ក្រុមប្រឹក្សាភិបាល |

### សិទ្ធិអំណាច ការធ្វើប្រតិភូកម្ម និងដែនកំណត់

ការធ្វើប្រតិភូកម្មសិទ្ធិអំណាច រួមទាំងកម្រិតនៃការកំណត់សិទ្ធិអំណាចនៅកម្រិតផ្សេងៗនៃគណៈគ្រប់គ្រង នៅក្នុងធនាគារត្រូវបានចងក្រងជាឯកសារ និងរៀបចំឡើងដើម្បីធានាគណនេយ្យភាព និងទំនួលខុសត្រូវ។

ធនាគារបានបង្កើតឡើងជាផ្លូវការនូវដំណើរការរាយការណ៍ជាទូទៅមួយ ក្នុងករណីមានសញ្ញានៃការប្រុងប្រយ័ត្នឬល្មើសវិសេសអាប់តែថាយ និងកម្រិតដាស់តឿនសកម្មភាពគណៈគ្រប់គ្រង។ ការល្មើសកម្រិតកំណត់វិសេសអាប់តែថាយ នឹងត្រូវរាយការណ៍ទៅដល់គណៈកម្មាធិការក្រុមប្រឹក្សាភិបាលហានិភ័យ ពោលគឺគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ឬគណៈកម្មាធិការសវនកម្ម និងក្រុមប្រឹក្សាភិបាល។ លើសពីនេះទៅទៀតដំណើរការក្នុងរាយការណ៍ជាក់លាក់ក៏មានចងក្រងជាឯកសារ នៅក្នុងគោលនយោបាយ គោលការណ៍ណែនាំ នីតិវិធី ឬក្របខ័ណ្ឌផ្សេងៗផងដែរ។

## ប្រព័ន្ធវាស់វែងហានិភ័យនិងលទ្ធផល និងការត្រួតពិនិត្យ

នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានធ្វើសវនកម្មលើផ្នែកមួយចំនួននៅក្នុងឆ្នាំដូចខាងក្រោម៖

១) ការត្រួតពិនិត្យប្រតិបត្តិការរបស់សាខាចំនួន៧ ដែលផ្តោតទៅលើ:

- ប្រតិបត្តិការរបស់សាខារួមមាន ការគ្រប់គ្រងសាច់ប្រាក់ ប្រាក់បញ្ញើរអតិថិជន ការផ្ទេរប្រាក់ ម៉ាស៊ីនអេធីអឹម និងហិរញ្ញប្បទានពាណិជ្ជកម្ម។ ប្រតិបត្តិការនេះរួមបញ្ចូលទាំងកម្រិតនៃការប្រតិបត្តិតាមតម្រូវការនៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងតម្រូវការច្បាប់អនុលោមភាពពន្ធគណនីបរទេស (FATCA) ឬស្តង់ដារបាយការណ៍ទូទៅ (CRS)។
- ប្រតិបត្តិការឥណទានរួមមាន មុខងារតាមដានលក្ខខណ្ឌបន្ទាប់ពីទម្លាក់លុយ ការបន្តឬពិនិត្យឡើងវិញនៃពាក្យស្នើសុំឥណទាន គោលនយោបាយធានារ៉ាប់រងអគ្គីភ័យ និងការក្រើនរំលឹកអតិថិជនអំពីការបង់ប្រាក់ក្រោយថ្ងៃកំណត់ ព្រមទាំងថ្លៃសេវាកម្ចីដល់អតិថិជន។
- ការគ្រប់គ្រងទូទៅនៅក្នុងសាខា
- ការថែរក្សា និងសុវត្ថិភាពសាខា

## ប្រព័ន្ធវាស់វែងហានិភ័យនិងលទ្ធផល និងការត្រួតពិនិត្យ (ត)

២) នាយកដ្ឋានទីផ្សារ និងទំនាក់ទំនង

៣) នាយកដ្ឋានហិរញ្ញវត្ថុ រតនាគារ និងយុទ្ធសាស្ត្រ

៤) នាយកដ្ឋានផ្នែកច្បាប់ និងលេខាធិការ

៦) នាយកដ្ឋានអភិវឌ្ឍន៍ និងគ្រប់គ្រងផលិតផល

៧) ប្រតិបត្តិការ និងការគ្រប់គ្រងព័ត៌មានវិទ្យា

បញ្ជីនៃគំហើញសំខាន់ៗដែលរកឃើញដោយនាយកដ្ឋានសវនកម្មផ្ទៃក្នុង ពាក់ព័ន្ធនឹងហានិភ័យ មានដូចខាងក្រោម៖

### ហានិភ័យប្រតិបត្តិតាមបទប្បញ្ញត្តិ

១) ចន្លោះប្រហោងក្នុងការអនុលោមទៅតាមតម្រូវការការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម៖

- ការពិនិត្យឡើងវិញប្រចាំ ៦ខែម្តងមិនត្រូវបានអនុវត្តលើអតិថិជនដែលមានហានិភ័យខ្ពស់
- ការដាក់ពិន្ទុមិនត្រឹមត្រូវលើការយកចិត្តទុកដាក់ស្គាល់អតិថិជន

### ហានិភ័យប្រតិបត្តិការ

១) ចន្លោះប្រហោងនៅក្នុងការរៀបចំ និងការផ្ទុកឯកសារ៖

- ព័ត៌មានដែលចាត់ទុកថាជាការសម្ងាត់ ត្រូវបានរក្សាទុកនៅក្នុងថតឯកសារដែលបុគ្គលិកទាំងអស់របស់ធនាគារ អ អេច ប៊ី (ខេមបូឌា) អាចចូលទៅយកបាន
- សេចក្តីព្រាងនៃកំណត់ត្រាប្រជុំ កិច្ចសន្យា និងឯកសារផ្សេងៗទៀត មិនត្រូវបានរក្សាទុកនៅក្នុងទូដែលបានចាក់សោរឡើយ

២) ចន្លោះប្រហោងក្នុងការគ្រប់គ្រងការមកទទួលយកសៀវភៅមូលប្បទានប័ត្រ៖

- ការមិនប្រកាន់ខ្ជាប់នូវនីតិវិធីការមកទទួលយកសៀវភៅមូលប្បទានប័ត្រដោយភាគីទីបី
- មិនមានភស្តុតាងនៃការត្រួតពិនិត្យទ្វេដងនៅក្នុងបញ្ជីសៀវភៅមូលប្បទានប័ត្រត្រូវបានធ្វើឡើងសម្រាប់ការមកទទួលយកសៀវភៅមូលប្បទានប័ត្រ

## ប្រព័ន្ធរៀបចំឯកសារ

គោលនយោបាយ នីតិវិធី និងដំណើរការទាំងអស់ គឺត្រូវបានធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់បុគ្គលិកនៅក្នុងធនាគារ។ គោលនយោបាយ នីតិវិធី និងដំណើរការទាំងនេះ ត្រូវបានពិនិត្យ និងអនុម័តដោយភាគីដែលបានផ្តល់សិទ្ធិអំណាច។

បទប្បញ្ញត្តិនិងឯកសារព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តអាជីវកម្ម ប្រតិបត្តិការ និងអង្គភាព ត្រូវបានចងក្រងជាឯកសារយ៉ាងច្បាស់លាស់ ហើយអាចរកបានដោយបុគ្គលិកទាំងអស់នៅក្នុងធនាគារ។ ឯកសារទាំងអស់នោះត្រូវបានរក្សាទុកទាំងច្បាប់ដើម និងច្បាប់ចម្លង។

ការបណ្តុះបណ្តាល និងរំលឹកឡើងវិញលើគោលនយោបាយ នីតិវិធី និងដំណើការត្រូវបានផ្តល់ទៅឲ្យទាំងបុគ្គលិកចាស់និងថ្មី តាមរយៈកម្មវិធីណែនាំ ការបណ្តុះបណ្តាលដោយផ្ទាល់ និងការរៀនតាមអេឡិចត្រូនិចដែលបានរៀបចំដោយនាយកដ្ឋានធនធានមនុស្ស។ លើសពីនេះទៅទៀត សិក្ខាសាលា ឬបទសង្ខេប ក៏ត្រូវបានរៀបចំឡើងជាទៀងទាត់ដោយនាយកដ្ឋានផ្សេងៗដើម្បីរំលឹកការយល់ដឹងទាក់ទងនឹងប្រតិបត្តិការប្រចាំថ្ងៃដល់និយោជិក។

## ផែនការយថាភាព និងការសាកល្បង

ធនាគារត្រូវបានដឹកនាំដោយ គោលនយោបាយ និងនីតិវិធីពាក់ព័ន្ធរបស់ខ្លួនដើម្បីធានាឲ្យបាននូវនិរន្តរភាពនៃប្រតិបត្តិការអាជីវកម្ម បើទោះបីស្ថិតនៅក្នុងស្ថានការណ៍មានការរំខាន មានគ្រោះមហន្តរាយ និងមានវិបត្តិក៏ដោយ។ ខាងក្រោមនេះគឺជាគោលការណ៍ និងនីតិវិធីដើម្បីដោះស្រាយស្ថានភាពខាងលើ៖

១) ផែនការគ្រប់គ្រងឧប្បត្តិហេតុសន្ទនីយភាព

២) សៀវភៅណែនាំផែនការនិរន្តរភាពអាជីវកម្ម

៣) គោលការណ៍សន្តិសុខព័ត៌មានបច្ចេកវិទ្យា

## ការគ្រប់គ្រងនិរន្តរភាពអាជីវកម្ម

ធនាគារទទួលស្គាល់ និងប្តេជ្ញាចិត្តយ៉ាងពេញទំហឹងទៅនឹងតម្រូវការក្នុងការផ្តល់សេវាកម្មសំខាន់ៗដែលគ្មានភាពរអាក់រអួលជូនអតិថិជន ធានាសុវត្ថិភាពជូនដល់បុគ្គលិក ព្រមទាំងការពារទ្រព្យសម្បត្តិរបស់ខ្លួនដែលរួមមាន ទិន្នន័យនិងការពារផលប្រយោជន៍អ្នកពាក់ព័ន្ធសំខាន់ៗរបស់ខ្លួន ដែលរួមគ្នាធានានូវលទ្ធភាពជោគជ័យរបស់អង្គភាព។ ដូច្នេះហើយ ធនាគារដឹងច្បាស់នូវសារៈសំខាន់នៃកម្មវិធី និងក្របខ័ណ្ឌគ្រប់គ្រងនិរន្តរភាពអាជីវកម្មដ៏ល្អមួយ ដើម្បីកសាងភាពរឹងមាំរបស់អង្គភាព និងការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ព្រមទាំងយន្តការស្តារឡើងវិញសម្រាប់ការពារផលប្រយោជន៍អ្នកពាក់ព័ន្ធសំខាន់ៗ កេរ្តិ៍ឈ្មោះ និងយីហោ។ កម្មវិធីគ្រប់គ្រងនិរន្តរភាពអាជីវកម្មរបស់ធនាគារ គឺពឹងផ្អែកលើការអនុវត្តនិរន្តរភាពអាជីវកម្មល្អៗ គោលការណ៍ណែនាំដោយបទប្បញ្ញត្តិ និងស្តង់ដារអន្តរជាតិ។

ធនាគារអនុវត្តកម្មវិធីគ្រប់គ្រងនិរន្តរភាពអាជីវកម្មដ៏ល្អមួយ ដើម្បីធានាឲ្យបានថាមុខងារអាជីវកម្មសំខាន់ៗមានភាពប្រសើរឡើងវិញទាន់ពេលវេលា បើទោះបីជាមានស្ថានការណ៍រំខានបែបណាក៏ដោយ។ ការពិនិត្យឡើងវិញ ការវាយតម្លៃការធ្វើបច្ចុប្បន្នភាព និងការសាកល្បងទៅលើផែនការគ្រប់គ្រងនិរន្តរភាពអាជីវកម្មត្រូវបានធ្វើឡើងជាប្រចាំដើម្បីធានាឲ្យបាននូវភាពគ្រប់គ្រាន់ ប្រសិទ្ធភាព និងភាពត្រៀមខ្លួនរួចជាស្រេចនៃការស្តារអាជីវកម្មឡើងវិញ។ លំហាត់សមយុទ្ធត្រូវបានធ្វើឡើងដើម្បីបន្សាំនិងផ្តល់ឲ្យបុគ្គលិកនូវជំនាញ និងដំណើរការចាំបាច់ដើម្បី

## ការគ្រប់គ្រងនិរន្តរភាពអាជីវកម្ម (ត)

ធានាថាដំណើរការអាជីវកម្មសំខាន់ៗអាចបន្តទៅមុខបាន ឬស្តារបានឡើងវិញទាន់ពេលវេលា បើទោះបីស្ថិតនៅក្នុងស្ថានការណ៍មានការរំខានបែបណាក៏ដោយ។

នៅក្នុងឆ្នាំ២០២០ធនាគារបានធ្វើការសាកល្បងទៅលើផែនការនិរន្តរភាពអាជីវកម្មនៅថ្ងៃទី២០ខែវិច្ឆិកា ឆ្នាំ២០២០ក្នុងគោលបំណងដើម្បីបង្កើនសមត្ថភាពដល់បុគ្គលិកជួរមុខ និងភ្នាក់ងារសេវាកម្មអតិថិជនក្នុងការឆ្លើយតបនិងគ្រប់គ្រងវិបត្តិ រួមបញ្ចូលទាំងការប្រាស្រ័យទាក់ទងយ៉ាងមានទំនុកចិត្ត និងប្រសិទ្ធភាពជាមួយនឹងអ្នកជាប់ពាក់ព័ន្ធនានាក្នុងកំឡុងពេលដែលមានវិបត្តិ។ ធនាគារក៏ទទួលបានជោគជ័យផងដែរ ក្នុងការធ្វើលំហាត់សមអំពីការប្រមូលទិន្នន័យមកវិញ ក្នុងករណីមានគ្រោះមហន្តរាយលើប្រព័ន្ធសំខាន់ៗរបស់ខ្លួនផងដែរ (ឧបករណ៍កុំព្យូទ័រ ប្រព័ន្ធ កម្មវិធី និងបណ្តាញ) នៅថ្ងៃទី៣០ខែមេសា ឆ្នាំ២០២០និងនៅថ្ងៃទី២៧ខែមិថុនា ឆ្នាំ២០២០។ ការធ្វើលំហាត់សមទាំងនេះមានគោលបំណងបណ្តុះឲ្យមានការត្រៀមខ្លួនរួចជាស្រេច និងដោះស្រាយរាល់ចន្លោះប្រហោងផ្សេងៗ នៅពេលប្រឈមមុខនឹងវិបត្តិដែលអាចកើតមានឡើងណាមួយ។

ឆ្នាំ២០២០គឺជាឆ្នាំដ៏លំបាកមួយសម្រាប់ពួកយើងនៅក្នុងធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក ដោយសារតែការរីករាលដាលនៃជំងឺរាតត្បាតកូវីដ~១៩។ យើងបានចាត់វិធានការយ៉ាងសកម្ម និងបង្ការទុកជាមុនតាំងពីខែមីនា ឆ្នាំ២០២០ ដើម្បីកាត់បន្ថយនិងគ្រប់គ្រងការរីករាលដាលនិងហានិភ័យ នៃការឆ្លង ជាមួយនឹងការធានាឲ្យបាននូវការផ្តល់សេវាកម្មសំខាន់ៗជាបន្តបន្ទាប់។ ធនាគារបានដាក់ឱ្យដំណើរការនូវយុទ្ធសាស្រ្តផែនការបន្តអាជីវកម្មរបស់ខ្លួនពេលមានជំងឺរាតត្បាតសម្រាប់មុខងារអាជីវកម្មទាំងអស់នៅក្នុងធនាគារទាំងមូល ដែលរួមមានការធ្វើប្រតិបត្តិការបំបែកគ្នា និងការរៀបចំឲ្យធ្វើការងារនៅផ្ទះ ការប្រើប្រាស់វេទិកាឌីជីថលសម្រាប់ការប្រជុំ ហើយផ្តល់ការប្រឹក្សានិងធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ ទៅលើនីតិវិធីប្រតិបត្តិការស្តង់ដារកូវីដ~១៩ សម្រាប់បុគ្គលិក អ អេច ប៊ីទាំងអស់។

# RHB ផ្នែកប្រតិបត្តិតាម



បទបញ្ញត្តិសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ កាន់តែមានភាពស្មុគស្មាញខ្លាំងឡើងៗ ហើយតែងតែត្រូវបានធ្វើវិសោធនកម្មជារឿយៗ។ ច្បាប់ និងបទបញ្ញត្តិថ្មីៗ ត្រូវបានកំពុងបន្តបង្កើតជាលំដាប់ ដែលធ្វើឱ្យការរំពឹងទុករបស់និយតករក៏កាន់តែមានការកើនឡើង។ រាល់ការបរាជ័យណាមួយក្នុងការធានាឲ្យបាននូវការប្រតិបត្តិតាមអាចបណ្តាលឱ្យមានការខាតបង់ហិរញ្ញវត្ថុគួរឱ្យកត់សម្គាល់ ការពិន័យយ៉ាងធ្ងន់ធ្ងរព្រមទាំងអាចប៉ះពាល់ដល់កេរ្តិ៍ឈ្មោះផងដែរ។

ក្នុងនាមជាអ្នកផ្តល់សេវាកម្មហិរញ្ញវត្ថុដែលប្រកបដោយទំនុកចិត្ត ធនាគារ អ អេច ប៊ី (កម្ពុជា) ម.ក ប្តេជ្ញានឹងប្រកាន់ខ្ជាប់នូវគោលការណ៍អភិបាលកិច្ចនិងតម្រូវការបទបញ្ញត្តិឲ្យបានល្អប្រសើរ។ គោលការណ៍ទាំងនេះ ត្រូវបានចែងយ៉ាងច្បាស់លាស់នៅក្នុងក្របខណ្ឌគ្រប់គ្រង និងគោលនយោបាយការប្រតិបត្តិតាមរបស់ធនាគារ ដែលជាការណែនាំយ៉ាងសំខាន់ ដើម្បីឲ្យធនាគារអាចរួមបញ្ចូលនូវការអនុវត្តការប្រតិបត្តិតាមដ៏ល្អបំផុតទៅក្នុងរាល់សកម្មភាពធុរៈកិច្ចរបស់ធនាគារ។

មុខងារប្រតិបត្តិតាមរបស់ធនាគារ ដើរតួជាខ្សែការពារក្នុងបន្ទាត់ទី២ ដោយប្រតិបត្តិមុខងារលើមូលដ្ឋានធនាគារទាំងមូល ដែលមានមន្ត្រីប្រតិបត្តិតាមម្នាក់ត្រូវបានចាត់តាំង ដើម្បីត្រួតពិនិត្យលើការគ្រប់គ្រងហានិភ័យនៃការប្រតិបត្តិតាមរបស់ធនាគារ ដោយគ្របដណ្តប់ទៅលើនាយកដ្ឋាន និង សាខាទាំងអស់។

## គំនិតផ្តួចផ្តើមសំខាន់ៗរបស់ផ្នែកប្រតិបត្តិតាមសម្រាប់ឆ្នាំ ២០២០ ដើម្បីរក្សានូវបម្រុងប្រយ័ត្នអោយបានខ្ជាប់ខ្ជួនក្នុងបរិបទនៃការរីករាលដាលនៃជំងឺកូវីត ១៩ រួមមាន៖

- ការអភិវឌ្ឍលើទម្រង់សិក្សា ដើម្បីបំពេញនូវតម្រូវការទៅលើការបណ្តុះបណ្តាលនិងកម្មវិធីវប្បធម៌អំពីការប្រតិបត្តិតាម ដែលនឹងត្រូវបានផ្តល់ជូនតាមរយៈទម្រង់អនឡាញ។
- ការចេញនូវព្រឹត្តិបត្រលើការប្រតិបត្តិតាម និងការផ្សព្វផ្សាយបទបញ្ញត្តិ លើបញ្ហានិងការអភិវឌ្ឍសំខាន់ៗពាក់ព័ន្ធនិងការប្រតិបត្តិតាមជាប្រចាំ។
- ការរួមបញ្ចូលនូវវប្បធម៌នៃការប្រតិបត្តិតាម ទៅក្នុងតារាងវាយតម្លៃសមិទ្ធផលការងារ (KPI) របស់បុគ្គលិក ដើម្បីបញ្ជាក់ថាការប្រតិបត្តិតាម ជាទំនួលខុសត្រូវសម្រាប់បុគ្គលគ្រប់រូប។
- ការពង្រឹងនូវដំណើរការត្រួតពិនិត្យលើការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម តាមរយៈការអនុវត្តនៃការត្រួតពិនិត្យប្រតិបត្តិការដោយស្វ័យប្រវត្តិ និងការវាយតម្លៃហានិភ័យការប្រឆាំងការសម្អាតប្រាក់។
- ការធ្វើការត្រួតពិនិត្យឡើងវិញពីចម្ងាយ (desktop review) ទៅលើការប្រតិបត្តិតាមរបស់សាខាដែលមានហានិភ័យខ្ពស់ ដើម្បីកំណត់និងបង្ហាញចន្លោះប្រហោងណាមួយនៅក្នុងដំណើរការប្រតិបត្តិការ និងធានានូវការប្រកាន់ខ្ជាប់នូវការអនុវត្តតាមតម្រូវការបទបញ្ញត្តិ ក៏ដូចជាគោលនយោបាយនិងនីតិវិធីផ្ទៃក្នុង។



www.rhbgroup.com.kh

**ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក**

ជាន់ទី២ និង ជាន់ទី៩  អគារ OHK កែងផ្លូវ១១០ & ផ្លូវ៩៣ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។
ទូរស័ព្ទលេខ ៖ ( ៨៥៥ ) ២៣ ៩៩២ ៨៣៣  ទូរសារលេខ ៖ ( ៨៥៥ ) ២៣ ៩៩១ ៨២២
Toll Free: ១៨០០-២០-៨១១៨
facebook.com/RHBCambodia/

# រីកចម្រើន ទាំងអស់គ្នា

# មាតិកា




## របាយការណ៍ហិរញ្ញវត្ថុ ២០២០

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០


**២៥៦** របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

**២៥៧** របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ

**២៥៨** របាយការណ៍បម្រែបម្រួលមូលធន

**២៥៩** របាយការណ៍លំហូរសាច់ប្រាក់

**២៦០** កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

**គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០**

| | កំណត់សម្គាល់ | ២០២០ | | ២០១៩ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤ | **៨.៧៦៩.៩៧៥** | ៣៥.៤៧៤.៥៤៩ | **៨.៤០៨.៨០២** | ៣៤.២៦៥.៨៦៨ |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារកណ្តាល | ៥ | **១៨៣.៩៥៦.៩២៤** | ៧៤៤.១០៥.៧៥៨ | **២០៩.៥៣១.៥០៦** | ៨៥៣.៨៤០.៨៨៧ |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារផ្សេងៗ | ៦ | **៨៣.៨០២.៣៩៩** | ៣៣៨.៩៨០.៧០៤ | **១២៣.៣៧០.៥៦៧** | ៥០២.៧៣៥.០៦១ |
| ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមតម្លៃសមស្របក្នុងលទ្ធផលលម្អិតផ្សេងៗ | ៧ | **២៥.០០០** | ១០១.១២៥ | **២៥.០០០** | ១០១.៨៧៥ |
| ឥណទាន និងបុរេប្រទានតាមថ្លៃដើមដករំលស់ | ៨ | **៥៦៤.៣៧៥.៦២៥** | ២.២៨២.៨៩៩.៤០៣ | **៥០៦.២២៦.៩៨៦** | ២.០៦២.៨៧៤.៩៦៨ |
| ប្រាក់តម្កល់តាមច្បាប់នៅធនាគារកណ្តាល | ៩ | **៨៧.៧៧០.៦៦២** | ៣៥៥.០៣២.៣២៨ | **៨៧.០៤១.៣៥០** | ៣៥៤.៦៩៣.៥០១ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ១០ | **៣.០៣៨.៦៤៦** | ១២.២៩១.៣២៣ | **២.៤១៧.០៨១** | ៩.៨៤៩.៦០៥ |
| ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ | ១១ | **១៣.៩៣២.៧៨៤** | ៥៦.៣៥៨.១១១ | **១.៣០៣.៩៨២** | ៥.៣១៣.៧២៧ |
| ទ្រព្យសកម្មអរូបី | ១២ | **៣.៨៦៨.១០៩** | ១៥.៦៤៦.៥០១ | **១.៣៧៨.៩០៣** | ៥.៦១៩.០៣០ |
| ពន្ធពន្យារទ្រព្យសកម្ម | ១៣ | **១.២៨២.០៧២** | ៥.១៨៥.៩៨១ | - | - |
| ទ្រព្យសកម្មផ្សេងៗ | ១៤ | **៣.៩៣៥.៩០៣** | ១៥.៩២០.៧២៨ | **៣.៥៩១.៧៦៣** | ១៤.៦៣៦.៤៣៤ |
| **ទ្រព្យសកម្មសរុប** | | **៩៥៤.៧៥៨.០៩៩** | ៣.៨៦១.៩៩៦.៥១១ | **៩៤៣.២៩៩.៩៤០** | ៣.៨៤៣.៩៣០.៩៥៦ |
| **បំណុល និងមូលធន** | | | | | |
| បំណុល | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ | ១៥ | **១៧០.៥៣០.៧៧៤** | ៦៨៩.៧៩៦.៩៨១ | **១៤៣.៣៩២.៣៦២** | ៥៨៤.៣២៣.៨៧៥ |
| ប្រាក់បញ្ញើរបស់អតិថិជន | ១៦ | **៥៩៩.១០៥.៨៤៨** | ២.៤២៣.៣៨៣.១៥៥ | **៦៣២.៧៦៩.៦៥៨** | ២.៥៧៨.៥៣៦.៣៥៦ |
| ប្រាក់កម្ចី | ១៧ | **៣៤.២៥២.៤៣៨** | ១៣៨.៥៥១.១១២ | **២៧.៦១១.១៥៨** | ១១២.៥១៥.៤៦៩ |
| បំណុលភតិសន្យា | ១១ | **១៤.៦៨៩.៩៧០** | ៥៩.៤២០.៩២៩ | **១.៨៣២.៣៧៥** | ៧.៤៦៦.៩២៨ |
| បំណុលពន្ធពន្យារ | ១៣ | - | - | **៥២៨.៥៣៩** | ២.១៥៣.៧៩៦ |
| បំណុលពន្ធលើប្រាក់ចំណូលក្នុងឆ្នាំ | ១៨ | **២.០៤០.៥៥៤** | ៨.២៥៤.០៤១ | **២.៨៩៣.៧៥៣** | ១១.៧៩២.០៤៣ |
| អត្ថប្រយោជន៍បុគ្គលិក | | **១៧៧.៣៣៣** | ៧១៧.៣១២ | **១១៩.៩៦២** | ៤៨៨.៨៤៥ |
| បំណុលផ្សេងៗ | ១៩ | **៣.៥៥០.៨៦៦** | ១៤.៣៦៣.២៥៣ | **៦.៤៧៩.២៥៤** | ២៦.៤០២.៩៦០ |
| **បំណុលសរុប** | | **៨២៤.៣៤៧.៧៨៣** | ៣.៣៣៤.៤៨៦.៧៨៣ | **៨១៥.៦២៧.០៦១** | ៣.៣២៣.៦៨០.២៧២ |
| **មូលធន** | | | | | |
| ដើមទុន | ២០ | **៧៥.០០០.០០០** | ៣០៣.៣៧៥.០០០ | **៧៥.០០០.០០០** | ៣០៥.៦២៥.០០០ |
| ប្រាក់ចំណេញរក្សាទុក | | **៤០.៨៧៦.៥៨៦** | ១៦៥.២៦៤.៦៥៣ | **៣៩.៧៤៦.៥៤៤** | ១៦០.៦៥៧.៤៧០ |
| ទុនបម្រុងតាមច្បាប់ | | **៤.៥៣៣.៧៣០** | ១៨.៣៣៨.៩៣៨ | **១២.៩២២.៣៣៥** | ៥២.២៧៨.៩៥៨ |
| ទុនបម្រុងមិនសម្រាប់បែងចែក | | **១០.០០០.០០០** | ៤០.៤៥០.០០០ | - | - |
| ទុនបម្រុងផ្សេងៗ | | - | ៨១.១៣៧ | - | ១.៦៨៩.២៥៦ |
| **មូលធនសរុប** | | **១៣០.៤១០.៣១៦** | ៥២៧.៥០៩.៧២៨ | **១២៧.៦៦៨.៨៧៩** | ៥២០.២៥០.៦៨៤ |
| **បំណុល និងមូលធនសរុប** | | **៩៥៤.៧៥៨.០៩៩** | ៣.៨៦១.៩៩៦.៥១១ | **៩៤៣.២៩៥.៩៤០** | ៣.៨៤៣.៩៣០.៩៥៦ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ២៦០ដល់ទំព័រទី ៣២០គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ

**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០**

| | កំណត់សម្គាល់ | ២០២០ | | ២០១៩ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលការប្រាក់ | ២១ | ៤៦.៥២៤.៩៦៤ | ១៨៩.៦៨២.២៧៨ | ៤១.១៨៨.២៣៣ | ១៦៦.៨៩៤.៧២០ |
| ចំណាយការប្រាក់ | ២១ | (២១.៦៤៨.៥៨៥) | (៨៨.២៦១.២៨១) | (១៥.៩៦៣.៣៩៩) | (៦៤.៦៨៣.៦៩៣) |
| **ចំណូលការប្រាក់សុទ្ធ** | ២១ | ២៤.៨៧៦.៣៧៩ | ១០១.៤២០.៩៩៧ | ២៥.២២៤.៨៣៤ | ១០២.២១១.០២៧ |
| ចំណូលកម្រៃជើងសា | ២២ | ២.៣១៣.០០៣ | ៩.៤៣០.១១៣ | ២.៤២៤.៧០០ | ៩.៨២៤.៨៨៤ |
| ចំណាយកម្រៃជើងសា | ២២ | (៩.៤១៦) | (៣៨.៣៨៩) | (៩.០០៨) | (៣៦.៥០០) |
| **ចំណូលកម្រៃជើងសាសុទ្ធ** | ២២ | ២.៣០៣.៥៨៧ | ៩.៣៩១.៧២៤ | ២.៤១៥.៦៩២ | ៩.៧៨៨.៣៨៤ |
| ចំណូលប្រតិបត្តិការផ្សេងៗ | ២៣ | ៩៣.១៧០ | ៣៧៩.៨៥៤ | ៨៧.៤៣៧ | ៣៥៤.២៩៥ |
| ចំណេញ/(ខាត) ផ្សេងៗ - សុទ្ធ | ២៤ | ៣១២.៤៧១ | ១.២៧៣.៩៤៤ | (១៣៤.៤៩៩) | (៥៤៤.៩៩០) |
| **ចំណេញ/(ខាត)ប្រតិបត្តិការសរុប** | | ៤០៥.៦៤១ | ១.៦៥៣.៧៩៨ | (៤៧.០៦២) | (១៩០.៦៩៥) |
| (ខាតពីការថយចុះតម្លៃឥណទាន)/ការកត់ត្រាការថយចុះ តម្លៃឥណទានត្រឡប់មកវិញ | ២៥ | (១៤.០០៧.១២០) | (៥៧.១០៧.០២៨) | ៧២៦.២២៤ | ២.៩៤២.៦៦០ |
| **ចំណេញ/(ខាត)ប្រតិបត្តិការផ្សេងៗសុទ្ធ** | | (១៣.៦០១.៤៧៩) | (៥៥.៤៥៣.២៣០) | ៦៧៩.១៦២ | ២.៧៥១.៩៦៥ |
| ចំណាយបុគ្គលិក | ២៦ | (៤.៤៥៥.២៥៧) | (១៨.១៦៤.០៨៣) | (៤.៥៤៥.៥៦៥) | (១៨.៤១៨.៦២៩) |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី | ២៧ | (២.៥៥០.៨២៤) | (១០.៣៩៩.៧០៩) | (១.៦៧៣.៤៩៦) | (៦.៧៨១.០០៦) |
| ចំណាយប្រតិបត្តិការផ្សេងៗ | ២៨ | (៣.៣១៩.៧៤៦) | (១៣.៥៣៤.៦០៤) | (៣.២៤៣.៣២៩) | (១៣.១៤១.៩៦៩) |
| **ចំណេញមុនពន្ធលើប្រាក់ចំណូល** | | ៣.២៥២.៦៦០ | ១៣.២៦១.០៩៥ | ១៨.៨៥៧.២៩៨ | ៧៦.៤០៩.៧៧២ |
| ចំណាយពន្ធលើប្រាក់ចំណូល | ២៩ | (៥១១.២២៣) | (២.០៨៤.២៥៥) | (៣.៨៦៨.០៩៧) | (១៥.៦៧៣.៥២៩) |
| **ចំណេញក្នុងឆ្នាំ** | | ២.៧៤១.៤៣៧ | ១១.១៧៦.៨៤០ | ១៤.៩៨៩.២០១ | ៦០.៧៣៦.២៤៣ |
| លទ្ធផលលម្អិតផ្សេងៗ៖ | | | | | |
| ខ្ទង់ដែលមិនត្រូវបានចាត់ថ្នាក់ឡើងវិញក្នុងចំណេញ-ខាត | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (១.៦០៨.១១៩) | - | ២.៤៩២.៤៩៦ |
| លទ្ធផលលម្អិតផ្សេងៗក្នុងឆ្នាំ កាត់កងជាមួយពន្ធ | | - | (១.៦០៨.១១៩) | - | ២.៤៩២.៤៩៦ |
| **លទ្ធផលលម្អិតផ្សេងៗសរុបក្នុងឆ្នាំ** | | ២.៧៤១.៤៣៧ | ៩.៥៦៨.៧២១ | ១៤.៩៨៩.២០១ | ៦៣.២២៨.៧៣៩ |
| **ចំណេញរបស់៖** | | | | | |
| ម្ចាស់ធនាគារ | | ២.៧៤១.៤៣៧ | ១១.១៧៦.៨៤០ | ១៤.៩៨៩.២០១ | ៦០.៧៣៦.២៤៣ |
| **លទ្ធផលលម្អិតសរុបរបស់៖** | | | | | |
| ម្ចាស់ធនាគារ | | ២.៧៤១.៤៣៧ | ៩.៥៦៨.៧២១ | ១៤.៩៨៩.២០១ | ៦៣.២២៨.៧៣៩ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ២៦០ដល់ទំព័រទី ៣២០គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍បម្រែបម្រួលមូលធន

## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | ដែលជារបស់ម្ចាស់ធនាគារ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដើមទុន | | ប្រាក់ចំណេញរក្សាទុក | | ទុនបម្រុងតាមច្បាប់ | | ទុនបម្រុងមិនសម្រាប់បែងចែក | | ទុនបម្រុងផ្សេងៗ | | សរុប | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារ អាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| សមតុល្យនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ | ៧៥.០០០.០០០ | ៣០១.៣៥០.០០០ | ២៨.៨៨៦.៩៩២ | ១១៦.៦៥៤.៥៦៥ | ៨.៧៩២.៦៨៦ | ៣៥.៥៤៥.៦២០ | - | - | - | (៨០៣.២៤០) | ១១២.៦៧៩.៦៧៨ | ៤៥២.៧៤៦.៩៤៥ |
| ចំណេញក្នុងឆ្នាំ | - | - | ១៤.៩៨៩.២០១ | ៦០.៧៣៦.២៤៣ | - | - | - | - | - | - | ១៤.៩៨៩.២០១ | ៦០.៧៣៦.២៤៣ |
| លទ្ធផលលម្អិតផ្សេងៗ | - | - | - | - | - | - | - | - | - | ២.៤៩២.៤៩៦ | - | ២.៤៩២.៤៩៦ |
| លទ្ធផលលម្អិតសរុបក្នុងឆ្នាំ | - | - | ១៤.៩៨៩.២០១ | ៦០.៧៣៦.២៤៣ | - | - | - | - | - | ២.៤៩២.៤៩៦ | ១៤.៩៨៩.២០១ | ៦៣.២២៨.៧៣៩ |
| ប្រតិបត្តិការជាមួយភាគទុននិកក្នុងនាមជាភាគទុនិក | | | | | | | | | | | | |
| ការផ្ទេរទៅទុនបម្រុងតាមច្បាប់ | - | - | (៤.១២៩.៦៤៩) | (១៦.៧៣៣.៣៣៨) | ៤.១២៩.៦៤៩ | ១៦.៧៣៣.៣៣៨ | - | - | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៤.២៧៥.០០០ | - | - | - | - | - | - | - | - | - | ៤.២៧៥.០០០ |
| ប្រតិបត្តិការសរុបជាមួយភាគទុនិក | - | ៤.២៧៥.០០០ | (៤.១២៩.៦៤៩) | (១៦.៧៣៣.៣៣៨) | ៤.១២៩.៦៤៩ | ១៦.៧៣៣.៣៣៨ | - | - | - | - | - | ៤.២៧៥.០០០ |
| សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | ៧៥.០០០.០០០ | ៣០៥.៦២៥.០០០ | ៣៩.៧៤៦.៥៤៤ | ១៦០.៦៥៧.៤៧០ | ១២.៩២២.៣៣៥ | ៥២.២៧៨.៩៥៨ | - | - | - | ១.៦៨៩.២៥៦ | ១២៧.៦៦៨.៨៧៩ | ៥២០.២៥០.៦៨៤ |
| សមតុល្យនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ | ៧៥.០០០.០០០ | ៣០៥.៦២៥.០០០ | ៣៩.៧៤៦.៥៤៤ | ១៦០.៦៥៧.៤៧០ | ១២.៩២២.៣៣៥ | ៥២.២៧៨.៩៥៨ | - | - | - | ១.៦៨៩.២៥៦ | ១២៧.៦៦៨.៨៧៩ | ៥២០.២៥០.៦៨៤ |
| ចំណេញក្នុងឆ្នាំ | - | - | ២.៧៤១.៤៣៧ | ១១.១៧៦.៨៤០ | - | - | - | - | - | - | ២.៧៤១.៤៣៧ | ១១.១៧៦.៨៤០ |
| លទ្ធផលលម្អិតផ្សេងៗ | - | - | - | - | - | - | - | - | - | (១.៦០៨.១១៩) | - | (១.៦០៨.១១៩) |
| លទ្ធផលលម្អិតសរុបក្នុងឆ្នាំ | - | - | ២.៧៤១.៤៣៧ | ១១.១៧៦.៨៤០ | - | - | - | - | - | (១.៦០៨.១១៩) | ២.៧៤១.៤៣៧ | ៩.៥៦៨.៧២១ |
| ប្រតិបត្តិការជាមួយភាគទុននិកក្នុងនាមជាភាគទុនិក | | | | | | | | | | | | |
| ការផ្ទេរទៅទុនបម្រុងមិនសម្រាប់បែងចែក | - | - | (១០.០០០.០០០) | (៤០.៧៧០.០០០) | - | - | ១០.០០០.០០០ | ៤០.៧៧០.០០០ | - | - | - | - |
| ការផ្ទេរទៅទុនបម្រុងតាមច្បាប់ | - | - | ៨.៣៨៨.៦០៥ | ៣៤.២០០.៣៤៣ | (៨.៣៨៨.៦០៥) | (៣៤.២០០.៣៤៣) | - | - | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (២.២៥០.០០០) | - | - | - | ២៦០.៣២៣ | - | (៣២០.០០០) | - | - | - | (២.៣០៩.៦៧៧) |
| ប្រតិបត្តិការសរុបជាមួយភាគទុនិក | - | (២.២៥០.០០០) | (១.៦១១.៣៩៥) | (៦.៥៦៩.៦៥៧) | (៨.៣៨៨.៦០៥) | (៣៣.៩៤០.០២០) | ១០.០០០.០០០ | ៤០.៤៥០.០០០ | - | - | - | (២.៣០៩.៦៧៧) |
| សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | ៧៥.០០០.០០០ | ៣០៣.៣៧៥.០០០ | ៤០.៨៧៦.៥៨៦ | ១៦៥.២៦៤.៦៥៣ | ៤.៥៣៣.៧៣០ | ១៨.៣៣៨.៩៣៨ | ១០.០០០.០០០ | ៤០.៤៥០.០០០ | - | ៨១.១៣៧ | ១៣០.៤១០.៣១៦ | ៥២៧.៥០៩.៧២៨ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ២៦០ដល់ទំព័រទី ៣២០គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ

# របាយការណ៍លំហូរសាច់ប្រាក់

## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | កំណត់សម្គាល់ | ២០២០ | | ២០១៩ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| សាច់ប្រាក់(បានប្រើក្នុង)/ចេញពីប្រតិបត្តិការ | ៣១ | (៩១.៥៩៣.៣៤៤) | (៣៧៣.៤៣១.៤៥៥) | ៥១.៧០៥.៨២៤ | ២០៩.៥១១.៩៩៩ |
| ការប្រាក់បានទទួល | | ៤៧.៦៩៣.០២៩ | ១៩៤.៤៤៤.៤៧៩ | ៣៩.៧២៣.៧៥៣ | ១៦០.៩៦០.៦៤៧ |
| ការប្រាក់បានបង់ | | (១៩.២៣០.៦៧០) | (៧៨.៤០៣.៤៤២) | (១៦.៣១៦.៧៨៨) | (៦៦.១១៥.៦២៥) |
| ពន្ធលើប្រាក់ចំណូលបានបង់ | ១៨ | (៣.១៧៥.០៣៣) | (១២.៩៤៤.៦១០) | (១.៨៣៤.៦៨០) | (៧.៤៣៤.១២៣) |
| **សាច់ប្រាក់(បានប្រើក្នុង)/ចេញពីសកម្មភាពប្រតិបត្តិការ** | | (៦៦.៣០៦.០១៨) | (២៧០.៣៣៥.០៧២) | ៧៣.២៧៨.១០៩ | ២៩៦.៩២២.៨៩៨ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារកណ្តាល - កាលកំណត់លើសពី៣ខែ | | (១០.១០៥.៥៧៣) | (៤១.២០០.៤២១) | (២២.៧៨៥.៦១៣) | (៩២.៣២៧.៣០៤) |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារផ្សេងៗ - កាលកំណត់លើសពី៣ខែ | | (៧.០៥៦.៣៧៣) | (២៨.៧៦៨.៨៣៣) | (២៦៦.៤៤៧) | (១.០៧៩.៦៤៣) |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ១០ | (១.៥១៣.៧៦២) | (៦.១៧១.៦០៨) | (១.១០៩.៨៣៧) | (៤.៤៩៧.០៦០) |
| ការទិញទ្រព្យសកម្មអរូបី | ១២ | (២.៩៦៧.៩៤០) | (១២.១០០.២៩១) | (៣១០.៥៥៥) | (១.២៥៨.៥៣១) |
| សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | | ៣០.២៥២ | ១២៣.៣៣៧ | ១៣០.៥៧៦ | ៥២៩.០៩៤ |
| **សាច់ប្រាក់ចេញពី/(បានប្រើក្នុង)សកម្មភាពវិនិយោគ** | | (២១.៦១៣.៣៩៦) | (៨៨.១១៧.៨១៦) | (២៤.៣៤១.៩១៦) | (៩៨.៦៣៣.៤៤៤) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់បានពីប្រាក់កម្ចី | ១៧ | ៦៨.៩៦១.៦៨១ | ២៨១.១៥៦.៧៧៣ | ២៩.៥៤៦.០៤០ | ១១៩.៧២០.៥៥៤ |
| ការទូទាត់សងប្រាក់កម្ចី | ១៧ | (៦២.៧៩៣.៥៧២) | (២៥៦.០០៩.៣៩៣) | (២.០៥៧.៨១៥) | (៨.៣៣៨.២៦៦) |
| ប្រាក់ដើមនៃការទូទាត់ភតិសន្យា | ១១ | (៩៨៤.៩១៩) | (៤.០១៥.៥១៥) | (៦១៥.០៨៩) | (២.៤៩២.៣៤១) |
| **សាច់ប្រាក់បានពីសកម្មភាពហិរញ្ញប្បទាន** | | ៥.១៨៣.១៩០ | ២១.១៣១.៨៦៥ | ២៦.៨៧៣.១៣៦ | ១០៨.៨៨៩.៩៤៧ |
| **(តំហយ)/កំណើនសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | (៨២.៧៣៦.២២៤) | (៣៣៧.៣២១.០២៣) | ៧៥.៨០៩.៣២៩ | ៣០៧.១៧៩.៤០១ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមឆ្នាំ | | ២៧៦.២១៨.០៣៥ | ១.១២៥.៥៨៨.៩៩២ | ២០០.៤០៨.៧០៦ | ៨០៥.២៤២.១៨០ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (៥.៦៣៣.៥៤៣) | - | ១៣.១៦៦.៩១១ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលដំណាច់ឆ្នាំ** | ៣០ | ១៩៣.៤៨១.៨១១ | ៧៨២.៦៣៣.៩២៦ | ២៧៦.២១៨.០៣៥ | ១.១២៥.៥៨៨.៩៩២ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ២៦០ដល់ទំព័រទី ៣២០គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

RHB◆

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០**

## ១. ព័ត៌មានទូទៅ

ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក (ហៅកាត់ថា "ធនាគារ") ត្រូវបានបង្កើតឡើងនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៨ និងបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ដោយមានវិញ្ញាបនបត្រចុះបញ្ជីលេខ ០០០០១៨១២ និងត្រូវបានធនាគារជាតិ នៃ កម្ពុជា (ហៅកាត់ថា "ធនាគារកណ្តាល") ផ្តល់អាជ្ញាប័ណ្ណប្រកបអាជីវកម្មធនាគារ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៨។ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ធនាគារបានប្តូរនាមករណ៍របស់ខ្លួនទៅជា ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក។ ធនាគារ គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលត្រូវបានកាន់កាប់ទាំងស្រុងដោយធនាគារ RHB Bank Berhad ជាក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកម្រិត បានចុះបញ្ជីពាណិជ្ជកម្មនៅប្រទេសម៉ាឡេស៊ី ហើយក្រុមហ៊ុនមេធំជាងគេគឺក្រុមហ៊ុន RHB Banking Group ដោយអនុលោមទៅតាមរចនាសម្ព័ន្ធសាជីវកម្មក្រុមហ៊ុនរួមចូលជាធរមានចាប់ពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦។

សកម្មភាពអាជីវកម្មចម្បងរបស់ធនាគារ គឺការផ្តល់សេវាផ្នែកធនាគារពាណិជ្ជច្រើនប្រភេទនៅក្នុងប្រទេសកម្ពុជា។

ការិយាល័យចុះបញ្ជីរបស់ធនាគារមានទីតាំងបច្ចុប្បន្នស្ថិតនៅអគារ ជាន់ទី១ ជាន់ M ជាន់ទី២ និងជាន់ទី៩ ផ្លូវលេខ១១០កែងផ្លូវលេខ ៩៣ ភូមិ ៣ សង្កាត់ ស្រះចក ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

ក្រុមប្រឹក្សាភិបាលបានអនុម័តឱ្យចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១។ ក្រុមប្រឹក្សាភិបាលមានសិទ្ធិកែប្រែ និងចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុនេះឡើងវិញ។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ

គោលការណ៍គណនេយ្យសំខាន់ៗដែលបានប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញ ខាងក្រោម។ គោលការណ៍ទាំងនេះ ត្រូវបានអនុវត្តយ៉ាងមានសង្គតិភាពគ្រប់ឆ្នាំដែលបានបង្ហាញទាំងអស់ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

### ២.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយអនុលោមទៅតាម CIFRS ដែលផ្អែកទាំងស្រុងទៅតាមស្តង់ដារទាំងអស់ដែលបានចេញផ្សាយដោយ IASB រួមទាំងបំណកស្រាយ និងវិសោធនកម្មផ្សេងៗ ដែលអាចកើតមានក្នុងកាលៈទេសៈណាមួយចំពោះស្តង់ដារនីមួយៗ។

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំតាមវិធីសាស្ត្រថ្លៃដើម លើកលែងតែទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាស់វែងតាមតម្លៃសមស្រប។

ធនាគារលាតត្រដាងចំនួនទឹកប្រាក់នៃទ្រព្យសកម្ម និងបំណុលនីមួយៗ ដែលបានរំពឹងថានឹងប្រមូលមកវិញ ឬត្រូវទូទាត់ក្នុងរយៈពេលមិនលើស១២ខែ បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ ជារយៈពេលខ្លី ហើយលើសពី១២ខែ បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ ជារយៈពេលវែង។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលស្របទៅតាម CIFRS តម្រូវឱ្យប្រើប្រាស់ការប៉ាន់ស្មានគណនេយ្យជាក់លាក់សំខាន់ៗ។ ហើយវាក៏តម្រូវឱ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យរបស់ខ្លួន នៅក្នុងដំណើរការនៃការអនុវត្តគោលការណ៍ គណនេយ្យនេះផងដែរ។ ផ្នែកដែលទាក់ទងនឹងការវិនិច្ឆ័យ ឬភាពស្មុគស្មាញក្នុងកម្រិតខ្ពស់ ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ៣ ។

របាយការណ៍ហិរញ្ញវត្ថុជាភាសាអង់គ្លេស ត្រូវបានរៀបចំឡើងចេញពី របាយការណ៍ហិរញ្ញវត្ថុជាភាសាខ្មែរ។ ក្នុងករណីមិនមានសង្គតិភាព ឬមានភាពខុសគ្នាក្នុងការបកស្រាយរវាងភាសាទាំងពីរ នោះត្រូវយករបាយការណ៍ហិរញ្ញវត្ថុជាភាសាខ្មែរជាគោល។

### ២.២ ស្តង់ដារគណនេយ្យថ្មី និងបំណកស្រាយ

#### ក) ស្តង់ដារគណនេយ្យថ្មី និងវិសោធនកម្ម ដែលធនាគារបានអនុវត្ត

ធនាគារបានអនុវត្តស្តង់ដារ និងវិសោធនកម្មដូចខាងក្រោមជាលើកដំបូង សម្រាប់ការិយបរិច្ឆេទរាយការណ៍ប្រចាំឆ្នាំ ចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២០៖

- និយមន័យនៃពាក្យ "សារវន្ត" – វិសោធនកម្ម CIAS ១ និង CIAS ៨
- ការកែប្រែក្របខណ្ឌគោលគំនិត សម្រាប់របាយការណ៍ហិរញ្ញវត្ថុ

វិសោធនកម្មខាងលើនេះ មិនមានផលប៉ះពាល់ទៅលើចំនួនដែលបានទទួលស្គាល់ក្នុងការិយបរិច្ឆេទមុនៗទេ ហើយធនាគារមិនរំពឹងថាវាមានផលប៉ះពាល់ជាសារវន្តចំពោះការិយបរិច្ឆេទបច្ចុប្បន្ន និងការិយបរិច្ឆេទអនាគតទេ។

# ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

## ២.២ ស្តង់ដារគណនេយ្យថ្មី និងបំណកស្រាយ (ត)

### ខ) ស្តង់ដារគណនេយ្យថ្មី និងបំណកស្រាយដែលធនាគារមិនទាន់បានអនុវត្ត

ធនាគារមិនបានអនុវត្តមុនកាលកំណត់នូវស្តង់ដារគណនេយ្យថ្មី និងបំណកស្រាយដែលត្រូវបានចេញផ្សាយរួច ប៉ុន្តែមិនទាន់ចាំបាច់ត្រូវអនុវត្តសម្រាប់ការិយបរិច្ឆេទរាយការណ៍ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ទេ។ ធនាគារមិនរំពឹងថាស្តង់ដារទាំងនេះមានផលប៉ះពាល់ជាសារវន្តលើមូលធនរបស់ធនាគារ សម្រាប់ការិយបរិច្ឆេទរាយការណ៍នេះ និងការិយបរិច្ឆេទរាយការណ៍នាពេលអនាគត និងចំពោះប្រតិបត្តិការនាពេលអនាគតខាងមុខនេះទេ។

## ២.៣ ការប្តូររូបិយប័ណ្ណ

### (ឃ) រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

គណនីទាំងអស់ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានវាស់តម្លៃដោយប្រើប្រាស់រូបិយប័ណ្ណនៃបរិយាកាសសេដ្ឋកិច្ចចម្បងដែលធនាគារធ្វើប្រតិបត្តិការ (ហៅកាត់ថា "រូបិយប័ណ្ណគោល")។ រូបិយប័ណ្ណគោលគឺប្រាក់ដុល្លារអាមេរិក ដោយសារវាមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការរបស់ធនាគារ។ របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិកដែលជារូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញរបស់ធនាគារ។

### (ខ) ប្រតិបត្តិការ និងសមតុល្យ

ប្រតិបត្តិការជារូបិយប័ណ្ណបរទេស ត្រូវបានប្តូរទៅជារូបិយប័ណ្ណគោល ដោយប្រើអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញនិងខាតពីប្រតិបត្តិការទាំងនេះ និងពីការប្តូរទ្រព្យសកម្ម និងបំណុលរូបិយវត្ថុជារូបិយប័ណ្ណផ្សេងក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ-ខាត។

ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណដែលពាក់ព័ន្ធនឹងប្រាក់កម្ចី ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ-ខាត ក្នុងខ្ទង់ចំណាយការប្រាក់។ ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណផ្សេងៗទៀតទាំងអស់ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ-ខាត តាមមូលដ្ឋានចំនួនទឹកប្រាក់សុទ្ធ។

### (គ) ការបង្ហាញជាប្រាក់រៀល

អនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម របាយការណ៍ហិរញ្ញវត្ថុត្រូវបង្ហាញជាប្រាក់រៀល។ របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ និងរបាយការណ៍លំហូរសាច់ប្រាក់ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើអត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំ/ការិយបរិច្ឆេទ។ ទ្រព្យសកម្ម និងបំណុលដែលបានបង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗ និងមូលធនរបស់ភាគទុនិក ត្រូវបានប្តូរដោយប្រើអត្រាប្តូរប្រាក់ថ្ងៃបិទបញ្ជី នាកាលបរិច្ឆេទរាយការណ៍។ លម្អៀងពីការប្តូរមូលធនភាគទុនិកត្រូវបានទទួលស្គាល់ផ្ទាល់ក្នុងមូលធនហើយរាល់លម្អៀងពីការប្តូរផ្សេងៗទៀតទាំងអស់ ត្រូវបានទទួលស្គាល់ក្នុងលទ្ធផលលម្អិតផ្សេងៗ។

ធនាគារបានប្រើអត្រាប្តូរប្រាក់ផ្លូវការដែលផ្សព្វផ្សាយដោយធនាគារកណ្តាល។ គិតត្រឹមកាលបរិច្ឆេទរាយការណ៍ អត្រាមធ្យមសម្រាប់ឆ្នាំនេះគឺ ១ដុល្លារអាមេរិក ស្មើនឹង ៤.០៧៧ រៀល (២០១៩ ៖ ១ដុល្លារអាមេរិកស្មើនឹង ៤.០៥២ រៀល) ហើយអត្រាបិទបញ្ជីគឺ ១ដុល្លារអាមេរិក ស្មើនឹង ៤.០៤៥រៀល (២០១៩ ៖ ១ដុល្លារអាមេរិក ស្មើនឹង ៤.០៧៥រៀល)។

## ២.៤ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

ក្នុងការបង្ហាញរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន សាច់ប្រាក់ក្នុងដៃ ប្រាក់បញ្ញើ និងការដាក់ប្រាក់មិនជាប់កម្រិតនៅធនាគារកណ្តាល ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារផ្សេងៗ និងការ វិនិយោគសាច់ប្រាក់ងាយស្រួលរយៈពេលខ្លីដែលមានរយៈពេលកំណត់បីខែ ឬតិចជាងបីខែ ដែលធនាគារអាចមាន លទ្ធភាពពេញលេញក្នុងការដកសាច់ប្រាក់ក្នុងគោលបំណងនៅពេលចាំបាច់ និងមានហានិភ័យបម្រែបម្រួលតម្លៃតិចតួច។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៥ ទ្រព្យសកម្មហិរញ្ញវត្ថុ

#### (ក) ចំណាត់ថ្នាក់

ធនាគារបែងចែកទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួន ទៅតាមចំណាត់ថ្នាក់នៃការវាស់វែងដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាស់វែងតាមថ្លៃដើមដករំលស់ រួមមាន សាច់ប្រាក់ក្នុងដៃ ប្រាក់បញ្ញើ និងការដាក់ ប្រាក់នៅធនាគារកណ្តាល និងធនាគារផ្សេងៗ ឥណទាន និងបុរេប្រទានវាស់វែងតាមថ្លៃដើមដករំលស់ ទ្រព្យសកម្មផ្សេងៗ និង
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាស់វែងនាពេលបន្ទាប់តាមតម្លៃសមស្រប ក្នុងលទ្ធផលលម្អិតផ្សេងៗ (OCI)

ការធ្វើចំណាត់ថ្នាក់នេះគឺអាស្រ័យទៅតាមគំរូអាជីវកម្មរបស់ធនាគារ ក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងលក្ខខណ្ឌក្នុងកិច្ចសន្យានៃលំហូរសាច់ប្រាក់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ។

ចំពោះទ្រព្យសកម្មដែលត្រូវបានវាស់វែងតាមតម្លៃសមស្រប ចំណេញឬខាតនឹងត្រូវបានកត់ត្រានៅក្នុងចំណេញ-ខាត ឬក្នុង OCI ។ ចំពោះការវិយោគក្នុងឧបករណ៍មូលធនដែលត្រូវបានកាន់កាប់សម្រាប់ការជួញដូរ ការកត់ត្រាគឺអាស្រ័យទៅលើជម្រើសរបស់ធនាគារនាពេលទទួលស្គាល់លើកដំបូង ថាតើធនាគារបានទទួលស្គាល់ការវិនិយោគមូលធនតាមតម្លៃសមស្របក្នុងលទ្ធផលលម្អិត (FVOCI) ឬទេ។

**(i) ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមតម្លៃសមស្របក្នុង OCI រួមមាន៖**

- មូលបត្រកម្មសិទ្ធិដែលមិនត្រូវបានកាន់កាប់សម្រាប់ការជួញដូរ ហើយដែលធនាគារបានជ្រើសរើសនាពេលទទួលស្គាល់លើកដំបូងតាមតម្លៃសមស្របក្នុងលទ្ធផលលម្អិតផ្សេងៗ ជាជាងក្នុងចំណេញ-ខាត។

**(ii) ធនាគារបានធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួនតាមថ្លៃដើមដករំលស់តែក្នុងករណីដែលស្របតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោមប៉ុណ្ណោះ ៖**

- ទ្រព្យសកម្មដែលត្រូវបានកាន់កាប់ក្នុងគំរូអាជីវកម្ម ដែលមានគោលបំណងដើម្បីប្រមូលលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យា និង
- លក្ខខណ្ឌក្នុងកិច្ចសន្យាដែលនាំឱ្យមានកាលបរិច្ឆេទជាក់លាក់នានា ចំពោះលំហូរសាច់ប្រាក់ ដែលជាការទូទាត់ប្រាក់ដើម និងការប្រាក់ទាំងស្រុង ទៅលើចំនួនប្រាក់ដើមដែលនៅមិនទាន់ទូទាត់។

#### (ខ) ការទទួលស្គាល់ និងការឈប់ទទួលស្គាល់

ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ នៅពេលដែលធនាគារក្លាយជាភាគីមួយក្នុងកិច្ចសន្យានៃឧបករណ៍ណាមួយ។ ការទិញនិងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុតាមមធ្យោបាយធម្មតា ត្រូវបានទទួលស្គាល់នាកាលបរិច្ឆេទជួញដូរ ជាកាលបរិច្ឆេទដែលធនាគារធ្វើការទិញ ឬលក់ទ្រព្យសកម្ម។

ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានគេឈប់ទទួលស្គាល់ នៅពេលដែលសិទ្ធិក្នុងការទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្មនោះបានហួសកាលកំណត់ ឬត្រូវបានផ្ទេរ ហើយធនាគារបានផ្ទេរនូវរាល់ហានិភ័យជាសារវន្ត និងផលកម្មសិទ្ធិទាំង អស់។ ចំណេញឬខាតពីការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ-ខាត នៅពេលដែលទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានគេឈប់ទទួលស្គាល់។

#### (គ) ការវាស់វែង

នាពេលទទួលស្គាល់លើកដំបូង ធនាគារវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុតាមតម្លៃសមស្រប បូកបន្ថែមជាមួយនឹងចំណាយប្រតិបត្តិការផ្សេងៗដែលបានចំណាយផ្ទាល់ក្នុងការទិញទ្រព្យសកម្មហិរញ្ញវត្ថុ ក្នុងករណីដែលទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានវាស់វែងតាមតម្លៃសមស្របក្នុងចំណេញ-ខាត (FVPL)។ បន្ទាប់ពីការទទួលស្គាល់លើកដំបូងភ្លាម សំវិធានធនសម្រាប់ការថយចុះតម្លៃឥណទានរំពឹងទុក (ECL) ត្រូវបានទទួលស្គាល់សម្រាប់ទ្រព្យសកម្មដែលត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ ដែលធ្វើឱ្យមានការខាតតាមគណនេយ្យមួយ ដែលត្រូវបានទទួលស្គាល់ក្នុងចំណេញ-ខាត នៅពេលទ្រព្យសកម្មមួយត្រូវបានបង្កើតឡើងថ្មី។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានដេរីវេទីវ ត្រូវបានគេគិតទៅលើចំនួនរបស់វាទាំងស្រុងនៅពេលធ្វើការកំណត់លំហូរសាច់ប្រាក់របស់វាសម្រាប់ការទូទាត់ប្រាក់ដើម និងការប្រាក់ទាំងស្រុង។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៥ ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

#### (គ) ការវាស់វែង (ត)

*ឧបករណ៍បំណុល*

ការវាស់វែងឧបករណ៍បំណុលគឺអាស្រ័យទៅលើគំរូអាជីវកម្មរបស់ធនាគារ ក្នុងការគ្រប់គ្រងទ្រព្យសកម្ម និង លក្ខណៈនៃលំហូរសាច់ប្រាក់របស់ទ្រព្យសកម្មនោះ។ ធនាគារធ្វើចំណាត់ថ្នាក់ឧបករណ៍បំណុលរបស់ខ្លួន ទៅក្នុងប្រភេទនៃការវាស់វែងណាមួយ ក្នុងចំណោមការវាស់វែងទាំងពីរប្រភេទ ដូចខាងក្រោម៖

(i) ថ្លៃដើមដករំលស់៖ ទ្រព្យសកម្មដែលត្រូវបានកាន់កាប់សម្រាប់ការប្រមូលលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យា ដែលលំហូរសាច់ប្រាក់នោះគឺជាការទូទាត់ប្រាក់ដើម និងការប្រាក់ទាំងស្រុង (SPPI) ត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់។ តម្លៃយោងនៃទ្រព្យសកម្មទាំងនេះត្រូវបានកែតម្រូវទៅតាមសំវិធានធនការខាតបង់ឥណទានរំពឹងទុកដែលបានទទួលស្គាល់។ ចំណូលការប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុទាំងនេះ ត្រូវបានដាក់បញ្ចូលនៅក្នុងចំណូលការប្រាក់ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាព។

(ii) ចំពោះឥណទានផ្តល់ឱ្យបុគ្គលិកដែលមានអត្រាការប្រាក់ទាបជាងអត្រាទីផ្សារ ត្រូវបានទទួលស្គាល់លើកដំបូងតាមតម្លៃបច្ចុប្បន្ននៃការទូទាត់សាច់ប្រាក់នាពេលអនាគត និងធ្វើអប្បហារតាមអត្រាការប្រាក់លើទីផ្សារនៃឥណទានប្រហាក់ប្រហែលគ្នា។ ចំនួនលម្អៀងរវាងសាច់ប្រាក់បានបង់ និងតម្លៃបច្ចុប្បន្ននៃសាច់ប្រាក់ក្នុងពេលអនាគតបានទទួល ត្រូវបានទទួលស្គាល់ជាលាភការរបស់បុគ្គលិក។ ចំនួនទឹកប្រាក់ទាំងនោះ ត្រូវបានទទួលស្គាល់ពន្យារ និងត្រូវបានដករំលស់ក្នុងចំណាយអត្ថប្រយោជន៍បុគ្គលិក ក្នុងចំណេញ-ខាតអាស្រ័យទៅតាមថិរវេលានៃឥណទាននោះ។

*ឧបករណ៍មូលធន*

ធនាគារវាស់វែងឧបករណ៍មូលធនទាំងអស់នៅពេលបន្ទាប់មក តាមតម្លៃសមស្រប។ ប្រសិនបើគណៈគ្រប់គ្រងធនាគារជ្រើសរើសបង្ហាញចំណេញឬខាតនៃតម្លៃសមស្របចំពោះការវិនិយោគមូលធន ក្នុងOCI នោះមិនមានការចាត់ថ្នាក់ឡើងវិញនាពេលបន្ទាប់មកចំពោះចំណេញឬខាតនៃតម្លៃសមស្របទៅក្នុងចំណេញ-ខាតទេ ដោយមានការអនុញ្ញាតឱ្យឈប់ទទួលស្គាល់ការវិនិយោគនោះ។ ភាគលាភបានពីការវិនិយោគប្រភេទនេះ ត្រូវបានបន្តទទួលស្គាល់ក្នុងចំណេញ-ខាត ជាចំណូលផ្សេងៗ នៅពេលដែលធនាគារមានសិទ្ធិទទួលការទូទាត់នោះ។ ការខាតដែលបណ្តាលមកពីការថយចុះតម្លៃ (និងការកត់ត្រាការខាតដែលបណ្តាលមកពីការថយចុះតម្លៃត្រឡប់ទៅវិញ) ចំពោះការវិនិយោគមូលធនដែលត្រូវបានវាស់វែងតាម FVOCI មិនត្រូវបានរាយការណ៍ដាច់ដោយឡែកពីការប្រែប្រួលតម្លៃសមស្របទេ។

#### (ឃ) ការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុឡើងវិញ

ធនាគារធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុឡើងវិញ នៅពេលដែលគំរូអាជីវកម្មសម្រាប់ការគ្រប់គ្រងទ្រព្យសកម្មរបស់ខ្លួន មានការប្រែប្រួល។

#### (ង) ការថយចុះតម្លៃ

ធនាគារវាយតម្លៃ ECL តាមមូលដ្ឋានរំពឹងមើលទៅថ្ងៃអនាគត ដែលទាក់ទងជាមួយនឹងឧបករណ៍បំណុលរបស់ខ្លួនដែលវាស់វែងតាមថ្លៃដើមដករំលស់ និងតាម FVOCI ជាហានិភ័យដែលកើតពីកិច្ចសន្យាផ្តល់ឥណទាន (រួមទាំង ឥណទានវិបារូបន៍ និងចំណែកឥណទាន និងបុរេប្រទានដែលមិនទាន់បានដក) និងកិច្ចសន្យាធានាផ្នែកហិរញ្ញវត្ថុ។ ធនាគារទទួលស្គាល់សំវិធានធនសម្រាប់ការខាតបង់ចំពោះការខាតប្រភេទនេះនាកាលបរិច្ឆេទរាយការណ៍។ ការវាស់វែង ECL ឆ្លុះបញ្ចាំងពី ៖

- ចំនួនលម្អៀង និងចំនួនដែលបានថ្លឹងប្រូបាប ដែលត្រូវបានកំណត់ដោយធ្វើការវាយតម្លៃលើលទ្ធភាពដែលអាចកើតឡើងមួយចំនួន
- ពេលវេលានៃតម្លៃទឹកប្រាក់ និង
- ព័ត៌មានដែលមានភាពសមហេតុផល និងមានការគាំទ្រ ដែលអាចរកបានដោយមិនចាំបាច់មានការចំណាយ និងការខំប្រឹងប្រែងលើសលប់នាកាលបរិច្ឆេទរាយការណ៍ អំពីព្រឹត្តិការណ៍នាពេលបច្ចុប្បន្ន និងការព្យាករអំពីលក្ខខណ្ឌនាពេលអនាគត

ធនាគារបានអនុវត្តវិធីសាស្ត្របីដំណាក់កាល ចំពោះការវាស់វែង ECL សម្រាប់ប្រភេទដូចខាងក្រោម៖

- ឧបករណ៍បំណុលដែលវាស់វែងតាមថ្លៃដើមដករំលស់ និង
- កិច្ចសន្យាផ្តល់ឥណទាន និងកិច្ចសន្យាធានាផ្នែកហិរញ្ញវត្ថុ

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៥ ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

#### (ង) ការថយចុះតម្លៃ (ត)

អនុវត្តវិធីសាស្ត្របីដំណាក់កាលផ្អែកទៅលើបម្រែបម្រួលហានិភ័យឥណទាន ចាប់តាំងពីការទទួលស្គាល់លើកដំបូង៖

**(i) ដំណាក់កាលទី ១ ៖ ECL ១២ខែ**

ដំណាក់កាលទី១រួមបញ្ចូលនូវទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមិនមានកំណើនហានិភ័យឥណទានគួរឱ្យកត់សម្គាល់ចាប់តាំងពីការទទួលស្គាល់លើកដំបូង ឬមានហានិភ័យឥណទានកម្រិតទាប នាកាលបរិច្ឆេទរាយការណ៍។ ECL ១២ខែ ត្រូវបានទទួលស្គាល់ ហើយចំណូលការប្រាក់ត្រូវបានគណនាតាមចំនួនតម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។

**(ii) ដំណាក់កាលទី ២ ៖ ECL ពេញមួយអាយុកាល – មិនមានការថយចុះតម្លៃឥណទាន**

ដំណាក់កាលទី ២ រួមមាន ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានកំណើនហានិភ័យឥណទានជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង (លើកលែងតែវាមានហានិភ័យឥណទានទាបនាកាលបរិច្ឆេទរាយការណ៍) ប៉ុន្តែមិនមានភ័ស្តុតាងជាក់ស្តែងបង្ហាញពីការថយចុះតម្លៃ។ ECL ពេញមួយអាយុកាលត្រូវបានទទួលស្គាល់ ហើយចំណូលការប្រាក់ត្រូវបានគណនាតាមចំនួនតម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។

**(iii) ដំណាក់កាលទី ៣ ៖ ECL ពេញមួយអាយុកាល – មានការថយចុះតម្លៃឥណទាន**

ដំណាក់កាលទី ៣ រួមមាន ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានភ័ស្តុតាងជាក់ស្តែងបង្ហាញពីការថយចុះតម្លៃ នាកាលបរិច្ឆេទរាយការណ៍។ ECL ពេញមួយអាយុកាលត្រូវបានទទួលស្គាល់ ហើយចំណូលការប្រាក់ត្រូវបានគណនាតាមចំនួនតម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។

#### (ច) ការកែប្រែឥណទាន និងបុរេប្រទាន

ជួនកាលធនាគារបានចរចាឡើងវិញ ឬបានកែប្រែលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យានៃឥណទានអតិថិជនឡើងវិញ។ នៅពេលដែលមានហេតុការណ៍នេះកើតឡើង ធនាគារវាយតម្លៃថាតើខ្លឹមសារនៃលក្ខខណ្ឌថ្មីមានភាពខុសគ្នាជា សារវន្តពីលក្ខខណ្ឌដំបូងឬទេ។ ធនាគារធ្វើបែបនេះដោយគិតពិចារណាទៅលើកត្តាផ្សេងៗ ក្នុងចំណោមកត្តាជាច្រើន ដូចខាងក្រោម៖

- ប្រសិនបើអ្នកខ្ចីប្រាក់មានផលវិបាកផ្នែកហិរញ្ញវត្ថុហើយការកែប្រែពិតជាអាចជួយកាត់បន្ថយលំហូរសាច់ប្រាក់ ក្នុងកិច្ចសន្យា ឱ្យនៅត្រឹមចំនួនដែលអ្នកខ្ចីប្រាក់រំពឹងថាមានលទ្ធភាពបង់ប្រាក់
- ថាតើមានលក្ខខណ្ឌថ្មីសំខាន់ៗត្រូវបានណែនាំ ដូចជាការបែងចែកប្រាក់ចំណេញ/ផលចំណេញដែលផ្អែកលើមូលធន ដែលមានផលប៉ះពាល់ជាសារវន្តលើទិន្នន័យហានិភ័យរបស់ឥណទាននោះ
- ការពន្យារពេលឥណទានជាក់លាក់ នៅពេលដែលអ្នកខ្ចីប្រាក់មិនមានផលវិបាកផ្នែកហិរញ្ញវត្ថុ
- ការប្រែប្រួលអត្រាការប្រាក់ជាក់លាក់
- ការផ្លាស់ប្តូរប្រភេទរូបិយប័ណ្ណរបស់ឥណទាន
- ការដាក់បញ្ចូលទ្រព្យបញ្ចាំ ការធានាផ្សេងៗ ឬការពង្រីកទំហំឥណទាន ដែលមានផលបះពាល់ជាសារវន្តលើ ហានិភ័យនៃឥណទាននោះ

ប្រសិនបើលក្ខខណ្ឌមានភាពខុសគ្នាជាសារវន្ត ធនាគារឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុដើម និងទទួលស្គាល់ទ្រព្យសកម្ម "ថ្មី" តាមតម្លៃសមស្រប និងគណនាអត្រាការប្រាក់មានប្រសិទ្ធភាពថ្មីសម្រាប់ទ្រព្យសកម្មឡើងវិញ។ បន្ទាប់មក កាលបរិច្ឆេទឈប់ទទួលស្គាល់ត្រូវបានចាត់ទុកជាកាលបរិច្ឆេទទទួលស្គាល់លើកដំបូង សម្រាប់ការគណនារកការថយចុះតម្លៃ រួមទាំងការកំណត់រកថាតើមានកំណើនហានិភ័យឥណទានជាសារវន្តបានកើតឡើងឬទេ។ ទោះជាយ៉ាងណាក៏ដោយ ធនាគារក៏វាយតម្លៃផងដែរថាតើទ្រព្យសកម្មហិរញ្ញវត្ថុថ្មីដែលបានទទួលស្គាល់ ត្រូវបានចាត់ទុកថាមានការថយចុះតម្លៃឥណទាន នាពេលទទួលស្គាល់លើកដំបូងឬទេ ជាពិសេសក្នុងកាលៈទេសៈដែលការចរចាត្រូវស្នើឡើងដោយកូនបំណុល ដែលមិនមានលទ្ធភាពទូទាត់សងប្រាក់ទៅតាមលក្ខខណ្ឌដែលបានព្រមព្រៀងរួចហើយ។ លម្អៀងនៃតម្លៃយោងត្រូវបានទទួលស្គាល់នៅក្នុងចំណេញ-ខាត ជា "ចំណេញឬខាត ពីការឈប់ទទួលស្គាល់"។

ប្រសិនបើលក្ខខណ្ឌមិនខុសគ្នាជាសារវន្ត នោះការចរចា ឬការកែប្រែមិនបណ្តាលឱ្យមានការឈប់ទទួលស្គាល់ទេ ហើយធនាគារគណនាតម្លៃយោងដុលឡើងវិញ អាស្រ័យទៅតាមលំហូរសាច់ប្រាក់នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែប្រែ និងទទួលស្គាល់ចំណេញឬខាតពីការកែប្រែនេះ នៅក្នុងចំណេញ-ខាត។ តម្លៃយោងដុលត្រូវបានគណនាឡើងវិញ ដោយធ្វើអប្បហារលំហូរសាច់ប្រាក់ដែលបានកែប្រែ តាមអត្រាការប្រាក់មានប្រសិទ្ធភាពដំបូង (ឬ អត្រាការប្រាក់មានប្រសិទ្ធភាពដែលបានកែតម្រូវឥណទាន សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការថយចុះតម្លៃឥណទានដែលបានទិញ ឬបានបង្កើតឡើង។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៦ បំណុលហិរញ្ញវត្ថុ

បំណុលហិរញ្ញវត្ថុត្រូវបានទទួលស្គាល់នៅពេលដែលធនាគារក្លាយជាភាគីមួយ នៅក្នុងកិច្ចសន្យានៃឧបករណ៍ណាមួយ។ បំណុលហិរញ្ញវត្ថុរបស់ធនាគាររួមមាន ប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ប្រាក់បញ្ញើរបស់អតិថិជន ប្រាក់កម្ចី បំណុលភតិសន្យា និងបំណុលហិរញ្ញវត្ថុផ្សេងៗ។

បំណុលហិរញ្ញវត្ថុត្រូវបានទទួលស្គាល់លើកដំបូងតាមតម្លៃសមស្រប ដកចំណាយប្រតិបត្តិការ ចំពោះបំណុលប្រតិបត្តិការទាំងអស់ដែលមិនវាស់វែងតាមតម្លៃសមស្រប ក្នុងចំណេញ-ខាត។

បំណុលហិរញ្ញវត្ថុដែលមិនត្រូវបានចាត់ថ្នាក់តាមតម្លៃសមស្របក្នុងចំណេញ-ខាត ត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់។ បំណុលហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ មានដូចជា ប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ប្រាក់បញ្ញើរបស់អតិថិជន ប្រាក់កម្ចី បំណុលភតិសន្យា និងបំណុលផ្សេងៗ។

បំណុលហិរញ្ញវត្ថុត្រូវបានគេឈប់ទទួលស្គាល់ នៅពេលដែលវាត្រូវបានបង្វិលអស់ ឬបើមិនដូច្នោះទេវាត្រូវបានព្រមព្រៀងឱ្យបញ្ឈប់ការសងប្រាក់តទៅទៀត។

### ២.៧ កិច្ចសន្យាផ្តល់ឥណទាន និងកិច្ចសន្យាធានាផ្នែកហិរញ្ញវត្ថុ

កិច្ចសន្យាផ្តល់ឥណទានដែលធនាគារបានផ្តល់ ត្រូវបានវាស់វែងតាមចំនួនសំវិធានធនបាត់បង់។ ធនាគារមិនបានផ្តល់កិច្ចសន្យាផ្តល់ឥណទានណាមួយ ដែលមានអត្រាការប្រាក់ទាបជាងអត្រាទីផ្សារទេ ឬកិច្ចសន្យាដែលអាចត្រូវបានទូទាត់ជាសាច់ប្រាក់សុទ្ធ ឬតាមរយៈការផ្តល់ ឬការចេញឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតទេ។

កិច្ចសន្យាធានាផ្នែកហិរញ្ញវត្ថុគឺជាកិច្ចសន្យាទាំងឡាយណាដែលតម្រូវឱ្យអ្នកចេញផ្សាយការធានា ធ្វើការទូទាត់ជាក់លាក់មួយដើម្បីផ្តល់សំណងទៅអ្នកកាន់កាប់ ចំពោះការខាតបង់ដែលកើតមានឡើង ដោយសារកូនបំណុលណាមួយមិនបានសងបំណុលនៅពេលដល់ថ្ងៃកំណត់ ដោយអនុលោមទៅតាមលក្ខខណ្ឌនៃឧបករណ៍បំណុលនោះ។ ការធានាផ្នែកហិរញ្ញវត្ថុប្រភេទនេះ គឺត្រូវបានផ្តល់ឱ្យធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុ និងអង្គភាពផ្សេងៗជំនួសគ្រឹះស្ថានទាំងនេះ ដើម្បីធានាលើឥណទាន ឥណទានវិបារូបន៍ និងហ្វាស៊ីលីធីធនាគារផ្សេងៗ។

ការធានាផ្នែកហិរញ្ញវត្ថុត្រូវបានទទួលស្គាល់លើកដំបូងក្នុងរបាយការណ៍ហិរញ្ញវត្ថុ តាមតម្លៃសមស្រប នាកាលបរិច្ឆេទផ្តល់ការធានានោះ។ ការធានាត្រូវបានព្រមព្រៀងតាមលក្ខខណ្ឌស្ម័គ្រចិត្តស្មើភាពគ្នា ហើយតម្លៃបុព្វលាភដែលបានព្រមព្រៀងមានចំនួនប្រហាក់ប្រហែលនឹងតម្លៃនៃកាតព្វកិច្ចក្នុងការធានា។ បុព្វលាភដែលត្រូវទទួលនាពេលអនាគត មិនត្រូវបានទទួលស្គាល់ទេ។ បន្ទាប់មកកិច្ចសន្យាធានាផ្នែកហិរញ្ញវត្ថុ ត្រូវបានវាស់វែងតាមចំនួនណាមួយដែលខ្ពស់ជាងគេរវាងចំនួនដែលត្រូវបានកំណត់ដោយផ្អែកទៅតាមគំរូ ECL ក្រោម CIFRS ៩ ស្តីពី "ឧបករណ៍ហិរញ្ញវត្ថុ" និងចំនួនដែលត្រូវបានទទួលស្គាល់លើកដំបូងដកនឹងចំនួនប្រាក់ចំណូលបង្គរ ដែលត្រូវបានទទួលស្គាល់ដោយផ្អែកទៅតាមគោលការណ៍របស់ CIFRS ១៥ ស្តីពី "ប្រាក់ចំណូលពីកិច្ចសន្យាជាមួយអតិថិជន" ទៅតាមការសមស្រប។

ការប៉ាន់ស្មានត្រូវបានកំណត់ដោយផ្អែកទៅតាមបទពិសោធន៍នៃប្រតិបត្តិការប្រហាក់ប្រហែលគ្នា និងប្រវត្តិនៃការខាតបង់ក្នុងគ្រាកន្លងមក និងបូកបន្ថែមជាមួយនឹងការវិនិច្ឆ័យរបស់គណៈគ្រប់គ្រង។ ចំណូលកម្រៃសោយហ៊ុយដែលរកបាន ត្រូវបានទទួលស្គាល់តាមមូលដ្ឋានថេរ អាស្រ័យទៅតាមអាយុកាលនៃការធានានោះ។

កំណើនបំណុលដែលពាក់ព័ន្ធនឹងការធានា ត្រូវបានរាយការណ៍នៅក្នុងចំណេញ-ខាត ក្នុងខ្ទង់ចំណាយប្រតិបត្តិការ។

ចំពោះកិច្ចសន្យាផ្តល់ឥណទាន និងកិច្ចសន្យាហិរញ្ញវត្ថុ ECL ត្រូវបានទទួលស្គាល់ជាសំវិធានធន (ដែលត្រូវបានបង្ហាញក្នុងបំណុលផ្សេងៗ)។ ទោះជាយ៉ាងណាក៏ដោយ ចំពោះកិច្ចសន្យាដែលរួមបញ្ចូលទាំងឥណទាន និងកិច្ចសន្យាដែលមិនទាន់ដកប្រាក់ ហើយដែលធនាគារមិនអាចកំណត់ ECL ដាច់ដោយឡែក ចំពោះកិច្ចសន្យាឥណទានដែលមិនទាន់ដកប្រាក់ពីសមាសធាតុឥណទានទាំងនោះ ECL នៃកិច្ចសន្យាដែលមិនទាន់ដកប្រាក់ ត្រូវបានទទួលស្គាល់រួមគ្នាក្នុងសំវិធានធនសម្រាប់ការខាតបង់ឥណទាន។ ក្នុងករណីដែល ECL រួមបញ្ចូលគ្នា លើសពីតម្លៃយោងដុលរបស់ឥណទាន នោះ ECL ត្រូវបានទទួលស្គាល់ជាសំវិធានធន។

### ២.៨ ការកាត់កងឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កង ហើយចំនួនទឹកប្រាក់សុទ្ធបន្ទាប់ពីកាត់កងត្រូវបានរាយការណ៍នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលធនាគារមានសិទ្ធិតាមផ្លូវច្បាប់ក្នុងការកាត់កងចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ ហើយធនាគារមានបំណងនឹងទូទាត់តាមមូលដ្ឋានចំនួនទឹកប្រាក់សុទ្ធ ឬមានបំណងទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)



## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៩ ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានរាយការណ៍តាមថ្លៃដើម ដករំលស់បង្គរ។ ថ្លៃដើមរួមមានចំណាយផ្ទាល់ផ្សេងៗ ដែលបានចំណាយក្នុងការទិញទ្រព្យនោះ។

ចំណាយបន្តបន្ទាប់ផ្សេងៗត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យនោះ ឬត្រូវបានទទួលស្គាល់ជាទ្រព្យដាច់ដោយឡែកតាមការសមស្របតែនៅពេលដែលមានភាពប្រាកដថាផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតនៃទ្រព្យនោះនឹងហូរចូលមកក្នុងធនាគារ ហើយថ្លៃដើមនៃទ្រព្យនោះអាចត្រូវបានវាស់វែងគួរឱ្យជឿជាក់បានតែប៉ុណ្ណោះ។ រាល់ចំណាយលើការជួសជុល និងការថែទាំផ្សេងៗទៀតទាំងអស់ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផល ក្នុង ការិយបរិច្ឆេទហិរញ្ញវត្ថុដែលប្រតិបត្តិការនោះកើតឡើង។

សំណង់កំពុងសាងសង់មិនត្រូវបានដករំលស់ទេ។ ការដករំលស់លើទ្រព្យសម្បត្តិនិងបរិក្ខារ ត្រូវបានគណនាដោយប្រើប្រាស់វិធីសាស្ត្ររំលស់ថេរដើម្បីបែងចែកថ្លៃដើមទៅនឹងតម្លៃសំណល់របស់វា អាស្រ័យទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មាននៃទ្រព្យនោះ ដូចខាងក្រោម៖

| | រយៈពេលរំលស់គិតជាឆ្នាំ |
|---|---|
| ការកែលម្អលើទ្រព្យជួល | រយៈពេលណាមួយដែលខ្លីជាង រវាងចិរវេលានៃកិច្ចសន្យាជួល និងអាយុកាលសេដ្ឋកិច្ចរបស់វាចំនួន ១០ឆ្នាំ |
| បរិក្ខារការិយាល័យ | ៥ |
| គ្រឿងសង្ហារិម និងបរិក្ខារបំពាក់ | ៥ |
| បរិក្ខារកុំព្យូទ័រ | ៣ - ៥ |
| យានយន្ត | ៥ |

ការដករំលស់លើសំណង់កំពុងសាងសង់ ចាប់ផ្តើមឡើងនៅពេលដែលទ្រព្យសកម្មមានភាពរួចរាល់សម្រាប់ការប្រើប្រាស់។ អាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មត្រូវបានត្រួតពិនិត្យ និងកែតម្រូវតាមការសមស្រប នាដំណាច់កាលបរិច្ឆេទរាយការណ៍។

ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្មណាមួយ លើសពីតម្លៃដែលអាចស្រង់មកវិញបាន វាត្រូវបានកត់ត្រាបន្ថយភ្លាមឱ្យនៅត្រឹមតម្លៃប៉ាន់ស្មានដែលអាចស្រង់មកវិញបាន។

ចំណេញ និងខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀបសាច់ប្រាក់បានពីការលក់ និងតម្លៃយោង ហើយត្រូវបានទទួលស្គាល់នៅក្នុងចំណេញ-ខាត។

### ២.១០ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីដែលរួមមានអាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ និងចំណាយពាក់ព័ន្ធផ្សេងៗ ត្រូវបានរាយការណ៍តាមថ្លៃដើម ដករំលស់បង្គរ និងការខាតដែលបណ្តាលមកពីការថយចុះតម្លៃ។ អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ ត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើមដែលបានកើតឡើង ក្នុងការទិញកម្មវិធីជាក់លាក់នោះមកប្រើប្រាស់។ ថ្លៃដើមត្រូវបានធ្វើរំលស់តាមវិធីសាស្ត្ររំលស់ថេរ លើអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់វាក្នុងរយៈពេល៥ឆ្នាំ។

ចំណាយនានាពាក់ព័ន្ធនឹងការថែរក្សាកម្មវិធីកុំព្យូទ័រ ត្រូវបានកត់ត្រាជាចំណាយនៅពេលដែលប្រតិបត្តិការនោះបានកើតឡើង។

### ២.១១ ការថយចុះតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មរូបីទាំងឡាយណាដែលមានអាយុកាលប្រើប្រាស់មិនកំណត់ មិនត្រូវបានដករំលស់ទេ និងត្រូវបានត្រួតពិនិត្យប្រចាំឆ្នាំរកការថយចុះតម្លៃរបស់វា ឬញឹកញាប់ជាងនេះ នៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈណាមួយចង្អុលបង្ហាញថាវាអាចមានការថយចុះតម្លៃ។ ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុផ្សេងៗដែលត្រូវដករំលស់ ត្រូវបានត្រួតពិនិត្យ និងត្រូវបានត្រួតពិនិត្យរកការថយចុះតម្លៃ នៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈណាមួយចង្អុលបង្ហាញថា តម្លៃយោងរបស់វានឹងមិនអាចស្រង់មកវិញបាន។ ការខាតបង់បណ្តាលមកពីការថយចុះតម្លៃ ត្រូវបានទទួលស្គាល់តាមចំនួនលម្អៀងរវាងតម្លៃយោងនៃទ្រព្យនោះ ធៀបជាមួយតម្លៃដែលអាចស្រង់មកវិញបាន។ តម្លៃដែលអាចស្រង់មកវិញបានគឺជាតម្លៃមួយណាដែលខ្ពស់ជាងគេរវាងតម្លៃសមស្របនៃទ្រព្យនោះ ដកចំណាយក្នុងការលក់ចេញ និងតម្លៃនៅប្រើប្រាស់។ ក្នុងការប៉ាន់ស្មានរកការថយចុះតម្លៃ ទ្រព្យសកម្មត្រូវបានដាក់ជាក្រុមតូចៗបំផុត ដែលគេអាចកំណត់លំហូរសាច់ប្រាក់របស់វាដាច់ដោយឡែកពីគ្នា ដែលវាមានឯករាជ្យទាំងស្រុងពីលំហូរសាច់ប្រាក់ចូលរបស់ទ្រព្យសកម្ម ឬក្រុមទ្រព្យសកម្មដទៃ (ក្រុមបង្កើតសាច់ប្រាក់)។ ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលមានការថយចុះតម្លៃ ត្រូវបានត្រួតពិនិត្យរកមើលលទ្ធភាពក្នុងការកត់ត្រាការថយចុះតម្លៃត្រឡប់ទៅវិញ នៅរៀងរាល់ដំណាច់ការិយបរិច្ឆេទរាយការណ៍នីមួយៗ។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១១ ការថយចុះតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ (ត)

ការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាជាបន្ទុកក្នុងចំណេញ-ខាតក្នុងការិយបរិច្ឆេទដែលប្រតិបត្តិការនោះបានកើតឡើង។ ការកត់ត្រាត្រលប់មកវិញនៃការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានទទួលស្គាល់ក្នុងចំណេញ-ខាតទៅតាមចំនួនតម្លៃយោងនៃទ្រព្យសកម្មនោះ ដែលមិនលើសតម្លៃយោងដែលបានកំណត់ កាត់កងជាមួយនឹងរំលស់ ប្រសិនបើមិនបានទទួលស្គាល់ការខាតដែលបណ្តាលមកពីការថយចុះតម្លៃ។

### ២.១២ ភតិសន្យា

*ធនាគារជាភាគីអ្នកជួល*

នៅពេលចាប់ផ្តើមកិច្ចសន្យា ធនាគារវាយតម្លៃថាតើកិច្ចសន្យានោះ ឬខ្លឹមសាររបស់វាជាភតិសន្យាដែរឬទេ។ កិច្ចសន្យាមួយ ឬ ខ្លឹមសារនៃកិច្ចសន្យាមួយត្រូវបានចាត់ទុកថាជាភតិសន្យាប្រសិនបើកិច្ចសន្យានោះផ្តល់សិទ្ធិក្នុងការគ្រប់គ្រងការប្រើប្រាស់ទ្រព្យសកម្មដែលត្រូវបានកំណត់ ក្នុងរយៈពេលណាមួយជាថ្នូរនឹងការបង់ប្រាក់។

កិច្ចសន្យាអាចមានទាំងធាតុភតិសន្យា និងធាតុមិនមែនភតិសន្យា។ ធនាគារបានបែងចែកសាច់ប្រាក់ក្នុងកិច្ចសន្យា ជាធាតុភតិសន្យា និងធាតុមិនមែនភតិសន្យាអាស្រ័យថ្លៃឈ្នួលដែលពាក់ព័ន្ធរបស់វា។

លក្ខខណ្ឌក្នុងភតិសន្យាត្រូវបានចរចាឡើងវិញតាមមូលដ្ឋានដាច់ដោយឡែក និងមានលក្ខខណ្ឌខុសៗពីគ្នា។ កិច្ចព្រមព្រៀងភតិសន្យាមិនបានបណ្តាលឱ្យមានកិច្ចសន្យាណាមួយ ក្រៅពីអត្ថប្រយោជន៍ដែលបានជានា នៅក្នុងទ្រព្យសកម្មភតិសន្យាដែលត្រូវបានកាន់កាប់ដោយភាគីម្ចាស់ជួលនោះទេ។ ទ្រព្យសកម្មដែលត្រូវបានជួល អាចនឹងមិនត្រូវបានប្រើប្រាស់ជាទ្រព្យធានាក្នុងការខ្ចីប្រាក់ទេ។

ភតិសន្យាត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ និងជាបំណុលពាក់ព័ន្ធ នាកាលបរិច្ឆេទដែលទ្រព្យសកម្មដែលបានជួល មានភាពរួចរាល់សម្រាប់ប្រើប្រាស់។

ទ្រព្យសកម្ម និងបំណុលដែលកើតពីភតិសន្យា ត្រូវបានទទួលស្គាល់លើកដំបូងតាមមូលដ្ឋានតម្លៃបច្ចុប្បន្ន។

#### (ក) បំណុលភតិសន្យា

បំណុលភតិសន្យារួមបញ្ចូលនូវតម្លៃបច្ចុប្បន្នសុទ្ធនៃការទូទាត់ភតិសន្យាថេរ (រួមទាំង ការបង់ប្រាក់ថេរផ្សេងៗ)ដកនឹងការលើកទឹកចិត្តផ្សេងៗសម្រាប់ការជួលដែលត្រូវទទួលបាន។

ការទូទាត់ភតិសន្យាដែលត្រូវធ្វើឡើងក្រោមជម្រើសដែលអាចពន្យាររយៈពេលបាន ប្រកបដោយភាពសមហេតុផល ត្រូវបានរួមបញ្ចូលនៅក្នុងការវាស់វែងបំណុល។

ការទូទាត់ភតិសន្យាត្រូវបានធ្វើអប្បហារ ដោយប្រើអត្រាជាក់ស្តែងក្នុងភតិសន្យា។ ប្រសិនបើអត្រាការប្រាក់មិនអាចកំណត់បានដោយភាពងាយស្រួលនោះ ដែលជាទូទៅចំពោះករណីភតិសន្យានៅក្នុងធនាគារ ភាគីអ្នកជួលត្រូវបានប្រើប្រាស់អត្រាកំណើនប្រាក់កម្ចីនោះ ហើយវាគឺជាអត្រាដែលភាគីអ្នកជួលនីមួយៗត្រូវចំណាយ ដើម្បីទទួលបានប្រាក់កម្ចី ដែលមានភាពចាំបាច់ ដើម្បីទទួលបានទ្រព្យសកម្មដែលមានតម្លៃប្រហាក់ប្រហែលនឹងទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ នៅក្នុងបរិយាកាសសេដ្ឋកិច្ចស្រដៀងគ្នា ជាមួយនឹងលក្ខខណ្ឌ និងការធានាប្រហាក់ប្រហែលគ្នា។

ដើម្បីកំណត់អត្រាកំណើនប្រាក់កម្ចី ធនាគារអាចធ្វើទៅបានដោយប្រើហិរញ្ញប្បទានភាគីទីបីដែលទទួលបានពីភាគីអ្នកជួលនីមួយៗ គឺជាចំណុចចាប់ផ្តើម ហើយកែតម្រូវលើការផ្លាស់ប្តូរលក្ខខណ្ឌហិរញ្ញប្បទាន ចាប់តាំងពីហិរញ្ញប្បទានភាគីទីបីទទួលបាន។

ការទូទាត់ភតិសន្យាត្រូវបានបែងចែករវាងប្រាក់ដើម និងចំណាយការប្រាក់។ ចំណាយការប្រាក់ត្រូវបានកត់ត្រាជាបន្ទុកក្នុងចំណេញ-ខាត ក្នុងរយៈពេលនៃភតិសន្យានោះ ដើម្បីបង្កើតអត្រាការប្រាក់ថេរតាមកាលកំណត់មួយ លើចំនួនសមតុល្យបំណុលដែលនៅសល់ ក្នុងការិយបរិច្ឆេទនីមួយៗ។

#### (ខ) ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់

ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ត្រូវបានទទួលស្គាល់លើកដំបូងតាមថ្លៃដើម ដែលរួមមាន៖

- ចំនួនទឹកប្រាក់នៃបំណុលភតិសន្យាដែលបានវាស់វែងលើកដំបូង
- ការទូទាត់ភតិសន្យាណាមួយដែលបានធ្វើឡើងនៅកាលបរិច្ឆេទចាប់ផ្តើម ឬមុនកាលបរិច្ឆេទចាប់ផ្តើម ដកការលើកទឹកចិត្តផ្សេងៗដែលទទួលបានពីការជួល

# RHB◆ កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)



## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១២ ភតិសន្យា (ត)

#### (ខ) ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ (ត)

- ចំណាយផ្ទាល់លើកដំបូង និង
- ចំណាយសម្រាប់ការជួសជុសឡើងវិញ ប្រសិនបើមាន

ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ ជាទូទៅត្រូវបានដករំលស់តាមមូលដ្ឋានរំលស់ថេរ លើរយៈពេលណាមួយដែលខ្លីជាងគេរវាង អាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម និងរយៈពេលជួល។ ប្រសិនបើធនាគារមានបំណងជាក់លាក់ដ៏សមហេតុផលក្នុងការទិញ នោះទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់នោះត្រូវបានដករំលស់ លើអាយុកាលប្រើប្រាស់មូលដ្ឋានរបស់ទ្រព្យសកម្មនោះ។

បន្ទាប់មកទៀត ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ ត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ និងការខាតដែលបណ្តាលមកពីការថយចុះតម្លៃបង្គរ ប្រសិនបើមាន។

#### (គ) ការទូទាត់ភតិសន្យាក្រោមការលើកលែងផ្សេងៗ

ការទូទាត់នានាដែលពាក់ព័ន្ធនឹងភតិសន្យាដែលមានរយៈពេលខ្លី ត្រូវបានទទួលស្គាល់តាមមូលដ្ឋានថេរ ជាចំណាយនៅក្នុងចំណេញ-ខាត។ ភតិសន្យារយៈពេលខ្លី គឺជាភតិសន្យាទាំងឡាយណាដែលមានរយៈពេលជួល១២ខែ ឬតិចជាង១២ខែ។

ការទូទាត់ភតិសន្យារយៈពេលខ្លី ត្រូវបានទទួលស្គាល់តាមមូលដ្ឋានថេរ ជាចំណាយក្នុងចំណេញ-ខាត។ ភតិសន្យារយៈពេលខ្លី គឺជាភតិសន្យាទាំងឡាយណាដែលមានរយៈពេលជួល១២ខែ ឬតិចជាង១២ខែ ដោយមិនមានជម្រើសក្នុងការទិញ។

### ២.១៣ ពន្ធលើប្រាក់ចំណូល

ចំណាយពន្ធលើប្រាក់ចំណូលគឺជាចំនួនប្រាក់ពន្ធត្រូវបង់ លើប្រាក់ចំណូលជាប់ពន្ធក្នុងការិយបរិច្ឆេទបច្ចុប្បន្ន ផ្អែកទៅតាមអត្រាពន្ធលើប្រាក់ចំណូលដែលចូលជរមាន និងធ្វើនិយ័តកម្មទៅតាមបម្រែបម្រួលពន្ធពន្យារទ្រព្យសកម្ម និងបំណុលពន្ធពន្យារ ដែលបណ្តាលឱ្យមានលម្អៀងបណ្តោះអាសន្ន និងការខាតពន្ធដែលមិនបានប្រើប្រាស់។

ចំណាយពន្ធលើប្រាក់ចំណូលក្នុងគ្រាត្រូវបានគណនាតាមមូលដ្ឋានច្បាប់ពន្ធ ដែលបានអនុម័តរួចជាស្ថាពរ ឬត្រូវបានអនុម័តរួចមួយផ្នែកធំ នាកាលបរិច្ឆេទរាយការណ៍ នៅក្នុងប្រទេសដែលធនាគារធ្វើប្រតិបត្តិការអាជីវកម្ម និងបង្កើតប្រាក់ចំណេញជាប់ពន្ធ។ គណៈគ្រប់គ្រងវាយតម្លៃទៅតាមការិយបរិច្ឆេទ អំពីស្ថានភាពដែលបានកើតឡើងក្នុងលិខិតប្រកាសពន្ធ ដែលទាក់ទិនទៅនឹងស្ថានភាពដែលត្រូវអនុវត្តបទប្បញ្ញត្តិពន្ធ និងបំណកស្រាយរបស់វា និងបានពិចារណាថាតើអាជ្ញាធរពន្ធដារនឹងទទួលយកការកត់ត្រាពន្ធដែលមិនមានភាពច្បាស់លាស់ឬទេ។ ធនាគារវាស់វែងសមតុល្យពន្ធរបស់ខ្លួន ដោយផ្អែកទៅលើចំនួនដែលប្រាកដជាត្រូវបង់ ឬតម្លៃរំពឹងទុក អាស្រ័យទៅលើវិធីសាស្រ្តដែលផ្តល់នូវការព្យាករល្អជាងមុន អំពីដំណោះស្រាយចំពោះភាពមិនច្បាស់លាស់។

ពន្ធពន្យារត្រូវបានកត់ត្រាសំវិធានធនពេញលេញ ដោយប្រើវិធីសាស្រ្តបំណុល លើចំនួនលម្អៀងបណ្តោះអាសន្នរវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងបំណុល និងតម្លៃយោងរបស់វានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ពន្ធពន្យារត្រូវបានកំណត់ដោយប្រើអត្រាពន្ធតាមច្បាប់ពន្ធ ដែលត្រូវបានអនុម័តរួចជាស្ថាពរ ឬត្រូវបានអនុម័តរួចមួយផ្នែកធំ នាកាលបរិច្ឆេទ រាយការណ៍ និងរំពឹងថាត្រូវអនុវត្តនៅពេលពន្ធពន្យារទ្រព្យសកម្មពាក់ព័ន្ធត្រូវបានទទួលស្គាល់ ឬ បំណុលពន្ធលើប្រាក់ចំណូលពន្យារត្រូវបានទូទាត់។

ពន្ធពន្យារទ្រព្យសកម្មត្រូវបានទទួលស្គាល់ លុះត្រាតែមានភាពប្រាកដថានឹងមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតសម្រាប់យកលម្អៀងបណ្តោះអាសន្នមកប្រើប្រាស់។ ពន្ធពន្យារទ្រព្យសកម្មត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ ហើយត្រូវបានកាត់បន្ថយទៅតាមចំនួន ដែលទំនងជាមិនមានប្រាក់ចំណេញជាប់ពន្ធត្រូវបានទទួលស្គាល់។

ពន្ធពន្យារទ្រព្យសកម្មត្រូវបានកាត់កងជាមួយនឹងបំណុលពន្ធពន្យារ ប្រសិនបើមានសិទ្ធិតាមផ្លូវច្បាប់ដើម្បីកាត់កងបំណុលពន្ធក្នុងឆ្នាំជាមួយនឹងពន្ធទ្រព្យសកម្មក្នុងឆ្នាំ ហើយប្រសិនបើវាទាក់ទងនឹងពន្ធលើប្រាក់ចំណូលដែលកំណត់ដោយអាជ្ញាធរពន្ធដារតែមួយ ទៅលើអង្គភាពជាប់ពន្ធតែមួយ។

ពន្ធក្នុងឆ្នាំ និងពន្ធពន្យារត្រូវបានទទួលស្គាល់នៅក្នុងចំណេញ-ខាត លើកលែងតែវាពាក់ព័ន្ធជាមួយនឹងខ្ទង់ ផ្សេងៗដែលបានទទួលស្គាល់ផ្ទាល់ក្នុងលទ្ធផលលម្អិតផ្សេងៗ ឬក្នុងមូលធន។ ក្នុងករណីនេះ ពន្ធត្រូវបានទទួលស្គាល់ក្នុងលទ្ធផលលម្អិតផ្សេងៗ ឬត្រូវបានទទួលស្គាល់ផ្ទាល់ក្នុងមូលធនដែរ។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១៤ សំវិធានធន

សំវិធានធនត្រូវបានទទួលស្គាល់នៅពេលដែលធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ហើយវាទំនងជាអាចតម្រូវឱ្យមានការចំណាយធនធានដើម្បីទូទាត់កាតព្វកិច្ចនោះហើយចំនួនទឹកប្រាក់ត្រូវបានប៉ាន់ស្មានគួរឱ្យជឿជាក់បាន។

នៅពេលដែលមានកាតព្វកិច្ចស្រដៀងគ្នាច្រើន កម្រិតនៃលំហូរចេញដើម្បីទូទាត់កាតព្វកិច្ចនោះ ត្រូវបានកំណត់ដោយគិតទៅលើចំណាត់ថ្នាក់នៃកាតព្វកិច្ចទាំងមូល។ សំវិធានធនត្រូវបានទទួលស្គាល់ ទោះបីជាកម្រិតនៃលំហូរចេញដើម្បីទូទាត់កាតព្វកិច្ចនោះមានចំនួនតូចក៏ដោយ។

សំវិធានធនត្រូវបានគណនាតាមតម្លៃបច្ចុប្បន្ននៃចំណាយដែលត្រូវទូទាត់កាតព្វកិច្ចនោះ ដោយប្រើអត្រាមុនបង់ពន្ធ ដើម្បីឆ្លុះបញ្ចាំងការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃសាច់ប្រាក់គិតតាមពេលវេលា និងហានិភ័យជាក់លាក់ផ្សេងៗនៃកាតព្វកិច្ចនោះ។ ការកើនឡើងនៃសំវិធានធនដោយសារពេលវេលាដែលបានកន្លងផុត ត្រូវបានទទួលស្គាល់ជាចំណាយការប្រាក់។

### ២.១៥ ទុនបម្រុង

#### (ក) ទុនបម្រុងតាមច្បាប់

ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុត្រូវបានតម្រូវឱ្យគណនាសំវិធានធនតាមច្បាប់ អនុលោមទៅតាមប្រកាសលេខធ៧-០១៧-៣៤៤ប្រ.ក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ និងសារាចរណែនាំលេខ ធ៧-០១៨-០០១ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពី “ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអឹមតែរមិន”។ ប្រសិនបើសំវិធានធនតាមច្បាប់បង្គរ មានចំនួនខ្ពស់ជាងការថយចុះតម្លៃបង្គរផ្អែកតាម CIFRS 9 នោះ ‘ការបំពេញបន្ថែម - topping up’ នឹងត្រូវបានកត់ត្រាជាទុនបម្រុងតាមច្បាប់ និងត្រូវបានបង្ហាញនៅក្នុងមូលធន។ បន្ទាប់មក ទុនបម្រុងត្រូវបានកត់ត្រាត្រឡប់ទៅវិញ (រហូតដល់សូន្យ) ប្រសិនបើសំវិធានធនតាមច្បាប់បង្គរ មានចំនួនស្មើគ្នា ឬ ទាបជាងការថយចុះតម្លៃបង្គរដែលផ្អែកតាម CIFRS 9 ។ ទុនបម្រុងតាមច្បាប់ត្រូវបានតម្កល់ទុកមួយឡែក ជាទ្រទាប់ទុន ហើយមិនអាចបែងចែកបាន និងមិនត្រូវបានអនុញ្ញាតឱ្យរួមបញ្ចូលនៅក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធទេ។

#### (ខ) ទុនបម្រុងមិនសម្រាប់បែងចែក

ទុនបម្រុងមិនសម្រាប់បែងចែកត្រូវបានរក្សាទុក យោងទៅតាមការអនុម័តរបស់ធនាគារកណ្តាល នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ស្តីពីការស្នើឱ្យធនាគារផ្ទេរប្រាក់ចំណេញរក្សាទុក ដោយអនុលោមទៅតាមប្រកាសរបស់ធនាគារកណ្តាល លេខ ធ៧-០១៨-០៦៨ ប្រ.ក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការកំណត់ទ្រទាប់ដើមទុនរបស់ធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុ។ បម្រែបម្រួលណាមួយតម្រូវឱ្យមានការអនុម័តពីក្រុមប្រឹក្សាភិបាល និងធនាគារកណ្តាល។

### ២.១៦ អត្ថប្រយោជន៍បុគ្គលិក

#### (ក) អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី

អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លីត្រូវបានកត់ត្រាបង្គរ ក្នុងឆ្នាំដែលបុគ្គលិកបានបម្រើការងារឱ្យធនាគារ។

#### (ខ) អត្ថប្រយោជន៍បុគ្គលិករយៈពេលវែងផ្សេងៗ - ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ

នៅខែមិថុនា ឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើវិសោធនកម្មលើច្បាប់ស្តីពីការងារ ដែលណែនាំពីគម្រោងការទូទាត់ប្រាក់បំណាច់អតីតភាពការងារ។ បន្ទាប់មកនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ប្រកាសលេខ ៤៤៣ ក.ប/ប្រ.ក.ខ.ល ត្រូវបានចេញផ្សាយ ដោយបានផ្តល់នូវគោលការណ៍ណែនាំស្តីពីការអនុវត្តច្បាប់នេះ។ អនុលោមទៅតាមច្បាប់/ប្រកាស តម្រូវឱ្យអង្គភាពនីមួយៗទូទាត់ប្រាក់បំណាច់អតីតភាពការងារឱ្យនិយោជិត ដែលមានកិច្ចសន្យាការងារមិនមានរយៈពេលកំណត់ ដូចខាងក្រោម៖

- ប្រាក់បំណាច់ការងារប្រចាំឆ្នាំ - ចូលជាធរមានក្នុងខែមករា ឆ្នាំ២០១៩ - ស្មើនឹង ១៥ ថ្ងៃ នៃប្រាក់បៀវត្សរ៍ប្រចាំខែរបស់បុគ្គលិក និងអត្ថប្រយោជន៍ក្នុងឆ្នាំនីមួយៗគិតជាមធ្យម ដែលត្រូវទូទាត់រៀងរាល់ ៦ ខែម្តង នៅថ្ងៃទី៣០ខែមិថុនា និងថ្ងៃទី៣១ ខែធ្នូ (៧.៥ ថ្ងៃ ក្នុងការទូទាត់ម្តងៗ)។

## ២. សេចក្ដីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១៦ អត្ថប្រយោជន៍បុគ្គលិក (ត)

#### (ខ) អត្ថប្រយោជន៍បុគ្គលិករយៈពេលវែងផ្សេងៗ - ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ (ត)

- ការបើករំលឹកប្រាក់បំណាច់អតីតភាពការងារ - និយោជិតមានសិទ្ធិទទួលបានការបើករំលឹកប្រាក់បំណាច់អតីតភាពការងារ ស្មើនឹង១៥ថ្ងៃនៃប្រាក់បៀវត្សរ៍របស់ពួកគេក្នុងមួយឆ្នាំ គិតចាប់តាំងពីថ្ងៃចូលបម្រើការងាររហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ហើយនៅតែបន្តការងារជាមួយធនាគារ។ ការបើករំលឹកប្រាក់បំណាច់អតីតភាពការងារ អាស្រ័យទៅតាមចំនួនឆ្នាំអតីតភាពការងាររបស់បុគ្គលិកម្នាក់ៗ ហើយមិនត្រូវលើសពី៦ខែនៃប្រាក់បៀវត្សរ៍ជាមធ្យមទេ។ នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញសេចក្តីណែនាំលេខ ០៤២/១៩ ក.ប/ស.ណ.ន.ខ.ល ដើម្បីពន្យារពេលការបើករំលឹកប្រាក់បំណាច់អតីតភាពការងារ ដែលនឹងត្រូវទូទាត់ឱ្យចំនួនបីថ្ងៃ ក្នុងខែមិថុនា និងខែធ្នូ ចាប់ផ្តើមនៅខែធ្នូ ឆ្នាំ២០២១។

ការទូទាត់ប្រាក់បំណាច់ការងារប្រចាំឆ្នាំ ត្រូវបានចាត់ទុកថាជាអត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី ហើយវាត្រូវបានកត់ត្រាបង្គរក្នុងឆ្នាំដែលបុគ្គលិកបានបម្រើការងារឱ្យធនាគារ។

ការបើករំលឹកប្រាក់បំណាច់អតីតភាពការងារ ត្រូវបានចាត់ថ្នាក់ជាអត្ថប្រយោជន៍បុគ្គលិករយៈពេលវែង។ បំណុលប្រាក់រំលឹកអតីតភាពការងារ ត្រូវបានទទួលស្គាល់តាមតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចដែលបានកំណត់ នាការិយបរិច្ឆេទរាយការណ៍ ដើម្បីធ្វើការប៉ាន់ស្មានឱ្យបានកាន់តែល្អនូវតម្លៃចុងក្រោយដែលធនាគារត្រូវបង់ឱ្យបុគ្គលិក ជាថ្នូរនឹងការបម្រើការងារឱ្យធនាគារក្នុងពេលបច្ចុប្បន្ន និងក្នុងឆ្នាំកន្លងមក។ តម្លៃបច្ចុប្បន្ននៃការបើករំលឹកប្រាក់បំណាច់អតីតភាពការងារ ត្រូវបានកំណត់ដោយធ្វើអប្បហារលើចំនួនទឹកប្រាក់ត្រូវទូទាត់នាពេលអនាគតប៉ាន់ស្មាន ដោយយោងទៅតាមសញ្ញាប័ណ្ណសាជីវកម្មដែលមានគុណភាពខ្ពស់នៃទិន្នផលប័ណ្ណរបស់បំណុលនោះ។

### ២.១៧ ចំណូល និងចំណាយការប្រាក់

ចំណូលនិងចំណាយការប្រាក់ពីឧបករណ៍ហិរញ្ញវត្ថុ ដែលវាស់វែងតាមថ្លៃដើមដករំលស់ ត្រូវបានទទួលស្គាល់ក្នុង “ ចំណូលការប្រាក់” និង “ចំណាយការប្រាក់” ក្នុងរបាយការណ៍ចំណេញ-ខាត ដោយប្រើវិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព។

វិធីសាស្រ្តការប្រាក់មានប្រសិទ្ធភាព គឺជាវិធីសាស្រ្តក្នុងការគណនាថ្លៃដើមដករំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុមួយឬបំណុលហិរញ្ញវត្ថុមួយ និងជាវិធីសាស្រ្តក្នុងការបែងចែកចំណូលការប្រាក់ ឬចំណាយការប្រាក់ លើរយៈពេលដែលពាក់ព័ន្ធ។ អត្រាការប្រាក់មានប្រសិទ្ធភាពគឺជាអត្រា ដែលធ្វើអប្បហារជាក់ស្តែងចំពោះការទូទាត់សាច់ប្រាក់នាពេលអនាគតប៉ាន់ស្មាន ឬបង្កាន់ដៃទទួលប្រាក់ ក្នុងរយៈពេលនៃអាយុកាលប៉ាន់ស្មានរបស់ឧបករណ៍ហិរញ្ញវត្ថុ ឬក្នុងរយៈពេលណាមួយដែលខ្លីជាងទៅតាមការសមស្រប ចំពោះតម្លៃយោងសុទ្ធរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។ នៅពេលគណនាអត្រាការប្រាក់មានប្រសិទ្ធភាព ធនាគារបានកត់ត្រារាល់លក្ខខណ្ឌក្នុងកិច្ចសន្យាទាំងអស់នៃឧបករណ៍ ហិរញ្ញវត្ថុ និងបានរួមបញ្ចូលនូវកម្រៃ ឬកំណើនចំណាយនានា ដែលបានចំណាយដោយផ្ទាល់ចំពោះឧបករណ៍មួយ ហើយវាជាផ្នែកមួយនៃអត្រាការប្រាក់មានប្រសិទ្ធភាព ប៉ុន្តែមិនមែនជាការខាតឥណទាននាពេលអនាគតទេ។

ចំណូលការប្រាក់ត្រូវបានគណនាដោយអនុវត្តអត្រាការប្រាក់មានប្រសិទ្ធភាព ចំពោះតម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ លើកលែងតែចំពោះ៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការថយចុះតម្លៃដែលបានទិញ ឬបានបង្កើតឡើង (Purchased or originated credit-impaired financial assets - POCI) ដែលអត្រាការប្រាក់មានប្រសិទ្ធភាពសម្រាប់កែតម្រូវឥណទានលើកដំបូង ត្រូវបានអនុវត្តចំពោះថ្លៃដើមដករំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ។
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនមែនជា POCI ប៉ុន្តែបានក្លាយជាឥណទានដែលមានការថយចុះតម្លៃមួយផ្នែកធំ (ឬ ‘ដំណាក់កាលទី ៣’) ដែលចំណូលការប្រាក់ត្រូវបានគណនាដោយប្រើអត្រាការប្រាក់មានប្រសិទ្ធភាព ចំពោះថ្លៃដើមដករំលស់របស់វា (ឧ. កាត់កងជាមួយនឹងសំវិធានធនការខាតឥណទានរំពឹងទុក)។

### ២.១៨ ចំណូលកម្រៃជើងសា

ចំណូលកម្រៃជើងសាត្រូវបានទទួលស្គាល់ជាចំណូល នៅពេលដែលវាបានបំពេញតាមគំរូលក្ខខណ្ឌទាំងអស់ (កាតព្វកិច្ចនៃដំណើរការត្រូវបានទទួលយក ហើយការគ្រប់គ្រងត្រូវបានផ្ទេរក្នុងពេលវេលាណាមួយ ឬ ចំណុចនៃពេលវេលាណាមួយ)។

កម្រៃក្នុងដំណើរការផ្តល់ឥណទាន បុរេប្រទាន និងហិរញ្ញប្បទាន ដែលទំនងជាអាចត្រូវបានផ្តល់ឱ្យ ត្រូវបានពន្យារ (ជាមួយនឹងចំណាយផ្ទាល់ពាក់ព័ន្ធ) ហើយចំណូលដែលជាផ្នែកនៃអត្រាការប្រាក់មានប្រសិទ្ធភាពរបស់ឧបករណ៍ហិរញ្ញវត្ថុមួយត្រូវបានទទួលស្គាល់ដោយធ្វើនិយ័តកម្មទៅលើអត្រាការប្រាក់មានប្រសិទ្ធភាពរបស់ឧបករណ៍ហិរញ្ញវត្ថុនោះ។

## ៣. ការប៉ាន់ស្មានគណនេយ្យជាក់លាក់ ការសន្មត និងការវិនិច្ឆ័យ

ធនាគារធ្វើការប៉ាន់ស្មាន និងការសន្មតដោយគិតទៅលើអនាគតកាល។ តាមនិយមន័យ លទ្ធផលនៃការប៉ាន់ស្មានគណនេយ្យកម្រស្មើគ្នាជាមួយនឹងលទ្ធផលជាក់ស្តែងណាស់។ ដើម្បីធ្វើឱ្យមាតិកាព័ត៌មាននៃការប៉ាន់ស្មានកាន់តែមានភាពល្អប្រសើរឡើង ជាតុអថេរជាក់លាក់សំខាន់ៗដែលជាជាតុធ្វើឱ្យមានការប៉ះពាល់ជាសារវន្តចំពោះលទ្ធផលនិងស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានធ្វើតេស្តរកភាពងាយប្រែប្រួលរបស់វាចំពោះបម្រែបម្រួលប៉ារ៉ាម៉ែត្រមូលដ្ឋាន។ ការប៉ាន់ស្មាន និងការសន្មតចំពោះតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល ក្នុងឆ្នាំហិរញ្ញវត្ថុបន្ទាប់ ត្រូវបានកត់សម្គាល់ដូចខាងក្រោម៖

### (ក) សំវិធានធនការខាតឥណទានរំពឹងទុក ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមថ្លៃដើមដករំលស់

សំវិធានធនការខាតឥណទានរំពឹងទុក ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមថ្លៃដើមដករំលស់ តម្រូវឱ្យប្រើប្រាស់គំរូស្មុគស្មាញ និងការសន្មតជាក់លាក់ចំពោះលក្ខខណ្ឌសេដ្ឋកិច្ចនាពេលអនាគត និងលក្ខណៈរបស់ឥណទាន ( ឧ. លទ្ធភាពដែលអតិថិជនអាចមិនសងប្រាក់ និងបណ្តាលឱ្យមានការខាតបង់ )។

ការវិនិច្ឆ័យជាក់លាក់មួយចំនួន ក៏ត្រូវបានតម្រូវនៅក្នុងការអនុវត្តតម្រូវការគណនេយ្យសម្រាប់ការវាស់វែង ECL ផងដែរ ដូចជា៖

- ការកំណត់លក្ខណៈវិនិច្ឆ័យចំពោះកំណើនហានិភ័យឥណទានជាក់លាក់
- ជ្រើសរើសគំរូ និងការសន្មតសមស្រប សម្រាប់ការវាស់វែង ECL
- ការបង្កើតចំនួនសេណារីយ៉ូ និងការថ្លឹងពាក់ព័ន្ធ សម្រាប់ពេលអនាគត ចំពោះប្រភេទនៃផលិតផល/ទីផ្សារនីមួយៗ និង ECL ដែលពាក់ព័ន្ធ
- ការបង្កើតក្រុមទ្រព្យសកម្មហិរញ្ញវត្ថុដែលមានលក្ខណៈស្រដៀងគ្នា ក្នុងគោលបំណងដើម្បីវាស់វែង ECL
- ចំពោះការវាយតម្លៃជាលក្ខណៈបុគ្គល គណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យទៅលើអនាគត ទាក់ទិននឹងការប៉ាន់ស្មានចំនួនទឹកប្រាក់ និងពេលវេលានៃលំហូរសាច់ប្រាក់ពីតម្លៃដែលអាចទទួលស្គាល់បានសុទ្ធ នៃតម្លៃវត្ថុបញ្ចាំជាមូលដ្ឋាន។

ព័ត៌មានលម្អិតអំពីការវិនិច្ឆ័យ និងការប៉ាន់ស្មាន ដែលធនាគារបានធ្វើក្នុងចំណុចខាងលើនេះ ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ ៣៤.១.គ។

### (ខ) អត្ថប្រយោជន៍បុគ្គលិករយៈពេលវែងផ្សេងៗ - ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ

តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចការការទូទាត់ប្រាក់បំណាច់អតីតភាពការងារ អាស្រ័យទៅលើកត្តាមួយចំនួនដែលត្រូវបានកំណត់ដោយមូលដ្ឋានមួយ ដែលប្រើប្រាស់ការសន្មតមួយចំនួន។ ការសន្មតដែលត្រូវបានប្រើប្រាស់ក្នុងការកំណត់ចំណាយចុងក្រោយសម្រាប់ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ រួមមានអត្រាបម្រែបម្រួលបុគ្គលិក និងអត្រាអប្បហារ។ បម្រែបម្រួលណាមួយក្នុងការសន្មតទាំងនេះ នឹងធ្វើឱ្យមានផលប៉ះពាល់លើតម្លៃយោងរបស់កាតព្វកិច្ចការទូទាត់ប្រាក់បំណាច់អតីតភាពការងារ។

### (គ) លក្ខខណ្ឌភតិសន្យា

ក្នុងការកំណត់លក្ខខណ្ឌភតិសន្យា គណៈគ្រប់គ្រងពិចារណាទៅលើភាពជាក់ស្តែង និងលក្ខខណ្ឌទាំងអស់ ដែលបង្កើតឱ្យមានការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ចដើម្បីអនុវត្តជម្រើសក្នុងការបន្តការជួល ឬជម្រើសមិនបន្តការជួល។ ជម្រើសក្នុងការបន្តការជួល ( ឬ រយៈពេលបន្ទាប់ពីជម្រើសបញ្ឈប់ការជួល ) ត្រូវបានរួមបញ្ចូលនៅក្នុងលក្ខខណ្ឌភតិសន្យា ប្រសិនបើភតិសន្យានោះមានភាពជាក់លាក់សមហេតុផល សម្រាប់ការបន្តការជួល ( ឬ មិនបញ្ឈប់តែប៉ុណ្ណោះ )។

### (ឃ) ស្ថានភាពពន្ធមិនច្បាស់លាស់ និង ពន្ធយថាហេតុ

ធនាគារចាត់ទុកថាចំណាយសំវិធានធនសម្រាប់ឥណទានខាតបង់ ក្នុងលិខិតប្រកាសពន្ធប្រចាំឆ្នាំ គឺជាចំណាយពន្ធដែលអាចកាត់កងបាន ដោយអនុលោមតាមច្បាប់ស្តីពីសារពើពន្ធ និងប្រកាសស្តីពីការអនុញ្ញាតចំណាយសំវិធានធនសម្រាប់ឥណទានខាតបង់ចំពោះធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ។ ធនាគារបានគណនាចំណាយពន្ធលើប្រាក់ចំណូលតាមវិធីសាស្ត្រនេះ។

ធនាគារមានមតិថាការប្រឈមមុខនឹងការបង់បំណុលពន្ធបន្ថែមនេះ បូករួមនឹងប្រាក់ពិន័យ និងការប្រាក់ ដែលបណ្តាលមកពីការកំណត់ពន្ធឡើងវិញ លើចំណាយសំវិធានធនសម្រាប់ឥណទានខាតបង់ និងពន្ធកាត់ទុកពីសេវាលើការកែលម្អទ្រព្យជួល ដោយសារមានមិនមានភាពច្បាស់លាស់ថាធនាគារនឹងត្រូវបង់ពន្ធនេះទេ ( សម្គាល់ ៣២ ( ឃ ) )។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)



## ៤. សាច់ប្រាក់ក្នុងដៃ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| រយៈពេលខ្លីៈ | | | | |
| ប្រាក់ដុល្លារអាមេរិក | ៧.៥១៥.១៦៩ | ៣០.៣៩៨.៨៥៩ | ៧.០២១.០០៥ | ២៨.៦១០.៥៩៥ |
| ប្រាក់រៀល | ១.២៥៤.៨០៦ | ៥.០៧៥.៦៩០ | ១.៣៨៧.៧៩៧ | ៥.៦៥៥.២៧៣ |
| | ៨.៧៦៩.៩៧៥ | ៣៥.៤៧៤.៥៤៩ | ៨.៤០៨.៨០២ | ៣៤.២៦៥.៨៦៨ |

## ៥. ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារកណ្តាល

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| រយៈពេលខ្លី | | | | |
| គណនីចរន្ត | **១០៩.៣៨៤.២៨២** | ៤៤២.៤៥៩.៤២១ | **១៣៤.៩២៥.៤០៤** | ៥៤៩.៨២១.០២១ |
| គណនីទូទាត់ | **៥.៩១៥.៨៣៣** | ២៣.៩២៨.៥៤៤ | **៥.០២២.២១៦** | ២០.៤៦៥.៥៣០ |
| មូលបត្រអាចជួញដូរបាន ( * ) | **៦៨.៦៥៦.៨០៩** | ២៧៧.៧១៦.៧៩៣ | **៦៩.៥៨៣.៨៨៦** | ២៨៣.៥៥៤.៣៣៦ |
| | **១៨៣.៩៥៦.៩២៤** | ៧៤៤.១០៥.៧៥៨ | **២០៩.៥៣១.៥០៦** | ៨៥៣.៨៤០.៨៨៧ |

( * ) មូលបត្រអាចជួញដូរបាន

ធនាគារបានដាក់មូលបត្រអាចជួញដូរបាន (NCD) ចំនួន ៧.៨០៩.៣៩៤ ដុល្លារអាមេរិក (២០១៩ ៖ ៣.៩៨១.៥៩៥ ដុល្លារអាមេរិក) នៅធនាគារកណ្តាលសម្រាប់ជាទ្រព្យបញ្ចាំលើហ្វាស៊ីលីធីគណនីទូទាត់។ មូលបត្រអាចជួញដូរបានមួយផ្សេងទៀតនៅធនាគារកណ្តាល ចំនួន ៣៤.៤៩០.០០០ដុល្លារអាមេរិក (២០១៩ ៖ ២៨.៥៣០.០០០ដុល្លារអាមេរិក) ត្រូវបានដាក់បញ្ចាំសម្រាប់ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) (កំណត់សម្គាល់ ១៧)។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ធនាគារមិនទាន់ប្រើឥណទានវិបារូបន៍ចំពោះហ្វាស៊ីលីធីគណនីទូទាត់នេះនៅឡើយទេ។

អត្រាការប្រាក់ប្រចាំឆ្នាំនៃប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារកណ្តាល មានដូចខាងក្រោមៈ

| | ២០២០ | ២០១៩ |
|---|---|---|
| គណនីចរន្ត | **សូន្យ** | សូន្យ |
| គណនីទូទាត់ | **សូន្យ** | សូន្យ |
| មូលបត្រអាចជួញដូរបាន | **០,៧០% ទៅ ១,៦០%** | ០,៦៥% ទៅ ០,៨៣% |

## ៦. ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារផ្សេងៗ

### (ក) វិភាគតាមស្ថានភាពនិវាសនដ្ឋាន

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារក្នុងប្រទេស | **៦៩.៧៩៨.១៧១** | ២៨២.៣៣៣.៦០២ | **៥៣.៦៥៣.៣៤៤** | ២១៨.៦៣៧.៣៧៧ |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារក្រៅប្រទេស | **១៥.៥៦៣.៣៥៧** | ៦២.៩៥៣.៧៧៩ | **៧២.០៥៥.៨៥៦** | ២៩៣.៦២៧.៦១៣ |
| | **៨៥.៣៦១.៥២៨** | ៣៤៥.២៨៧.៣៨១ | **១២៥.៧០៩.២០០** | ៥១២.២៦៤.៩៩០ |
| ដកៈ សំវិធានធនការខាតឥណទានរំពឹងទុក (កំណត់សម្គាល់ ៣៤.១.ង) | **(១.៥៥៩.១២៩)** | (៦.៣០៦.៦៧៧) | **(២.៣៣៨.៦៣៣)** | (៩.៥២៩.៩២៩) |
| សរុប - រយៈពេលខ្លី | **៨៣.៨០២.៣៩៩** | ៣៣៨.៩៨០.៧០៤ | **១២៣.៣៧០.៥៦៧** | ៥០២.៧៣៥.០៦១ |

## ៦. ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារផ្សេងៗ (ត)

(ខ) វិភាគតាមប្រភេទគណនី

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារក្នុងប្រទេស៖ | | | | |
| គណនីចរន្ត | **១១.១៨១.៧៣៨** | ៤៥.២៣០.១៣១ | **១.០១៦.៧៣៧** | ៤.១៤៣.២០៣ |
| ប្រាក់បញ្ញើមានកាលកំណត់ | **៥៨.៦១៦.៤៣២** | ២៣៧.១០៣.៤៦៧ | **៥២.៦៣៦.៦០៧** | ២១៤.៤៩៤.១៧៤ |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារក្រៅប្រទេស៖ | | | | |
| គណនីចរន្ត | **១៥.៥៦៣.៣៥៨** | ៦២.៩៥៣.៧៨៣ | **៧២.០៥៥.៨៥៦** | ២៩៣.៦២៧.៦១៣ |
| | **៨៥.៣៦១.៥២៨** | ៣៤៥.២៨៧.៣៨១ | **១២៥.៧០៩.២០០** | ៥១២.២៦៤.៩៩០ |
| ដក៖ សំវិធានធនការខាតឥណទានរំពឹងទុក (កំណត់សម្គាល់ ៣៤.១.ង) | **(១.៥៥៩.១២៩)** | (៦.៣០៦.៦៧៧) | **(២.៣៣៨.៦៣៣)** | (៩.៥២៩.៩២៩) |
| សរុប - រយៈពេលខ្លី | **៨៣.៨០២.៣៩៩** | ៣៣៨.៩៨០.៧០៤ | **១២៣.៣៧០.៥៦៧** | ៥០២.៧៣៥.០៦១ |

អត្រាការប្រាក់ប្រចាំឆ្នាំនៃប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារផ្សេងៗ មានដូចខាងក្រោម៖

| | ២០២០ | ២០១៩ |
|---|---|---|
| គណនីចរន្ត | **សូន្យ** | សូន្យ |
| ប្រាក់បញ្ញើមានកាលកំណត់ | **១% ទៅ ៣,៨%** | ២,២% ទៅ ៤% |

## ៧. ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមតម្លៃសមស្រប ក្នុងលទ្ធផលលម្អិតផ្សេងៗ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| រយៈពេលវែង | | | | |
| មូលបត្រដែលមិនបានចុះបញ្ជី | | | | |
| ការវិនិយោគក្នុងការិយាល័យឥណទាននៃកម្ពុជា | **២៥.០០០** | ១០១.១២៥ | **២៥.០០០** | ១០១.៨៧៥ |

ធនាគារមានការវិនិយោគនៅក្នុងការិយាល័យឥណទានកម្ពុជា (CBC) ដែលត្រូវបានវាស់វែងតាមតម្លៃសមស្របក្នុងលទ្ធផលលម្អិតផ្សេងៗ ដោយសារវាមិនត្រូវបានកាន់កាប់សម្រាប់ការជួញដូរទេ ហើយធនាគារបានជ្រើសរើសយកការទទួលស្គាល់លើកដំបូង ជាការទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុតាម FVOCI ។ នេះគឺជាវិធីសាស្ត្រក្នុងការវិនិយោគ ហើយធនាគារយល់ឃើញថាការធ្វើចំណាត់ថ្នាក់បែបនេះ គឺមានភាពសមស្រប។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០តម្លៃសមស្របនៃការវិនិយោគនេះ មានចំនួន ២៥.០០០ដុល្លារអាមេរិក។

ភាគលាភបានទទួលក្នុងអំឡុងឆ្នាំមានចំនួន ២៨.៩៥២ដុល្លារអាមេរិក (២០១៩ ៖ ២៥.៥៧៥ដុល្លារអាមេរិក)។ សូមយោងទៅកំណត់សម្គាល់ ២៣។

មិនមានការទទួលស្គាល់ចំណេញ/ខាត នៅក្នុងលទ្ធផលលម្អិតផ្សេងៗទេ ដោយសារតម្លៃសមស្របរបស់វា មានចំនួនប្រហាក់ប្រហែលនឹងតម្លៃយោង។ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០មិនមានសំវិធានធនសម្រាប់ការខាតបង់ ចំពោះ FVOCI នេះទេ ។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ៨. ឥណទាន និងបុរេប្រទានវាស់វែងតាមថ្លៃដើមដករំលស់

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទានពាណិជ្ជ៖ | | | | |
| ឥណទានមានកាលកំណត់ | **៣២០.៦០២.៤២៩** | ១.២៩៦.៨៣៦.៨២៥ | **២៧៨.៣២២.៥៨៨** | ១.១៣៤.១៦៤.៥៤៦ |
| ឥណទានទិញគេហដ្ឋាន | **៤.៩០៩.៤៥៨** | ១៩.៨៥៨.៧៥៨ | **១.៧៧៣.២៩៨** | ៧.២២៦.១៨៩ |
| ឥណទានវិបារូបន៍ | **៥៩.៨៩៦.២២៣** | ២៤២.២៨០.២២២ | **៦២.៧៦០.៥៣៨** | ២៥៥.៧៤៩.១៩២ |
| | **៣៨៥.៤០៨.១១០** | ១.៥៥៨.៩៧៥.៨០៥ | **៣៤២.៨៥៦.៤២៤** | ១.៣៩៧.១៣៩.៩២៧ |
| ឥណទានអ្នកប្រើប្រាស់៖ | | | | |
| ឥណទានមានកាលកំណត់ | **៨៦.៨៤៥.៣១១** | ៣៥១.២៨៩.២៨៣ | **៨៧.៩០៦.១៤៤** | ៣៥៨.២១៧.៥៣៧ |
| ឥណទានទិញគេហដ្ឋាន | **៩២.០៨៨.១០១** | ៣៧២.៤៩៦.៣៦៩ | **៦៦.៤៨៩.៩៨៩** | ២៧០.៩៤៦.៧០៥ |
| ឥណទានវិបារូបន៍ | **១៣.៤៨៦.៥៩៤** | ៥៤.៥៥៣.២៧៣ | **១៥.៣៣៨.៧៦៥** | ៦២.៥០៥.៤៦៧ |
| ឥណទានទិញគេហដ្ឋានរបស់បុគ្គលិក | **៤.២៦០.២២៣** | ១៧.២៣២.៦០២ | **៣.៥៤២.៤២៦** | ១៤.៤៣៥.៣៨៦ |
| ឥណទានទិញយានយន្តរបស់បុគ្គលិក | **៤២២.៦៥៦** | ១.៧០៩.៦៤៤ | **២៨៤.៣៦២** | ១.១៥៨.៧៧៦ |
| ឥណទានបុគ្គលិកផ្សេងៗ | **១៥.៣១៦** | ៦១.៩៥៤ | - | - |
| | **១៩៧.១១៨.២០១** | ៧៩៧.៣៤៣.១២៥ | **១៧៣.៥៦១.៦៨៦** | ៧០៧.២៦៣.៨៧១ |
| ឥណទានដុលសរុប | **៥៨២.៥២៦.៣១១** | ២.៣៥៦.៣១៨.៩៣០ | **៥១៦.៤១៨.១១០** | ២.១០៤.៤០៣.៧៩៨ |
| ដកៈ សំវិធានធនការខាតឥណទានរំពឹងទុក (កំណត់សម្គាល់ ៣៤.១.ច.i) | **(១៨.១៥០.៦៨៦)** | (៧៣.៤១៩.៥២៧) | **(១០.១៩១.១២៤)** | (៤១.៥២៨.៨៣០) |
| ឥណទានសុទ្ធសរុប | **៥៦៤.៣៧៥.៦២៥** | ២.២៨២.៨៩៩.៤០៣ | **៥០៦.២២៦.៩៨៦** | ២.០៦២.៨៧៤.៩៦៨ |

### (ក) សំវិធានធនការខាតឥណទានរំពឹងទុក

បម្រែបម្រួលសំវិធានសម្រាប់ការខាតឥណទានរំពឹងទុក ដោយប្រើវិធីសាស្ត្របីដំណាក់កាល មានដូចខាងក្រោម៖

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ECL ១២ខែ (ដំណាក់កាលទី ១) | **១.៤៩៦.៧៥៨** | ៦.០៥៤.៣៨៦ | **៦៩៦.៦៥៥** | ២.៨៣៨.៨៦៩ |
| ECL ពេញមួយអាយុកាល-មិនថយចុះតម្លៃឥណទាន (ដំណាក់កាលទី ២) | **១៤.២៦៥.២២២** | ៥៧.៧០២.៨២៣ | **៣៦.០៥៧** | ១៤៦.៩៣២ |
| ECL ពេញមួយអាយុកាល-ថយចុះតម្លៃឥណទាន (ដំណាក់កាលទី ៣) | **២.៣៨៨.៧០៦** | ៩.៦៦២.៣១៨ | **៩.៤៥៨.៤១២** | ៣៨.៥៤៣.០២៩ |
| | **១៨.១៥០.៦៨៦** | ៧៣.៤១៩.៥២៧ | **១០.១៩១.១២៤** | ៤១.៥២៨.៨៣០ |

## ៨. ឥណទាន និងបុរេប្រទានវាស់វែងតាមថ្លៃដើមដករំលស់ (ត)

### (ខ) វិភាគតាមចំណាត់ថ្នាក់ឥណទាន

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទានដំណើរការ | | | | |
| ចំនួនដុល | ៤៦៥.២៤២.០៥៧ | ១.៨៨១.៩០៤.១២១ | ៤៨១.៤៥២.៣១៧ | ១.៩៦១.៩១៨.១៩២ |
| ចំនួនដែលមានហានិភ័យមិនសង | ៤៩៦.៤២៥.៩១២ | ២.០០៨.០៤២.៨១៤ | ៥០៧.៩០៦.៦០៦ | ២.០៦៩.៧១៩.៤១៩ |
| សំវិធានធនការខាតឥណទានរំពឹងទុក | ១.៤៩៦.៧៥៨ | ៦.០៥៤.៣៨៦ | ៦៩៦.៦៥៥ | ២.៨៣៨.៨៦៩ |
| ឥណទានក្រោមដំណើរការ | | | | |
| ចំនួនដុល | ៩១.៥១២.៧៤១ | ៣៧០.១៦៩.០៣៧ | ១១.៤៥៦.២១៨ | ៤៦.៦៨៤.០៨៨ |
| ចំនួនដែលមានហានិភ័យមិនសង | ៩៣.៤០១.១៧៥ | ៣៧៧.៨០៧.៧៥៣ | ១១.១៦៦.៤៨២ | ៤៥.៥០៣.៤១៤ |
| សំវិធានធនការខាតឥណទានរំពឹងទុក | ១៤.២៦៥.២២២ | ៥៧.៧០២.៨២៣ | ៣៦.០៥៧ | ១៤៦.៩៣២ |
| ឥណទានមិនដំណើរការ | | | | |
| ចំនួនដុល | ២៥.៧៧១.៥១៣ | ១០៤.២៤៥.៧៧២ | ២៣.៥០៩.៥៧៥ | ៩៥.៨០១.៥១៨ |
| ចំនួនដែលមានហានិភ័យមិនសង | ២៥.៨២៣.២៥៨ | ១០៤.៤៥៥.០៧៩ | ៤១.០៩០.៧៨០ | ១៦៧.៤៤៤.៩២៩ |
| សំវិធានធនការខាតឥណទានរំពឹងទុក | ២.៣៨៨.៧០៦ | ៩.៦៦២.៣១៨ | ៩.៤៥៨.៤១២ | ៣៨.៥៤៣.០២៩ |
| សរុប | | | | |
| ចំនួនដុល | ៥៨២.៥២៦.៣១១ | ២.៣៥៦.៣១៨.៩៣០ | ៥១៦.៤១៨.១១០ | ២.១០៤.៤០៣.៧៩៨ |
| ចំនួនដែលមានហានិភ័យមិនសង | ៦១៥.៦៥០.៣៤៥ | ២.៤៩០.៣០៥.៦៤៦ | ៥៦០.១៦៣.៨៦៨ | ២.២៨២.៦៦៧.៧៦២ |
| សំវិធានធនការខាតឥណទានរំពឹងទុក | ១៨.១៥០.៦៨៦ | ៧៣.៤១៩.៥២៧ | ១០.១៩១.១២៤ | ៤១.៥២៨.៨៣០ |

### (គ) វិភាគតាមហានិភ័យឥណទាន

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ហានិភ័យធំ | ២៥.៦៣២.០៦៨ | ១០៣.៦៨១.៧១៥ | ៧២.១៤១.៥៥២ | ២៩៣.៩៧៦.៨២៤ |
| ហានិភ័យធម្មតា | ៥៥៦.៨៩៤.២៤៣ | ២.២៥២.៦៣៧.២១៥ | ៤៤៤.២៧៦.៥៥៨ | ១.៨១០.៤២៦.៩៧៤ |
| ឥណទានដុលសរុប | ៥៨២.៥២៦.៣១១ | ២.៣៥៦.៣១៨.៩៣០ | ៥១៦.៤១៨.១១០ | ២.១០៤.៤០៣.៧៩៨ |

ហានិភ័យធំត្រូវបានកំណត់និយមន័យដោយធនាគារកណ្ដាលថាជាហានិភ័យឥណទានទូទៅ ចំពោះអ្នកទទួលជាឯកត្តជនណាមួយ ដែលលើសពី ១០% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។

### (ឃ) វិភាគតាមទំនាក់ទំនង

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ភាគីពាក់ព័ន្ធ | ៦៣៣.៧៨២ | ២.៥៦៣.៦៤៨ | ១៥៩.៥៥៩ | ៦៥០.២០៣ |
| ភាគីមិនពាក់ព័ន្ធ | ៥៨១.៨៩២.៥២៩ | ២.៣៥៣.៧៥៥.២៨២ | ៥១៦.២៥៨.៥៥១ | ២.១០៣.៧៥៣.៥៩៥ |
| ឥណទានដុលសរុប | ៥៨២.៥២៦.៣១១ | ២.៣៥៦.៣១៨.៩៣០ | ៥១៦.៤១៨.១១០ | ២.១០៤.៤០៣.៧៩៨ |

## ៨. ឥណទាន និងបុរេប្រទានរាស់វែងតាមថ្លៃដើមដករំលស់ (ត)

### (ង) វិភាគតាមនិវាសនដ្ឋាន

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| និវាសដ្ឋាន | **៥៨២.៣៥៦.៥៤៣** | ២.៣៥៥.៦៣២.២១៨ | **៥០៩.៥៣៧.៧១៥** | ២.០៧៦.៣៦៦.១៨៨ |
| អនិវាសដ្ឋាន | **១៦៩.៧៦៨** | ៦៨៦.៧១២ | **៦.៨៨០.៣៩៥** | ២៨.០៣៧.៦១០ |
| ឥណទានដុលសរុប | **៥៨២.៥២៦.៣១១** | ២.៣៥៦.៣១៨.៩៣០ | **៥១៦.៤១៨.១១០** | ២.១០៤.៤០៣.៧៩៨ |

### (ច) អត្រាការប្រាក់

ឥណទាន និងបុរេប្រទានអតិថិជនទាំងនេះ មានអត្រាការប្រាក់ប្រចាំឆ្នាំ ដូចខាងក្រោម៖

| | ២០២០ | ២០១៩ |
|---|---|---|
| ឥណទានពាណិជ្ជកម្ម | ៦,៥០% - ២៤% | ៦,៨៨% - ២៤% |
| ឥណទានអតិថិជន | ៤% - ២៤% | ៤% - ២៤% |

## ៩. ប្រាក់តម្កល់តាមច្បាប់នៅធនាគារកណ្តាល

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| រយៈពេលខ្លី | | | | |
| ទុនបម្រុងកាតព្វកិច្ច (i) | **៨០.២៧០.៦៦២** | ៣២៤.៦៩៤.៨២៨ | **៧៩.៥៤១.៣៥០** | ៣២៤.១៣១.០០១ |
| រយៈពេលវែង | | | | |
| ប្រាក់តម្កល់ធានាលើដើមទុន (ii) | **៧.៥០០.០០០** | ៣០.៣៣៧.៥០០ | **៧.៥០០.០០០** | ៣០.៥៦២.៥០០ |
| | **៨៧.៧៧០.៦៦២** | ៣៥៥.០៣២.៣២៨ | **៨៧.០៤១.៣៥០** | ៣៥៤.៦៩៣.៥០១ |

### (i) ទុនបម្រុងកាតព្វកិច្ច

ទុនបម្រុងកាតព្វកិច្ចគឺជាទុនបម្រុងអប្បបរមាដែលត្រូវបានគណនាតាមអត្រា ៧% នៃប្រាក់បញ្ញើរបស់អតិថិជន និងប្រាក់កម្ចីជាប្រាក់រៀល និងជារូបិយប័ណ្ណផ្សេងៗ (២០១៩ ៖ ៨% ជាប្រាក់រៀល និង ១២,៥% ជារូបិយប័ណ្ណផ្សេងៗ)។ ទុនបម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើរបស់អតិថិជន និងប្រាក់កម្ចី មិនមានការប្រាក់ទេ។

### (ii) ប្រាក់តម្កល់ធានាលើដើមទុន

យោងតាមប្រកាសលេខ ធ៧-០១-១៣៦ប្រ.ក. ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ចេញដោយធនាគារកណ្តាល ស្តីពី "ប្រាក់តម្កល់ធានាលើដើមទុន" តម្រូវឱ្យធនាគារតម្កល់ប្រាក់ចំនួន ១០% នៃដើមទុនបានបង់របស់ធនាគារ ជាប្រាក់តម្កល់ធានាលើដើមទុននៅធនាគារកណ្តាល។ ប្រាក់តម្កល់នេះមិនសម្រាប់ប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារទេ ហើយនឹងត្រូវបង្វិលជូនធនាគារវិញ នៅពេលដែលធនាគារស្ម័គ្រចិត្តបញ្ចប់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា។

### (iii) អត្រាការប្រាក់

| | ២០២០ | ២០១៩ |
|---|---|---|
| ទុនបម្រុងកាតព្វកិច្ច | គ្មាន | គ្មាន |
| ប្រាក់តម្កល់ធានាលើដើមទុន | ០,៤៨% | ០,៤៨% |

## ១០. ទ្រព្យសម្បត្តិ និងបរិក្ខារ

| រយៈពេលវែង | ការកែលម្អទ្រព្យជួល<br>ដុល្លារអាមេរិក | បរិក្ខារការិយាល័យ<br>ដុល្លារអាមេរិក | គ្រឿងសង្ហារិម និងបរិក្ខារបំពាក់<br>ដុល្លារអាមេរិក | បរិក្ខារកុំព្យូទ័រ<br>ដុល្លារអាមេរិក | យានយន្ត<br>ដុល្លារអាមេរិក | ការងារកំពុងដំណើរការ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|
| **នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩** | | | | | | | |
| ថ្លៃដើម | ៣.២៦៥.៨១១ | ២.៤៧១.៤១៨ | ៥២៣.៧៧២ | ១.៣៦៤.៧៥៧ | ៧៣៨.៧២១ | ១៩១.៦២៩ | ៨.៥៥៦.១០៨ |
| រំលស់បង្គរ | (២.៣៧៤.៥៣៥) | (២.០១១.៣២១) | (៣៦៦.៥៧៨) | (១.៣០៤.៦៩៦) | (៤៧២.១៨៤) | - | (៦.៥២៩.៣១៤) |
| តម្លៃចុះបញ្ជីសុទ្ធ | ៨៩១.២៧៦ | ៤៦០.០៩៧ | ១៥៧.១៩៤ | ៦០.០៦១ | ២៦៦.៥៣៧ | ១៩១.៦២៩ | ២.០២៦.៧៩៤ |
| គិតជាពាន់រៀល | ៣.៥៨១.១៤៧ | ១.៨៤៨.៦៧០ | ៦៣១.៦០៥ | ២៤១.៣២៥ | ១.០៧០.៩៤៦ | ៧៦៩.៩៦៥ | ៨.១៤៣.៦៥៨ |
| **សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | | | | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ៨៩១.២៧៦ | ៤៦០.០៩៧ | ១៥៧.១៩៤ | ៦០.០៦១ | ២៦៦.៥៣៧ | ១៩១.៦២៩ | ២.០២៦.៧៩៤ |
| បន្ថែម | - | ១១០.៤០៣ | - | ៣៧.០៤៤ | ៤៣៧.៥០០ | ៥២៤.៨៩០ | ១.១០៩.៨៣៧ |
| លក់ចេញ | (២៦.៧៧៣) | - | - | - | (៦.០០៣) | - | (៣២.៧៧៦) |
| រំលស់ | (២៦៧.៩៨០) | (២០៨.១៣៥) | (៦៣.៩៩៥) | (៤៧.២០៧) | (៩៩.៤៥៧) | - | (៦៨៦.៧៧៤) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ៥៩៦.៥២៣ | ៣៦២.៣៦៥ | ៩៣.១៩៩ | ៤៩.៨៩៨ | ៥៩៨.៥៧៧ | ៧១៦.៥១៩ | ២.៤១៧.០៨១ |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | | | | | | | |
| ថ្លៃដើម | ២.៦៧៥.៥៨៧ | ២.៥៨១.៨២១ | ៥២៣.៧៧២ | ១.៤០១.៨០១ | ៩០២.១២០ | ៧១៦.៥១៩ | ៨.៨០១.៦២០ |
| រំលស់បង្គរ | (២.០៧៩.០៦៤) | (២.២១៩.៤៥៦) | (៤៣០.៥៧៣) | (១.៣៥១.៩០៣) | (៣០៣.៥៤៣) | - | (៦.៣៨៤.៥៣៩) |
| តម្លៃចុះបញ្ជីសុទ្ធ | ៥៩៦.៥២៣ | ៣៦២.៣៦៥ | ៩៣.១៩៩ | ៤៩.៨៩៨ | ៥៩៨.៥៧៧ | ៧១៦.៥១៩ | ២.៤១៧.០៨១ |
| គិតជាពាន់រៀល | ២.៤៣០.៨៣១ | ១.៤៧៦.៦៣៨ | ៣៧៩.៧៨៦ | ២០៣.៣៣៤ | ២.៤៣៩.២០១ | ២.៩១៩.៨១៥ | ៩.៨៤៩.៦០៥ |
| **សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០** | | | | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ៥៩៦.៥២៣ | ៣៦២.៣៦៥ | ៩៣.១៩៩ | ៤៩.៨៩៨ | ៥៩៨.៥៧៧ | ៧១៦.៥១៩ | ២.៤១៧.០៨១ |
| បន្ថែម | ៣៧៥.០៦៦ | ២៧៨.៧៥២ | ២០៨.៣៧៦ | ៣៨៣.០១៩ | ៤១.៥០០ | ២២៧.០៤៩ | ១.៥១៣.៧៦២ |
| លក់ចេញ | ២៨៩.៣៣២ | - | - | ៤៣៧.៦៩១ | - | (៧២៧.០២៣) | - |
| រំលស់ | - | (១២.១១៤) | (១៥.៩៦៨) | - | (៥.៧៣៥) | - | (៣៣.៨១៧) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | (២៣៤.១៣៧) | (២០៧.១៩២) | (៦៨.៣៣៧) | (២០០.៤២៥) | (១៤៨.២៨៩) | - | (៨៥៨.៣៨០) |
| | ១.០២៦.៧៨៤ | ៤២១.៨១១ | ២១៧.២៧០ | ៦៧០.១៨៣ | ៤៨៦.០៥៣ | ២១៦.៥៤៥ | ៣.០៣៨.៦៤៦ |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០** | | | | | | | |
| ថ្លៃដើម | | | | | | | |
| រំលស់បង្គរ | ៣.៣៣៩.៩៨៥ | ២.៦៥៤.៩០៤ | ៦៤៥.៦០៨ | ២.២១៤.៩៨៤ | ៩០៥.១២០ | ២១៦.៥៤៥ | ៩.៩៧៧.១៤៦ |
| តម្លៃចុះបញ្ជីសុទ្ធ | (២.៣១៣.២០១) | (២.២៣៣.០៩៣) | (៤២៨.៣៣៨) | (១.៥៤៤.៨០១) | (៤១៩.០៦៧) | - | (៦.៩៣៨.៥០០) |
| គិតជាពាន់រៀល | ១.០២៦.៧៨៤ | ៤២១.៨១១ | ២១៧.២៧០ | ៦៧០.១៨៣ | ៤៨៦.០៥៣ | ២១៦.៥៤៥ | ៣.០៣៨.៦៤៦ |
| | ៤.១៥៣.៣៤១ | ១.៧០៦.២២៥ | ៨៧៨.៨៥៧ | ២.៧១០.៨៩០ | ១.៩៦៦.០៨៤ | ៨៧៥.៩២៦ | ១២.២៩១.៣២៣ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ១១. ភតិសន្យា

កំណត់សម្គាល់នេះផ្តល់នូវព័ត៌មានអំពីភតិសន្យា ដែលធនាគារជាភាគីអ្នកជួល។

ធនាគារជួលអគារមួយចំនួនសម្រាប់ធ្វើប្រតិបត្តិការជាការិយាល័យកណ្តាល ការិយាល័យសាខា និងបរិក្ខារ។ ជាទូទៅ កិច្ចសន្យាជួលត្រូវបានធ្វើឡើងសម្រាប់រយៈពេលកំណត់ចាប់ពី២ឆ្នាំរហូតដល់១៥ឆ្នាំ។ ភតិសន្យាទាំងនេះមានរយៈពេលជួល ដែលបញ្ជាក់ពីការឡើងថ្លៃ និងសិទ្ធិបន្តកិច្ចសន្យាខុសៗគ្នា។ ចំពោះការបន្តកិច្ចសន្យាជាថ្មី លក្ខខណ្ឌនៃ ភតិសន្យាទាំងនេះត្រូវបានចរចាឡើងវិញ។

### (ក) ចំនួនទឹកប្រាក់ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ (រយៈពេលវែង)៖ | | | | |
| អគារ | **១៣.៩៣២.៧៨៤** | ៥៦.៣៥៨.១១១ | **១.៣០៣.៩៨២** | ៥.៣១៣.៧២៧ |
| | | | | |
| បំណុលភតិសន្យា៖ | | | | |
| រយៈពេលខ្លី | **១.៥៣៨.១៥៩** | ៦.២២១.៨៥៣ | **២៨៥.២១៥** | ១.១៦២.២៥១ |
| រយៈពេលវែង | **១៣.១៥១.៨១១** | ៥៣.១៩៩.០៧៦ | **១.៥៤៧.១៦០** | ៦.៣០៤.៦៧៧ |
| | **១៤.៦៨៩.៩៧០** | ៥៩.៤២០.៩២៩ | **១.៨៣២.៣៧៥** | ៧.៤៦៦.៩២៨ |

ក្នុងអំឡុងឆ្នាំ ការបន្ថែមទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ មានចំនួន ១៣.០៣៦.២៤៦ ដុល្លារអាមេរិក (២០១៩ ៖ សូន្យ)។

### (ខ) ចំនួនទឹកប្រាក់ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ-ខាត

របាយការណ៍ចំណេញ-ខាត បង្ហាញនូវចំនួនទឹកប្រាក់ដែលពាក់ព័ន្ធនឹងភតិសន្យា ដូចខាងក្រោម ៖

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| រំលស់ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ (កំណត់សម្គាល់ ២៧) | **១.២១៣.៧១០** | ៤.៩៤៨.២៩៦ | **៤៩៧.២៤៨** | ២.០១៤.៨៤៩ |
| ចំណាយការប្រាក់លើបំណុលភតិសន្យា (កំណត់សម្គាល់ ២១) | **៥៣៩.១៤៦** | ២.១៩៨.០៩៨ | **៨៨.០០៦** | ៣៥៦.៦០០ |
| ចំណាយពាក់ព័ន្ធនឹងភតិសន្យារយៈពេលខ្លី (រួមបញ្ចូលក្នុងចំណាយប្រតិបត្តិការផ្សេងៗ) (កំណត់សម្គាល់ ២៨) | **១៥៣.២៨៥** | ៦២៤.៩៤៣ | **៨៥.០៦៧** | ៣៤៤.៦៩១ |
| | **១.៩០៦.១៤១** | ៧.៧៧១.៣៣៧ | **៦៧០.៣២១** | ២.៧១៦.១៤០ |

លំហូរសាច់ប្រាក់ចេញសរុបសម្រាប់ភតិសន្យាឆ្នាំ២០២០មានចំនួន ១.៦៧៧.៣៥០ដុល្លារអាមេរិក (២០១៩៖ ៧៨៨.១៦២ ដុល្លារអាមេរិក)។

## ១២. ទ្រព្យសកម្មអរូបី

| រយៈពេលវែង | កម្មវិធីកុំព្យូទ័រ<br>ដុល្លារអាមេរិក | កម្មវិធីកំពុងដំណើរការ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|
| នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ | | | |
| ថ្លៃដើម | ២.៩០០.៣២៦ | - | ២.៩០០.៣២៦ |
| រំលស់បង្គរ | (១.៣៤២.៥៤៤) | - | (១.៣៤២.៥៤៤) |
| តម្លៃចុះបញ្ជីសុទ្ធ | ១.៥៥៧.៧៨២ | - | ១.៥៥៧.៧៨២ |
| គិតជាពាន់រៀល | ៦.២៥៩.១៦៨ | - | ៦.២៥៩.១៦៨ |
| សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ១.៥៥៧.៧៨២ | - | ១.៥៥៧.៧៨២ |
| បន្ថែម | ៣១០.៥៩៥ | - | ៣១០.៥៩៥ |
| រំលស់ | (៤៨៩.៤៧៤) | - | (៤៨៩.៤៧៤) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ១.៣៧៨.៩០៣ | - | ១.៣៧៨.៩០៣ |
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | | | |
| ថ្លៃដើម | ៣.២១០.៩២១ | - | ៣.២១០.៩២១ |
| រំលស់បង្គរ | (១.៨៣២.០១៨) | - | (១.៨៣២.០១៨) |
| តម្លៃចុះបញ្ជីសុទ្ធ | ១.៣៧៨.៩០៣ | - | ១.៣៧៨.៩០៣ |
| គិតជាពាន់រៀល | ៥.៦១៩.០៣០ | - | ៥.៦១៩.០៣០ |
| សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ១.៣៧៨.៩០៣ | - | ១.៣៧៨.៩០៣ |
| បន្ថែម | ១.១២៣.២៨៥ | ១.៨៤៤.៦៥៥ | ២.៩៦៧.៩៤០ |
| រំលស់ | (៤៧៨.៧៣៤) | - | (៤៧៨.៧៣៤) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ២.០២៣.៤៥៤ | ១.៨៤៤.៦៥៥ | ៣.៨៦៨.១០៩ |
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | | |
| ថ្លៃដើម | ៤.៣៣៤.២០៦ | ១.៨៤៤.៦៥៥ | ៦.១៧៨.៨៦១ |
| រំលស់បង្គរ | (២.៣១០.៧៥២) | - | (២.៣១០.៧៥២) |
| តម្លៃចុះបញ្ជីសុទ្ធ | ២.០២៣.៤៥៤ | ១.៨៤៤.៦៥៥ | ៣.៨៦៨.១០៩ |
| គិតជាពាន់រៀល | ៨.១៨៤.៨៧១ | ៧.៤៦១.៦៣០ | ១៥.៦៤៦.៥០១ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)



## ១៣. (បំណុល)ពន្ធពន្យារ/ពន្ធពន្យារទ្រព្យសកម្ម

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| រយៈពេលវែង | | | | |
| ពន្ធពន្យារទ្រព្យសកម្ម | ៤.០៦៨.៦២៩ | ១៦.៤៥៧.៦០៣ | ១.០០១.៣៨៥ | ៤.០៨០.៦៤៤ |
| បំណុលពន្ធពន្យារ | (២.៧៨៦.៥៥៧) | (១១.២៧១.៦២២) | (១.៥២៩.៩២៤) | (៦.២៣៤.៤៤០) |
| ពន្ធពន្យារទ្រព្យសកម្ម/(បំណុល)សុទ្ធ | ១.២៨២.០៧២ | ៥.១៨៥.៩៨១ | (៥២៨.៥៣៩) | (២.១៥៣.៧៩៦) |

បម្រែបម្រួលពន្ធពន្យារទ្រព្យសកម្ម/(បំណុល)សុទ្ធ ក្នុងអំឡុងឆ្នាំ មានដូចខាងក្រោម៖

(i) ពន្ធពន្យារទ្រព្យសកម្ម

| | បំណុលភតិសន្យា | ខាតពីការថយចុះតម្លៃ | រំលស់ពន្លឿន | អត្ថប្រយោជន៍បុគ្គលិក | កម្រៃឥណទានមិនទាន់រំលស់ | សរុប |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ | ៤៨៩.៤៩៣ | - | ២៦.៨៨៥ | ២៣.៩៩២ | ៤៧៩.៤៩៤ | ១.០១៩.៨៦៤ |
| កត់ត្រាជា(បន្ទុក)/ឥណទានក្នុងចំណេញ-ខាត | (១២៣.០១៨) | - | ៨៦.២០៤ | - | ១៨.៣៣៥ | (១៨.៤៧៩) |
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | ៣៦៦.៤៧៥ | - | ១១៣.០៨៩ | ២៣.៩៩២ | ៤៩៧.៨២៩ | ១.០០១.៣៨៥ |
| គិតជាពាន់រៀល | ១.៤៩៣.៣៨៦ | - | ៤៦០.៨៣៨ | ៩៧.៧៦៧ | ២.០២៨.៦៥៣ | ៤.០៨០.៦៤៤ |
| នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ | ៣៦៦.៤៧៥ | - | ១១៣.០៨៩ | ២៣.៩៩២ | ៤៩៧.៨២៩ | ១.០០១.៣៨៥ |
| កត់ត្រាជា(បន្ទុក)/ឥណទានក្នុងចំណេញ-ខាត | ២.៥៧១.៥១៩ | ៤៨០.០៧៩ | (២១.០៩២) | - | ៣៦.៧៣៨ | ៣.០៦៧.២៤៤ |
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | ២.៩៣៧.៩៩៤ | ៤៨០.០៧៩ | ៩១.៩៩៧ | ២៣.៩៩២ | ៥៣៤.៥៦៧ | ៤.០៦៨.៦២៩ |
| គិតជាពាន់រៀល | ១១.៨៨៤.១៨៦ | ១.៩៤១.៩២០ | ៣៧២.១២៨ | ៩៧.០៤៨ | ២.១៦២.៣២១ | ១៦.៤៥៧.៦០៣ |

(ii) បំណុលពន្ធពន្យារ

| | ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ | ខាតពីការថយចុះតម្លៃ | សរុប |
|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ | (៣៦០.២៤៦) | (៦៣៩.៩០៣) | (១.០០០.១៤៩) |
| កត់ត្រាជាឥណទាន/(បន្ទុក)ក្នុងចំណេញ-ខាត | ៩៩.៤៥០ | (៦២៩.២២៥) | (៥២៩.៧៧៥) |
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | (២៦០.៧៩៦) | (១.២៦៩.១២៨) | (១.៥២៩.៩២៤) |
| គិតជាពាន់រៀល | (១.០៦២.៧៤៤) | (៥.១៧១.៦៩៦) | (៦.២៣៤.៤៤០) |
| នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ | (២៦០.៧៩៦) | (១.២៦៩.១២៨) | (១.៥២៩.៩២៤) |
| កត់ត្រាជាឥណទាន/(បន្ទុក)ក្នុងចំណេញ-ខាត | (២.៥២៥.៧៦១) | ១.២៦៩.១២៨ | (១.២៥៦.៦៣៣) |
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | (២.៧៨៦.៥៥៧) | - | (២.៧៨៦.៥៥៧) |
| គិតជាពាន់រៀល | (១១.២៧១.៦២២) | - | (១១.២៧១.៦២២) |

## ១៤. ទ្រព្យសកម្មផ្សេងៗ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| បុរេប្រទានអត្ថប្រយោជន៍បុគ្គលិក | **១.៥២០.៦៩២** | ៦.១៥១.១៩៩ | **១.៣២០.៩០៥** | ៥.៣៨២.៦៨៧ |
| កម្រៃផ្នែកច្បាប់ដែលត្រូវទទួល | **១.២៩២.៧៩៦** | ៥.២២៩.៣៦០ | **១.០៩០.៦៥៩** | ៤.៤៤៤.៤៣៥ |
| ប្រាក់កក់ | **៦៤២.៩៧៦** | ២.៦០០.៨៣៨ | **៦៣៤.៨៣៦** | ២.៥៨៦.៩៥៧ |
| សម្ភារផ្គត់ផ្គង់ | **១៨៨.៩៩០** | ៧៦៤.៤៦៤ | **១៣៥.៤៩៩** | ៥៥២.១៥៨ |
| ចំណាយបង់មុន | **១៧៩.៧១៦** | ៧២៦.៩៥២ | **៥៩៧.៦៨៣** | ២.៤៣៥.៥៥៨ |
| ទឹកប្រាក់ភាគីពាក់ព័ន្ធជំពាក់ (កំណត់សម្គាល់ ៣៣.គ) | **៥១.៨៩៣** | ២០៩.៩០៧ | **១៣៧.៣៦៥** | ៥៥៩.៧៦៣ |
| ផ្សេងៗ | **២២៧.០២២** | ៩១៨.៣០៤ | **៦៧.០៩៦** | ២៧៣.៤១៧ |
| | **៤.១០៤.០៨៥** | ១៦.៦០១.០២៤ | **៣.៩៨៤.០៤៣** | ១៦.២៣៤.៩៧៥ |
| ដកៈ សំវិធានធនការខាតឥណទានរំពឹងទុក (កំណត់សម្គាល់ ៣៤.១.ង) | **(១៦៨.១៨២)** | (៦៨០.២៩៦) | **(៣៩២.២៨០)** | (១.៥៩៨.៥៤១) |
| | **៣.៩៣៥.៩០៣** | ១៥.៩២០.៧២៨ | **៣.៥៩១.៧៦៣** | ១៤.៦៣៦.៤៣៤ |
| រយៈពេលខ្លី | ១.៦៦៩.៧៦៨ | ៦.៧៥៤.២១២ | ១.៧៦២.៦៥៧ | ៧.១៨២.៨២៧ |
| រយៈពេលវែង | ២.២៦៦.១៣៥ | ៩.១៦៦.៥១៦ | ១.៨២៩.១០៦ | ៧.៤៥៣.៦០៧ |
| | ៣.៩៣៥.៩០៣ | ១៥.៩២០.៧២៨ | ៣.៥៩១.៧៦៣ | ១៤.៦៣៦.៤៣៤ |

## ១៥. ប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| រយៈពេលខ្លី | | | | |
| ប្រាក់បញ្ញើមានកាលកំណត់ | **១៤៩.៨៣៧.១៩៤** | ៦០៦.០៩១.៤៥០ | **១០១.៣១៤.៣៤២** | ៤១២.៨៥៥.៩៤៣ |
| គណនីចរន្ត | **១៨.២៦៨.២៩១** | ៧៣.៨៩៥.២៣៧ | **៤១.៥៨២.៦៣៧** | ១៦៩.៤៤៩.២៤៦ |
| ប្រាក់បញ្ញើសន្សំ | **២.៤២៥.២៨៩** | ៩.៨១០.២៩៤ | **៤៩៥.៣៨៣** | ២.០១៨.៦៨៦ |
| | **១៧០.៥៣០.៧៧៤** | ៦៨៩.៧៩៦.៩៨១ | **១៤៣.៣៩២.៣៦២** | ៥៨៤.៣២៣.៨៧៥ |

អត្រាការប្រាក់ប្រចាំឆ្នាំសម្រាប់ប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ មានដូចខាងក្រោមៈ

| | ២០២០ | ២០១៩ |
|---|---|---|
| គណនីចរន្ត | 0%-២,៧៨% | 0% - ២,៨0% |
| ប្រាក់បញ្ញើសន្សំ | 0,៥0% | 0,៥0% |
| ប្រាក់បញ្ញើមានកាលកំណត់ | 0,៨៩%-២,៤0% | ២% - ៥,៥0% |

## ១៦. ប្រាក់បញ្ញើរបស់អតិថិជន

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| ប្រាក់បញ្ញើមានកាលកំណត់ | **៣៧៥.៨៨៦.៨៤៧** | ១.៥២០.៤៦២.២៩៦ | **២៩៨.៤៣៤.៩៣៨** | ១.២១៦.១២២.៣៧២ |
| គណនីចរន្ត | **១៥៦.៨៥៣.៦៩៧** | ៦៣៤.៤៧៣.២០៤ | **២៦៩.៦៩៨.១៧២** | ១.០៩៩.០២០.០៥១ |
| ប្រាក់បញ្ញើសន្សំ | **៦៦.៣៦៥.៣០៤** | ២៦៨.៤៤៧.៦៥៥ | **៦៤.៦៣៦.៥៤៨** | ២៦៣.៣៩៣.៩៣៣ |
| | **៥៩៩.១០៥.៨៤៨** | ២.៤២៣.៣៨៣.១៥៥ | **៦៣២.៧៦៩.៦៥៨** | ២.៥៧៨.៥៣៦.៣៥៦ |
| រយៈពេលខ្លី | **៥៨៥.៤៥៥.៣៣៩** | ២.៣៦៨.១៦៦.៨៤៦ | **៦២៤.៦៩០.២៨៥** | ២.៥៤៥.៦១២.៩១១ |
| រយៈពេលវែង | **១៣.៦៥០.៥០៩** | ៥៥.២១៦.៣០៩ | **៨.០៧៩.៣៧៣** | ៣២.៩២៣.៤៤៥ |
| | **៥៩៩.១០៥.៨៤៨** | ២.៤២៣.៣៨៣.១៥៥ | **៦៣២.៧៦៩.៦៥៨** | ២.៥៧៨.៥៣៦.៣៥៦ |

អត្រាការប្រាក់ប្រចាំឆ្នាំសម្រាប់ប្រាក់បញ្ញើរបស់អតិថិជន មានដូចខាងក្រោម៖

| | ២០២០ | ២០១៩ |
|---|---|---|
| គណនីចរន្ត | **0% - ២,៣៨%** | 0% - ២,១0% |
| ប្រាក់បញ្ញើសន្សំ | **0,៥0% - ១,២៥%** | 0,៥0% - ១,៣0% |
| ប្រាក់បញ្ញើមានកាលកំណត់ | **១,៥0% - ៦,៦៨%** | ១,៥0% - ១0% |

## ១៧. ប្រាក់កម្ចី

ប្រាក់កម្ចីពីធនាគារកណ្តាល គឺជាប្រាក់កម្ចីក្នុងទម្រង់ជាប្រតិបត្តិការផ្តល់សន្ទនីយភាព ដោយមានការធានា (LPCO) គឺជាប្រាក់កម្ចីជាប្រាក់រៀល ដែលមានរយៈពេលក្នុងចន្លោះពី ៦ខែ ទៅ ១២ខែ ដែលធនាគារបានប្រើប្រាស់ NCD ជាប្រាក់ដុល្លារអាមេរិកជាទ្រព្យបញ្ចាំ (កំណត់សម្គាល់ ៥)។ អត្រាការប្រាក់ប្រចាំឆ្នាំស្ថិតក្នុងចន្លោះពី ២,៧0% ទៅ ៤,៥0% (២០១៩ ៖ ២,៨0% ទៅ ៣%)។

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| LPCO នៅធនាគារកណ្តាល - រយៈពេលខ្លី៖ | | | | |
| ចំនួនប្រាក់ដើម | **៣៣.៨៥៦.៦៤២** | ១៣៦.៩៥០.១១៧ | **២៧.៤៨៤.៦៨៨** | ១១២.000.១0៤ |
| ការប្រាក់ត្រូវបង់ | **៣៩៥.៧៩៦** | ១.៦00.៩៩៥ | **១២៦.៤៧0** | ៥១៥.៣៦៥ |
| | **៣៤.២៥២.៤៣៨** | ១៣៨.៥៥១.១១២ | **២៧.៦១១.១៥៨** | ១១២.៥១៥.៤៦៩ |

បម្រែបម្រួលបំណុលដែលកើតមកពីសកម្មភាពហិរញ្ញប្បទាន – ប្រាក់កម្ចី

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| នៅថ្ងៃទី០១ ខែមករា | **២៧.៦១១.១៥៨** | ១១២.៥១៥.៤៦៩ | - | - |
| ការបន្ថែម | **៦៨.៩៦១.៦៨១** | ២៨១.១៥៦.៧៧៣ | **២៩.៥៤៦.0៤0** | ១១៩.៧២0.៥៥៤ |
| ការទូទាត់សង | **(៦២.៧៩៣.៥៧២)** | (២៥៦.00៩.៣៩៣) | **(២.0៥៧.៨១៥)** | (៨.៣៣៨.២៦៦) |
| ចំណាយការប្រាក់ក្នុងឆ្នាំ(កំណត់សម្គាល់២១) | **១.២២២.៦១៦** | ៤.៩៨៤.៦0៥ | **១៥៦.២៧៨** | ៦៣៣.២៣៨ |
| ការទូទាត់ការប្រាក់ | **(៩៩៨.៣១៩)** | (៤.0៧0.១៤៧) | **(២៦.៣២៣)** | (១0៦.៦៦១) |
| លម្អៀងពីការផ្តោះប្តូរ | **២៤៨.៨៧៤** | ១.0១៤.៦៥៩ | **(៧.0២២)** | (២៨.៤៥៣) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (១.0៤0.៨៥៤) | - | ៦៣៥.0៥៧ |
| នៅថ្ងៃទី៣១ ខែធ្នូ | **៣៤.២៥២.៤៣៨** | ១៣៨.៥៥១.១១២ | **២៧.៦១១.១៥៨** | ១១២.៥១៥.៤៦៩ |

## ១៨. បំណុលពន្ធលើប្រាក់ចំណូលក្នុងឆ្នាំ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| នៅថ្ងៃទី០១ ខែមករា | **២.៨៩៣.៧៥៣** | ១១.៧៩២.០៤៣ | **១.៤០៨.៥៩០** | ៥.៦៥៩.៧១៥ |
| ពន្ធលើប្រាក់ចំណូលក្នុងឆ្នាំ (កំណត់សម្គាល់ ២៩) | **២.៥២៩.២៧៧** | ១០.៣១១.៨៦១ | **៣.៣១៩.៨៤៣** | ១៣.៤៥២.០០៤ |
| ពន្ធលើប្រាក់ចំណូលបានបង់ | **(៣.១៧៥.០៣៣)** | (១២.៩៤៤.៦១០) | **(១.៨៣៤.៦៨០)** | (៧.៤៧៦.៣២៣) |
| ការប៉ាន់ស្មានលើសនៃពន្ធក្នុងឆ្នាំរបស់ឆ្នាំមុន | **(២០៧.៤៤៣)** | (៨៤៥.៧៤៥) | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (៥៩.៥០៨) | - | ១៥៦.៦៤៧ |
| នៅថ្ងៃទី៣១ ខែធ្នូ | **២.០៤០.៥៥៤** | ៨.២៥៤.០៤១ | **២.៨៩៣.៧៥៣** | ១១.៧៩២.០៤៣ |

## ១៩. បំណុលផ្សេងៗ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| មូលប្បទានបត្រសម្រាប់ប្រមូលប្រាក់ | **១.៨៦០.១០៥** | ៧.៥២៤.១២៥ | **៤.១១២.៩៣៥** | ១៦.៧៦០.២១០ |
| បង្គរប្រាក់រង្វាន់ | **៤១៤.០៣១** | ១.៦៧៤.៧៥៥ | **១.២៥០.២៤២** | ៥.០៩៤.៧៣៦ |
| សំវិធានធនសម្រាប់ការខាតឥណទានរំពឹងទុក លើកិច្ចសន្យាផ្តល់ឥណទាន និងកិច្ចសន្យាធានាផ្នែកហិរញ្ញវត្ថុ (កំណត់សម្គាល់ ៣៤.១.ច.ii) | **៣៧៧.៩២៦** | ១.៥២៨.៧១១ | **៣៩.៤៨៧** | ១៦០.៩១០ |
| ពន្ធត្រូវបង់ផ្សេងៗ | **២៦៩.៤៧៤** | ១.០៩០.០២២ | **១៥៨.៨៩២** | ៦៤៧.៤៨៥ |
| បង្គរចំណាយផ្សេងៗ | **១៣៦.១៧៣** | ៥៥០.៨២០ | **៧០២.៥០៤** | ២.៨៦២.៧០៤ |
| ផ្សេងៗ | **៤៩៣.១៥៧** | ១.៩៩៤.៨២០ | **២១៥.១៩៤** | ៨៧៦.៩១៥ |
| | **៣.៥៥០.៨៦៦** | ១៤.៣៦៣.២៥៣ | **៦.៤៧៩.២៥៤** | ២៦.៤០២.៩៦០ |
| រយៈពេលខ្លី | **៣.៤៣៩.៦៥៥** | ១៣.៩១០.០៦៨ | **៦.៣៦៨.០៧៣** | ២៥.៩៤៩.៨៩៧ |
| រយៈពេលវែង | **១១១.២១១** | ៤៥៣.១៨៥ | **១១១.១៨១** | ៤៥៣.០៦៣ |
| | **៣.៥៥០.៨៦៦** | ១៤.៣៦៣.២៥៣ | **៦.៤៧៩.២៥៤** | ២៦.៤០២.៩៦០ |

## ២០. ដើមទុន

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ដើមទុនចុះបញ្ជីសរុបរបស់ធនាគារមានចំនួន ៧៥.០០០.០០០ភាគហ៊ុន(២០១៩ ៖ ៧៥.០០០.០០០ភាគហ៊ុន) ដែលមានតម្លៃចារឹក១ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន (២០១៩៖ ១ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន)។ ភាគហ៊ុនដែលបានអនុម័តទាំងអស់ ត្រូវបានចេញផ្សាយ និងបានបង់ប្រាក់រួចរាល់ទាំងស្រុង។

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| នៅថ្ងៃទី០១ ខែមករា | **៧៥.០០០.០០០** | ៣០៥.៦២៥.០០០ | **៧៥.០០០.០០០** | ៣០១.៣៥០.០០០ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (២.២៥០.០០០) | - | ៤.២៧៥.០០០ |
| នៅថ្ងៃទី៣១ ខែធ្នូ | **៧៥.០០០.០០០** | ៣០៣.៣៧៥.០០០ | **៧៥.០០០.០០០** | ៣០៥.៦២៥.០០០ |

## ២១. ចំណូលការប្រាក់សុទ្ធ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| ចំណូលការប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមថ្លៃដើមដករំលស់៖ | | | | |
| ឥណទាន និងបុរេប្រទាន | ៤៤.៥២៤.៦៥៦ | ១៨១.៥២៧.០២៣ | ៣៨.៧៣៥.០៥២ | ១៥៦.៩៥៤.៤៣១ |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារផ្សេងៗ | ១.៦១០.២៧៣ | ៦.៥៦៥.០៨៣ | ១.៩៤០.៥៤៩ | ៧.៨៦៣.១០៤ |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារកណ្តាល | ៣៩០.០៣៥ | ១.៥៩០.១៧២ | ៥១២.៦៣២ | ២.០៧៧.១៨៥ |
| | ៤៦.៥២៤.៩៦៤ | ១៨៩.៦៨២.២៧៨ | ៤១.១៨៨.២៣៣ | ១៦៦.៨៩៤.៧២០ |
| ចំណាយការប្រាក់លើបំណុលហិរញ្ញវត្ថុ វាស់វែងតាមថ្លៃដើមដករំលស់៖ | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | ១៧.៥០១.៩៥៦ | ៧១.៣៥៥.៤៧៥ | ១៤.៥៥៤.៩៤៥ | ៥៨.៩៧៦.៦៣៨ |
| ប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ | ២.៣៨៤.៨៦៧ | ៩.៧២៣.១០៣ | ១.១៦៤.១៧០ | ៤.៧១៧.២១៧ |
| ប្រាក់កម្ចី (កំណត់សម្គាល់ ១៧) | ១.២២២.៦១៦ | ៤.៩៨៤.៦០៥ | ១៥៦.២៧៨ | ៦៣៣.២៣៨ |
| បំណុលភតិសន្យា (កំណត់សម្គាល់១១) | ៥៣៩.១៤៦ | ២.១៩៨.០៩៨ | ៨៨.០០៦ | ៣៥៦.៦០០ |
| | ២១.៦៤៨.៥៨៥ | ៨៨.២៦១.២៨១ | ១៥.៩៦៣.៣៩៩ | ៦៤.៦៨៣.៦៩៣ |
| ចំណូលការប្រាក់សុទ្ធ | ២៤.៨៧៦.៣៧៩ | ១០១.៤២០.៩៩៧ | ២៥.២២៤.៨៣៤ | ១០២.២១១.០២៧ |

រួមបញ្ចូលនៅក្នុងចំណូលការប្រាក់ពីឥណទាន និងបុរេប្រទានវាស់វែងតាមថ្លៃដើមដករំលស់ មានចំណូលការប្រាក់បង្គរលើឥណទានដែលមានការថយចុះតម្លៃ ចំនួន ១.៦១៥.៧៧១ ដុល្លារអាមេរិក (២០១៩ ៖ ៣.៥៣១.៤៨១ ដុល្លារអាមេរិក)។

## ២២. ចំណូលកម្រៃជើងសាសុទ្ធ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| ចំណូលកម្រៃជើងសា៖ | | | | |
| កម្រៃពីសេវាផ្ទេរប្រាក់ | **១.០១៦.០១៧** | ៤.១៤២.៣០១ | **៩៣៨.១០៦** | ៣.៨០១.២០៦ |
| កម្រៃពីការសងឥណទានមុនកាលកំណត់ | **៤៣៦.១០៨** | ១.៧៧៨.០១២ | **៦៤៦.៥៦៣** | ២.៦១៩.៨៧៣ |
| កម្រៃពីឥណទានវិបារូបន៍មិនបានប្រើ | **២៨៤.៦៨៦** | ១.១៦០.៦៦៥ | **២៧៧.៣៧១** | ១.១២៣.៩០៧ |
| កម្រៃសេវាឥណទានពាណិជ្ជកម្ម | **១៣៩.៤៥៣** | ៥៦៨.៥៥០ | **១៧២.០៣៧** | ៦៩៧.០៩៤ |
| កម្រៃផ្សេងៗ | **៤៣៦.៧៣៩** | ១.៧៨០.៥៨៥ | **៣៩០.៦២៣** | ១.៥៨២.៨០៤ |
| | **២.៣១៣.០០៣** | ៩.៤៣០.១១៣ | **២.៤២៤.៧០០** | ៩.៨២៤.៨៨៤ |
| ចំណាយកម្រៃជើងសា | **៩.៤១៦** | ៣៨.៣៨៩ | **៩.០០៨** | ៣៦.៥០០ |
| ចំណូលកម្រៃជើងសាសុទ្ធ | **២.៣០៣.៥៨៧** | ៩.៣៩១.៧២៤ | **២.៤១៥.៦៩២** | ៩.៧៨៨.៣៨៤ |

## ២៣. ចំណូលប្រតិបត្តិការផ្សេងៗ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលភាគលាភ | **២៨.៩៥២** | ១១៨.០៣៧ | **២៥.៥៧៥** | ១០៣.៦៣០ |
| ចំណូលផ្សេងៗ | **៦៤.២១៨** | ២៦១.៨១៧ | **៦១.៨៦២** | ២៥០.៦៦៥ |
| | **៩៣.១៧០** | ៣៧៩.៨៥៤ | **៨៧.៤៣៧** | ៣៥៤.២៩៥ |

## ២៤. ចំណេញ/(ខាត)ផ្សេងៗ - សុទ្ធ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណេញ/(ខាត)ពីការប្តូររូបិយប័ណ្ណ | **៣១៦.០៣៦** | ១.២៨៨.៤៧៩ | **(២៣២.២៩៩)** | (៩៤១.២៧៦) |
| (ខាត)/ចំណេញពីការលក់ទ្រព្យសកម្ម | **(៣.៥៦៥)** | (១៤.៥៣៥) | **៩៧.៨០០** | ៣៩៦.២៨៦ |
| | **៣១២.៤៧១** | ១.២៧៣.៩៤៤ | **(១៣៤.៤៩៩)** | (៥៤៤.៩៩០) |

## ២៥. ខាតបណ្តាលមកពីការថយចុះតម្លៃឥណទាន

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណាយការថយចុះតម្លៃឥណទាន/(កត់ត្រាត្រឡប់មកវិញ)៖ | | | | |
| ឥណទាន និងបុរេប្រទានវាស់វែងតាមថ្លៃដើមដករំលស់ | **១៤.៦៧២.២៨៣** | ៥៩.៨១៨.៨៩៨ | **(១.៣២៨.៨៩៥)** | (៥.៣៨៤.៦៨៣) |
| កិច្ចសន្យាផ្តល់ឥណទាន និងការធានាផ្នែកហិរញ្ញវត្ថុ | **៣៣៨.៤៣៩** | ១.៣៧៩.៨១៦ | **(២៧.៤៤៦)** | (១១១.២១១) |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារផ្សេងៗ | **(៧៧៩.៥០៤)** | (៣.១៧៨.០៣៨) | **៦២៤.៥៩៥** | ២.៥៣០.៨៥៩ |
| ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗវាស់វែងតាមថ្លៃដើមដករំលស់ | **(២២៤.០៩៨)** | (៩១៣.៦៤៨) | **៥.៥២២** | ២២.៣៧៥ |
| | **១៤.០០៧.១២០** | ៥៧.១០៧.០២៨ | **(៧២៦.២២៤)** | (២.៩៤២.៦៦០) |

## ២៦. ចំណាយបុគ្គលិក

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់បៀវត្សរ៍ និងប្រាក់ម៉ោង | **៣.៧៣៨.៧៣៤** | ១៥.២៤២.៨១៩ | **៣.២០៤.៣០៣** | ១២.៩៨៣.៨៣៦ |
| ប្រាក់រង្វាន់ និងចំណាយប្រាក់លើកទឹកចិត្ត | **២៣៧.៨០៦** | ៩៦៩.៥៣៥ | **៧០៩.៨៨៥** | ២.៨៧៦.៤៥៤ |
| ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ | **១៥៨.៧០៥** | ៦៤៧.០៤០ | **១៧០.១២៦** | ៦៨៩.៣៥១ |
| អត្ថប្រយោជន៍បុគ្គលិកផ្សេងៗ | **៣២០.០១២** | ១.៣០៤.៦៨៩ | **៤៦១.២៥១** | ១.៨៦៨.៩៨៨ |
| | **៤.៤៥៥.២៥៧** | ១៨.១៦៤.០៨៣ | **៤.៥៤៥.៥៦៥** | ១៨.៤១៨.៦២៩ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ២៧. រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| រំលស់ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់(កំណត់សម្គាល់ ១១) | **១.២១៣.៧១០** | ៤.៩៤៨.២៩៦ | **៤៩៧.២៤៨** | ២.០១៤.៨៤៩ |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ (កំណត់សម្គាល់ ១០) | **៨៥៨.៣៨០** | ៣.៤៩៩.៦១៥ | **៦៨៦.៧៧៤** | ២.៧៨២.៨០៨ |
| រំលស់ទ្រព្យសកម្មអរូបី (កំណត់សម្គាល់ ១២) | **៤៧៨.៧៣៤** | ១.៩៥១.៧៩៨ | **៤៨៩.៤៧៤** | ១.៩៨៣.៣៤៩ |
| | **២.៥៥០.៨២៤** | ១០.៣៩៩.៧០៩ | **១.៦៧៣.៤៩៦** | ៦.៧៨១.០០៦ |

## ២៨. ចំណាយប្រតិបត្តិការផ្សេងៗ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណាយជួសជុល និងថែទាំ | **៧៧៥.៦៣៩** | ៣.១៦២.២៨០ | **៦៥៨.៧៥២** | ២.៦៦៩.២៦៣ |
| ចំណាយសន្តិសុខ | **៣១៤.២៧៦** | ១.២៨១.៣០៣ | **២៩៣.០៨៩** | ១.១៨៧.៥៩៧ |
| កម្រៃអាជ្ញាប័ណ្ណ | **២៧២.៣២៣** | ១.១១០.២៦១ | **២៧៩.៧៤៣** | ១.១៣៣.៥១៩ |
| សេវាធនាគារ | **២៣៧.២៥៩** | ៩៦៧.៣០៥ | **២៣០.៨០១** | ៩៣៥.២០៦ |
| ទឹកភ្លើង | **២៣៤.២៣៥** | ៩៥៤.៩៧៦ | **២០៩.៩៤១** | ៨៥០.៦៨១ |
| ចំណាយធានារ៉ាប់រង | **១៩៥.៧០៧** | ៧៩៧.៨៩៧ | **១៦៩.៧២២** | ៦៨៧.៧១៤ |
| ចំណាយការជួល | **១៥៣.២៨៥** | ៦២៤.៩៤៣ | **៨៥.០៦៧** | ៣៤៤.៦៩១ |
| ចំណាយទំនាក់ទំនង | **១២៣.៦៨២** | ៥០៤.២៥២ | **១១៧.៥២១** | ៤៧៦.១៩៥ |
| កម្រៃសេវាផ្នែកច្បាប់ និងសេវាវិជ្ជាជីវៈ | **១២៣.២៩០** | ៥០២.៦៥៣ | **១២៣.៣៧៣** | ៤៩៩.៩០៧ |
| ផ្សាយពាណិជ្ជកម្ម និងទំនាក់ទំនងសាធារណៈ | **១១៥.៧៧៥** | ៤៧២.០១៥ | **៤៣៦.២១២** | ១.៧៦៧.៥៣១ |
| ចំណាយដំណើរការយានយន្ត | **១១០.៨០១** | ៤៥១.៧៣៦ | **១១៦.៨៦៦** | ៤៧៣.៥៤១ |
| សម្ភារផ្គត់ផ្គង់ការិយាល័យ | **៧២.៧៣២** | ២៩៦.៥២៨ | **៥១.១៧៦** | ២០៧.៣៦៥ |
| ការបោះពុម្ព និងទម្រង់បែបបទផ្សេងៗ | **៦១.៨១៥** | ២៥២.០២០ | **៣៤.៩៩៨** | ១៤១.៨១២ |
| ការធ្វើដំណើរ ការស្នាក់នៅ និងអាហារ | **៥១.១៩៦** | ២០៨.៧២៦ | **១០៦.៦១៧** | ៤៣២.០១២ |
| កម្រៃរបស់ក្រុមប្រឹក្សាភិបាល (កំណត់សម្គាល់ ៣៣.ង) | **៣០.០៥៧** | ១២២.៥៤២ | **៣៨.៤១២** | ១៥៥.៦៤៥ |
| ផ្សេងៗ | **៤៤៧.៦៧៤** | ១.៨២៥.១៦៧ | **២៩១.០៣៩** | ១.១៧៩.២៩០ |
| | **៣.៣១៩.៧៤៦** | ១៣.៥៣៤.៦០៤ | **៣.២៤៣.៣២៩** | ១៣.១៤១.៩៦៩ |

## ២៩. ចំណាយពន្ធលើប្រាក់ចំណូល

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ពន្ធលើប្រាក់ចំណូលក្នុងឆ្នាំ | **២.៥២៩.២៧៧** | ១០.៣១១.៨៦១ | **៣.៣១៩.៨៤៣** | ១៣.៤៥២.០០៤ |
| ការប៉ាន់ស្មានលើសនៃពន្ធក្នុងឆ្នាំ របស់ឆ្នាំមុន | **(២០៧.៤៤៣)** | (៨៤៥.៧៤៥) | - | - |
| | **២.៣២១.៨៣៤** | ៩.៤៦៦.១១៦ | **៣.៣១៩.៨៤៣** | ១៣.៤៥២.០០៤ |
| ពន្ធពន្យារលើប្រាក់ចំណូល | **(១.៨១០.៦១១)** | (៧.៣៨១.៨៦១) | **៥៤៨.២៥៤** | ២.២២១.៥២៥ |
| | **៥១១.២២៣** | ២.០៨៤.២៥៥ | **៣.៨៦៨.០៩៧** | ១៥.៦៧៣.៥២៩ |

## ២៩. ចំណាយពន្ធលើប្រាក់ចំណូល (ត)

### (i) ការផ្ទៀងផ្ទាត់រវាងចំណាយពន្ធលើប្រាក់ចំណូល និងចំណេញតាមគណនេយ្យ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| ចំណេញមុនពន្ធលើប្រាក់ចំណូល | **៣.២៥២.៦៦០** | ១៣.២៦១.០៩៥ | **១៨.៨៥៧.២៩៨** | ៧៦.៤០៩.៧៧២ |
| ពន្ធគណនាតាមអត្រា ២០% | **៦៥០.៥៣២** | ២.៦៥២.២១៩ | **៣.៧៧១.៤៦០** | ១៥.២៨១.៩៥៦ |
| ផលប៉ះពាល់ពន្ធនៃចំណាយដែលមិនត្រូវកាត់កងតាមច្បាប់ពន្ធ | **៦៨.១៣៤** | ២៧៧.៧៨១ | **៩៦.៦៣៧** | ៣៩១.៥៧៣ |
| ការប៉ាន់ស្មានលើសនៃពន្ធក្នុងឆ្នាំ របស់ឆ្នាំមុន | **(២០៧.៤៤៣)** | (៨៤៥.៧៤៥) | - | - |
| ចំណាយពន្ធលើប្រាក់ចំណូល | **៥១១.២២៣** | ២.០៨៤.២៥៥ | **៣.៨៦៨.០៩៧** | ១៥.៦៧៣.៥២៩ |

យោងតាមច្បាប់ស្តីពីសារពើពន្ធនៃកម្ពុជា ធនាគារត្រូវបង់ពន្ធលើប្រាក់ចំណូលតាមអត្រា ២០%។

### (ii) បញ្ហាផ្សេងៗ

ពន្ធ ត្រូវបានគណនាតាមមូលដ្ឋានបំណកស្រាយបច្ចុប្បន្នលើបទប្បញ្ញត្តិពន្ធដារ ដែលបានចូលជាធរមាននាកាលបរិច្ឆេទរាយការណ៍។ គណៈគ្រប់គ្រងវាយតម្លៃទៅតាមការិយបរិច្ឆេទ អំពីស្ថានភាពដែលបានកើតឡើងក្នុងលិខិតប្រកាសពន្ធ ដែលទាក់ទិនទៅនឹងបទប្បញ្ញត្តិពន្ធ និងបំណកស្រាយរបស់វាដែលនៅជាធរមាន។ ធនាគារកត់ត្រា សំវិធានធនតាមការសមស្រប ទៅតាមមូលដ្ឋាននៃចំនួនទឹកប្រាក់ដែលរំពឹងថាត្រូវបង់ជូនអាជ្ញាធរពន្ធដារ។

ទោះជាយ៉ាងណាក៏ដោយ បទប្បញ្ញត្តិទាំងអស់នេះមានការផ្លាស់ប្តូរពីមួយគ្រាទៅមួយគ្រា ហើយការកំណត់ចុងក្រោយបំផុតលើចំនួនបំណុលពន្ធនឹងធ្វើឡើង បន្ទាប់ពីមានការត្រួតពិនិត្យដោយអាជ្ញាធរពន្ធដារ។ នៅពេលដែលលទ្ធផលពន្ធចុងក្រោយខុសគ្នាពីចំនួនដែលបានទទួលស្គាល់ពីដំបូងនោះ ភាពលម្អៀងនេះនឹងធ្វើឱ្យប៉ះពាល់ដល់សមតុល្យបំណុលពន្ធក្នុងការិយបរិច្ឆេទដែលការកំណត់ពន្ធត្រូវបានធ្វើឡើង។

## ៣០. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| សាច់ប្រាក់ក្នុងដៃ (កំណត់សម្គាល់ ៤) | **៨.៧៦៩.៩៧៥** | ៣៥.៤៧៤.៥៤៩ | **៨.៤០៨.៨០២** | ៣៤.២៦៥.៨៦៨ |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារកណ្តាល (កំណត់សម្គាល់ ៥)៖ | | | | |
| គណនីចរន្ត | **១០៩.៣៨៤.២៨២** | ៤៤២.៤៥៩.៤២១ | **១៣៤.៩២៥.៤០៤** | ៥៤៩.៨២១.០២១ |
| គណនីទូទាត់ | **៥.៩១៥.៨៣៣** | ២៣.៩២៩.៥៤៤ | **៥.០២២.២១៦** | ២០.៤៦៥.៥៣០ |
| មូលបត្រអាចជួញដូរបាន (កាលកំណត់ បីខែ ឬតិចជាង) | **២៦.០០០.០០០** | ១០៥.១៧០.០០០ | **៣៧.០៣២.៦៥០** | ១៥០.៩០៨.០៤៩ |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារផ្សេងៗ (កំណត់សម្គាល់ ៦)៖ | | | | |
| គណនីចរន្ត | **២៦.៧៤៥.០៩៦** | ១០៨.១៨៣.៩១៤ | **៧៣.០៧២.៥៩៣** | ២៩៧.៧៧០.៨១៦ |
| ប្រាក់បញ្ញើមានកាលកំណត់ (កាលកំណត់បីខែ ឬ តិចជាង) | **១៦.៦៦៦.៦២៥** | ៦៧.៤១៦.៤៩៨ | **១៧.៧៥៦.៣៧០** | ៧២.៣៥៧.២០៨ |
| | **១៩៣.៤៨១.៨១១** | ៧៨២.៦៣៣.៩២៦ | **២៧៦.២១៨.០៣៥** | ១.១២៥.៥៨៨.៤៩២ |

## ៣១. ព័ត៌មានលំហូរសាច់ប្រាក់

### (ក) សាច់ប្រាក់(បានប្រើក្នុង)/ចេញពីប្រតិបត្តិការ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណេញមុនពន្ធលើប្រាក់ចំណូល | **៣.២៥២.៦៦០** | ១៣.២៦១.០៩៥ | **១៨.៨៥៧.២៩៨** | ៧៦.៤០៩.៧៧២ |
| និយ័តកម្មៈ | | | | |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី (កំណត់សម្គាល់ ២៧) | **២.៥៥០.៨២៤** | ១០.៣៩៩.៧០៩ | **១.៦៧៣.៤៩៦** | ៦.៧៨១.០០៦ |
| ខាតពីការថយចុះតម្លៃឥណទាន (កំណត់សម្គាល់ ២៥) | **១៤.០០៧.១២០** | ៥៧.១០៧.០២៨ | **(៧២៦.២២៤)** | (២.៩៤២.៦៦០) |
| ខាត/(ចំណេញ)ពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ (កំណត់សម្គាល់ ២៤) | **៣.៥៦៥** | ១៤.៥៣៥ | **(៩៧.៨០០)** | (៣៩៦.២៨៦) |
| ខាតពីការប្តូររូបិយប័ណ្ណប្រាក់កម្ចី និងការទូទាត់ការប្រាក់ (កំណត់សម្គាល់ ១៧) | **២៤៨.៨៧៤** | ១.០១៤.៦៥៩ | **៧.០២២** | ២៨.៤៥៣ |
| ចំណូលការប្រាក់សុទ្ធ (កំណត់សម្គាល់ ២១) | **(២៤.៨៧៦.៣៧៩)** | (១០១.៤២០.៩៩៧) | **(២៥.២២៤.៨៣៤)** | (១០២.២១១.០២៧) |
| | | | | |
| បម្រែបម្រួលដើមទុនបង្វិលៈ | | | | |
| ទុនបម្រុងកាតព្វកិច្ច | **(៧២៥.៩១៩)** | (២.៩៥៩.៥៧២) | **(៧.១៤៣.៤៥៦)** | (២៨.៩៤៥.២៨៤) |
| ឥណទាន និងបុរេប្រទានវាស់វែងតាមថ្លៃដើមដករំលស់ | **(៧៤.០០៥.៥៧៥)** | (៣០១.៧២០.៧២៩) | **(៧៤.៨៣៤.៣៥៣)** | (៣០៣.២២៨.៧៩៨) |
| ទ្រព្យសកម្មផ្សេងៗ | **(១២០.០៤២)** | (៤៨៩.៤១១) | **(១.២៦៦.៤៣១)** | (៥.១៣១.៥៧៨) |
| ប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ | **២៧.១០១.១២៣** | ១១០.៤៩១.២៧៨ | **៩១.២០០.៩១២** | ៣៦៩.៥៤៦.០៩៥ |
| ប្រាក់បញ្ញើរបស់អតិថិជន | **(៣៥.៨២០.១៤០)** | (១៤៦.០៣៨.៧១១) | **៤៧.៩៥០.៦៨២** | ១៩៤.២៩៦.១៦៣ |
| អត្ថប្រយោជន៍បុគ្គលិក | **៥៧.៣៧១** | ២២៨.៤៦៧ | - | - |
| បំណុលផ្សេងៗ | **(៣.២៦៦.៨២៦)** | (១៣.៣១៨.៨៥០) | **១.៣០៩.៥១២** | ៥.៣០៦.១៤៣ |
| សាច់ប្រាក់(បានប្រើក្នុង)/ចេញពីប្រតិបត្តិការ | **(៩១.៥៩៣.៣៤៤)** | (៣៧៣.៤៣១.៤៩៩) | **៥១.៧០៥.៨២៤** | ២០៩.៥១១.៩៩៩ |

### (ខ) សកម្មភាពហិរញ្ញប្បទានដែលមិនមែនជាសាច់ប្រាក់

សកម្មភាពហិរញ្ញប្បទានដែលមិនមែនជាសាច់ប្រាក់ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ស្តីពីការទិញ ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ (កំណត់សម្គាល់ ១១)។

## ៣២. បំណុលយថាហេតុ និងកិច្ចសន្យាផ្សេងៗ

### (ក) កិច្ចសន្យាផ្តល់ឥណទាន និងកិច្ចសន្យាធានាផ្នែកហិរញ្ញវត្ថុ

ធនាគារមានចំនួនទឹកប្រាក់ក្នុងកិច្ចសន្យា នៃឧបករណ៍ហិរញ្ញវត្ថុក្រៅតារាងតុល្យការរបស់ខ្លួន ដែលត្រូវផ្តល់ឥណទានជូនអតិថិជន ការធានា និងហ្វាស៊ីលីធីផ្សេងៗ ដូចខាងក្រោម៖

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| កិច្ចសន្យាផ្តល់ឥណទាន៖ | | | | |
| ឥណទានវិបារូបន៍ដែលមិនបានប្រើប្រាស់ | **២២.៦៦៩.៦១២** | ៩១.៦៩៨.៥៨១ | **២៧.២៤៨.៩៥០** | ១១១.០៣៩.៤៧១ |
| ឥណទានមានកាលកំណត់ដែលមិនបានប្រើប្រាស់ | **៧.៥៥៦.៣៣៩** | ៣០.៥៦៥.៣៩១ | **១០.៨១៧.៧៧៤** | ៤៤.០៨២.៤២៩ |
| កិច្ចសន្យាធានាផ្នែកហិរញ្ញវត្ថុ៖ | | | | |
| លិខិតឥណទាន | **១៥.០០០.០០០** | ៦០.៦៧៥.០០០ | - | - |
| លិខិតធានារបស់ធនាគារ | **៣.៦២៤.២៣០** | ១៤.៦៦០.០១០ | **៤.៤២២.៣២៩** | ១៨.០២០.៩៩១ |
| ហានិភ័យសរុប | **៤៨.៨៥០.១៨១** | ១៩៧.៥៩៨.៩៨២ | **៤២.៤៨៩.០៥៣** | ១៧៣.១៤២.៨៩១ |
| | | | | |
| កិច្ចសន្យាផ្តល់ឥណទាន និង កិច្ចសន្យាធានាផ្នែកហិរញ្ញវត្ថុ | **៤៨.៨៥០.១៨១** | ១៩៧.៥៩៨.៩៨២ | **៤២.៤៨៩.០៥៣** | ១៧៣.១៤២.៨៩១ |
| សំវិធានធនសម្រាប់ការខាតឥណទានរំពឹងទុក | **(៣៧៧.៩២៦)** | (១.៥២៨.៧១១) | **(៣៩.៤៨៧)** | (១៦០.៩១០) |
| ហានិភ័យសុទ្ធ | **៤៨.៤៧២.២៥៥** | ១៩៦.០៧០.២៧១ | **៤២.៤៤៩.៥៦៦** | ១៧២.៩៨១.៩៨១ |

### (ខ) កិច្ចសន្យាទាក់ទងនឹងការទិញទ្រព្យសកម្ម

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | **៦៧.៩៥១** | ២៧៤.៨៦២ | **៣៣៤.៤២៦** | ១.៣៦២.៧៨៦ |
| ទ្រព្យសកម្មអរូបី | **២៨១.១៧៣** | ១.១៣៧.៣៤៥ | - | - |
| | **៣៤៩.១២៤** | ១.៤១២.២០៧ | **៣៣៤.៤២៦** | ១.៣៦២.៧៨៦ |

### (គ) កិច្ចសន្យាភតិសន្យា

ធនាគារបានទទួលស្គាល់ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ និងបំណុលភតិសន្យាចំពោះកិច្ចសន្យាភតិសន្យាដែលធនាគារជាភាគីអ្នកជួល លើកលែងតែភតិសន្យាទាំងឡាយណាដែលមានរយៈពេលខ្លី សូមមើលកំណត់សម្គាល់ ២.១២.c និងកំណត់សម្គាល់ ១១ សម្រាប់ព័ត៌មានបន្ថែម។ កិច្ចសន្យាភតិសន្យាដែលមានរយៈពេលខ្លី មិនមានចំនួនជាសារវន្តទេ។

### (ឃ) ការកំណត់ពន្ធឡើងវិញ

នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០អគ្គនាយកដ្ឋានពន្ធដារ (GDT) បានចេញលទ្ធផលនៃការកំណត់ពន្ធពេញលេញឡើងវិញ សម្រាប់ធនាគារសម្រាប់ការិយបរិច្ឆេទពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ដែលតម្រូវឱ្យធនាគារបង់បំណុលពន្ធបន្ថែម រួមទាំងប្រាក់ពិន័យ និងការប្រាក់ចំនួន ២១.៧៩២.៧២៩.២៤៨ រៀល (ស្មើនឹង ៥.៣៨៧.៥៧២ ដុល្លារអាមេរិក)។ បំណុលពន្ធបន្ថែមនេះភាគច្រើនពាក់ព័ន្ធនឹងការកាត់កងចំណាយសំវិធានសម្រាប់ឥណទានបាត់បង់នៅក្នុងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំរបស់ធនាគារ។ ធនាគារបានដាក់លិខិតជំទាស់តវ៉ា នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០ ដោយបានស្នើសុំឱ្យ GDT ធ្វើការវាយតម្លៃឡើងវិញ។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)



## ៣២. បំណុលយថាហេតុ និងកិច្ចសន្យាផ្សេងៗ (ត)

### (ឃ) ការកំណត់ពន្ធឡើងវិញ (ត)

បន្ទាប់មក នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ GDT បានចេញលទ្ធផលនៃការកំណត់ពន្ធពេញលេញឡើងវិញ សម្រាប់ធនាគារ សម្រាប់ការិយបរិច្ឆេទពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដែលតម្រូវឱ្យធនាគារបង់បំណុលពន្ធបន្ថែម រួមទាំងប្រាក់ពិន័យ និងការប្រាក់ចំនួន ៥.៦៩៩.៨៦៨.៨៦២ រៀល (ស្មើនឹង ១.៤០៩.១១៥ ដុល្លារអាមេរិក)។ បំណុលពន្ធបន្ថែមនេះភាគច្រើនពាក់ព័ន្ធនឹងការកាត់កងចំណាយសំវិធានសម្រាប់ឥណទានបាត់បង់នៅក្នុងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំរបស់ធនាគារ និងពន្ធកាត់ទុកពីសេវាលើការកែលម្អទ្រព្យជួល។ ធនាគារបានដាក់លិខិតជំទាស់តវ៉ា នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ ដោយបានស្នើសុំឱ្យ GDT ធ្វើការវាយតម្លៃឡើងវិញ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០មិនមានការឆ្លើយតបពី GDT ចំពោះលិខិតជំទាស់តវ៉ានេះទេ។ ធនាគារមិនបានបង់ពន្ធ ឬទទួលស្គាល់ផលប៉ះពាល់នៃការវាយតម្លៃពន្ធឡើងវិញនេះជាបំណុលទេ ដោយសារមិនមានភាពច្បាស់លាស់ថាធនាគារត្រូវបង់ពន្ធនេះទេ។

## ៣៣. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ

ក្នុងដំណើរការអាជីវកម្មធម្មតា ធនាគារមានប្រតិបត្តិការមួយចំនួនជាមួយភាគីពាក់ព័ន្ធ។ ទំហំប្រតិបត្តិការភាគីពាក់ព័ន្ធ សមតុល្យនាដំណាច់ឆ្នាំដែលនៅមិនទាន់ទូទាត់ និងចំណាយ-ចំណូលពាក់ព័ន្ធក្នុងឆ្នាំ មានដូចខាងក្រោម៖

### (ក) ភាគីពាក់ព័ន្ធ និងទំនាក់ទំនង

ទំនាក់ទំនង និងភាគីពាក់ព័ន្ធរបស់ធនាគារ មានដូចខាងក្រោម៖

| ទំនាក់ទំនង | ភាគីពាក់ព័ន្ធ |
|---|---|
| ក្រុមហ៊ុនមេធំជាងគេ | RHB Banking Group |
| ក្រុមហ៊ុនមេផ្ទាល់ | RHB Bank Berhad |
| ក្រុមហ៊ុនពាក់ព័ន្ធ | ក្រុមហ៊ុននានាដែលស្ថិតនៅក្រោមក្រុមហ៊ុនមេធំជាងគេតែមួយ |
| បុគ្គលិកគណៈគ្រប់គ្រងសំខាន់ៗ | សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់របស់ធនាគារ ដែលមានសិទ្ធិធ្វើការសម្រេចចិត្តសំខាន់ៗ ពាក់ព័ន្ធទៅនឹងគោលដៅយុទ្ធសាស្ត្ររបស់ធនាគារ និងបុគ្គលិកគណៈគ្រប់គ្រងជាន់ខ្ពស់ (រួមទាំងសមាជិកគ្រួសារជិតស្និទ្ធរបស់ពួកគេផងដែរ)។ |

### (ខ) ឥណទាន និងបុរេប្រទានផ្តល់ឱ្យបុគ្គលិកគណៈគ្រប់គ្រងសំខាន់ៗ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទានផ្តល់ឱ្យបុគ្គលិកគណៈគ្រប់គ្រងសំខាន់ៗ | **៦៣១.០៧០** | ២.៥៥២.៦៧៨ | **១៥៩.៣២៨** | ៦៤៩.២៦២ |
| ចំណូលការប្រាក់ | **២៥.២៥១** | ១០៣.៣៥៦ | **១១.៥០៥** | ៤៦.៦១៨ |

ឥណទាន និងបុរេប្រទានផ្តល់ឱ្យបុគ្គលិកគណៈគ្រប់គ្រងសំខាន់ៗ មិនមានការធានាទេ និងមានអត្រាការប្រាក់ ៤% ក្នុងមួយឆ្នាំ (២០១៩ ៖ ៤% ក្នុងមួយឆ្នាំ)។

### (គ) ទឹកប្រាក់ភាគីពាក់ព័ន្ធជំពាក់

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ក្រុមហ៊ុនពាក់ព័ន្ធ | **៤២.៧៧៤** | ១៧៣.០២១ | **១២២.៦៦៤** | ៤៩៩.៨៥៦ |
| ក្រុមហ៊ុនមេផ្ទាល់ | **៩.១១៩** | ៣៦.៨៨៦ | **១៤.៧០១** | ៥៩.៩០៧ |
| | **៥១.៨៩៣** | ២០៩.៩០៧ | **១៣៧.៣៦៥** | ៥៥៩.៧៦៣ |

ទឹកប្រាក់ភាគីពាក់ព័ន្ធជំពាក់ មិនមានការធានាទេ និងត្រូវទទួលជាសាច់ប្រាក់។

## ៣៣. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ (ត)

### (ឃ) ប្រាក់បញ្ញើរបស់ភាគីពាក់ព័ន្ធ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ក្រុមហ៊ុនមេផ្ទាល់ | **៥០.៨៥៥.៥១៧** | ២០៥.៧១០.៥៦៦ | **៥១.១៨៩.៧៣៨** | ២០៨.៥៩៨.១៨២ |
| ក្រុមហ៊ុនពាក់ព័ន្ធ | **១០.០៤៧.៣៥២** | ៤០.៦៤១.៥៣៩ | **៣៨៥.៧២៦** | ១.៥៧១.៨៣៤ |
| អភិបាល និងគណៈគ្រប់គ្រងសំខាន់ៗ | **២៤២.១៤០** | ៩៧៩.៤៥៦ | **៦៨២.៤៤០** | ២.៧៨០.៨៤៣ |
| | **៦១.១៤៥.០០៩** | ២៤៧.៣៣១.៥៦១ | **៥២.២៥៧.៩០៤** | ២១២.៩៥០.៨៥៩ |
| ចំណាយការប្រាក់ | **៩៥៨.៩២៩** | ៣.៩០៩.៥៥៤ | **៧៥.៩៦៦** | ៣០៧.៨១៤ |

អត្រាការប្រាក់ប្រចាំឆ្នាំ ក្នុងអំឡុងឆ្នាំ មានដូចខាងក្រោម៖

| | ២០២០ | ២០១៩ |
|---|---|---|
| ក្រុមហ៊ុនមេផ្ទាល់ | **0% - ១%** | 0% - ៣% |
| ក្រុមហ៊ុនពាក់ព័ន្ធ | **0% - ៥,២៥%** | 0% - ៤,៣០% |
| អភិបាល និងគណៈគ្រប់គ្រងសំខាន់ៗ | **0,00% - ៤,៧៥%** | 0,៥0% - ៦,៥0% |

### (ង) ការទូទាត់ជូនគណៈគ្រប់គ្រងសំខាន់ៗ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| កម្រៃរបស់អភិបាល | **៣០.០៥៧** | ១២២.៥៤២ | **៣៨.៤១២** | ១៥៥.៦៤៥ |
| គណៈគ្រប់គ្រងសំខាន់ៗ៖ | | | | |
| អត្ថប្រយោជន៍រយៈពេលខ្លី | **១.៣១៥.៦៦៣** | ៥.៣៦៣.៩៥៨ | **១.៩២៣.៧២២** | ៧.៧៩៤.៩២២ |
| អត្ថប្រយោជន៍រយៈពេលវែងផ្សេងៗ | **៦៨.១៨៩** | ២៧៨.០០៧ | **៦៨.៩៥៨** | ២៧៩.៣៧៧ |
| | **១.៤១៣.៩០៩** | ៥.៧៦៤.៥០៧ | **២.០៣១.០៨២** | ៨.២២៩.៩៤៤ |

### (ច) ប្រតិបត្តិការផ្សេងៗជាមួយភាគីពាក់ព័ន្ធ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណាយសេវាណែនាំអតិថិជន បង់ឱ្យភាគីពាក់ព័ន្ធ | **-** | - | **៣.៣១០** | ១៣.៤១២ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ៣៤. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

ធនាគារបានរួមបញ្ចូលការគ្រប់គ្រងហានិភ័យជាផ្នែកមួយនៃអាជីវកម្ម ប្រតិបត្តិការ និងដំណើរនៃការសម្រេចចិត្តរបស់ធនាគារ។ ក្នុងការធ្វើឱ្យប្រាកដថាធនាគារសម្រេចបាននូវផលចំណេញខ្ពស់បំផុត ទន្ទឹមនឹងពេលធ្វើប្រតិបត្តិការក្នុងបរិយាកាសអាជីវកម្មល្អ ក្រុមការងារផ្នែកគ្រប់គ្រងហានិភ័យបានចូលរួមតាំងពីដំណាក់កាលដំបូងក្នុងដំណើរការទទួលយកហានិភ័យ ដោយផ្តល់នូវការចូលរួមឯករាជ្យ រួមមានរបាយការណ៍វាយតម្លៃពាក់ព័ន្ធ ការវាយតម្លៃឥណទាន ការវាយ តម្លៃលើផលិតផលថ្មី និងកំណត់បរិមាណតម្រូវការដើមទុន។ ការចូលរួមទាំងនេះជួយជម្រុញឱ្យផ្នែកអាជីវកម្មផ្សេងៗធ្វើការ វាយតម្លៃហានិភ័យធៀបនឹងផលចំណេញ ក្នុងផែនការអាជីវកម្មរបស់ពួកគេ ដូចនេះធ្វើឱ្យហានិភ័យត្រូវបានកំណត់តម្លៃ សមស្រប ពាក់ព័ន្ធនឹងផលចំណេញ។

ជាទូទៅ គោលដៅនៃសកម្មភាពក្នុងការគ្រប់គ្រងហានិភ័យរបស់ធនាគារ គឺដើម្បី៖

- កំណត់ពីហានិភ័យផ្សេងៗ និងតម្រូវការដើមទុន
- ធានាថាសកម្មភាពទទួលយកហានិភ័យ មានភាពស៊ីសង្វាក់គ្នាជាមួយនឹងគោលការណ៍ហានិភ័យ ហើយស្ថានភាពនៃបណ្តុំហានិភ័យ គឺស្ថិតក្នុងកម្រិតហានិភ័យដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល និង
- បង្កើតតម្លៃរបស់ភាគទុនិក តាមរយៈក្របខណ្ឌនៃការគ្រប់គ្រងហានិភ័យដ៏ល្អ

ធនាគារកាន់កាប់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ដូចខាងក្រោម៖

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមថ្លៃដើមដករំលស់ | | | | |
| សាច់ប្រាក់ក្នុងដៃ | **៨.៧៦៩.៩៧៥** | ៣៥.៤៧៤.៥៤៩ | **៨.៤០៨.៨០២** | ៣៤.២៦៥.៨៦៨ |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារកណ្តាល | **១៨៣.៩៥៦.៩២៤** | ៧៤៤.១០៥.៧៥៨ | **២០៩.៥៣១.៥០៦** | ៨៥៣.៨៤០.៨៨៧ |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារផ្សេងៗ | **៨៣.៨០២.៣៩៩** | ៣៣៨.៩៨០.៧០៤ | **១២៣.៣៧០.៥៦៧** | ៥០២.៧៣៥.០៦១ |
| ឥណទាន និងបុរេប្រទានវាស់វែងតាមថ្លៃដើមដករំលស់ | **៥៦៤.៣៧៥.៦២៥** | ២.២៨២.៨៩៩.៤០៣ | **៥០៦.២២៦.៩៨៦** | ២.០៦២.៨៧៤.៩៦៨ |
| ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ | **១.៩៥១.១៦៣** | ៧.៨៩២.៤៥៤ | **១.៥៣៧.៦៧៦** | ៦.២៦៦.០៣០ |
| | **៨៤២.៨៥៦.០៨៦** | ៣.៤០៩.៣៥២.៨៦៨ | **៨៤៩.០៧៥.៥៣៧** | ៣.៤៥៩.៩៨២.៨១៤ |
| ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមតម្លៃសមស្រប ក្នុងលទ្ធផលលម្អិតផ្សេងៗ | **២៥.០០០** | ១០១.១២៥ | **២៥.០០០** | ១០១.៨៧៥ |
| ទ្រព្យសកម្មហិរញ្ញវត្ថុសរុប | **៨៤២.៨៨១.០៨៦** | ៣.៤០៩.៤៥៣.៩៩៣ | **៨៤៩.១០០.៥៣៧** | ៣.៤៦០.០៨៤.៦៨៩ |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| បំណុលហិរញ្ញវត្ថុវាស់វែងតាមថ្លៃដើមដករំលស់៖ | | | | |
| ប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ | **១៧០.៥៣០.៧៧៤** | ៦៨៩.៧៩៦.៩៨១ | **១៤៣.៣៩២.៣៦២** | ៥៨៤.៣២៣.៨៧៥ |
| ប្រាក់បញ្ញើរបស់អតិថិជន | **៥៩៩.១០៥.៨៤៨** | ២.៤២៣.៣៨៣.១៥៥ | **៦៣២.៧៦៩.៦៥៨** | ២.៥៧៨.៥៣៦.៣៥៦ |
| ប្រាក់កម្ចី | **៣៤.២៥២.៤៣៨** | ១៣៨.៥៥១.១១២ | **២៧.៦១១.១៥៨** | ១១២.៥១៥.៤៦៩ |
| បំណុលភតិសន្យា | **១៤.៦៨៩.៩៧០** | ៥៩.៤២០.៩២៩ | **១.៨៣២.៣៧៥** | ៧.៤៦៦.៩២៨ |
| បំណុលហិរញ្ញវត្ថុផ្សេងៗ | **២.៨៦៧.៣៦១** | ១១.៥៩៨.៤៧៦ | **៥.០៧០.១២០** | ២០.៦៦០.៧៣៩ |
| បំណុលហិរញ្ញវត្ថុសរុប | **៨២១.៤៤៦.៣៩១** | ៣.៣២២.៧៥០.៦៥៣ | **៨១០.៦៧៥.៦៧៣** | ៣.៣០៣.៥០៣.៣៦៧ |

# ៣៤. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

## ៣៤.១ ហានិភ័យឥណទាន

ហានិភ័យឥណទានគឺជាហានិភ័យដែលធ្វើឱ្យមានការខាតបង់ផ្នែកហិរញ្ញវត្ថុ ប្រសិនបើអតិថិជនរបស់ធនាគារ ឬភាគីដៃគូក្នុងទីផ្សារ ខកខានមិនបានបំពេញកាតព្វកិច្ចសងប្រាក់ទៅតាមកិច្ចសន្យាឱ្យធនាគារ។ ហានិភ័យឥណទានកើតមកពីការដាក់ប្រាក់នៅធនាគារកណ្តាល និងធនាគារផ្សេងៗ ឥណទាន និងបុរេប្រទាន ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ កិច្ចសន្យាផ្តល់ឥណទាន និងកិច្ចសន្យាធានាផ្នែកហិរញ្ញវត្ថុ។ ហានិភ័យឥណទានភាគច្រើនកើតមកពីសកម្មភាពផ្តល់ប្រាក់កម្ចី។

### (ក) ការវាស់វែងហានិភ័យឥណទាន

ហានិភ័យឥណទានត្រូវបានគ្រប់គ្រងតាមមូលដ្ឋានជាក្រុម។

ចំពោះឥណទាន និងបុរេប្រទាន និងកិច្ចសន្យាផ្តល់ឥណទាន ការប៉ាន់ស្មានហានិភ័យឥណទានក្នុងគោលដៅគ្រប់គ្រងហានិភ័យ តម្រូវឱ្យប្រើប្រាស់គំរូ ដោយសារហានិភ័យមានភាពខុសប្លែកគ្នាទៅតាមបម្រែបម្រួលលក្ខខណ្ឌលើទីផ្សារ លំហូរសាច់ប្រាក់រំពឹងទុក និងពេលវេលាដែលកន្លងផុត។ ការវាយតម្លៃហានិភ័យឥណទាននៃផលបត្រទ្រព្យសកម្មមួយ តម្រូវឱ្យមានការប៉ាន់ស្មានបន្ថែមទៀត ដូចជា លទ្ធភាពនៃការមិនសងប្រាក់នៃអនុបាតការខាតបង់ពាក់ព័ន្ធ និងការមិនសងប្រាក់ទៅវិញទៅមករវាងភាគីដៃគូ។ ធនាគារវាស់វែងហានិភ័យឥណទានដោយប្រើ ប្រូបាបនៃការមិនសងប្រាក់ (PD) ចំនួនដែលមានហានិភ័យមិនសង (EAD) និងការខាតបង់នៅពេលមិនមានការសងប្រាក់ (LGD) ក្នុងការវាស់វែង ECL ក្រោម CIFRS 9 ។

ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារកណ្តាល និងធនាគារផ្សេងៗ ត្រូវបានចាត់ទុកថាមានហានិភ័យឥណទានតិចតួច។ ចំណាត់ថ្នាក់ឥណទាននៃទ្រព្យសកម្មទាំងនេះ ត្រូវបានតាមដានដើម្បីស្វែងរកការថយចុះតម្លៃនៃឥណទាន។ ការវាស់វែងការថយចុះតម្លៃត្រូវបានកំណត់ត្រឹម ការខាតបង់ឥណទានរំពឹងទុក១២ខែ។ ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗដែលត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ ត្រូវបានតាមដានដើម្បីស្វែងរកពីការថយចុះចំណាត់ថ្នាក់ឥណទានរបស់វា ហើយការវាស់វែងការថយចុះតម្លៃគឺអនុវត្តតាមវិធីសាស្ត្របីដំណាក់កាល ដូចបានពណ៌នាក្នុងកំណត់សម្គាល់ ៣៤.១.គ។

### (ខ) ការគ្រប់គ្រងកម្រិតហានិភ័យ និងគោលការណ៍បន្ថយហានិភ័យ

ធនាគារធ្វើប្រតិបត្តិការ និងផ្តល់ឥណទាននិងបុរេប្រទានជូនអតិថិជនជាឯកត្តជន ឬ សហគ្រាសនានាក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារគ្រប់គ្រងកម្រិតហានិភ័យ និងផ្តោតការយកចិត្តទុកដាក់លើហានិភ័យឥណទាន នៅពេលដែលហានិភ័យត្រូវបានរកឃើញ។

ធនាគារបានប្រើប្រាស់គោលការណ៍និងការអនុវត្តជាច្រើន ដើម្បីកាត់បន្ថយហានិភ័យឥណទាន។ គោលការណ៍ដែលមានប្រសិទ្ធភាពបំផុតក្នុងចំណោមគោលការណ៍ទាំងអស់នេះ គឺការធានាដោយដាក់វត្ថុបញ្ចាំលើឥណទាននិងបុរេប្រទានអតិថិជន ដែលជាការអនុវត្តទូទៅ។ ធនាគារអនុវត្តគោលការណ៍ណែនាំស្តីពីការទទួលយកនូវចំណាត់ថ្នាក់ជាក់លាក់នៃវត្ថុបញ្ចាំ ឬការកាត់បន្ថយហានិភ័យឥណទាន។ ប្រភេទនៃវត្ថុបញ្ចាំសំខាន់ៗដើម្បីធានាឥណាន និងបុរេប្រទានអតិថិជន មានដូចជា៖

- វត្ថុបញ្ចាំជាទ្រព្យសម្បត្តិក្នុងលក្ខណៈជាលំនៅដ្ឋាន (មានដីធ្លី អគារ និងទ្រព្យសម្បត្តិផ្សេងៗ)
- សាច់ប្រាក់ក្នុងទម្រង់ជាប្រាក់បញ្ញើមានកាលកំណត់ ប្រសិនបើមាន
- អគារពាណិជ្ជកម្ម និងដីធ្លី

### (គ) គោលការណ៍ការថយចុះតម្លៃ (ការខាតបង់ឥណទានរំពឹងទុក)

ការវាស់វែងសំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុក ក្រោមវិធីសាស្ត្របីដំណាក់កាលរបស់ CIFRS 9 គឺដើម្បីទទួលស្គាល់សំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុកពេញមួយអាយុកាល ចំពោះឧបករណ៍ហិរញ្ញវត្ថុដែលមានកំណើនហានិភ័យឥណទានជាសារវន្តចាប់តាំងពីការទទួលស្គាល់លើកដំបូង ឬឧបករណ៍ហិរញ្ញវត្ថុដែលមានការថយចុះតម្លៃឥណទាន នាកាលបរិច្ឆេទរាយការណ៍។ ឧបករណ៍ហិរញ្ញវត្ថុដែលមិនទាន់មានការថយចុះតម្លៃគួរឱ្យកត់សម្គាល់ ក្នុងហានិភ័យឥណទាន នឹងត្រូវបានទទួលស្គាល់ក្នុងសំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុក១២ខែ។

ក្រោមវិធីសាស្ត្របីដំណាក់កាល ឧបករណ៍ហិរញ្ញវត្ថុត្រូវបានបែងចែកជាបីដំណាក់កាល អាស្រ័យទៅតាមបម្រែបម្រួលដែលពាក់ព័ន្ធ នៅក្នុងហានិភ័យឥណទាន។

- ដំណាក់កាលទី១ រួមមានឧបករណ៍ហិរញ្ញវត្ថុដែលមិនមានកំណើនហានិភ័យឥណទានជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង និងមិនមានការថយចុះតម្លៃឥណទាននាកាលបរិច្ឆេទរាយការណ៍។ ចំពោះទ្រព្យសកម្មទាំងនេះ ត្រូវបានទទួលស្គាល់ក្នុងសំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុក១២ខែ។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ៣៤. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៤.១ ហានិភ័យឥណទាន (ត)

#### (គ) គោលការណ៍ការថយចុះតម្លៃ (ការខាតបង់ឥណទានរំពឹងទុក) (ត)

- ដំណាក់កាលទី២ រួមមានឧបករណ៍ហិរញ្ញវត្ថុដែលមានកំណើនហានិភ័យឥណទានជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង ប៉ុន្តែមិនមានភ័ស្តុតាងជាក់ស្តែងបង្ហាញថាមានការថយចុះតម្លៃ។ ចំពោះទ្រព្យសកម្មទាំងនេះ ត្រូវបានទទួលស្គាល់ក្នុងសំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុកពេញមួយអាយុកាល។
- ដំណាក់កាលទី៣ រួមមានឧបករណ៍ហិរញ្ញវត្ថុដែលមានភ័ស្តុតាងជាក់ស្តែងបង្ហាញថាមានការថយចុះតម្លៃ នាកាលបរិច្ឆេទរាយការណ៍។ ចំពោះទ្រព្យសកម្មទាំងនេះ ត្រូវបានទទួលស្គាល់ក្នុងសំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុកពេញមួយអាយុកាល។
- ការទិញទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការថយចុះតម្លៃឥណទាន ឬ ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការថយចុះតម្លៃឥណទានពីដំបូង គឺជាទ្រព្យសកម្មហិរញ្ញវត្ថុទាំងឡាយណាដែលមានការថយចុះតម្លៃឥណទានចាប់តាំងពីការកត់ត្រាលើកដំបូង។ សំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុក តែងតែត្រូវបានវាស់វែងតាមមូលដ្ឋានពេញមួយអាយុកាល ( ដំណាក់កាលទី ៣ )។

ការវិនិច្ឆ័យនិងការសន្មតសំខាន់ៗ ដែលធនាគារបានអនុវត្តទៅតាមតម្រូវការនានារបស់ស្តង់ដារ ក្នុងការវាស់វែងសំវិធានធន មានដូចខាងក្រោម៖

**(i) កំណើនហានិភ័យឥណទានជាសារវន្ត** - significant increase in credit risk (SICR)

ការប៉ាន់ស្មាន SICR គឺជាការវិភាគពហុកត្តា និងការវិភាគជារួម អាស្រ័យទៅលើការរួមបញ្ចូលគ្នារវាងព័ត៌មានផ្អែកបរិមាណ និង/ឬ គុណភាព។ ដើម្បីកំណត់ថាតើហានិភ័យនៃការមិនសងប្រាក់ចំពោះឥណទាន/ហិរញ្ញប្បទានបានកើនឡើងគួរឱ្យកត់សម្គាល់ឬទេចាប់តាំងពីការទទួលស្គាល់លើកដំបូងមក គេយកហានិភ័យនៃការមិនសងប្រាក់នាពេលបច្ចុប្បន្នប្រៀបធៀបជាមួយនឹងហានិភ័យនៃការមិនសងប្រាក់នាពេលទទួលស្គាល់លើកដំបូង។ អ្នកខ្ចីប្រាក់ម្នាក់ត្រូវបានចាត់ទុកថាមានកំណើនហានិភ័យឥណទានជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង ប្រសិនបើស្របតាមលក្ខណៈវិនិច្ឆ័យណាមួយ ក្នុងចំណោមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

<u>លក្ខណៈវិនិច្ឆ័យផ្អែកបរិមាណ</u>

- អតិថិជនបានហួសកាលកំណត់សងប្រាក់ ទៅតាមការសងប្រាក់ក្នុងកិច្ចសន្យា លើសពី ៣០ថ្ងៃនាកាលបរិច្ឆេទរាយការណ៍
- មានការសងប្រាក់យឺតយ៉ាវកើតឡើងដដែលៗ ដែលផ្អែកទៅតាមការតាមដានលើការទូទាត់សងប្រាក់របស់ អតិថិជន ដូចខាងក្រោម៖
  ១. មានករណីនៃការសងប្រាក់ហួសកាលកំណត់សង៣០ថ្ងៃ ដោយផ្អែកទៅតាមការទូទាត់ប្រាក់ក្នុងកិច្ចសន្យា ចំនួនបីដង ក្នុងរយៈពេល ៦ខែ ឬ
  ២. មានករណីនៃការសងប្រាក់ហួសកាលកំណត់សង៦០ថ្ងៃ ដោយផ្អែកទៅតាមការទូទាត់ប្រាក់ក្នុងកិច្ចសន្យា ចំនួនមួយដងក្នុងរយៈពេល៦ខែ

<u>លក្ខណៈវិនិច្ឆ័យផ្អែកគុណភាព</u>

- ការធ្វើចំណាត់ថ្នាក់ឥណទានផ្ទៃក្នុង
- កំណើនហានិភ័យឥណទានជាសារវន្ត លើឧបករណ៍ហិរញ្ញវត្ថុផ្សេងៗ របស់អតិថិជនតែមួយ
- មានភាពជាក់ស្តែង ឬបានរំពឹងទុកថាមានផលប៉ះពាល់អាក្រក់ជាសារវន្ត ក្នុងអាជីវកម្ម ហិរញ្ញវត្ថុ ឬស្ថានភាពសេដ្ឋកិច្ច ដែលបង្កឱ្យមានការផ្លាស់ប្តូរសមត្ថភាពទូទាត់កាតព្វកិច្ចរបស់អតិថិជនជាសារវន្ត។

**(ii) និយមន័យនៃការមិនសងប្រាក់ និងការថយចុះតម្លៃឥណទាន**

ធនាគារកំណត់ថាឧបករណ៍ហិរញ្ញវត្ថុមួយស្ថិតក្នុងចំណាត់ថ្នាក់មិនសងប្រាក់ និង មានការថយចុះតម្លៃឥណទាន នៅពេលដែលឧបករណ៍ហិរញ្ញវត្ថុនោះស្របទៅតាមលក្ខណៈវិនិច្ឆ័យណាមួយ ដូចខាងក្រោម៖

- ប្រាក់ដើម ឬការប្រាក់ ឬទាំងប្រាក់ដើម និងការប្រាក់នៃឥណទាន ហួសកំណត់សងលើសពី៩០ថ្ងៃ។ ក្នុងករណីហ្វាស៊ីលីធីដែលអាចប្រើប្រាស់ឡើងវិញ ( ឧ. ឥណទានវិបារូបន៍ ) ហ្វាស៊ីលីធីត្រូវបានចាត់ថ្នាក់ថាមានការថយចុះតម្លៃ នៅពេលដែលចំនួនទឹកប្រាក់ដែលនៅមិនទាន់ទូទាត់ នៅសល់លើសពីកម្រិតដែលបានអនុម័ត ក្នុងរយៈពេល៩០ថ្ងៃ ឬលើសក្នុងថ្ងៃបន្តបន្ទាប់។ ដើម្បីបញ្ជាក់ពីរយៈពេលនៃបំណុលដែលនៅជំពាក់ មានដូចខាងក្រោម៖

## ៣៤. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៤.១ ហានិភ័យឥណទាន (ត)

#### (គ) គោលការណ៍ការថយចុះតម្លៃ (ការខាតបង់ឥណទានរំពឹងទុក) (ត)

#### (ii) និយមន័យនៃការមិនសងប្រាក់ និងការថយចុះតម្លៃឥណទាន (ត)

១. ការទូទាត់សងតាមគ្រានីមួយៗ ត្រូវធ្វើឡើងឱ្យគ្រប់ចំនួន។ ការទូទាត់សងតែមួយចំណែកនៃការសងតាមគ្រាត្រូវចាត់ទុកជាការសងយឺត។
២. នៅពេលដែលការបង់សងឥណទានត្រូវបានផ្អាកឬពន្យារអាស្រ័យទៅតាមការចរចា និងការរៀបចំឥណទានឡើងវិញ នោះការកំណត់រយៈពេលនៃបំណុលដែលនៅជំពាក់ នឹងត្រូវបានដកចេញពីរយៈពេលនៃការផ្អាកឬពន្យារនោះ។ ការផ្អាក ឬពន្យារមិនត្រូវលើសពីរយៈពេល៦ខែទេ គិតចាប់ពីកាលបរិច្ឆេទនៃពាក្យស្នើសុំផ្អាកឬពន្យាររបស់អ្នកជាប់កាតព្វកិច្ច/ភាគីដៃគូ។
៣. នៅពេលដែលការបង់សងប្រាក់ត្រូវបានរៀបចំឡើងវិញ ក្នុងចន្លោះពេល៩០ថ្ងៃ ឬយូរជាងនេះ នោះឥណទានត្រូវបានចាត់ថ្នាក់ថាមានការថយចុះតម្លៃ នៅពេលដែលការមិនសងប្រាក់បានកើតឡើង លុះត្រាតែវាមិនមានបង្ហាញពីចំណុចខ្សោយណាមួយ ដែលអាចបណ្តាលឱ្យវាត្រូវបានចាត់ថ្នាក់អាស្រ័យទៅតាមគោលការណ៍ចំណាត់ថ្នាក់ហានិភ័យឥណទាន។

- ឥណទានត្រូវបានដាក់ដោយបង្ខំក្នុងចំណាត់ថ្នាក់ថយចុះតម្លៃ អាស្រ័យទៅតាមហេតុផលជាច្រើនដូចជា ការក្ស័យធន ផលវិបាកផ្នែកហិរញ្ញវត្ថុជាសារវន្តជាដើម។ ក្នុងព្រឹត្តិការណ៍ដែលឥណទានមិនស្ថិតក្នុងការមិនសងប្រាក់ ឬមិនហួសកំណត់សង ប៉ុន្តែត្រូវបានដាក់ដោយបង្ខំក្នុងចំណាត់ថ្នាក់ថយចុះតម្លៃ ឥណទាននោះត្រូវបានចាត់ថ្នាក់ថាមានការថយចុះតម្លៃ អាស្រ័យទៅតាមការអនុម័តរបស់គណៈកម្មាធិការឥណទាន។

- ការរៀបចំ និងការកំណត់កាលវិភាគហ្វាស៊ីលីធីឥណទានមួយឡើងវិញ ពាក់ព័ន្ធនឹងការកែប្រែរយៈពេល និងលក្ខខណ្ឌបង់ប្រាក់លើកដំបូងនៃហ្វាស៊ីលីធីឥណទាន អាស្រ័យទៅតាមកំណើននៃហានិភ័យឥណទានរបស់អ្នកជាប់កាតព្វកិច្ច/ភាគីដៃគូ។

- ក្នុងករណីដែលអ្នកជាប់កាតព្វកិច្ច/ភាគីដៃគូមានឥណទានច្រើនជាមួយធនាគារ ហើយមានការអនុវត្តកាតព្វកិច្ចការសងប្រាក់គ្នាទៅវិញទៅមក (cross default) នោះតម្រូវឱ្យមានការប៉ាន់ស្មានសំវិធានធន ក្រោមការមិនសងប្រាក់នៃកាតព្វកិច្ចបំណុលមួយដែលធ្វើឱ្យមានការមិនសងប្រាក់នៃកាតព្វកិច្ចបំណុលមួយផ្សេងទៀត (ការមិនសងប្រាក់ឆ្លងគ្នា)។ ក្នុងករណីមិនមានឃ្លាដែលចែងពីសិទ្ធិដើម្បីទាមទារការទូទាត់សង នោះការវាយតម្លៃសំវិធានធនចាំបាច់ត្រូវធ្វើឡើងចំពោះឥណទានក្នុងកម្រិតឯកត្តជនជំនួសឱ្យកម្រិតអ្នកជាប់កាតព្វកិច្ច/ភាគីដៃគូជារួម។

#### (iii) ការវាស់វែង (ECL - លទ្ធផល វិធីសាស្ត្រក្នុងការសន្មត និងការប៉ាន់ស្មាន)

ECL ត្រូវបានវាស់វែងតាមមូលដ្ឋាន ១២ខែ ឬតាមមូលដ្ឋានពេញមួយអាយុកាលអាស្រ័យទៅតាមកំណើន ហានិភ័យឥណទានជាសារវន្តដែលបានកើតឡើង ចាប់តាំងពីការទទួលស្គាល់លើកដំបូង ឬប្រសិនបើទ្រព្យសកម្មមួយត្រូវបានចាត់ទុកថាមានការថយចុះតម្លៃឥណទាន។ ECL ត្រូវបានវាយតម្លៃ និងវាស់វែងតាមមូលដ្ឋានប្រមូលផ្តុំ។

ចំពោះការវាយតម្លៃជាក្រុម ECL ត្រូវបានកំណត់ដោយធ្វើការប៉ាន់ស្មាន PD, LGD និង EAD សម្រាប់ខែបន្ទាប់ក្នុងអនាគត និងសម្រាប់ផ្នែករួម។ ធាតុទាំងបីនេះត្រូវបានគុណបញ្ចូលគ្នាដើម្បីគណនារក ECL សម្រាប់ឆ្នាំនីមួយៗក្នុងពេលអនាគត ដែលបន្ទាប់មកវាត្រូវបានធ្វើអប្បហារត្រឡប់ទៅវិញនាកាលបរិច្ឆេទរាយការណ៍ និងត្រូវបានបូកបញ្ចូលគ្នាវិញ។ អត្រាអប្បហារដែលត្រូវបានប្រើក្នុងការគណនា ECL គឺជាអត្រាការប្រាក់មានប្រសិទ្ធភាពដំបូង ឬអត្រាដែលប្រហាក់ប្រហែល។

ចំពោះការវាយតម្លៃលក្ខណៈបុគ្គល សំវិធានធន ECL ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀបសមតុល្យដែលមិនទាន់ទូទាត់ ជាមួយនឹងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ដែលរំពឹងថាត្រូវទទួលបានពីអ្នកខ្ចីប្រាក់។

<u>ប្រូបាបនៃការមិនសងប្រាក់ (Probability of Default)</u>

PD គឺជាលទ្ធភាពដែលអតិថិជនម្នាក់មិនសងប្រាក់ចំពោះកាតព្វកិច្ចហិរញ្ញវត្ថុរបស់ខ្លួន ក្នុងរយៈពេល១២ខែបន្ទាប់ (PD១២ខែ) ឬក្នុងរយៈពេលពេញមួយអាយុកាលដែលនៅសល់ (PD ពេញមួយអាយុកាល) របស់កាតព្វកិច្ចនោះ។

គំរូ PD ១២ ខែ គឺត្រូវប៉ាន់ស្មានប្រចាំឆ្នាំអំពីប្រូបាបនៃការមិនសងប្រាក់ របស់ portfolio ដែលអាចត្រូវបានប្រើប្រាស់ដើម្បីបង្កើតខ្សែកោង PD ពេញមួយអាយុកាល ដើម្បីគ្របដណ្តប់លើអាយុកាលសន្មតនៃគណនីនីមួយៗនៅក្នុង portfolio នោះ។

## ៣៤. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៤.១ ហានិភ័យឥណទាន (ត)

#### (គ) គោលការណ៍ការថយចុះតម្លៃ (ការខាតបង់ឥណទានរំពឹងទុក) (ត)

#### (iii) ការវាស់វែង (ECL - លទ្ធផល វិធីសាស្រ្តក្នុងការសន្មត និងការប៉ាន់ស្មាន) (ត)

PD ពេញមួយអាយុកាល ត្រូវបានបង្កើតឡើងដោយអនុវត្តទម្រង់កាលផុតកំណត់ រហូតដល់ PD ១២ ខែនាពេលបច្ចុប្បន្ន។ ទិន្នន័យផុតកំណត់ពិនិត្យមើលទៅលើរបៀបដែលការមិនសងប្រាក់ត្រូវបានចាប់ផ្តើមបង្កើតឡើងចំពោះ portfolio មួយ ចាប់ពីចំណុចទទួលស្គាល់លើកដំបូង និងពេញមួយអាយុកាលនៃឥណទាននោះ។ ទិន្នន័យផុតកំណត់អាស្រ័យទៅលើទិន្នន័យដែលត្រូវបានអង្កេតឃើញក្នុងគ្រាកន្លងមក និងត្រូវបានសន្មតថាមានភាពដូចគ្នាចំពោះទ្រព្យសកម្មទាំងអស់ដែលស្ថិតនៅក្នុងទម្រង់នោះ ហើយវាត្រូវបានគាំទ្រដោយការវិភាគដែលបានធ្វើក្នុងគ្រាកន្លងមក។

<u>ចំនួនដែលមានហានិភ័យមិនសង (Exposure at Default)</u>

EAD គឺជាចំនួនទឹកប្រាក់សរុបដែលធនាគារមានហានិភ័យ នៅពេលដែលអ្នកខ្ចីប្រាក់មិនសងប្រាក់ដែលនៅជំពាក់។

EAD ១២ខែ ឬ ពេញមួយអាយុកាល ត្រូវបានកំណត់អាស្រ័យទៅតាមទិន្នន័យការបង់ប្រាក់រំពឹងទុក ដែលមានភាពខុសគ្នាអាស្រ័យទៅតាមប្រភេទផលិតផល។

- ចំពោះផលិតផលដែលត្រូវដករំលស់ និងឥណទានដែលត្រូវសងប្រាក់ទាំងស្រុង គឺអាស្រ័យទៅលើការសងប្រាក់ក្នុងកិច្ចសន្យាដែលអ្នកខ្ចីប្រាក់នៅជំពាក់ ក្នុងរយៈពេល១២ខែ ឬ រយៈពេលផុតកំណត់ដែលនៅសល់។
- ចំពោះផលិតផលហ្វាស៊ីលីធីដែលអាចប្រើប្រាស់ឡើងវិញ ហានិភ័យនៃការមិនសងប្រាក់ត្រូវបានព្យាករ ដោយយកកម្រិតកំណត់របស់ឥណទាន គុណជាមួយនឹងការប្រើប្រាស់នាពេលមិនសងប្រាក់ ដែលកម្រិតកំណត់របស់ឥណទានគឺជាចំនួនទឹកប្រាក់អតិបរមាដែលអ្នកខ្ចីប្រាក់ម្នាក់អាចខ្ចីបាន ហើយការប្រើប្រាស់នាពេលមិនសងប្រាក់ គឺជាសមមាត្រនៃកម្រិតកំណត់របស់ឥណទាន ដែលត្រូវបានប្រើប្រាស់ដោយអតិថិជននាចំណុចពេលមិនសងប្រាក់។

<u>ការខាតបង់នៅពេលដែលមិនមានការសងប្រាក់ (Loss Given Default)</u>

LGD គឺជាការរំពឹងទុករបស់ធនាគារអំពីកំណើននៃការខាតបង់ចំពោះហានិភ័យនៃការមិនសងប្រាក់។ LGD មានភាពខុសប្លែកគ្នាអាស្រ័យទៅតាមប្រភេទភាគីដៃគូ ប្រភេទ និងអតីតភាពនៃសំណង និងទ្រព្យបញ្ចាំដែលមាន ឬការគាំទ្រឥណទានផ្សេងៗ។ LGD ត្រូវបានបង្ហាញដោយភាគរយនៃការខាតបង់ក្នុងមួយឯកតាហានិភ័យ នាចំណុចពេលមិនសងប្រាក់ (EAD)។ LGD ត្រូវបានគណនាទាំងចំពោះរយៈពេល១២ខែ និងរយៈពេលពេញមួយអាយុកាល។ LGD គឺជាភាគរយនៃការខាតបង់ដែលរំពឹងថាត្រូវបានបង្កើតឡើង ប្រសិនបើមានការមិនសងប្រាក់កើតឡើង លើរយៈពេលពេញមួយអាយុកាលរំពឹងទុកដែលនៅសល់របស់ឥណទាន។

ការសន្មតដែលជាមូលដ្ឋានសម្រាប់ការគណនា ECL ត្រូវបានតាមដាន និងត្រួតពិនិត្យជាបន្តបន្ទាប់។ មិនមានការប្រែប្រួលជាសារវន្តណាមួយចំពោះវិធីសាស្រ្តនៃការប៉ាន់ស្មាន ឬការសន្មតជាក់លាក់ណាមួយត្រូវបានធ្វើឡើងក្នុងការិយបរិច្ឆេទរបាយការណ៍នេះទេ។

#### (iv) ព័ត៌មាននាពេលអនាគតដែលត្រូវបានបញ្ចូលទៅក្នុងគំរូ ECL

ការគណនា ECL ត្រូវបានបញ្ចូលនូវព័ត៌មាននាពេលអនាគត។ ធនាគារបានអនុវត្តការវិភាគក្នុងគ្រាមុន និងបានកត់សម្គាល់នូវជាតុអថេរផ្នែកសេដ្ឋកិច្ចសំខាន់ៗដែលមានផលប៉ះពាល់លើហានិភ័យឥណទាន និងការខាតឥណទានរំពឹងទុក សម្រាប់ portfolio នីមួយៗ។

ជាតុអថេរផ្នែកសេដ្ឋកិច្ចសំខាន់ៗ និងផលប៉ះពាល់ពាក់ព័ន្ធរបស់វាចំពោះ PD មានភាពខុសប្លែកគ្នាទៅតាមឧបករណ៍ហិរញ្ញវត្ថុ។ ការវិនិច្ឆ័យរបស់អ្នកឯកទេស ក៏ត្រូវបានអនុវត្តនៅក្នុងដំណើរការនេះផងដែរ។ ការព្យាករក្នុងគ្រាកន្លងមកចំពោះជាតុអថេរផ្នែកសេដ្ឋកិច្ចទាំងនេះ ("សេណារីយ៉ូសេដ្ឋកិច្ចមូលដ្ឋាន") ត្រូវបានដកស្រង់ប្រភពមកពីការស្រាវជ្រាវខាងក្រៅ។ ផលប៉ះពាល់នៃជាតុអថេរផ្នែកសេដ្ឋកិច្ចទាំងនេះចំពោះ PD ត្រូវបានកំណត់ដោយការអនុវត្តការវិភាគស្ថិតិត្រឡប់ថយក្រោយ ដើម្បីស្វែងយល់អំពីបម្រែបម្រួលនៃផលប៉ះពាល់នៅក្នុងជាតុអថេរទាំងនេះដែលធ្លាប់មានប្រវត្តិនៃអត្រាមិនសងប្រាក់ នៅពេលដែល LGD ផ្អែកលើការកំណត់របស់ធនាគារនៃការកាត់បន្ថយវត្ថុបញ្ចាំ និង EAD គឺផ្អែកលើទម្រង់ការទូទាត់រំពឹងទុក។

## ៣៤. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៤.១ ហានិភ័យឥណទាន (ត)

#### (គ) គោលការណ៍ការថយចុះតម្លៃ (ការខាតបង់ឥណទានរំពឹងទុក) (ត)

#### (iv) ព័ត៌មាននាពេលអនាគតដែលត្រូវបានបញ្ចូលទៅក្នុងគំរូ ECL (ត)

បន្ថែមពីលើសេណារីយ៉ូដែលពឹងផ្អែកទៅលើសេដ្ឋកិច្ច ធនាគារពិចារណាទៅលើលទ្ធភាពនៃសេណារីយ៉ូផ្សេងៗទៀត ជាមួយនឹងការការថ្លឹងសេណារីយ៉ូ។ ចំនួននៃសេណារីយ៉ូផ្សេងៗដែលត្រូវបានប្រើប្រាស់ ត្រូវបានកំណត់ដោយពឹងផ្អែកទៅលើការវិភាគប្រភេទផលិតផលចម្បងនីមួយៗ ដើម្បីធានាថាមិនមាន non-linearities។ ចំនួនសេណារីយ៉ូ និង លទ្ធផលសន្មតរបស់វា ត្រូវបានវាយតម្លៃនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ធនាគារបានសន្និដ្ឋានថាមានសេណារីយ៉ូចំនួនបីដែលចាប់បាន non-linearities យ៉ាងសមស្រប។ ការថ្លឹងសេណារីយ៉ូត្រូវបានកំណត់ដោយការផ្តុំបញ្ចូលគ្នានៃការវិភាគស្ថិតិ និងការវិនិច្ឆ័យរបស់អ្នកជំនាញខាងផ្នែកឥណទាន ដោយគិតទៅលើលទ្ធភាពដែលអាចកើតមានឡើងមួយចំនួនដែលមានសេណារីយ៉ូនីមួយៗជាតំណាង។

ជាមួយនឹងការព្យាករផ្នែកសេដ្ឋកិច្ច ការធ្វើគម្រោង និងលទ្ធភាពដែលអាចកើតមានឡើងនានា គឺប្រឈមនឹងភាពមិនច្បាស់លាស់ពាក់ព័ន្ធក្នុងកម្រិតខ្ពស់ ដូចនេះ លទ្ធផលជាក់ស្តែងអាចមានភាពខុសគ្នាជាសារវន្តពីការធ្វើគម្រោងទាំងនេះ។ ធនាគារពិចារណាទៅលើការព្យាករទាំងនេះ ដើម្បីបង្ហាញពីការប៉ាន់ស្មានល្អបំផុតទៅលើលទ្ធភាពដែលអាចកើតមានឡើង និងបានធ្វើការវិភាគទៅលើ non-linearities និងភាពមិនស៊ីមេទ្រីគ្នានៃ portfolios ខុសៗគ្នារបស់ធនាគារ ដើម្បីកំណត់ថាសេណារីយ៉ូដែលត្រូវបានជ្រើសរើស គឺជាតំណាងដ៏សមស្របចំពោះសេណារីយ៉ូនានាដែលអាចកើតមានឡើង។

*ការសន្មតជាតុអថេរម៉ាក្រូសេដ្ឋកិច្ច*

ការថ្លឹងដែលត្រូវបានកំណត់ចំពោះសេណារីយ៉ូសេដ្ឋកិច្ចនីមួយៗ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០មានដូចខាងក្រោម៖

| | ២០២០ | ២០១៩ |
|---|---|---|
| **ការថ្លឹងសំពៀតទាំងអស់** | | |
| មូលដ្ឋាន | **៥០%** | ៥០% |
| ល្អបំផុត | **១៥%** | ២៥% |
| អាក្រក់បំផុត | **៣៥%** | ២៥% |
| | **១០០%** | ១០០% |

*ការវិភាគភាពប្រែប្រួល Sensitivity analysis*

ការសន្មតដែលមានភាពជាសារវន្តបំផុតដែលធ្វើឱ្យប៉ះពាល់ដល់សំវិធានអតិផរណាធន ECL គឺអតិផរណា ដែលវាធ្វើឱ្យមានផលប៉ះពាល់ជាសារវន្តលើលទ្ធភាព របស់អ្នកជាប់កាតព្វកិច្ច ក្នុងការបំពេញការសងប្រាក់ទៅតាមកិច្ចសន្យា ក៏ដូចជា ដំណើរការអាជីវកម្ម និងតម្លៃនៃវត្ថុបញ្ចាំរបស់ពួកគេ។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ៣៤. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៤.១ ហានិភ័យឥណទាន (ត)

(គ) គោលការណ៍ការថយចុះតម្លៃ (ការខាតបង់ឥណទានរំពឹងទុក) (ត)

(iv) ព័ត៌មាននាពេលអនាគតដែលត្រូវបានបញ្ចូលទៅក្នុងគំរូ ECL (ត)

បម្រែបម្រួល ECL គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ដែលអាចកើតមានដោយសារការប្រែប្រួលប៉ារ៉ាម៉ែត្រដ៏សមហេតុផល ខុសពីការសន្មតជាក់ស្តែង ដែលត្រូវបានប្រើប្រាស់ក្នុងការសន្មតជាតុអថេរសេដ្ឋកិច្ចរបស់ធនាគារ មានដូចខាងក្រោម៖

| | កំណើន/(តំហយ) ECL | | |
|---|---|---|---|
| | បម្រែបម្រួល | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **២០២០** | | | |
| អតិផរណា | +/- ៦ អត្រាគោលមូលដ្ឋាន | ៣៥២.០០០ | (៣៦៧.០០០) |
| អត្រាគ្មានការងារធ្វើ (*) | +/- ១០អត្រាគោលមូលដ្ឋាន | ២៤៩.០០០ | (២៥៨.០០០) |
| | | ៦០១.០០០ | (៦២៥.០០០) |
| គិតជាពាន់រៀល | | ២.៤៥០.២៧៧ | (២.៥២៨.១២៥) |
| **២០១៩** | | | |
| អតិផរណា | +/- ៥០អត្រាគោលមូលដ្ឋាន | ៥៤.៣៥១ | (៤៨.៩០៨) |
| គិតជាពាន់រៀល | | ២២១.៤៨០ | (១៩៧.៤៤២) |

(*) ភាពប្រែប្រួលនៃអត្រាគ្មានការងារធ្វើ មិនមានចំនួនជាសារវន្តទេក្នុងឆ្នាំ២០១៩ ដោយសារអថេរនេះមានស្ថិរភាព។

(v) ការដាក់ហានិភ័យជាក្រុម ចំពោះ ECL ដែលត្រូវបានវាស់វែងតាមមូលដ្ឋានប្រមូលផ្តុំ

ចំពោះសំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុក ដែលយកគំរូតាមមូលដ្ឋានប្រមូលផ្តុំ ការប្រមូលផ្តុំហានិភ័យត្រូវបានធ្វើឡើងតាមមូលដ្ឋាននៃលក្ខណៈហានិភ័យជារួម ក៏ធ្វើបែបនេះហានិភ័យដែលស្ថិតនៅក្នុងក្រុមតែមួយគឺមានភាពដូចគ្នា។

ក្នុងការដាក់ជាក្រុម តម្រូវឱ្យមានព័ត៌មានគ្រប់គ្រាន់សម្រាប់ក្រុម ដើម្បីអាចប្រមូលស្ថិតិបាន។ ប្រសិនបើមិនមានព័ត៌មានផ្ទៃក្នុងគ្រប់គ្រាន់ទេនោះធនាគារបានពិចារណាទៅលើទិន្នន័យគោលខាងក្នុង/ខាងក្រៅបន្ថែម ដើម្បីប្រើប្រាស់សម្រាប់ការធ្វើគំរូ។

ភាពសមស្របក្នុងការដាក់ជាក្រុម ត្រូវបានតាមដាន និងត្រួតពិនិត្យ តាមមូលដ្ឋានប្រចាំការិយបរិច្ឆេទ ដោយផ្នែកហានិភ័យឥណទាន។

(vi) គោលការណ៍ជម្រះចេញពីបញ្ជី

ជាទូទៅ ការជម្រះចេញពីបញ្ជីត្រូវបានធ្វើឡើងនៅពេលដែលសកម្មភាពនានាក្នុងការប្រមូលប្រាក់ ត្រូវបានធ្វើឡើងគ្រប់មធ្យោបាយរួចហើយ ឬនៅពេលដែលការប្រមូលប្រាក់បន្ថែមទៀតមិនអាចធ្វើទៅបាន ឬមិនអាចទទួលយកបានដោយភាពសមស្រប។ នៅពេលដែលឥណទាន ឬឧបករណ៍បំណុលត្រូវបានចាត់ទុកថាមិនអាចប្រមូលបាន វាត្រូវបានជម្រះចេញពីបញ្ជីក្នុងគណនីសំវិធានធន ឬគណនីថយចុះតម្លៃដែលពាក់ព័ន្ធ។ ឥណទាននោះត្រូវបានជម្រះចេញពីបញ្ជីទាំងស្រុង ឬត្រូវបានជម្រះចេញពីបញ្ជីមួយផ្នែក បន្ទាប់ពីគិតពិចារណាទៅលើតម្លៃដែលអាចលក់បានជាក់ស្តែងរបស់ទ្រព្យបញ្ចាំ (ប្រសិនបើមាន) និងនៅពេលដែលការវិនិច្ឆ័យរបស់គណៈគ្រប់គ្រងយល់ឃើញថា មិនមានលទ្ធភាពក្នុងការប្រមូលប្រាក់មកវិញទេ។ ឥណទានដែលត្រូវជម្រះចេញពីបញ្ជីទាំងអស់ ត្រូវតែមានការអនុម័តដោយក្រុមប្រឹក្សាភិបាល ឬអាជ្ញាធរដែលបានទទួលសិទ្ធិ។

## ៣៤. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៤.១ ហានិភ័យឥណទាន (ត)

#### (គ) គោលការណ៍ការថយចុះតម្លៃ (ការខាតបង់ឥណទានរំពឹងទុក) (ត)

##### (vii) ការកែប្រែឥណទានឡើងវិញ

ជួនកាលធនាគារកែប្រែលក្ខខណ្ឌឥណទានដែលបានផ្តល់ឱ្យអតិថិជនឡើងវិញ ដែលបណ្តាលមកពីការចរចាផ្នែកពាណិជ្ជកម្ម ឬ ឥណទានដែលមានផលលំបាកក្នុងការបំពេញកាតព្វកិច្ចសងប្រាក់ ក្នុងទស្សនវិស័យមួយគឺប្រមូលប្រាក់មកវិញឱ្យបានជាអតិបរមា។

សកម្មភាពក្នុងការរៀបចំឥណទានឡើងវិញមានដូចជា ការរៀបចំការពន្យារពេលសងប្រាក់ ការផ្អាកការសងប្រាក់ និង ការលើកលែងការសងប្រាក់ជាដើម។ គោលការណ៍ និងការអនុវត្តនានាក្នុងការរៀបចំឥណទានឡើងវិញ គឺពឹងផ្អែកទៅលើសូចនាករ ឬលក្ខណៈវិនិច្ឆ័យ ដែលនៅក្នុងការវិនិច្ឆ័យរបស់គណៈគ្រប់គ្រង ចង្អុលបង្ហាញថាការទូទាត់សងប្រាក់ ទំនងជាអាចនៅបន្តទៅមុខទៀតបាន។ គោលការណ៍ទាំងនេះត្រូវបានរក្សាទុកក្រោមការពិនិត្យមើលឡើងវិញជាបន្តបន្ទាប់។ ការរៀបចំឡើងវិញត្រូវបានអនុវត្តជាទូទៅបំផុតចំពោះឥណទានមានកាលកំណត់។

បន្ទាប់ពីបានធ្វើការកែប្រែរួចហើយ ហានិភ័យនៃការមិនសងប្រាក់ពាក់ព័ន្ធនឹងឥណទានទាំងនេះ ត្រូវបានវាយតម្លៃនាកាលបរិច្ឆេទរាយការណ៍ និងត្រូវបានប្រៀបធៀបជាមួយនឹងហានិភ័យក្រោមលក្ខខណ្ឌដើមនៅពេលទទួលស្គាល់លើកដំបូង នៅពេលដែលការកែប្រែមិនមានភាពជាសារវន្ត ហើយមិនបណ្តាលឱ្យមានការឈប់ទទួលស្គាល់ឥណទានដំបូង (កំណត់សម្គាល់ ២.៥.ច)។ ធនាគារតាមដានដំណើរការទ្រព្យសកម្មដែលបានកែប្រែជាបន្តបន្ទាប់។ ធនាគារអាចកំណត់ថាហានិភ័យឥណទាន ត្រូវបានកែលម្អគួរឱ្យកត់សម្គាល់បន្ទាប់ពីការរៀបចំឡើងវិញរួច ដូចនេះទ្រព្យសកម្មនោះត្រូវបានដកចេញពីដំណាក់កាលទី៣ ឬដំណាក់កាលទី២ (ECL ពេញមួយអាយុកាល) មកដំណាក់កាលទី១ (ECL ១២ខែ) វិញ។ ករណីនេះគឺសម្រាប់តែទ្រព្យសកម្មដែលមានដំណើរការល្អស្របទៅតាមលក្ខខណ្ឌថ្មី ក្នុងរយៈពេល៦ខែបន្តបន្ទាប់ ឬលើសពីនេះ ដោយមិនរួមបញ្ចូលអ្នកខ្ចីប្រាក់ ដែលទទួលបានការព្យួរការសងប្រាក់បណ្តោះអាសន្នក្នុងអំឡុងឆ្នាំ ដោយសារផលប៉ះពាល់នៃជម្ងឺ Covid-19។

##### (viii) ហានិភ័យក្រៅតារាងតុល្យការ

ហានិភ័យក្រៅតារាងតុល្យការមានដូចជា ហ្វាស៊ីលីធីហិរញ្ញវត្ថុពាណិជ្ជកម្ម និងចំណែកហ្វាស៊ីលីធីឥណទានដែលមិនទាន់បានដកប្រាក់។ ធនាគារបានប្រើ Credit Conversion Factor (CCF) ដើម្បីប៉ាន់ស្មាន EAD នៃខ្ទង់ក្រៅតារាងតុល្យការ។ EAD ត្រូវបានប៉ាន់ស្មានចំនួន ១០០% នៃហានិភ័យខ្ទង់ក្រៅតារាងតុល្យការ ដោយប្រើ CCF។

#### (ឃ) ហានិភ័យឥណទានអតិបរមាមុនពេលរឹបអូសវត្ថុបញ្ចាំ ឬមុនពេលពង្រឹកឥណទានផ្សេងៗ

ហានិភ័យឥណទានអតិបរមា ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ ហិរញ្ញវត្ថុ គឺស្មើនឹងតម្លៃយោងរបស់វា។ ចំពោះបំណុលយថាហេតុ ហានិភ័យឥណទានអតិបរមាគឺស្មើនឹងចំនួនទឹកប្រាក់អតិបរមាដែលធនាគារត្រូវបង់ ប្រសិនបើកាតព្វកិច្ចនៃឧបករណ៍ដែលបានចេញផ្សាយត្រូវបានគេស្នើឱ្យបង់។ ចំពោះកិច្ចសន្យាផ្តល់ឥណទាន ហានិភ័យឥណទានអតិបរមា គឺជាចំនួនទឹកប្រាក់ទាំងស្រុងនៃហ្វាស៊ីលីធីឥណទានបានផ្តល់ឱ្យ អតិថិជន ដែលមិនទាន់បានដក។ តារាងខាងក្រោមនេះ បង្ហាញពីហានិភ័យឥណទានអតិបរមាចំពោះធនាគារ ចំពោះឧបករណ៍ហិរញ្ញវត្ថុដែលអាចមានការថយចុះតម្លៃ៖

## ៣៤. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៤.១ ហានិភ័យឥណទាន (ត)

#### (ឃ) ហានិភ័យឥណទានអតិបរមាមុនពេលរឹបអូសវត្ថុបញ្ចាំ ឬមុនពេលពង្រីកឥណទានផ្សេងៗ (ត)

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ហានិភ័យឥណទានពាក់ព័ន្ធនឹងទ្រព្យសកម្មក្នុងតារាងតុល្យការ** | | | | |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារផ្សេងៗ | **៨៥.៣៦១.៥២៨** | ៣៤៥.២៨៧.៣៨១ | **១២៥.៧០៩.២០០** | ៥១២.២៦៤.៩៩០ |
| ឥណទាន និងបុរេប្រទានវាស់វែងតាមថ្លៃដើម ដករំលស់ | **៥៨២.៥២៦.៣១១** | ២.៣៥៦.៣១៨.៩៣០ | **៥១៦.៤១៨.១១០** | ២.១០៤.៤០៣.៧៩៨ |
| ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ | **២.១១៩.៣៤៥** | ៨.៥៧២.៧៥០ | **១.៩២៩.៩៥៦** | ៧.៨៦៤.៥៧១ |
| **ហានិភ័យឥណទានពាក់ព័ន្ធនឹងខ្ទង់ក្រៅតារាងតុល្យការ** | | | | |
| កិច្ចសន្យាពាក់ព័ន្ធនឹងឥណទាន | **៣០.២២៥.៩៥១** | ១២២.២៦៣.៩៧២ | **៣៨.០៦៦.៧២៤** | ១៥៥.១២១.៩០០ |
| កិច្ចសន្យាធានាផ្នែកហិរញ្ញវត្ថុ | **១៨.៦២៤.២៣០** | ៧៥.៣៣៥.០១០ | **៤.៤២២.៣២៩** | ១៨.០២០.៩៩១ |
| ហានិភ័យឥណទានដុលសរុប | **៧១៨.៨៥៧.៣៦៥** | ២.៩០៧.៧៧៨.០៤៣ | **៦៨៦.៥៤៦.៣១៩** | ២.៧៩៧.៦៧៦.២៥០ |
| សំវិធានធនសម្រាប់ការខាតបង់ (ECL) | **(២០.២៥៥.៩២៣)** | (៨១.៩៣៥.២០៩) | **(១២.៩៦១.៥២៤)** | (៥២.៨១៨.២១០) |
| ហានិភ័យឥណទានសុទ្ធសរុប | **៦៩៨.៦០១.៤៤២** | ២.៨២៥.៨៤២.៨៣៤ | **៦៧៣.៥៨៤.៧៩៥** | ២.៧៤៤.៨៥៨.០៤០ |

តារាងខាងលើនេះបង្ហាញពីសេណារីយ៉ូដែលអាក្រក់បំផុតនៃហានិភ័យឥណទានរបស់ធនាគារ ដោយមិនបានគិតដល់ទ្រព្យបញ្ចាំដែលបានកាន់កាប់ និង/ឬ ការពង្រីកឥណទានផ្សេងៗទេ។ ចំពោះទ្រព្យសកម្មក្នុងតារាងតុល្យការ ហានិភ័យខាងលើគឺផ្អែកទៅលើតម្លៃយោងសុទ្ធ។ ដូចបានបង្ហាញខាងលើ ៨១% (២០១៩ ៖ ៧៥%) នៃហានិភ័យឥណទានអតិបរមាសរុប កើតមកពីឥណទាន និងបុរេប្រទាន។ គណៈគ្រប់គ្រងជឿជាក់លើលទ្ធភាពរបស់ខ្លួនក្នុងការបន្ត ការគ្រប់គ្រងនិងរក្សាហានិភ័យឥណទានដែលកើតមកពីឥណទាន និងបុរេប្រទានរបស់ធនាគារឱ្យស្ថិតក្នុងកម្រិតអប្បបរមា តាមវិធីដូចខាងក្រោម៖

- ស្ទើរតែគ្រប់ឥណទាន និងបុរេប្រទានទាំងអស់ ត្រូវបានធានាដោយទ្រព្យបញ្ចាំ ហើយទ្រព្យបញ្ចាំមានតម្លៃក្នុងចន្លោះពី ៦០% ទៅ ៧០% នៃឥណទាន។
- ធនាគារមាននីតិវិធីវាយតម្លៃឥណទានសមស្រប មុនពេលផ្តល់ឥណទាន និងបុរេប្រទានជូនអតិថិជន។
- ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារផ្សេងៗ ត្រូវបានផ្ញើនៅធនាគារក្នុងស្រុក ហើយគណៈគ្រប់គ្រងបានធ្វើការវាយតម្លៃហានិភ័យសមស្រប ហើយជឿជាក់ថាធនាគារមិនមានការខាតបង់ជាសារវន្តពីធនាគារក្នុងស្រុកទាំងនេះទេ។

## ៣៤. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៤.១ ហានិភ័យឥណទាន (ត)

#### (ង) គុណភាពឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុ

ធនាគារវាយតម្លៃគុណភាពឥណទាន នៃឥណទាន និងបុរេប្រទាន និងហិរញ្ញប្បទាន ដោយប្រើវិធីសាស្ត្រវាយតម្លៃចំណាត់ថ្នាក់ផ្ទៃក្នុង ដែលត្រូវបានតាក់តែងឡើងយ៉ាងសមស្របជាមួយនឹងប្រភេទផលិតផល និងភាគីដៃគូផ្សេងៗគ្នា។ វិធីសាស្ត្រទាំងនេះត្រូវបានបង្កើតឡើងផ្ទៃក្នុងធនាគារ និងបានគួបផ្សំជាមួយនឹងការវិភាគស្ថិតិ រួមជាមួយនឹងការវិនិច្ឆ័យរបស់បុគ្គលិកផ្នែកឥណទាន។

ការពណ៌នាពីគុណភាពឥណទាន ត្រូវបានសង្ខេបដូចខាងក្រោម៖

| គុណភាពឥណទាន | ពណ៌នា |
|---|---|
| ការតាមដានស្តង់ដារ | អ្នកជាប់កាតព្វកិច្ចក្នុងប្រភេទនេះ បង្ហាញពីសមត្ថភាពរឹងមាំក្នុងការបំពេញកាតព្វកិច្ចសងប្រាក់។<br>ធនាគារតាមដានអ្នកជាប់បំណុលក្នុងប្រភេទនេះ ទៅតាមស្ថានភាពនៃការសងប្រាក់យឺតយ៉ាវ។ អ្នកជាប់កាតព្វកិច្ចដែលសងប្រាក់ហួសកាលកំណត់សងតិចជាង ៣០ថ្ងៃ ក្នុងកិច្ចសន្យាសងប្រាក់ ទាំងចំពោះហ្វាស៊ីលីធីរយៈពេលខ្លី និងហ្វាស៊ីលីធីរយៈពេលវែង គឺស្ថិតនៅក្នុងការតាមដានស្តង់ដារ។ |
| ការតាមដានពិសេស | អ្នកជាប់កាតព្វកិច្ចក្នុងប្រភេទនេះ មានសមត្ថភាពមធ្យមក្នុងការបំពេញកាតព្វកិច្ចសងប្រាក់។<br>ធនាគារតាមដានអ្នកជាប់បំណុលក្នុងប្រភេទនេះ ទៅតាមស្ថានភាពនៃការសងប្រាក់យឺតយ៉ាវ។ អ្នកជាប់កាតព្វកិច្ចដែលសងប្រាក់ហួសកាលកំណត់សង៣០ថ្ងៃជាងក្នុងកិច្ចសន្យាសងប្រាក់ ត្រូវបានរួមបញ្ចូលទៅក្នុងការតាមដានពិសេស។ |
| ការមិនសងប្រាក់/ការថយចុះតម្លៃឥណទាន | អ្នកជាប់កាតព្វកិច្ចត្រូវបានវាយតម្លៃថាមានការថយចុះតម្លៃ។ |

គុណភាពឥណទាននៃឧបករណ៍ហិរញ្ញវត្ថុក្រៅពីឥណទាន និងបុរេប្រទាន និងហិរញ្ញប្បទាន ត្រូវបានកំណត់ដោយផ្អែកទៅលើចំណាត់ថ្នាក់របស់ភាគីដៃគូ ដែលត្រូវបានកំណត់ថាមានតម្លៃស្មើនឹងអត្រារបស់ភ្នាក់ងារវាយតម្លៃចំណាត់ថ្នាក់អន្តរជាតិផ្សេងៗ ដូចខាងក្រោម៖

| គុណភាពឥណទាន | ពណ៌នា |
|---|---|
| អធិបតេយ្យ | សំដៅដល់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលចេញដោយធនាគារកណ្តាល/រដ្ឋបាល ឬត្រូវបានធានាដោយធនាគារកណ្តាល/រដ្ឋបាល។ |
| ចំណាត់ថ្នាក់វិនិយោគ | សំដៅដល់គុណភាពឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលអ្នកចេញផ្សាយមានលទ្ធភាពបំពេញ កាតព្វកិច្ចសងបំណុល ហើយអ្នកកាន់កាប់សញ្ញាប័ណ្ណមានហានិភ័យឥណទានទាប ចំពោះការមិន សងប្រាក់។ |
| មិនមានចំណាត់ថ្នាក់វិនិយោគ | សំដៅដល់គុណភាពឥណទានកម្រិតទាបនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានការប្រឈមខ្ពស់នឹងហានិភ័យនៃការមិនសងប្រាក់។ |
| មិនមានចំណាត់ថ្នាក់ | សំដៅដល់ទ្រព្យសកម្មហិរញ្ញវត្ថុដែលបច្ចុប្បន្ននេះមិនមានចំណាត់ថ្នាក់ទេ អាស្រ័យដោយមិនមានគំរូ ចំណាត់ថ្នាក់។ |
| ថយចុះតម្លៃឥណទាន | សំដៅដល់ទ្រព្យសកម្មដែលមានការថយចុះតម្លៃ។ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (ត)

## ៣៤. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៤.១ ហានិភ័យឥណទាន (ត)

#### (ង) គុណភាពឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

តារាងខាងក្រោមនេះបង្ហាញពីការវិភាគហានិភ័យឥណទាន តាមដំណាក់កាល រួមជាមួយនឹងសំវិធានធន ECL៖

| | ២០២០ | | | | ២០១៩ | | | |
|---|---|---|---|---|---|---|---|---|
| | ដំណាក់កាលទី១ ECL ១២ខែ | ដំណាក់កាលទី២ ECL ពេញមួយអាយុកាល-មិនថយចុះតម្លៃឥណទាន | ដំណាក់កាលទី៣ ECL ពេញមួយអាយុកាល-ថយចុះតម្លៃឥណទាន | សរុប | ដំណាក់កាលទី១ ECL ១២ខែ | ដំណាក់កាលទី២ ECL ពេញមួយអាយុកាល-មិនថយចុះតម្លៃឥណទាន | ដំណាក់កាលទី៣ ECL ពេញមួយអាយុកាល-ថយចុះតម្លៃឥណទាន | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារផ្សេងៗ** | | | | | | | | |
| មានចំណាត់ថ្នាក់វិនិយោគ | ៣៤.១៧៤.៩២២ | - | - | ៣៤.១៧៤.៩២២ | ៩៥.៧៦៤.៧៥៣ | - | - | ៩៥.៧៦៤.៧៥៣ |
| មិនមានចំណាត់ថ្នាក់វិនិយោគ | ៥១.១៨៦.៦០៦ | - | - | ៥១.១៨៦.៦០៦ | ២៩.៩៤៤.៤៤៧ | - | - | ២៩.៩៤៤.៤៤៧ |
| តម្លៃយោងដុល | ៨៥.៣៦១.៥២៨ | - | - | ៨៥.៣៦១.៥២៨ | ១២៥.៧០៩.២០០ | - | - | ១២៥.៧០៩.២០០ |
| សំវិធានធនសម្រាប់ការខាតបង់ (ECL) | (១.៥៥៩.១២៩) | - | - | (១.៥៥៩.១២៩) | (២.៣៣៨.៦៣៣) | - | - | (២.៣៣៨.៦៣៣) |
| តម្លៃយោងសុទ្ធ | ៨៣.៨០២.៣៩៩ | - | - | ៨៣.៨០២.៣៩៩ | ១២៣.៣៧០.៥៦៧ | - | - | ១២៣.៣៧០.៥៦៧ |
| គិតជាពាន់រៀល | ៣៣៨.៩៨០.៧០៤ | - | - | ៣៣៨.៩៨០.៧០៤ | ៥០២.៧៣៥.០៦១ | - | - | ៥០២.៧៣៥.០៦១ |
| **ឥណទាន និងបុរេប្រទានវាស់វែងតាមថ្លៃដើមដករំលស់** | | | | | | | | |
| ការតាមដានស្តង់ដារ | ៤៦៥.២២៥.៥៤១ | ៩១.៥១២.៧៤៤ | - | ៥៥៦.៧៣៨.២៨៥ | ៤៨១.៤៥២.៣១៧ | ១១.៤៥៦.២១៨ | - | ៤៩២.៩០៨.៥៣៥ |
| ការតាមដានពិសេស | - | - | - | - | - | - | - | - |
| ការមិនសងប្រាក់ | - | - | ២៥.៧៨៨.០២៦ | ២៥.៧៨៨.០២៦ | - | - | ២៣.៥០៩.៥៧៥ | ២៣.៥០៩.៥៧៥ |
| តម្លៃយោងដុល | ៤៦៥.២២៥.៥៤១ | ៩១.៥១២.៧៤៤ | ២៥.៧៨៨.០២៦ | ៥៨២.៥២៦.៣១១ | ៤៨១.៤៥២.៣១៧ | ១១.៤៥៦.២១៨ | ២៣.៥០៩.៥៧៥ | ៥១៦.៤១៨.១១០ |
| សំវិធានធនសម្រាប់ការខាតបង់ (ECL) | (១.៤៩៦.៧៥៨) | (១៤.២៦៥.២២២) | (២.៣៨៨.៧០៦) | (១៨.១៥០.៦៨៦) | (៦៩៦.៦៥៥) | (៣៦.០៥៧) | (៩.៤៥៨.៤១២) | (១០.១៩១.១២៤) |
| តម្លៃយោងសុទ្ធ | ៤៦៣.៧២៨.៧៨៣ | ៧៧.២៤៧.៥២២ | ២៣.៣៩៩.៣២០ | ៥៦៤.៣៧៥.៦២៥ | ៤៨០.៧៥៥.៦៦២ | ១១.៤២០.១៦១ | ១៤.០៥១.១៦៣ | ៥០៦.២២៦.៩៨៦ |
| គិតជាពាន់រៀល | ១.៨៧៥.៧៨២.៩២៧ | ៣១២.៤៦៦.២២៦ | ៩៤.៦៥០.២៥០ | ២.២៨២.៨៩៩.៤០៣ | ១.៩៥៩.០៧៩.៣២៣ | ៤៦.៥៣៧.១៥៦ | ៥៧.២៥៨.៤៨៩ | ២.០៦២.៨៧៤.៩៦៨ |

## ៣៤. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៤.១ ហានិភ័យឥណទាន (ត)

#### (ង) គុណភាពឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

| | ២០២០ | | | | ២០១៩ | | | |
|---|---|---|---|---|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ | | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ | |
